សៀវភៅសិក្សាថ្នាក់ទារកដ្ឋាន

មើលន់កូនតូចៗ របស់អ្នករាល់គ្នា

មើលុន់កូនតូចៗ
របស់អ្នកវាល់គ្នា

សៀវភៅសិក្សាថ្នាក់ទារកដ្ឋាន

បោះពុម្ពដោយ
សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ
ទីក្រុងសលត៍ លេក រដ្ឋយូថាហ៍

យើងមានអំណរគុណចំពោះមតិកែលម្អ និង យោបល់ផ្សេងៗរបស់លោកអ្នក ស្តីអំពីសៀវភៅសិក្សានេះ ។ សូមផ្ញើមតិកែលម្អ
ទាំងឡាយទៅកាន់ការិយាល័យកម្មវិធីសិក្សា អាសយដ្ឋាន 50 East North Temple Street, Room 2404, Salt Lake
City, UT 84150-3200 USA
cur-development@ldschurch.org

សូមសរសេរឈ្មោះ អាសយដ្ឋាន អាសយដ្ឋានអ៊ីម៉ែល រួដ និងស្តេករបស់អ្នក ។ សូមកុំភ្លេច
សរសេរចំណងជើងសៀវភៅសិក្សា ។ បន្ទាប់មក សូមផ្តល់មតិកែលម្អ និង យោបល់ផ្សេងៗ
របស់អ្នក ស្តីអំពីចំណុចខ្លាំង និង ចំណុចដែលត្រូវកែលម្អក្នុងសៀវភៅសិក្សានេះ ។

© 2008 by Intellectual Reserve, Inc ។
រក្សាសិទ្ធគ្រប់យ៉ាង
បោះពុម្ពនៅសហរដ្ឋអាមេរិក
អនុមតិជាភាសាអង់គ្លេស ៖ 7/08
ការអនុម័តឲ្យបកប្រែ ៖ 7/08
ការបកប្រែនៃ ៖ *Nursery Manual: Behold Your Little Ones*
Cambodian
37108 258

មាតិកា

សេចក្តីផ្តើម 1
សំបុត្រទៅកាន់ឪពុកម្តាយ 7
មេរៀន
1. ខ្ញុំជាកូនរបស់ព្រះ 8
2. ព្រះវរបិតាសួគ៌មានផែនការសម្រាប់ខ្ញុំ 12
3. ខ្ញុំអាចអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ 16
4. ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្តស្រឡាញ់ខ្ញុំ 20
5. ព្រះយេស៊ូវគ្រីស្ត បានបង្ហាញយើងអំពីរបៀបដើម្បីស្រឡាញ់អ្នកដទៃ 24
6. ព្រះវិញ្ញាណបរិសុទ្ធជួយខ្ញុំ 28
7. ព្រះយេស៊ូវគ្រីស្ត បានបង្កើតពិភពលោកសម្រាប់ខ្ញុំ 32
8. ថ្ងៃអាទិត្យ គឺជាថ្ងៃមួយដើម្បីចងចាំដល់ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ត 36
9. ខ្ញុំមានរូបកាយដូចជារូបអង្គរបស់ព្រះវរបិតាសួគ៌ 40
10. ខ្ញុំនឹងមើលថែរូបកាយរបស់ខ្ញុំ 44
11. ខ្ញុំស្រឡាញ់គ្រួសារខ្ញុំ 48
12. ខ្ញុំអាចអធិស្ឋានជាមួយនឹងគ្រួសាររបស់ខ្ញុំ 52
13. គ្រួសារខ្ញុំ អាចរស់នៅជាមួយគ្នាជានិរន្ត្រ 56
14. ខ្ញុំនឹងគោរពតាម 60
15. ខ្ញុំនឹងមានអំណរគុណ 64
16. ខ្ញុំនឹងនិយាយថា « ខ្ញុំសុំទោស » 68
17. ខ្ញុំនឹងចែករំលែក 72
18. ខ្ញុំនឹងស្រឡាញ់អ្នកដទៃ 76
19. ខ្ញុំអាចសប្បាយចិត្ត 80
20. ខ្ញុំនឹងមានគារវភាព 84
21. យ៉ូសែប ស្ម៊ីធ បានឃើញព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ត 88
22. ព្រះគម្ពីរមរមន បង្រៀនខ្ញុំអំពីព្រះយេស៊ូវគ្រីស្ត 92
23. ខ្ញុំស្រឡាញ់ព្រះគម្ពីរទាំងឡាយ 96
24. ខ្ញុំនឹងធ្វើតាមព្យាការី 100
25. ខ្ញុំជារបស់ផងនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្តនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ 104
26. ខ្ញុំនឹងទទួលបុណ្យជ្រមុជទឹក និង ទទួលពិធីបញ្ជាក់ 108
27. ពិធីសាក្រាម៉ង់ ជួយខ្ញុំគិតអំពីព្រះយេស៊ូវគ្រីស្ត 112
28. ព្រះវរបិតាសួគ៌ ប្រទានពរខ្ញុំតាមរយៈបព្វជិតភាព 116
មេរៀនសម្រាប់ស្ថានភាពពិសេស
29. ព្រះយេស៊ូវគ្រីស្ត បានរស់ឡើងវិញ (បុណ្យអ៊ីសស្ទើរ) 120
30. ព្រះយេស៊ូវគ្រីស្ត គឺជាព្រះរាជបុត្រារបស់ព្រះវរបិតាសួគ៌ (បុណ្យគ្រីស្តម៉ាស) 124
មេរៀនខ្លី ៗ ៖ សូមស្វាគមន៍មកកាន់ថ្នាក់ទារកដ្ឋាន 128
មេរៀនខ្លី ៗ ៖ រីករាយថ្ងៃកំណើត 129
លិបិក្រមសកម្មភាព 130
លិបិក្រមរូបភាព 131

សេចក្តីផ្តើម

ថ្នាក់ទារកដ្ឋាន

គោលបំណង គោលបំណងនៃថ្នាក់ទារកដ្ឋាន គឺដើម្បីជួយដល់កុមារតូចៗឲ្យរៀនអំពីដំណឹងល្អដែលបានស្តារឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ហើយរស់នៅតាមដំណឹងល្អនោះ ។ ថ្នាក់ទារកដ្ឋាន គប្បីជួយដល់កុមារតូចៗឲ្យបង្កើនការយល់ដឹង និង ក្តីស្រឡាញ់របស់ពួកគេចំពោះ ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ហើយជួយពួកគេឲ្យមាននូវបទពិសោធន៍វិជ្ជមាន នៅក្នុងទីតាំងសាសនាចក្រ ហើយមានអារម្មណ៍រីកចម្រើនអំពីតម្លៃផ្ទាល់ខ្លួន ។

សំបុត្រទៅកាន់ឱពុកម្តាយ សមាជិកនៃគណៈប្រធានថ្នាក់អង្គការបឋមសិក្សា គួរតែផ្ញើសំបុត្រមួយច្បាប់ នៅទំព័រ 7 ទៅឲ្យឱពុកម្តាយរបស់កុមារ ក្នុងរយៈពេលពីរបីសប្តាហ៍ មុនពេលកុមារចាប់ផ្តើមចូលរួមក្នុងថ្នាក់ទារកដ្ឋាន ។

អ្នកដឹកនាំថ្នាក់ទារកដ្ឋាន យ៉ាងហោចណាស់ មានមនុស្សពីរនាក់ (អ្នកដឹកនាំថ្នាក់ទារកដ្ឋានម្នាក់ និង ជំនួយការអ្នកដឹកនាំថ្នាក់ទារកដ្ឋានម្នាក់) គប្បីត្រូវបានហៅបម្រើនៅក្នុងថ្នាក់ទារកដ្ឋាននីមួយៗ ។ បើអ្នកដឹកនាំថ្នាក់ទារកដ្ឋាន ពុំមែនជាស្វាមី និងភរិយាទេ នោះពួកគេគួរតែមានភេទដូចគ្នា ។ អ្នកដឹកនាំថ្នាក់ទារកដ្ឋាន គប្បីធ្វើការជាមួយគ្នាអំឡុងពេលថ្នាក់ទារកដ្ឋានទាំងមូល ដើម្បីប្រាកដថា កុមារមានសុវត្ថិភាព និងសុខុមាលភាព ។

បរិដ្ឋានខាងសាច់ឈាម ថ្នាក់ទារកដ្ឋាន គួរតែផ្តល់នូវបទពិសោធន៍គួរជាទីស្រឡាញ់ សុវត្ថិភាព និងបទពិសោធន៍ការរៀនសូត្រដែលបានរៀបចំឡើងចំពោះកុមារតូចៗ ។ បន្ទប់ គួរតែស្អាត រីករាយ និងមានការទាក់ទាញ ហើយមានទីតាំងនៅជិតនឹងបន្ទប់ទឹក បើអាចធ្វើទៅបាន ។ សម្ភារលេង គួរតែស្អាត សុវត្ថិភាព និង នៅក្នុងស្ថានភាពល្អ ។ ឧបករណ៍តោងឡើង ពុំគួរប្រើទេ ។

កាលវិភាគ ជាធម្មតា ថ្នាក់ទារកដ្ឋាន មានរយៈពេលពេញម៉ោង តាមដែលបានដាក់កាលវិភាគសម្រាប់ថ្នាក់អង្គការបឋមសិក្សា ។ ក្នុងម៉ោងនេះ គួរតែបំបែកទៅជាច្រើនវគ្គដូចជា ម៉ោងមេរៀន ម៉ោងអាហារសម្រន់ ម៉ោងតន្ត្រី និងម៉ោងលេង ។

តម្រូវការទាំងឡាយរបស់កុមារតូចៗ នឹងជួយអ្នកសម្រេចចិត្តអំពីលំដាប់លំដោយនៃវគ្គ និងរយៈពេលនៃវគ្គនីមួយៗ ។ កុមារតូចៗឆ្លើយតបបានយ៉ាងល្អទៅនឹងភាពខ្ជាប់ខ្ជួន ដូច្នេះ សូមធ្វើតាមលំដាប់លំដោយដូចគ្នាជារៀងរាល់សប្តាហ៍ ។

- *មេរៀន ៖* សូមចាប់ផ្តើម និង បញ្ចប់មេរៀនដោយការអធិស្ឋាន ដែលជាធម្មតាគួរតែអធិស្ឋានដោយកុមារម្នាក់ (ដោយមានជំនួយមកពីអ្នកដឹកនាំថ្នាក់ទារកដ្ឋានម្នាក់ បើចាំបាច់) ។ អំឡុងពេលមេរៀន សូមធ្វើតាមសកម្មភាពណាមួយ ឬ សកម្មភាពទាំងអស់ ដែលមាននៅក្នុងមេរៀនមួយនៃសៀវភៅសិក្សានេះ ។ អ្នកអាចធ្វើតាមសកម្មភាពទាំងនេះឡើងវិញដដែលៗ នៅក្នុងថ្នាក់ទារកដ្ឋាន ។ ធនធានដែលបានបោះពុម្ពដោយសាសនាចក្រ ដូចជា *សៀវភៅចម្រៀងរបស់កុមារ* និង ទស្សនាវដ្តីសាសនាចក្រ ក៏អាចជាជំនួយផងដែរ ។
- *ការលេង ៖* ចូរអនុញ្ញាតឲ្យកុមារតូចៗលេងសម្ភារលេង, រូបផ្ទុំ និង សៀវភៅទាំងឡាយដោយសេរី ។ កុមារតូចៗរៀនតាមរយៈការលេង ។ នៅចុងបញ្ចប់នៃម៉ោងលេង សូមជួយកុមាររៀបចំរបស់ទាំងអស់ទុកដាក់តាមកន្លែងដើមវាវិញ ។
- *អាហារសម្រន់ ៖* សូមផ្តល់អាហារសម្រន់ដ៏មានជីវជាតិ ដែលងាយស្រួលនឹងរៀបចំ ។ ចូរសួរដល់



គន្លឹះក្នុងការបង្រៀន

សម្រាប់ជាព័ត៌មានអំពីចរិតលក្ខណៈរបស់កុមារដែលមានអាយុស្ថិតក្នុងថ្នាក់ទារកដ្ឋាន សូមមើល *Teaching, No Greater Call: A Resource for Gospel Teaching* (ឆ្នាំ 1999) ទំព័រ 110–11 ។

កាលវិភាគ ៖ នៅពេលរៀបចំកាលវិភាគសម្រាប់ថ្នាក់ទារកដ្ឋានរបស់អ្នក សូមគិតពិចារណាអំពីសេចក្តីត្រូវការទាំងឡាយរបស់កុមារ ។ តើពួកគេអាចអង្គុយស្ងៀមបានយូរប៉ុណ្ណា មុនពេលពួកគេត្រូវងាកចុះឡើងនោះ ? តើពួកគេនឹងឃ្លាន ហើយត្រូវការអាហារសម្រន់នៅពេលណា ? តើសកម្មភាពស្ងប់ស្ងៀមមួយ នឹងជួយពួកគេរៀបចំខ្លួនសម្រាប់មេរៀននេះដែរឬទេ ? សូមចាំថា កុមារតូចៗភាគច្រើន មានរយៈពេលយកចិត្តទុកដាក់ខ្លីណាស់ ។ សូមមើលទៅលើតរិយាបទរសាប់រសល់ និងតរិយាបទដទៃទៀត ដែលប្រាប់អ្នកថា កុមារតូចៗត្រូវការការផ្លាស់ប្តូរមួយ ។

ការលេង ៖ កុមារដែលមានអាយុស្ថិតក្នុង-ថ្នាក់ទារកដ្ឋាន ពុំបានត្រៀមខ្លួនទាំងខាងផ្លូវអារម្មណ៍ ឬក៏ខាងសង្គមក្នុងការចែកចាយសម្ភារលេង និងរបស់លេងផ្សេងទៀតនោះទេ ។ ចូរកុំបង្ខំពួកគេឲ្យចែកសម្ភារលេងជាមួយគេ ប៉ើពួកគេពុំចង់ចែកទេនោះ ។

ឪពុកម្តាយ បើសិនជាមានចំណីអាហារណា ដែលពួកគាត់ពុំចង់ឲ្យកូនៗរបស់ពួកគាត់បរិភោគ ។ សូមជួយដល់កុមារឲ្យលាងដៃរបស់ពួកគេ ហើយអធិស្ឋានប្រសិទ្ធពរដល់ម្ហូបអាហារ មុនពេលពួកគេបរិភោគ ។ ថវិកាសម្រាប់អាហារសម្រន់ គួរតែបានមកពីថវិកាថ្នាក់អង្គការបឋមសិក្សា ។

- *តន្ត្រី ៖* ចូរច្រៀងចម្រៀង លេងឧបករណ៍ភ្លេងងាយៗ ឬធ្វើចលនា ឬធ្វើតាមតន្ត្រី (សូមមើល « តន្ត្រីនៅក្នុងថ្នាក់ទារកដ្ឋាន » នៅទំព័រ 4) ។ វគ្គក្នុងថ្នាក់ទារកដ្ឋាននេះអាចជាផ្នែកនៃម៉ោងមេរៀន ឬក៏អាចត្រូវបានបំបែកជាវគ្គដែលសម្រាប់តែតន្ត្រី ។

នៅចុងម៉ោងនៃថ្នាក់ទារកដ្ឋាន គ្រូបង្រៀនគួរតែប្រាកដថា អ្នកដែលមកទទួលកុមារតូចៗ គឺជាឪពុកម្តាយរបស់ពួកគេ ឬ សមាជិកដទៃទៀតនៃគ្រួសារសាច់ញាតិជិតដិតរបស់ពួកគេប៉ុណ្ណោះ ។ ពួកគេពុំគួរអនុញ្ញាតឲ្យនរណាម្នាក់ផ្សេងទៀត មកទទួលយកកុមារឡើយ លុះត្រាតែមានការអនុញ្ញាតពីឪពុកម្តាយគេសិន ។

ការផ្លាស់ប្តូរ សូមជួយឲ្យកុមារមានទម្លាប់មួយ ដែលជួយពួកគេផ្លាស់ប្តូរពីមួយវគ្គទៅមួយវគ្គទៀត ។ ឧទាហរណ៍ អ្នកអាចច្រៀងចម្រៀងមួយដូចជា« សប្បាយធ្វើការ »*(ចម្រៀងកុមារ* ទំព័រ 253) ដោយប្រើពាក្យដូចឮជា « រីសល្បែងលេងទុកវិញ គឺសប្បាយណាស់ » ឬ « លាងដៃគឺសប្បាយណាស់ » ជាដើម ។

អំពីមេរៀននៅក្នុងសៀវភៅសិក្សានេះ

គោលបំណងនៃមេរៀននៅក្នុងសៀវភៅសិក្សានេះ គឺដើម្បីជួយដល់កុមារដែលមានអាយុស្ថិតក្នុង-ថ្នាក់ទារកដ្ឋាន ឲ្យរៀននូវគោលលទ្ធិមូលដ្ឋាននានានៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញ ។ ចូរអធិស្ឋានសុំការណែនាំ ហើយស្វែងរកឥទ្ធិពលពីព្រះវិញ្ញាណ នៅពេលអ្នករៀបចំបង្រៀនមេរៀនទាំងនេះ (សូមមើល *Teaching, No Greater Call* ទំព័រ 97–99) ។ អ្នកអាចបង្រៀនពួកគេតាមលំដាប់លំដោយណាក៏បាន ហើយអ្នកអាចបង្រៀនមេរៀនដូចគ្នានៅក្នុងសប្តាហ៍បន្តបន្ទាប់ទៀត ។ អ្នកក៏អាចបង្រៀនមេរៀនដូចគ្នាពីរដង អំឡុងពេលថ្នាក់ទារកដ្ឋានមួយបានផងដែរ អាស្រ័យលើតម្រូវការ និង ចំណាប់អារម្មណ៍របស់កុមារ ។

សូមប្រើធនធានដែលបានបោះពុម្ពដោយសាសនាចក្រតែប៉ុណ្ណោះនៅក្នុងថ្នាក់ទារកដ្ឋាន ។ បន្ថែមពីលើសកម្មភាពទាំងឡាយនៅក្នុងសៀវភៅសិក្សានេះ អ្នកអាចប្រើល្បែងកំសាន្ត, រូបភាព, ចម្រៀង, រឿងនិទាន និងសកម្មភាពដទៃទៀត មកពីទស្សនាវដ្តីសាសនាចក្រ ។

សូមប្រើព្រះគម្ពីរ នៅពេលអ្នកបង្រៀនកុមារតូចៗ ។ នៅពេលមេរៀនស្នើថា អ្នកត្រូវប្រាប់រឿងចេញមកពីបទគម្ពីរ សូមបើកព្រះគម្ពីរ ហើយចង្អុលបង្ហាញពីកន្លែងដែលរឿងនោះបានកើតឡើង ។ ការធ្វើដូច្នេះ ជួយដល់កុមារតូចៗឲ្យយល់ថា អ្វីដែលអ្នកកំពុងបង្រៀនគឺចេញមកពីព្រះគម្ពីរ ។ ចូរបង្រៀនពួកគេឲ្យមានអំណរគុណ និង មានគារវភាពចំពោះព្រះគម្ពីរ ។ បើអ្នកពុំមានព្រះគម្ពីរផ្ទាល់ខ្លួនទេនោះ ចូរសុំដល់ប៊ីស្សព ឬប្រធានសាខារបស់អ្នក អំពីរបៀបដែលអ្នកអាចទទួលបានព្រះគម្ពីរមួយក្បាល ។

នៅពេលអ្នកបង្រៀនមេរៀនទាំងនេះ ចូរយល់អំពីស្ថានភាពនៅគេហដ្ឋាន និង ស្ថានភាពគ្រួសាររបស់កុមារតូចៗ ។ នៅពេលមានមេរៀនមួយសំដៅទៅលើឪពុកម្តាយ ឬក្រុមគ្រួសាររបស់កុមារតូចៗ ចូរពិចារណាអំពីអារម្មណ៍របស់កុមារម្នាក់ៗ ដែលត្រូវបានចិញ្ចឹម ដោយមានតែម្តាយ ឬមានតែឪពុក ដោយជីដូនជីតា ឬ ដោយសមាជិកគ្រួសារដទៃទៀត ។

សូមយល់ពីអារម្មណ៍របស់កុមារគ្រប់គ្នា ដែលនៅក្នុងថ្នាក់ទារកដ្ឋានរបស់អ្នក ដែលគេមានពិការភាពផងដែរ ។ សូមផ្តោតទៅលើចំនុចទាំងឡាយ ដែលកុមារ*អាច* ធ្វើបាន គឺពុំមែនផ្តោតទៅលើអ្វីដែលពួកគេពុំអាចធ្វើបាននោះទេ ។ សម្រាប់ព័ត៌មានបន្ថែមអំពីការបង្រៀនដល់កុមារទាំងឡាយដែលពិការ សូមមើល *Teaching, No Greater Call* ទំព័រ 38–39 ។

ផ្នែកសំខាន់នៃមេរៀនទាំងឡាយ ត្រូវបានពិពណ៌នាដូចខាងក្រោម ៖

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន មេរៀននីមួយៗ ចាប់ផ្តើមជាមួយនឹងការពន្យល់ដោយសង្ខេបអំពីគោលលទ្ធិ ដែលត្រូវបង្រៀន រួមមានទាំងបទគម្ពីរយោងទាំងឡាយផងដែរ ។ ការអាន និង ការពិចារណាអំពីសេចក្តីផ្តើមនេះ ព្រមទាំងបទគម្ពីរដែលទាក់ទងទាំងឡាយ នឹងជួយដល់អ្នករៀបចំខាងវិញ្ញាណ ដើម្បីបង្រៀនគោលលទ្ធិ ដល់កុមារតូចៗដោយព្រះវិញ្ញាណ ។ សេចក្តីណែនាំនេះពុំមានគម្រោងថា ត្រូវអានទៅដល់កុមារថ្នាក់ទារកដ្ឋាននោះឡើយ ។

សកម្មភាពនានាក្នុងការរៀនសូត្រ គោលបំណងនៃសកម្មភាពរៀនសូត្រនានា គឺដើម្បីបង្រៀនកុមារតូចៗអំពីដំណឹងល្អតាមរយៈការផ្តល់ឱកាសឲ្យពួកគេ ៖

- សូមស្តាប់អំពីគោលលទ្ធិ ។

គន្លឹះក្នុងការបង្រៀន

សកម្មភាព ៖ សូមពិនិត្យមើលនូវការចូលរួមរបស់កុមារអំឡុងពេលសកម្មភាព ។ អ្នកស្គាល់ពីសមត្ថភាព និង តម្រូវការរបស់កុមារនៅក្នុងថ្នាក់ទារកដ្ឋានរបស់អ្នក ។ សូមសម្របសកម្មភាពទៅតាមតម្រូវការ ។ (សូមមើល *Teaching, No Greater Call* ទំព័រ 33–34) ។

ប្រអប់សកម្មភាព ៖ អ្នកអាចនឹងចង់ធ្វើជាប្រអប់សកម្មភាពមួយ ដើម្បីរក្សាទុកនៅក្នុងបន្ទប់រៀនថ្នាក់ទារកដ្ឋាន ។ ប្រអប់នោះអាចផ្ទុកនូវសម្ភារទាំងឡាយដែលអ្នកបានធ្វើ ឬ បានប្រើសម្រាប់សកម្មភាពទាំងឡាយដូចជា រូបគំនូរ, រូបភាព, កុក្កតាអាយ៉ង, សំណៅទំព័រឆាត់ពណ៌ ជាដើម ។ អ្នកអាចប្រើសម្ភារទាំងនេះនៅគ្រប់ពេល អំឡុងពេលថ្នាក់ទារកដ្ឋាន ។

- សូមមើលរូបភាពដែលទាក់ទងទៅនឹងគោលលទ្ធិ ។
- សូមច្រៀង (ឬ ស្តាប់ចម្រៀង) អំពីគោលលទ្ធិ ។
- សូមធ្វើកាយវិការ ដែលទាក់ទងទៅនឹងគោលលទ្ធិ ។
- សូមនិយាយអ្វីមួយអំពីគោលលទ្ធិ ។

សូមរៀបចំកន្លែងពិសេសមួយនៅក្នុងបន្ទប់ថ្នាក់ទារកដ្ឋាន ជាកន្លែងដែលអ្នកអាចប្រមូលផ្តុំកុមារតូចៗឲ្យមកជិតអ្នកសម្រាប់សកម្មភាពទាំងឡាយក្នុងការរៀនសូត្រ ។ អាចជាការជុំគ្នាលើភួយមួយ ឬលើកម្រាលនៅលើឥដ្ឋ ឬជាកៅអីដែលបានរៀបជារង្វង់មូល ។ សូមអង្គុយ ឬលុតជង្គង់ ដើម្បីអ្នកអាចនៅជិតនឹងកុមារតូចៗ និង នៅត្រឹមកម្រិតដែលគេអាចមើលឃើញ ។ (កំណត់ចំណាំ ៖ សូមស្មៀកសម្លៀកបំពាក់សមរម្យពេលលុតជង្គង់ អង្គុយលើឥដ្ឋ ឬឱនចុះ) ។

សកម្មភាពប្រមូលផ្តុំ ៖ សូមចាប់ផ្តើមមេរៀននីមួយៗ ដោយការប្រមូលផ្តុំកុមារតូចៗជាមួយនឹងចម្រៀងដែលអនុម័តដោយសាសនាចក្រ ឬសកម្មភាពដទៃទៀត ។ នៅពេលអ្នកប្រើសកម្មភាពប្រមូលផ្តុំដូចគ្នារាល់សប្តាហ៍ កុមារតូចៗនឹងស្គាល់សកម្មភាពជាសញ្ញាដែលថា មេរៀនកំពុងចាប់ផ្តើម ហើយការណ៍នេះ នឹងជួយពួកគេត្រៀមខ្លួនសម្រាប់មេរៀន ។ ជាធម្មតា សកម្មភាពនៃការប្រមូលផ្តុំ អាចជាការទះដៃរបស់អ្នកតាមចង្វាក់ ហើយអញ្ជើញឲ្យកុមារទះដៃជាមួយនឹងអ្នក ។ ចម្រៀង ឬ សកម្មភាពដែលអនុម័តនៅក្នុងសាសនាចក្រស្ទើរតែទាំងអស់ នឹងមានប្រសិទ្ធភាព បើវាស្រួល ហើយអ្នកប្រើវាយ៉ាងខ្លាប់ខ្លួនជារៀងរាល់សប្តាហ៍ ។

នេះគឺជាឧទាហរណ៍ផ្សេងទៀតមួយចំនួន អំពីសកម្មភាពក្នុងការប្រមូលផ្តុំ ៖

- ចូរច្រៀងចម្រៀងដែលកុមារចូលចិត្ត ដូចជាបទ « ខ្ញុំជាកូនរបស់ព្រះ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 58) ឬ បទ « ចូរអ្នកស្រឡាញ់គ្នា » (*សៀវភៅចម្រៀងកុមារ*, 136) ។
- សូមច្រៀងបទ « បើអ្នកសប្បាយ » (*សៀវភៅចម្រៀងកុមារ*, 266), ដោយប្រើពាក្យដូចខាងក្រោម ៖
  បើប្អូនៗត្រៀមខ្លួនសម្រាប់មេរៀនរបស់យើងរួចហើយ សូមមកអង្គុយចុះ ។
  បើប្អូនៗត្រៀមខ្លួនសម្រាប់មេរៀនរបស់យើងរួចហើយ សូមមកអង្គុយចុះ ។
  បើប្អូនៗត្រៀមខ្លួនសម្រាប់មេរៀនរបស់យើងរួចហើយ វាគឺជាពរជ័យមួយដ៏ពិត ។
  បើប្អូនៗត្រៀមខ្លួនសម្រាប់មេរៀនរបស់យើងរួចហើយ សូមមកអង្គុយចុះ ។
- សូមរៀបរាប់វគ្គសកម្មភាពដូចខាងក្រោម ហើយសូមអញ្ជើញកុមារឲ្យធ្វើសកម្មភាពជាមួយអ្នក
  ខ្ញុំរីករាយដែលខ្ញុំបានមកព្រះវិហារថ្ងៃនេះ *(ដាក់ម្រាមដៃទល់គ្នាដើម្បីបង្កើតជារាងកំពូលស្រួច)*
  ដើម្បីរៀនអំពីព្រះយេស៊ូវ ច្រៀង *(យកដៃខ្ទប់មាត់)* និង អធិស្ឋាន ។ *(ឱបដៃ)*

សកម្មភាពជម្រើស មេរៀននីមួយៗផ្តល់ឲ្យជាយោបល់សកម្មភាពជម្រើសពី 2 ទៅ 4 ដែលអ្នកអាចជ្រើសរើសមកអនុវត្តនៅក្នុងមេរៀន បើអ្នកចង់ប្រើ ។ អ្នកក៏អាចប្រើសកម្មភាពទាំងនេះនៅពេលផ្សេងទៀត អំឡុងម៉ោងថ្នាក់ទារកដ្ឋានផងដែរ ។ សកម្មភាពទាំងនេះជាច្រើន តម្រូវឲ្យមានការរៀបចំបន្ថែម ។ បើអ្នកពុំអាចរកបាននូវសម្ភារដែលតម្រូវឲ្យមានសម្រាប់សកម្មភាពទាំងនេះទេ អ្នកអាចជំនួសដោយសម្ភារដែលស្រដៀងគ្នាបាន ។ ចរិកាសម្រាប់សម្ភារទាំងនេះអាចដកចេញមកពីចរិកាសម្រាប់ថ្នាក់អង្គការបឋមសិក្សា ។

គន្លឹះក្នុងការបង្រៀន

ការប្រមូលផ្តុំ ៖ សូមសរសើរដល់កុមារដែលអង្គុយជាមួយអ្នក ។ បើមានកុមារខ្លះពុំចង់អង្គុយទេ សូមកុំបង្ខិំពួកគេ ប៉ុន្តែសូមលើកទឹកចិត្តពួកគេក្នុងសកម្មភាពផ្សេង។ ។ ខណៈដែលអ្នកដឹកនាំថ្នាក់ទារកដ្ឋានម្នាក់កំពុងបង្រៀន អ្នកដឹកនាំថ្នាក់ទារកដ្ឋានម្នាក់ទៀត អាចជួយធ្វើឲ្យកុមារយកចិត្តទុកដាក់ ។

ចម្រៀង ៖ បើអ្នកប្រើចម្រៀង ឬ សកម្មភាពមួយសម្រាប់សកម្មភាពការប្រមូលផ្តុំរបស់អ្នក សូមធ្វើវាដដែល។ពីរបីដង ដោយប្រើសំឡេងទន់ភ្លន់គ្រប់ពេល ។

ពាក្យផ្តួន ជួយដល់កុមារឲ្យរៀន ។ ជាពិសេស បើកុមារពេញចិត្តនឹងសកម្មភាពក្នុងការរៀនសូត្រ ឬ សកម្មភាពជម្រើសណាមួយ សូមធ្វើវាឡើងវិញនៅពេលផ្សេងទៀត អំឡុងម៉ោងថ្នាក់ទារកដ្ឋាន និង នៅសប្តាហ៍ក្រោយ។ ។

រូបភាព មេរៀននីមួយៗមានបញ្ចូលនូវទំព័ររូបភាពចំនួនពីរ ៖ រូបភាពពណ៌មួយ និង រូបគំនូរមួយ ។ គោលបំណងរូបភាពទាំងនោះ គឺដើម្បីជាការពង្រឹងបន្ថែមខាងចក្ខុអំពីគោលការណ៍ទាំងឡាយ ដែលបានបង្រៀននៅក្នុងមេរៀន ។ យោបល់សម្រាប់ការប្រើប្រាស់រូបភាព ត្រូវបានដាក់បញ្ចូលនៅក្នុងមេរៀនទាំងឡាយ ។

គន្លឹះក្នុងការបង្រៀន នៅផ្នែកខាងស្តាំនៃទំព័រនីមួយៗ មានយោបល់ និង គំនិតជាច្រើន ដើម្បីជួយដល់អ្នកបង្រៀនមេរៀនដោយជោគជ័យ ។ ចំណុចទាំងនេះមួយចំនួន ជាយោបល់អំពីការបង្ហាញសកម្មភាពជាក់លាក់មួយ ប៉ុន្តែភាគច្រើនបំផុត គឺជាគោលការណ៍ទូទៅដែលអនុវត្តរាល់ពេល ដែលអ្នកកំពុងបង្រៀនកុមារតូចៗ ។

តន្ត្រីនៅក្នុងថ្នាក់ទារកដ្ឋាន

កុមារដែលមានអាយុស្ថិតក្នុងថ្នាក់ទារកដ្ឋាន គឺបានត្រៀមខ្លួនជាស្រេច និង ចង់រៀនអំពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ហើយតន្ត្រីអាចជួយពួកគេរៀន ។ តន្ត្រីអញ្ជើញព្រះវិញ្ញាណ ហើយវាអាចបង្កើតបរិយាកាសកក់ក្តៅ និង ពោរពេញដោយក្តីស្រឡាញ់ ដែលធ្វើឲ្យថ្នាក់ទារកដ្ឋានជាកន្លែងដ៏សប្បាយរីករាយមួយ ។

ចូរកុំបារម្ភ បើអ្នកពុំមែនជាអ្នកច្រៀងដែលមានទេពកោសល្យទេនោះ ។ កុមារនឹងស្តាប់ពាក្យ ហើយមើលការបង្ហាញនៅលើទឹកមុខរបស់អ្នក ហើយរីករាយជាមួយនឹងទំនុកច្រៀងជាជាងផ្តោតទៅលើទេពកោសល្យនៃការច្រៀងរបស់អ្នក ។

របៀបដើម្បីប្រើតន្ត្រី តន្ត្រី អាចបម្រើក្នុងគោលបំណងផ្សេងៗនៅក្នុងថ្នាក់ទារកដ្ឋាន ។ អ្នកអាចប្រើតន្ត្រីដើម្បី ៖

- ស្វាគមន៍ដល់កុមារ ។ ឧទាហរណ៍ អ្នកអាចចាក់តន្ត្រីតិចៗ នៅពេលកុមារចូលមកថ្នាក់ទារកដ្ឋាន ។
- បង្រៀនគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ មេរៀនភាគច្រើននៅក្នុងសៀវភៅសិក្សានេះ ផ្តល់ជាចម្រៀងដែលទាក់ទងនឹងប្រធានបទនៃមេរៀន ។
- សូមជួយកុមារឲ្យរៀបចំខ្លួន ដើម្បីចាប់ផ្តើមសកម្មភាពមួយផ្សេងទៀត—ឧទាហរណ៍ ដើម្បីបង្កើតបរិយាកាសដ៏មានគារវភាពនៅក្នុងការរៀបចំសម្រាប់ពេលមេរៀន ។
- សូមផ្តល់ឱកាសដល់កុមារឲ្យប្រែខ្លួន ហើយរីករាយនឹងខ្លួនគេ ។
- សូមជួយឲ្យកុមារស៊ាំនឹងចម្រៀង ដែលពួកគេនឹងច្រៀងនៅក្នុងថ្នាក់អង្គការបឋមសិក្សា ។

ការជួយកុមារឲ្យចូលរួម ដើម្បីបង្រៀនចម្រៀងមួយដល់កុមារ សូមច្រៀងឃ្លាខ្លីមួយឲ្យបានពីរបីដង រួចហើយអញ្ជើញពួកគេឲ្យច្រៀងជាមួយអ្នក ។ សូមសរសើរពួកគេចំពោះការខិតខំរបស់ពួកគេ ។ ដំបូង ពួកគេអាចច្រៀងតែមួយពាក្យ ឬពីរពាក្យប៉ុណ្ណោះ ហើយកុមារដែលតូចជាងគេ ពុំអាចច្រៀងទេ ប៉ុន្តែពួកគេនៅតែអាចរៀន ហើយសប្បាយនឹងស្តាប់អ្នកច្រៀង ។ ពួកគេក៏អាចរីករាយនឹងការធ្វើសកម្មភាពងាយៗ ដែលមានក្នុងចម្រៀងផងដែរ ។ នៅទីបំផុត ពួកគេនឹងរៀនពាក្យ ហើយចាប់ផ្តើមច្រៀងជាមួយនឹងអ្នកជាពិសេស បើអ្នកច្រៀងចម្រៀងដដែលៗ ។

គន្លឹះក្នុងការបង្រៀន

រូបភាព ៖ ដើម្បីជួយដល់កុមារឲ្យរៀនពីរូបភាព និងរូបគំនូរ ចូរចង្អុលបង្ហាញព័ត៌មានលម្អិត ដែលទាក់ទងទៅនឹងគោលការណ៍ទាំងឡាយ ដែលអ្នកកំពុងបង្រៀន ។

តន្ត្រី ៖ អ្នកពុំចាំបាច់ត្រូវការព្យាណូ ឬ ម៉ាញ៉េចាក់សឺឌី ដើម្បីប្រើតន្ត្រីនៅក្នុងថ្នាក់ទារកដ្ឋាននោះទេ ។ កុមារនឹងមានអារម្មណ៍សុខស្រួល បើអ្នកគ្រាន់តែប្រមូលពួកគេឲ្យមកនៅជុំវិញអ្នក ហើយច្រៀង ។ សូមចាំពាក្យទាំងឡាយក្នុងចម្រៀង ដើម្បីអ្នកអាចសម្លឹងមើលទៅកុមារ ។

ធនធានតន្ត្រី ៖ ចូរពិចារណាអំពីការរៀបចំប្រអប់នៃធនធានតន្ត្រីមួយ ដើម្បីរក្សាទុកនៅក្នុងបន្ទប់ថ្នាក់ទារកដ្ឋាន ។ វាអាចមាននូវបញ្ជីចម្រៀងមួយ និងវគ្គសកម្មភាពនានា ដែលកុមារពេញចិត្ត រូបភាពសាមញ្ញសម្រាប់កុមារកាន់ ពេលអ្នកច្រៀង ឬ ឧបករណ៍តន្ត្រីសាមញ្ញ ។

ធនធានដទៃទៀត ពាក្យទាំងឡាយក្នុងចម្រៀងជាច្រើន មានបញ្ចូលនៅក្នុងមេរៀនក្នុងសៀវភៅសិក្សានេះ ។ អ្នកអាចប្រើផងដែរ ៖

- *សៀវភៅចម្រៀងកុមារ* និង ការសែតចម្រៀងអង្គការបឋមសិក្សា ។ ចម្រៀងដែលសាមញ្ញ និង ចម្រៀងដែលមានឃ្លាដដែលៗ គឺសមរម្យសម្រាប់កុមារដែលមានអាយុស្ថិតក្នុងថ្នាក់ទារកដ្ឋាន ។ អ្នកអាចបន្ថែមសកម្មភាពងាយៗ ដែលបានស្នើដោយពាក្យទាំងឡាយនោះ ។
- គេហទំព័រតន្ត្រីសាសនាចក្រ www.lds.org/churchmusic ។ នៅទីនេះ អ្នកអាចស្តាប់តន្ត្រីចំពោះចម្រៀងនៅក្នុង *សៀវភៅចម្រៀងកុមារ* និង សៀវភៅទំនុកតម្កើង ។
- ជំនួយមកពីអ្នកដឹកនាំតន្ត្រីអង្គការបឋមសិក្សារបស់អ្នក ។

បញ្ហាចម្បង និង ដំណោះស្រាយដែលអាចមាន

នៅខាងក្រោមនេះ គឺជាបញ្ហាទូទៅមួយចំនួន ដែលអាចកើតមាននៅក្នុងថ្នាក់ទារកដ្ឋាន និង យោបល់មួយចំនួនសម្រាប់ជាដំណោះស្រាយ ។ នៅក្នុងស្ថានភាពទាំងអស់ ចូរសរសើរដល់កុមារដោយស្មោះ នៅពេលគេមានឥរិយាបទត្រឹមត្រូវ ។ ការបង្ខំកុមារឲ្យធ្វើតាម គឺពុំមែនជាដំណោះស្រាយចំពោះបញ្ហាឥរិយាបទនោះទេ ។ សូមចងចាំថា វាសំខាន់ដើម្បីឲ្យកុមារគ្រប់រូបមានបទពិសោធន៍អំពីក្តីស្រឡាញ់ ភាពរីករាយ នៅក្នុងថ្នាក់ទារកដ្ឋាន ។

បញ្ហា	*ដំណោះស្រាយដែលអាចមាន*
ឪពុក ឬ ម្តាយនាំកូនមកថ្នាក់ទារកដ្ឋាន ហើយកុមារយំ នៅពេលឪពុក ឬ ម្តាយ ព្យាយាមចេញពីថ្នាក់ ។	សូមអញ្ជើញឲ្យឪពុក ឬម្តាយ បន្តនៅរហូតដល់កុមារ ស្ងៀម ហើយឈប់យំ ។ ចូរព្យាយាមដើម្បីធ្វើឲ្យកុមារចាប់អារម្មណ៍ទៅលើសកម្មភាព ដែលមាននៅក្នុងថ្នាក់ទារកដ្ឋាន ហើយអញ្ជើញគេឲ្យចូលរួម ។
កុមារ ហាក់ដូចជាខ្លាចអ្នក ឬខ្លាចកុមារផ្សេងទៀត ដោយចង់ដើរជុំវិញថ្នាក់ទារកដ្ឋាន ឬ ពុំចង់ប្រាស្រ័យទាក់ទងនឹងនរណាម្នាក់ ។	ចូរអត់ធ្មត់ កុំបង្ខំកុមារឲ្យចូលរួមឡើយ ។ ទុកពេលឲ្យគេ ស្គាល់អ្នក ស្គាល់កុមារផ្សេងទៀត និង បរិដ្ឋានជុំវិញ ។ ចូរបញ្ជាក់អះអាងនឹងកុមារម្តងម្កាល ហើយសូមបន្តអញ្ជើញគេឲ្យចូលរួមក្នុងសកម្មភាពមួយ ។ សូមជួយអះអាងថា ថ្នាក់ទារកដ្ឋាន គឺជាបទពិសោធន៍មួយនៃក្តីស្រឡាញ់ដ៏រីករាយសម្រាប់កុមារ ។
កុមារនៅតែជាប់នឹងអ្នក ហើយតម្រូវឲ្យអ្នកយកចិត្តទុកដាក់ខ្លាំងខ្លួន ។	កុមារតូចៗ ត្រូវការភាពកក់ក្តៅ និង ការយកចិត្តទុកដាក់ ។ តាមធម្មតា ការនិយាយ និង ទំនាក់ទំនងជាមួយនឹងកុមារក្នុងឥរិយាបទពោរពេញទៅដោយក្តីស្រឡាញ់ នឹងធ្វើឲ្យគេពេញចិត្ត ។ បន្ទាប់មក សូមលើកទឹកចិត្តដល់កុមារឲ្យចូលរួមនៅក្នុងសកម្មភាពនានារបស់ថ្នាក់ទារកដ្ឋាន ។
កុមារនឹងពុំអង្គុយនៅស្ងៀម និង ស្តាប់អំឡុងមេរៀននោះឡើយ ។ គេរំខាន ឬ ធ្វើឲ្យកុមារដទៃទៀតអន់ចិត្ត ។	អ្នកដឹកនាំថ្នាក់ទារកដ្ឋានម្នាក់ អាចនាំឲ្យកុមារយកចិត្តទុកដាក់ទៅលើសកម្មភាព ខណៈពេលដែលអ្នកដឹកនាំម្នាក់ទៀត កំពុងបង្រៀន ។ ការផ្តល់អ្វីមួយឲ្យកុមារកាន់នោះ អាចជួយឲ្យគេចូលរួមយ៉ាងសកម្មនៅក្នុងមេរៀន ។ បើចាំបាច់ អ្នកអាចឲ្យកុមារនោះអង្គុយជាមួយនឹងគ្រូបង្រៀនទីពីរ ដើម្បីអនុញ្ញាតឲ្យកុមារដទៃទៀត មានបទពិសោធន៍អំពីមេរៀនដ៏ល្អ និងមានប្រយោជន៍ ។ សូមចងចាំថា ត្រូវទំនាក់ទំនងជាមួយកុមារដោយមានឥរិយាបទនៃក្តីស្រឡាញ់ និងការគាំទ្រជានិច្ច ។

បញ្ហា	*ដំណោះស្រាយដែលអាចមាន*
កុមារក្រោកឡើង ហើយដើរចេញមុនពេលសកម្មភាពមួយ ត្រូវបានបញ្ចប់ ។	ត្រូវប្រុងប្រៀប និងដឹងអំពីតម្រូវការ ចំណាប់អារម្មណ៍ និង រយៈពេលនៃការយកចិត្តទុកដាក់របស់កុមារម្នាក់ៗ ។ សូមរកមើលពីសញ្ញានៃការសាប់រសល់ ដូច្នេះអ្នកអាចសម្របសកម្មភាព ដើម្បីឲ្យត្រូវនឹងតម្រូវការរបស់កុមារ ។ ខណៈពេលដែលគ្រូបង្រៀនម្នាក់ កំពុងដឹកនាំសកម្មភាព គ្រូបង្រៀនដទៃទៀត អាចអញ្ជើញ និងលើកទឹកចិត្តកុមារដែលពុំចាប់អារម្មណ៍បាន ។ ចូរកុំបង្ខំកុមារឲ្យចូលរួមនៅក្នុងសកម្មភាពណាមួយឡើយ ។
កុមារចាប់ផ្តើមឈ្លោះដណ្តើមសម្ភារគ្នាលេង ។	កុមារតូចៗមានការពិបាកនៅក្នុងការចែកចាយរបស់លេងជាមួយនឹងគ្នា ។ អ្នកអាចត្រូវចូលទៅជួយពួកគេដោះស្រាយបញ្ហា ឬ រារាំងកុំឲ្យពួកគេវាយគ្នាទៅវិញទៅមក ។ សូមប្រាប់ពួកគេពីរបៀបដែលពួកគេ អាចលេងសម្ភារលេងជាមួយគ្នា ឬ ឲ្យពួកគេលេងសម្ភារ និងសកម្មភាពផ្សេងៗទៀត ។ សូមធ្វើឲ្យប្រាកដថា មានសម្ភារលេងគ្រប់គ្រាន់សម្រាប់កុមារម្នាក់ៗ ។ សូមសរសើរដល់កុមារដែលលេងបានត្រឹមត្រូវ ។
កុមារចាប់ផ្តើមលេងក្តាំង ដូចជា — ការបោះ ការយោល ឬ ការបោកសម្ភារលេង ។	អ្នកចាំបាច់ត្រូវធ្វើអន្តរាគមន៍ចំពោះឥរិយាបទនេះ ។ ថ្នាក់ទារកដ្ឋាន ត្រូវការបរិដ្ឋានសុវត្ថិភាពសម្រាប់កុមារ ។ ចូរពន្យល់ដល់កុមារដោយក្តីស្រឡាញ់ថា គេពុំអាចលេងរបៀបនេះបានទេ បន្ទាប់មកសូមនាំកុមារឲ្យចាប់អារម្មណ៍លេងអ្វីផ្សេងវិញ ។ សូមសរសើរដល់កុមារចំពោះឥរិយាបទត្រឹមត្រូវ ។
កុមារចាប់ផ្តើមយំ ហើយយំរង្គំវៗ ។ នៅពេលអ្នកព្យាយាមលួងលោម គេនិយាយអ្វីមួយដូចជា « ខ្ញុំមិនចូលចិត្តអ្នកទេ » ឬ « អ្នកពុំមែនជាម្តាយខ្ញុំទេ » ហើយរុញអ្នកចេញ ។	ចូរនាំកុមារឲ្យយកចិត្តទុកដាក់លើអ្វី ដែលកំពុងតែមាននៅក្នុងថ្នាក់ទារកដ្ឋាន ឬសម្ភារលេង ឬ សៀវភៅវិញ ។ ការណ៍នេះ អាចជួយកុមារឲ្យនៅស្ងៀម ។ បើសិនជាគេពុំស្រួលចិត្តទេ ចូរនាំកុមារទៅឲ្យឪពុកម្តាយរបស់គេវិញ ។

ជូនចំពោះមាតាបិតា

យើងខ្ញុំទន្ទឹងរង់ចាំដើម្បីទទួលកូនរបស់លោកអ្នកមកក្នុងថ្នាក់ទារកដ្ឋាន ! នេះជាចំនុចមួយចំនួនដែលលោកអ្នកអាចធ្វើ ដើម្បីធ្វើឲ្យកូនរបស់លោកអ្នកមានបទពិសោធន៍រីករាយ ៖

- សូមនិយាយចំនុចវិជ្ជមានអំពីថ្នាក់ទារកដ្ឋានប្រាប់កូនរបស់លោកអ្នក អំឡុងពេលសប្តាហ៍ មុនពេលគេចូលរួមថ្នាក់ទារកដ្ឋានជាលើកដំបូង ។
- សូមនិយាយទៅកាន់កូនរបស់លោកអ្នក អំពីអ្វីដែលកើតមាននៅក្នុងថ្នាក់ទារកដ្ឋាន ។ សូមជួយគេឲ្យដឹងអំពីអ្វីដែលត្រូវរំពឹងទុក ។
- សូមមើលថែកូនរបស់លោកអ្នកឲ្យទៅបន្ទប់ទឹក ហើយទទួលទានឲ្យរួចរាល់ មុនពេលនាំគេមកថ្នាក់ទារកដ្ឋាន ។ កុមារដែលត្រូវការដូរខោទឹកនោម នឹងត្រូវនាំទៅរកឪពុកម្តាយ ។
- សូមជូនដំណឹងដល់អ្នកដឹកនាំថ្នាក់ទារកដ្ឋាន បើកូនរបស់លោកអ្នក មានបញ្ហាពិសេសមួយ ដូចជាមានប្រតិកម្មនឹងចំណីអ្វីមួយ ។
- សូមបន្តនៅក្នុងថ្នាក់ទារកដ្ឋានជាមួយនឹងកូនរបស់លោកអ្នក បើគេមានភាពភ័យខ្លាច ។
- សូមប្រាប់ដល់អ្នកដឹកនាំថ្នាក់ទារកដ្ឋាន ពីកន្លែងដែលលោកអ្នកនឹងនៅ អំឡុងពេលថ្នាក់ទារកដ្ឋាន ។
- សូមប្រាប់អះអាងដល់កូនរបស់លោកអ្នកថា អ្នកនឹងត្រឡប់មកវិញនៅពេលក្រោយ ។
- សូមត្រឡប់មកទទួលកូនរបស់លោកអ្នកវិញភ្លាម នៅពេលថ្នាក់ទារកដ្ឋានបញ្ចប់ ។ បើមាននរណាម្នាក់ក្រៅពីឪពុកម្តាយ ឬបងប្អូន នឹងមកទទួលយកកូនរបស់លោកអ្នក សូមប្រាប់អ្នកដឹកនាំថ្នាក់ទារកដ្ឋានឲ្យបានដឹងថា បុគ្គលម្នាក់នោះ ទទួលបានការអនុញ្ញាតរបស់លោកអ្នកឲ្យមកទទួល ។
- សូមពង្រឹងបន្ថែមនូវអ្វីដែលបានបង្រៀនក្នុងមេរៀនថ្នាក់ទារកដ្ឋាននៅឯគេហដ្ឋាន ។
- បើអាចធ្វើទៅបាន សូមផ្តល់រូបថតកូនរបស់លោកអ្នក និង រូបថតនៃគ្រួសារកូនរបស់លោកអ្នកមួយសន្លឹកដល់យើងខ្ញុំ ។

សូមកុំនាំកូនរបស់លោកអ្នកមកកាន់ថ្នាក់ទារកដ្ឋាន នៅពេលគេឈឺ ឬ មានរោគសញ្ញាណាមួយដូចខាងក្រោមនេះ ៖

- គ្រុនក្តៅ
- ហូរសម្បោរ
- ក្អក
- អារម្មណ៍ខុសពីធម្មតា
- ក្អួត
- រាគរូស
- កន្ទួលក្រហមអុចៗ
- រោគភ្នែកឆ្លង
- ក្បាលមានចៃ
- មានជំងឺ ឬ រោគឆ្លងដែលបានព្យាបាលដោយប្រើថ្នាំ ក្នុងរយៈពេល 48 ម៉ោងមុន
- ជំងឺឆ្លងអំឡុងពេលមួយដែលនៅឆ្លង ៖
  - ជំងឺអុតស្វាយ (ប្រាំពីរថ្ងៃ)
  - ជំងឺកញ្ជ្រិល (រហូតដល់កន្ទួលក្រហមរលុបបាត់)
  - ជំងឺអុចក្តាម (រហូតដល់កន្ទួលក្រហមរលុបបាត់)
  - ជំងឺស្រឡើទែន (រហូតដល់ការហើមបានស្រកបាត់ ជាធម្មតាមានរយៈពេលប្រាំពីរថ្ងៃ)
  - ពងបែកតូចៗលើដៃ និង ជើង

បើកូនរបស់លោកអ្នកមានប្រតិកម្មដែលបណ្តាលឲ្យហៀរសំបោរ ក្អក ឬ កន្ទួលក្រហម សូមប្រាប់ដល់អ្នកដឹកនាំថ្នាក់ទារកដ្ឋានឲ្យបានដឹងថា រោគសញ្ញារបស់កូនលោកអ្នក ពុំឆ្លងដល់គេទេ ។

សូមទំនាក់ទំនងទៅកាន់អ្នកដឹកនាំថ្នាក់ទារកដ្ឋានបានគ្រប់ពេល បើលោកអ្នកមានចម្ងល់ ឬ មានសំណួរណាមួយនោះ ៖

_____	_____
អ្នកដឹកនាំថ្នាក់ទារកដ្ឋាន	លេខទូរស័ព្ទ
_____	_____
អ្នកដឹកនាំថ្នាក់ទារកដ្ឋាន	លេខទូរស័ព្ទ

1 ខ្ញុំជាកូនរបស់ព្រះ

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

យើងម្នាក់ៗ គឺជាបុត្រា ឬ បុត្រីសំណប់ខាងវិញ្ញាណរបស់ព្រះមាតាបិតាសួគ៌ ។ យើងបានរស់នៅជាមួយទ្រង់ មុនពេលយើងចាប់កំណើតមក ។ ព្រះវរបិតាសួគ៌របស់យើង ស្គាល់យើងម្នាក់ៗច្បាស់ ហើយទ្រង់ស្រឡាញ់យើង ។ (សូមមើល ទំនុកតម្កើងតម្កើង 82:6 ; កិច្ចការ 17:28–29 ; ហេព្រើរ 12:9) ។

ការរៀបចំខ្លួន

- សូមយកគម្ពីរមកផង ។ សូមគូសចំណាំ ទំនុកតម្កើង 82:6 និង ម៉ូសេ 1:4 ដើម្បីអ្នកអាចបើកវាដោយងាយស្រួល ។
- សូមគូសចំណាំទំព័រ 99 នៅក្នុងសៀវភៅសិក្សានេះ ដើម្បីអ្នកអាចបើកវាដោយងាយស្រួល ។

សកម្មភាពទាំងឡាយក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

ចម្រៀង ច្រៀង ឬនិយាយវគ្គទីមួយនៃបទ « ខ្ញុំជាកូនរបស់ព្រះ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 58) ៖

ខ្ញុំជាកូនរបស់ព្រះ
ហើយទ្រង់បានចាត់ខ្ញុំមក ។

សូមនិយាយឡើងវិញពីរ ឬ បីដង រួចអញ្ជើញកុមារដើម្បីច្រៀងជាមួយនឹងអ្នក ។

ចម្រៀង ៖ ចូរប្រើតន្ត្រី ដើម្បីបង្រៀនគោលការណ៍ទាំងឡាយនៃដំណឹងល្អ និង អញ្ជើញព្រះវិញ្ញាណ ។ កុមារមួយចំនួនតូច អាចនឹងព្យាយាមច្រៀងជាមួយអ្នក ប៉ុន្តែកុមារភាគច្រើននឹងប្រហែលជាគ្រាន់តែមើលអ្នកខណៈពេលអ្នកច្រៀង ។ ពួកគេរៀនចម្រៀង តាមរយៈការស្តាប់ ហើយពួកគេចូលចិត្តចម្រៀង ទោះបីជាពួកគេពុំច្រៀងក្តី ។

បទគម្ពីរ សូមប្រាប់កុមារថា ពួកគេមានម្តាយ និង ឪពុកនៅលើផែនដីដែលស្រឡាញ់ពួកគេ ។ សូមប្រាប់ពួកគេថា ពួកគេក៏មានព្រះវរបិតាសួគ៌មួយអង្គ ដែលស្គាល់ និង ស្រឡាញ់ពួកគេផងដែរ ។ សូមបើកព្រះគម្ពីរបរិសុទ្ធ ទំនុកតម្កើង 82:6 ហើយអាន « អ្នកទាំងអស់គ្នា គឺជាកូនរបស់ [ព្រះ] » ។

រឿងបទគម្ពីរ សូមបង្ហាញរូបភាពម៉ូសេ នៅទំព័រ 99 (អ្នកអាចនឹងចង់ចាំងរូបភាពដទៃទៀតនៅលើទំព័រនេះ ដើម្បីជួយកុមារឲ្យផ្តោតទៅលើរូបម៉ូសេ) ។ សូមពន្យល់ថា ម៉ូសេ គឺជាព្យាការីដ៏អស្ចារ្យម្នាក់ ដែលបានរស់នៅកាលពីយូរលង់មកហើយ ។ សូមប្រាប់ដល់កុមារថា ម៉ូសេបានឡើងទៅលើភ្នំមួយដើម្បីអធិស្ឋាន ។ សូមអញ្ជើញកុមារឲ្យសម្តែងធ្វើជាឡើងលើភ្នំ រួចហើយឲ្យពួកគេឱបដៃ ធ្វើដូចជាអធិស្ឋាន ។ សូមបើកទៅគម្ពីរមុត្តាជំមានតម្លៃមហិមានៅ ម៉ូសេ 1:4 ហើយនិយាយថា « ព្រះមានព្រះបន្ទូលទៅកាន់ម៉ូសេថា ‹ ហើយមើលចុះ អ្នកជាបុត្ររបស់យើង › » ។ សូមពន្យល់ថា ម៉ូសេ បានដឹងថា គាត់គឺជាកូនម្នាក់របស់ព្រះ ។

ឈ្មោះ ៖ កុមារថ្នាក់ទារកដ្ឋានពេញចិត្តស្តាប់ឮឈ្មោះរបស់ពួកគេឮ ហើយចង់មានចំណែកក្នុងមេរៀន ។ សូមបង្ហាញដល់កុមារថា អ្នកស្រឡាញ់ពួកគេ តាមរយៈការរៀនពីឈ្មោះរបស់ពួកគេ ហើយសរសើរដល់ពួកគេចំពោះការចូលរួម ។

សកម្មភាពផ្សេងៗ សូមអញ្ជើញកុមារម្នាក់ឲ្យឈរនៅជិតអ្នក នៅខាងមុខថ្នាក់រៀន ។
សូមនិយាយថា ៖ « នេះគឺជា [ឈ្មោះរបស់កុមារ] ។
ចូរសុំឲ្យកុមារទាំងឡាយនិយាយ ឈ្មោះរបស់កុមារនោះឡើងវិញ ។
សូមនិយាយថា ៖ [ឈ្មោះរបស់កុមារ] គឺជាកូនរបស់ព្រះ » ។
ចូរសុំឲ្យកុមារថាសារឡើងវិញ ៖ « [ឈ្មោះរបស់កុមារ] ជាកូនរបស់ព្រះ » ។
ចូរធ្វើសកម្មភាព សម្រាប់កុមារម្នាក់ៗក្នុងថ្នាក់ទារកដ្ឋាន សារឡើងវិញ ។ បើសិនជាថ្នាក់ទារកដ្ឋានមានទំហំធំ អ្នកអាចបង្ហាញកុមារពីរនាក់ម្តងៗ ឬ កាត់សកម្មភាពឲ្យនៅខ្លីបើចាំបាច់ ។

រូបភាព សូមបង្ហាញរូបភាពនៅទំព័រ 10 ចង្អុលទៅកុមារម្នាក់នៅក្នុងរូបភាព ហើយសូមសួរថា « តើមនុស្សម្នាក់នេះជាកូនរបស់ព្រះដែរឬទេ ? » ងក់ក្បាល ហើយនិយាយថា បាទ ឬ ចាស៎ ! និយាយរឿងសារឡើងវិញក្នុងរូបភាពដល់កុមារម្នាក់ៗ ។ បន្ទាប់មក សូមចង្អុលមកខ្លួនអ្នក

គន្លឹះក្នុងការបង្រៀន

ហើយសួរថា « តើខ្ញុំជាកូនរបស់ព្រះដែរឬទេ ? » ងក់ក្បាល ហើយនិយាយថា បាទ ឬ ចាស៎ ! សូមគូសបញ្ជាក់ថា *មនុស្សគ្រប់រូប* គឺជាកូនរបស់ព្រះ ហើយទ្រង់ស្គាល់ និង ស្រឡាញ់យើងម្នាក់ៗ ។

សេចក្តីបញ្ចប់ សូមចែកចាយទីបន្ទាល់របស់អ្នកថា យើងទាំងអស់គ្នា គឺជាកូនរបស់ព្រះ ហើយថា ទ្រង់ស្គាល់ និង ស្រឡាញ់យើង ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់សកម្មភាពប័ណ្ណប្រកាស ៖* សូមអញ្ជើញឪពុកម្តាយឲ្យយករូបថតរបស់កូនៗ ពួកគាត់មកថ្នាក់ទារកដ្ឋាន (ពួកគាត់ប្រហែលជាបានឲ្យរូបថតរួចហើយ ពេលកុមារមកចូលរួមថ្នាក់ទារកដ្ឋានជាលើកដំបូង សូមមើល ទំព័រ 7) ។ នៅផ្នែកខាងលើនៃប័ណ្ណប្រកាស សូមសរសេរថា « ខ្ញុំជាកូនរបស់ព្រះ » ។ សូមទុកចន្លោះឲ្យបានធំ សម្រាប់បិទរូបថតរបស់កុមារ ។

សម្រាប់សកម្មភាពរូបភាព ៖ សូមថតចម្លងរូបភាពនៅលើទំព័រ 11 ដើម្បីឲ្យកុមារម្នាក់ៗអាចទទួលបានមួយ ។

វគ្គសកម្មភាព សូមអញ្ជើញកុមារឲ្យឈរ ហើយធ្វើតាមវគ្គសកម្មភាពដូចខាងក្រោមជាមួយអ្នក ៖

បើសិនអ្នកខ្ពស់ ខ្ពស់ពេក *(សូមលើកដៃឡើងខ្ពស់)*
ព្រះវរបិតាសួគ៌ស្គាល់ និង ស្រឡាញ់អ្នក ។
បើសិនជាអ្នកតូច តូចបំផុត *(សូមក្រាបខ្លួនចុះ)*
ព្រះវរបិតាសួគ៌ស្គាល់ និង ស្រឡាញ់អ្នក ។
ខ្ពស់ *(សូមលើកដៃឡើងលើ)*
តូច *(សូមក្រាបខ្លួនចុះ)*
ខ្ពស់*(សូមលើកដៃឡើងលើ)*
តូច*(សូមក្រាបខ្លួនចុះ)*
ព្រះវរបិតាសួគ៌ស្គាល់ និងស្រឡាញ់អ្នក ។

ប័ណ្ណប្រកាស បិទរូបថតកុមារទៅលើប័ណ្ណប្រកាស ដែលអ្នកបានរៀបចំ ។ សូមអានចំណងជើងនៃប័ណ្ណប្រកាសដល់កុមារ ហើយសូមរំឭកពួកគេថា យើងទាំងអស់គ្នាជាកូនរបស់ព្រះ ។ សូមដាក់តាំងប័ណ្ណប្រកាសជារៀងរាល់សប្តាហ៍ ហើយសូមបន្ថែមរូបថតនៅលើនោះ ពេលមានកុមារដទៃទៀតចូលមកក្នុងថ្នាក់ទារកដ្ឋាន ។

រូបភាព សូមផ្តល់ដល់កុមារម្នាក់ៗនូវរូបភាពមួយនៃរូបភាពទាំងឡាយនៅលើទំព័រ 11 ។ សូមអញ្ជើញកុមារឲ្យចង្អុលផ្នែកផ្សេងៗនៃផ្នែកមុខ (ដូចជា ភ្នែក មាត់ ជាដើម) ។ ចូរឲ្យកុមារជាត់ពណ៌រូបភាព តាមចំណូលចិត្ត ។

គន្លឹះក្នុងការបង្រៀន

ការអធិស្ឋាន ៖ បើកុមារត្រូវការជំនួយក្នុងការអធិស្ឋាន សូមជួយគេឲ្យអធិស្ឋានប្រាប់ជាឃ្លាខ្លី។ សាមញ្ញ។ដើម្បីឲ្យគេចាតាម ។ កុមារកុមារធំ។ អាចអធិស្ឋានដោយប្រើពាក្យរបស់គេផ្ទាល់ ។

ធ្វើការថតចម្លង ៖ បើអ្នកពុំមានម៉ាស៊ីនថតចម្លង អ្នកអាចដាក់ក្រដាសទទេមួយពីលើរូបភាព ហើយដានរូបភាពនោះ ។

ការជាត់ពណ៌ ៖ ពុំមែនកុមារទាំងអស់ សុទ្ធតែចូលចិត្តជាត់ពណ៌រូបនោះទេ ។ កុមារមួយចំនួនអាចនឹងគូសតែមួយ ឬពីរបន្ទាត់នៅលើទំព័រគំនូរនោះតែប៉ុណ្ណោះ ។ គោលបំណងនៃរូបភាពនៅក្នុងមេរៀនទាំងនេះ គឺដើម្បីផ្តល់ដល់កុមារនូវការបង្ហាញជារូបភាពអំពីមេរៀន ដែលពួកគេអាចកាន់ និង យកទៅផ្ទះបាន ។ វាពុំសំខាន់ទេ ដែលពួកគេត្រូវជាត់ពណ៌រូបភាពដោយប៉ិនប្រសប់នោះទេ ។



ខ្ញុំជាកូនរបស់ព្រះ



ខ្ញុំជាកូនរបស់ព្រះ

2 ព្រះវរបិតាសួគ៌មានផែនការមួយសម្រាប់ខ្ញុំ

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

យើងបានរស់នៅជាមួយព្រះវរបិតាសួគ៌ជាវិញ្ញាណ មុនពេលយើងចាប់កំណើតមក ។ ព្រះវរបិតាសួគ៌ បានរៀបចំផែនការមួយដែលអនុញ្ញាតឲ្យយើងមកកាន់ផែនដី និង ទទួលយករូបកាយសាច់ឈាម ដើម្បីយើងអាចប្រែក្លាយដូចជាទ្រង់ ហើយត្រឡប់ទៅកាន់វត្តមានរបស់ទ្រង់វិញ ។ ការណ៍នេះ អាចធ្វើទៅបាន តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ និង ការគោរពប្រតិបត្តិរបស់យើង ។ ព្រះយេស៊ូវគ្រីស្ទ ត្រូវបានជ្រើសរើសឲ្យធ្វើជាព្រះអង្គសង្គ្រោះរបស់យើង ។ (សូមមើល អ័ប្រាហាំ 3:24–27 ; មាត្រានៃសេចក្តីជំនឿ 1:3) ។

ការរៀបចំខ្លួន

សូមគូសចំណាំទំព័រ 98 នៅក្នុងសៀវភៅសិក្សានេះ ដើម្បីអ្នកអាចបើកវាដោយងាយស្រួល ។

សកម្មភាពទាំងឡាយក្នុងការរៀនសូត្រ

ចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន អញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

ច្រៀងរឿងមួយ ប្រើបទ « ខ្ញុំជាកូនរបស់ព្រះ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 58) ដើម្បីបង្រៀនដល់កុមារនូវព័ត៌មានលម្អិតជាមូលដ្ឋានមួយចំនួនអំពីផែនការសង្គ្រោះ ។ គម្រោងដូចខាងក្រោម គឺជាយោបល់មួយ ៖

សូមប្រាប់ដល់កុមារថា យើងទាំងអស់គ្នាបានរស់នៅជាមួយនឹងព្រះវរបិតាសួគ៌ មុនពេលយើងចាប់កំណើតមក ។

ច្រៀង ឬ និយាយ (សូមអញ្ជើញកុមារឲ្យចូលរួមនឹងអ្នក) ៖

ខ្ញុំជាកូនរបស់ព្រះ
ហើយទ្រង់បានចាត់ខ្ញុំមក ។

ចូរប្រាប់កុមារថា ព្រះវរបិតាសួគ៌ មានផែនការមួយសម្រាប់យើង ។ ទ្រង់បានមានបន្ទូលប្រាប់យើងថា យើងនឹងមករស់នៅលើផែនដី ។ យើងសប្បាយចិត្តជាខ្លាំង រហូតដល់យើងបានស្រែកអំណរសាទរ ។ សូមអញ្ជើញកុមារឲ្យនិយាយថា « ជយោ ! »

សូមបង្ហាញរូបភាពរបស់គ្រួសារមួយនៅទំព័រ 14 ។ ចូរប្រាប់កុមារថា យើងមកកាន់ផែនដីដើម្បីរស់នៅជាមួយនឹងគ្រួសារមួយ ដែលស្រឡាញ់យើង ។ សូមអញ្ជើញកុមារឲ្យឱបដៃរបស់ពួកគេ ហើយឱបខ្លួន ។

ច្រៀង ឬ និយាយ ៖

បានឲ្យផ្ទះខ្ញុំនៅលើផែនដី
ជាមួយឪពុកម្តាយល្អ ។

សូមប្រាប់ដល់កុមារថា ខណៈពេលដែលយើងនៅលើផែនដី ព្រះវរបិតាសួគ៌ សព្វព្រះទ័យចង់ឲ្យយើងសប្បាយរីករាយ ហើយធ្វើតាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

ច្រៀង ឬ និយាយ ៖

នាំខ្ញុំ ដឹកខ្ញុំ ដើរនៅក្បែរខ្ញុំ
ជួយខ្ញុំឲ្យរកផ្លូវ ។

សូមបង្ហាញរូបភាពរបស់ព្រះយេស៊ូវគ្រីស្ទ នៅលើទំព័រ 98 ។ សូមប្រាប់ដល់កុមារថា ព្រះវរបិតាសួគ៌ បានជ្រើសរើសព្រះយេស៊ូវគ្រីស្ទ ដើម្បីជួយយើងឲ្យត្រឡប់ទៅរកទ្រង់វិញ ។ សូមពន្យល់ថា ដោយសារតែព្រះយេស៊ូវ នោះយើងអាចរស់នៅជាមួយ

គន្លឹះក្នុងការបង្រៀន

ការរៀបចំ ៖ សូមរៀបចំរូបភាពរូបគំនូរ និង សម្ភារដទៃទៀត មុនពេលថ្នាក់ទារកដ្ឋានចាប់ផ្តើម ។ ការណ៍នេះនឹងជួយអ្នកឲ្យផ្តោតការយកចិត្តទុកដាក់ទៅលើកុមារ ។

សកម្មភាពនានាក្នុងការរៀនសូត្រ ៖ ដើម្បីលើកទឹកចិត្តកុមារ ហើយជួយពួកគេឲ្យផ្តោតទៅលើមេរៀន សូមប្រមូលផ្តុំពួកគេមកជិតនៅជុំវិញអ្នក ។ បើអាចធ្វើទៅបាន សូមលុតជង្គង់ ឬ អង្គុយចុះ ដើម្បីអ្នកអាចមើលចំតែភ្នែកពួកគេ ។ សូមកាន់រូបភាពឲ្យជិតពួកគេ ។

នឹងព្រះវរបិតាសួគ៌ និង ក្រុមគ្រួសាររបស់យើងជានិរន្តរ៍ បើយើងកាន់តាមបទបញ្ញត្តិទាំងឡាយ ។

ច្រៀង ឬ និយាយ ៖
បង្រៀនខ្ញុំអ្វីដែលត្រូវធ្វើ
ដើម្បីរស់នៅនឹងទ្រង់ ។

ច្រៀងចម្រៀងទាំងអស់ ដោយបង្ហាញរូបភាពនៅពេលអ្នកច្រៀង ។
ខ្ញុំជាកូនរបស់ព្រះ
ហើយទ្រង់បានចាត់ខ្ញុំមក
បានឲ្យផ្ទះខ្ញុំនៅលើផែនដី *(បង្ហាញរូបភាពរបស់គ្រួសារនៅទំព័រ 14)* ។
ជាមួយឪពុកម្តាយល្អ ។
នាំខ្ញុំ ដឹកខ្ញុំ ដើរនៅក្បែរខ្ញុំ
ជួយខ្ញុំឲ្យរកផ្លូវ ។
បង្រៀនខ្ញុំអ្វីដែលត្រូវធ្វើ *(បង្ហាញរូបភាពរបស់ព្រះយេស៊ូវនៅទំព័រ 98)* ។
ដើម្បីរស់នៅនឹងទ្រង់ ។

សេចក្តីបញ្ចប់ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីផែនការរបស់ព្រះវរបិតាសួគ៌សម្រាប់យើង ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់ល្បែងថង់ ៖* សូមថតចម្លង និង កាត់រូបភាពចេញមកពីទំព័រ 15 ។ សូមនាំយកអ្វីមួយដូចជា ថង់តូចមួយ ឬ ក្រណាត់មកបាំងរូបភាពនៅខាងក្នុង ។
សម្រាប់សកម្មភាពជាត់ពណ៌ ៖ ថតចម្លងទំព័រ 15 សម្រាប់កុមារម្នាក់ៗ ។ សូមកាត់រូបភាព និង ក្រដាសពាក្យចេញមក ។ សូមយកខ្សែ ឬខ្សែអំបោះមក ហើយបិទកាវធ្វើឲ្យវាអាចធ្វើចលនាបានសម្រាប់កុមារ ។

ល្បែងថង់ ដាក់រូបភាពនៅក្នុងថង់ ។ សូមឲ្យកុមារម្នាក់ជ្រើសរើសរូបភាពមួយចេញពីថង់ ។ សូមអានឬច្រៀងចំណងជើង ហើយសូមឲ្យកុមារនិយាយ ឬច្រៀងពាក្យនោះឡើងវិញជាមួយអ្នក ។ សូមថាឡើងវិញរហូតដល់កុមារម្នាក់ៗដែលចង់ដល់វេនខ្លួន បានធ្វើម្តង ។

ការជាត់ពណ៌ សូមឲ្យកុមារជាត់ពណ៌លើរូបភាពដែលថតចម្លងចេញពីទំព័រ 15 ហើយសូមឲ្យពួកគេយកវាទៅផ្ទះ ដើម្បីបង្ហាញដល់ឪពុកម្តាយរបស់ពួកគេអំពីអ្វីដែលពួកគេបានរៀនក្នុងថ្នាក់ទារកដ្ឋាន ។ បើអ្នកមានពេល សូមប្រើខ្សែ ឬខ្សែអំបោះ ហើយបិទវាដោយធ្វើឲ្យវាអាចធ្វើចលនាបានសម្រាប់កុមារ ដូចបានបង្ហាញនៅក្នុងរូបនៅខាងស្តាំ ។



គន្លឹះក្នុងការបង្រៀន

ធនធានទាំងឡាយ ៖ សូមប្រើតែធនធានទាំងឡាយណាដែលបានបោះពុម្ពដោយសាសនាចក្រនៅក្នុងថ្នាក់ទារកដ្ឋាន (សូមមើល *Teaching, No Greater Call* ទំព័រ 105) ។ បើអ្នកត្រូវការអ្វីច្រើនទៀតសម្រាប់កុមារធ្វើ សូមជ្រើសរើសរឿង ល្បែងកំសាន្ត តុក្កតាអាយ៉ង ឬ សកម្មភាពជាត់ពណ៌ផ្សេងទៀតចេញពីសៀវភៅនេះ ឬ ចេញមកពីទស្សនាវដ្តីសាសនាចក្រនានា ។ អ្នកអាចប្រើសកម្មភាពទាំងនេះញឹកញាប់តាមតែអ្នកចង់ប្រើ ហើយអ្នកអាចបង្រៀនមេរៀនមួយក្នុងរយៈពេលមួយ ឬពីរសប្តាហ៍ជាប់ៗគ្នាក៏បាន ។

សកម្មភាពជម្រើស ត្រូវបានផ្តល់ឲ្យអ្នកដើម្បីបន្ថែមនៅក្នុងមេរៀនរបស់អ្នក តាមចំណូចិត្ត ។ បើពុំមានសម្ភារដែលត្រូវការទេ អ្នកអាចជំនួសវាដោយសម្ភារដែលស្រដៀងគ្នាបាន ។

ការជាត់ពណ៌ ៖ ខណៈពេលដែលកុមារកំពុងជាត់ពណ៌ សូមរឭកអំពីគោលការណ៍ទាំងឡាយដែលបានបង្រៀននៅក្នុងមេរៀន ។ សូមចង្អុលបង្ហាញពីព័ត៌មានលម្អិតនៅក្នុងរូបភាព ហើយសូមពន្យល់ទៅដល់កុមារអំពីអ្វីដែលពួកគេកំពុងជាត់ពណ៌ ។ សូមអានពាក្យនៅលើរូបភាពដល់ពួកគេ ។

ព្រះវរបិតាសួគ៌មាន ផែនការមួយសម្រាប់ខ្ញុំ



ខ្ញុំជាកូនរបស់ព្រះ ហើយ
ទ្រង់បានចាត់ខ្ញុំមក ។

បានឲ្យផ្ទះខ្ញុំនៅលើផែនដី
ជាមួយឪពុកម្តាយល្អ ។



បង្រៀនខ្ញុំអ្វីដែលត្រូវធ្វើ
ដើម្បីរស់នៅនឹងទ្រង់ ។

3 ខ្ញុំអាចអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

តាមរយៈការអធិស្ឋាន យើងអាចសន្ទនាជាមួយនឹងព្រះវរបិតាសួគ៌របស់យើងបាន ។ យើងទូលប្រាប់ទ្រង់ថា យើងស្រឡាញ់ទ្រង់ យើងអរព្រះគុណទ្រង់ចំពោះពរជ័យទាំងឡាយ ហើយយើងសុំទ្រង់ឲ្យជួយដល់ខ្លួនយើង និង អ្នកដទៃដែលខ្វះខាត ។ យើងបញ្ចប់ការអធិស្ឋានរបស់យើង ដោយនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ។ ការអធិស្ឋាន គឺជាពរជ័យដ៏មហិមាបំផុតមួយដែលយើងមាន ខណៈពេលដែលយើងនៅលើផែនដីនេះ ។ (សូមមើល ម៉ាថាយ 6:9–13 ; អាលម៉ា 34:18–27 ; នីហ្វៃទី 3 18:19–21) ។

ការរៀបចំខ្លួន

- សូមនាំយកវត្ថុតូចៗមួយចំនួន ឬរូបភាព ដែលតំណាងឲ្យវត្ថុដែលយើងមានអំណរគុណចំពោះវា (ដូចជា សម្លៀកបំពាក់, អាហារ, គម្ពីរ ជាដើម) ដាក់នៅក្នុងថង់ធំមួយ ។ សូមសរសេរពាក្យថា « យើងខ្ញុំអរព្រះគុណទ្រង់ » នៅលើថង់ ។ សូមយកថង់មួយទៀតដែលមានវត្ថុ ឬរូបភាព តំណាងឲ្យវត្ថុដែលយើងអាចនឹងសុំនៅក្នុងការអធិស្ឋាន (ដូចជា គ្រួសារីករាយ រូបកាយរឹងមាំ ក្តីស្រឡាញ់ ជាដើម) ។ សូមសរសេរពាក្យថា « សូមប្រទានពរដល់យើង » នៅលើថង់នេះ ។
- សូមគូសចំណាំទំព័រ 106 នៅលើសៀវភៅសិក្សានេះ ដើម្បីអ្នកអាចបើកវាដោយងាយស្រួល ។

សកម្មភាពទាំងឡាយក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

រូបភាព សូមបង្ហាញរូបភាពកុមារយេស៊ូវ កំពុងអធិស្ឋាន (ទំព័រ 18) ។ សូមប្រាប់កុមារថា នេះគឺជារូបភាពមួយរបស់ព្រះយេស៊ូវ កំពុងអធិស្ឋាន កាលទ្រង់នៅតូច ។ សូមបង្ហាញរូបភាពកុមារកំពុងអធិស្ឋាន (ទំព័រ 18) ។ សូមពន្យល់ថា នៅពេលយើងអធិស្ឋាន យើងកំពុងតែនិយាយទៅកាន់ព្រះវរបិតាសួគ៌ យើងចាប់ផ្តើមដោយការនិយាយថា « ឱព្រះវរបិតាសួគ៌ » ។ សូមអញ្ជើញកុមារឲ្យនិយាយថា « ឱព្រះវរបិតាសួគ៌ » ។

ចូរប្រាប់កុមារថា បន្ទាប់មកទៀត យើងអរព្រះគុណទ្រង់ចំពោះពរជ័យទាំងឡាយរបស់យើង ។ សូមឲ្យកុមារម្នាក់ជ្រើសរើសវត្ថុមួយមកពីថង់ ដែលបានបិទស្លាកថា « យើងខ្ញុំសូមអរព្រះគុណទ្រង់ » ។ សូមនិយាយថា « យើងខ្ញុំសូមអរព្រះគុណទ្រង់ចំពោះ [ឈ្មោះវត្ថុដែលកុមារបានជ្រើសរើស] របស់យើង » ។ សូមអញ្ជើញកុមារឲ្យនិយាយថា « យើងខ្ញុំសូមអរព្រះគុណទ្រង់ » ។ សូមធ្វើសកម្មភាពនេះសារឡើងវិញ រហូតដល់វត្ថុទាំងអស់ត្រូវបានរើសអស់ ។ បន្ទាប់មកសូមប្រាប់កុមារថា បន្ទាប់មកទៀត យើងទូលសុំព្រះវរបិតាសួគ៌នូវពរជ័យទាំងឡាយ ហើយធ្វើសកម្មភាពជាមួយនឹងថង់ ដែលបិទស្លាកថា « សូមប្រទានពរដល់យើងខ្ញុំ » ។ សូមអញ្ជើញកុមារឲ្យនិយាយថា « សូមប្រទានពរដល់យើងខ្ញុំ » ។

សូមបង្ហាញរូបភាពព្រះយេស៊ូវនៅទំព័រ 106 ។ សូមប្រាប់កុមារថា យើងបញ្ចប់ការអធិស្ឋានរបស់យើង ដោយនិយាយថា « នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន » ។ សូមអញ្ជើញកុមារឲ្យនិយាយជាមួយនឹងអ្នក ។

វគ្គសកម្មភាព សូមរៀបរាប់វគ្គសកម្មភាពដូចខាងក្រោម ហើយសូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ៖

ខ្ញុំចាប់ផ្តើមដោយការនិយាយថា « ឱ ព្រះវរបិតាសួគ៌ជាទីស្រឡាញ់ » ; *(សូមលើកម្រាមដៃមួយឡើង —បន្តលើកម្រាមដៃក្នុងវគ្គសកម្មភាពទាំងមូល)*

ខ្ញុំអរព្រះគុណទ្រង់ចំពោះពរជ័យទាំងឡាយ ដែលទ្រង់ប្រទាន *(សូមលើកម្រាមដៃទីពីរឡើង)*

គន្លឹះក្នុងការបង្រៀន

ការអធិស្ឋាន ៖ អ្នកអាចធ្វើបានច្រើន ដើម្បីជួយដល់កុមារឲ្យមានអារម្មណ៍គារវភាព នៅពេលពួកគេរៀបចំអធិស្ឋាន ។ ឧទាហរណ៍ សូមរំឭកពួកគេឲ្យអង្គុយចុះដោយស្ងៀមស្ងាត់ និង ឱបដៃរបស់ពួកគេ ។ អ្នកក៏អាចបង្រៀនភាសាអធិស្ឋានផងដែរ ដោយជួយពួកគេឲ្យប្រើពាក្យគួរគោរព ដូចជា *ទ្រង់, ព្រះទ្រង់, របស់ទ្រង់* និង *នៃទ្រង់* ជំនួសឲ្យពាក្យ *អ្នក* និង *របស់អ្នក* ។ អ្នកអាចរំឭកពួកគេនៅពេលពួកគេអធិស្ឋាន រហូតទាល់តែពួកគេរៀនប្រើពាក្យផ្ទាល់ខ្លួនរបស់ពួកគេបានដោយខ្លួនឯង ។

ការអញ្ជើញឲ្យមានការឆ្លើយតប ៖ កម្រិតសំឡេង ការមើលចំកែវភ្នែក និង ឥរិយាបថ គឺសំខាន់ នៅពេលកំពុងបង្រៀន ។ នៅពេលសួរសំណួរមួយ សូមមើលទៅកុមារ និយាយដោយសំឡេងលើកទឹកចិត្ត ដូចជា « តើប្អូនអាចនិយាយថា ‹ យើងខ្ញុំសូមអរព្រះគុណទ្រង់ › បានឬទេ ? » សូមសរសើរកុមារចំពោះការចូលរួម ។

បន្ទាប់មក ខ្ញុំទូលសុំដល់ទ្រង់ដោយរាបសារនូវអ្វីៗដែលខ្ញុំត្រូវការ *(សូមលើកម្រាមដៃទីបីឡើង)*
នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។ *(សូមលើកម្រាមដៃទីបួនឡើង)*
[« I Pray in Faith (ខ្ញុំអធិស្ឋានដោយក្តីជំនឿ) » *សៀវភៅចម្រៀងកុមារ* ទំព័រ 14]

សេចក្តីបញ្ចប់ សូមរំឭកដល់កុមារថា នៅពេលពួកគេអធិស្ឋាន នោះពួកគេកំពុងតែនិយាយទៅកាន់ព្រះវរបិតាសួគ៌ ។ សូមចែកចាយទីបន្ទាល់របស់អ្នកថា ព្រះវរបិតាសួគ៌ ស្តាប់ឮការអធិស្ឋានរបស់យើង ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់សកម្មភាពសៀវភៅបើកមើលរូប ៖* ថតចម្លងរូបភាពនៅទំព័រ 19 ។ ជាត់ពណ៌តាមចំណូចិត្ត ។ សូមធ្វើសៀវភៅបើកមើលរូបភាព ដោយកាត់តាមខ្សែបន្ទាត់ត្រង់ ហើយសូមបត់តាមចំនុចចុចៗ ។

សម្រាប់រឿងបទគម្ពីរ ៖ សូមអាន អេណុស 1:1–8 ហើយត្រៀមខ្លួនដើម្បីសង្ខេបរឿងនេះសម្រាប់កុមារ ។ សូមនាំយកព្រះគម្ពីរមរមនមកជាមួយផង ។ គួសចំណាំ អេណុស 1 ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។

សម្រាប់សកម្មភាពជាត់ពណ៌ ៖ សូមថតចម្លងរូបភាពនៅទំព័រ 19 សម្រាប់កុមារម្នាក់ៗ ជាត់ពណ៌ ។ សូមកាត់តាមបន្ទាត់ត្រង់ មុនពេលចាប់ផ្តើមថ្នាក់ទារកដ្ឋាន ។

សៀវភៅបើកមើលរូប សូមរំឭកសេចក្តីណែនាំនៅទំព័រ 16 ឡើងវិញ អំពីអ្វីដែលយើងនិយាយ នៅពេលយើងអធិស្ឋាន ក្នុងពេលនេះសូមប្រើសៀវភៅបើកមើលរូប ដែលអ្នកបានរៀបចំ ។ នៅពេលអ្នកពន្យល់ផ្នែកនីមួយៗ អំពីការអធិស្ឋាន សូមបើកគម្របដែលត្រូវគ្នា ឬ សូមអញ្ជើញកុមារម្នាក់ឲ្យបើកគម្របនោះ ។ អ្នកក៏អាចប្រើសៀវភៅបើកមើលរូប ខណៈពេលដែលអ្នករៀបរាប់ពីវគ្គសកម្មភាពនៅលើទំព័រ 6 ផងដែរ ។ អ្នកអាចរក្សាទុកសៀវភៅបើកមើលរូប ដើម្បីប្រើអំឡុងពេលថ្នាក់ទារកដ្ឋាននាសប្តាហ៍ក្រោយៗទៀត ។



រឿងបទគម្ពីរ សូមបើកព្រះគម្ពីរមរមនទៅ អេណុស 1 ហើយសូមប្រាប់កុមារអំពីរឿងនៃការអធិស្ឋានរបស់អេណុស ។ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយ ៖

មានថ្ងៃមួយ អេណុស បានចូលទៅក្នុងព្រៃ *(សូមឲ្យកុមារលើកដៃរបស់ពួកគេឡើង ធ្វើដូចជាដើមឈើ)* ដើម្បីបរបាញ់សត្វ *(សូមឲ្យពួកគេធ្វើដូចជាបាញ់ព្រួញ)* ។ នៅពេលគាត់នៅក្នុងព្រៃ គាត់បានអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ *(សូមឲ្យកុមារលុតជង្គង់ចុះ ធ្វើដូចជាអធិស្ឋាន សូមបញ្ចប់រឿងនៅពេលដែលពួកគេកំពុងលុតជង្គង់)* ។ ព្រះវរបិតាសួគ៌បានឆ្លើយតបការអធិស្ឋានរបស់គាត់ ហើយអេណុសមានចិត្តសប្បាយរីករាយ ។ គាត់បានដឹងថា ព្រះវរបិតាសួគ៌ នឹងប្រទានពរដល់គាត់ ។

សូមនិយាយថា « ខ្ញុំអាចអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ » ។ សូមអញ្ជើញកុមារឲ្យនិយាយតាមអ្នកនូវពាក្យពីរបីពាក្យម្តងៗ ។

ការជាត់ពណ៌ សូមឲ្យកុមារជាត់ពណ៌រូបភាពដែលបានថតចម្លងនៅទំព័រ 19 ។ នៅពេលអ្នកបញ្ចប់ សូមបត់តាមចំនុចចុចៗ ។



គន្លឹះក្នុងការបង្រៀន

ទីបន្ទាល់ ៖ សូមឆ្លើងទីបន្ទាល់របស់អ្នកតាមរបៀបដែលសាមញ្ញ សង្ខេបមួយ ឧទាហរណ៍ ៖ « ខ្ញុំដឹងថា ព្រះវរបិតាសួគ៌ ស្តាប់ឮការអធិស្ឋានរបស់យើង » ។

កុមារធំៗ ៖ ចូរពិចារណាអំពីការអញ្ជើញឲ្យកុមារដែលធំជាងជួយដល់អ្នកក្នុងការបង្រៀនដល់កុមារតូចៗឲ្យអធិស្ឋាន ។ នេះគឺជាវិធីមួយដ៏ល្អ ដើម្បីជួយពង្រឹងដល់អ្វីដែលអ្នកបានបង្រៀន ។

រឿងទាំងឡាយ ៖ នៅពេលកុមារសម្តែងព្រឹត្តិការណ៍ដែលមានក្នុងរឿងមួយ នោះពួកគេនឹងយល់ហើយចងចាំវាបានល្អប្រសើរជាង ។ សូមចងចាំថា ព្រះជាព្រះវរបិតា ពុំត្រូវមានឲ្យដើរតួទេ នៅពេលសម្តែងរឿងមួយនោះ ។ ចូរកុំដើរតួធ្វើជាព្រះយេស៊ូវលើកលែងតែនៅក្នុងឆាករឿងប្រសូត្រកម្ម ។ (សូមមើល *Teaching, No Greater Call* ទំព័រ 165–66) ។

ការជាត់ពណ៌ ៖ ខណៈពេលដែលកុមារកំពុងជាត់ពណ៌ សូមរំឭកគោលការណ៍ទាំងឡាយដែលបានបង្រៀននៅក្នុងមេរៀននេះ ។ សូមចង្អុលបង្ហាញព័ត៌មានលម្អិតនៅក្នុងរូបភាព ហើយសូមពន្យល់ដល់កុមារអំពីអ្វីដែលពួកគេកំពុងតែជាត់ពណ៌ ។ សូមអានពាក្យនៅលើរូបភាពដល់ពួកគេ ។

ខ្ញុំបាន
ចាប់ផ្តើម
ដោយនិយាយ
ថា៖ « ឱ
ព្រះវរបិតាសួគ៌
នៃយើង » ។



ទូលបង្គំសូមអរព្រះគុណ
ចំពោះពរជ័យទាំងឡាយ ។

ទូលបង្គំសុំទ្រង់ប្រទាន
ពរជ័យ ។

នៅក្នុងព្រះនាមនៃ
ព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

ខ្ញុំអាចអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌

4 ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទស្រឡាញ់ខ្ញុំ

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ មានសេចក្តីស្រឡាញ់ដ៏តន់ខ្ជោះចំពោះយើងម្នាក់ៗ ។ ទ្រង់ទាំងពីរព្រះអង្គ បានស្រឡាញ់យើងមុនពេលយើងមកកាន់ផែនដីនេះ ពួកទ្រង់នៅតែបន្តស្រឡាញ់យើងក្នុងពេលឥឡូវនេះ ហើយក្តីស្រឡាញ់របស់ទ្រង់ចំពោះយើង នឹងពុំដែលផ្លាស់ប្តូរនោះឡើយ ។ អំឡុងពេលការបម្រើរបស់ទ្រង់នៅលើផែនដី ព្រះអង្គសង្គ្រោះ បានបង្ហាញសេចក្តីស្រឡាញ់ដ៏មហិមាចំពោះកុមារតូចៗតាមរបៀបដ៏វិសេស (សូមមើល ម៉ាថាយ 18:5, 10 ; ម៉ាកុស 10:13–16 ; នីហ្វៃទី 3 17:11–24) ។

ការរៀបចំខ្លួន

- សូមអាន នីហ្វៃទី3 17:11–12, 21–24 ហើយសូមត្រៀមខ្លួនដើម្បីសង្ខេបរឿងនេះឲ្យខ្លីសម្រាប់កុមារ ។
- សូមយកព្រះគម្ពីរមរមនមកជាមួយផង ។

សកម្មភាពទាំងឡាយក្នុងការបង្រៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

សេចក្តីណែនាំអំពីគោលលទ្ធិ សូមប្រាប់ដល់កុមារថា អ្នកស្រឡាញ់ពួកគេ ហើយនិយាយដោយសង្ខេបអំពីមនុស្សផ្សេងមួយចំនួនទៀត ដែលស្រឡាញ់ពួកគេ ដូចជា ឪពុកម្តាយ បងប្អូនប្រុសស្រី ជីដូនជីតារបស់ពួកគេ ជាដើម ។ បន្ទាប់មក សូមពន្យល់ថា មានតួអង្គពីរទៀត ដែលស្រឡាញ់ពួកគេច្រើនជាងនរណាៗទាំងអស់ គឺជា—ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។ សូមប្រាប់កុមារថា « ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវ ស្គាល់ថាប្អូនជានរណា ។ ពួកទ្រង់ស្គាល់ឈ្មោះរបស់ប្អូន ហើយស្រឡាញ់ប្អូនៗ » ។ សូមចង្អុលទៅកុមារម្នាក់ ហើយនិយាយថា « ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវស្រឡាញ់ [ឈ្មោះកុមារ] » ។ សូមធ្វើដដែលៗចំពោះកុមារម្នាក់ៗ ។

វគ្គសកម្មភាព សូមរៀបរាប់វគ្គសកម្មភាពដូចខាងក្រោម ហើយសូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ៖

ព្រះវរបិតាសួគ៌ ស្គាល់ខ្ញុំ *(សូមចង្អុលមកខ្លួនឯង)*
និង អ្វីដែលខ្ញុំចូលចិត្តធ្វើ ។
ទ្រង់ស្គាល់ឈ្មោះរបស់ខ្ញុំ និង កន្លែងដែលខ្ញុំរស់នៅ ។ *(សូមដាក់ចុងចង្អុលដៃទល់គ្នាធ្វើជាដំបូលផ្ទះ)*
ខ្ញុំដឹងថា ទ្រង់ស្រឡាញ់ខ្ញុំផងដែរ ។ *(សូមឱបខ្លួនឯង)*

រឿងបទគម្ពីរ សូមបង្ហាញរូបភាពនៅទំព័រ 22 ។ សូមប្រាប់កុមារថា យើងរៀននៅក្នុងព្រះគម្ពីរថា ព្រះយេស៊ូវស្រឡាញ់កុមារតូចៗ ។ សូមបើកព្រះគម្ពីរមរមន ហើយសង្ខេបយ៉ាងខ្លីនូវរឿងអំពីព្រះយេស៊ូវគ្រីស្ទ ប្រទានពរដល់កុមារសាសន៍នីហ្វៃ (នីហ្វៃទី 3 17:11–12, 21–24) ។ នៅខាងក្រោម គឺជាឧទាហរណ៍មួយ ៖

ព្រះយេស៊ូវ កំពុងបង្រៀនប្រជាជន *(សូមចង្អុលរូបព្រះយេស៊ូវនៅក្នុងរូបភាព)* ។ ទ្រង់បានសុំឲ្យពួកគេនាំកូនតូចៗរបស់ពួកគេមករកទ្រង់ *(សូមចង្អុលទៅកុមារនៅក្នុងរូបភាព)* ។ ពួកគេអង្គុយចុះនៅលើដីជុំវិញទ្រង់ ហើយព្រះយេស៊ូវ បានលុតជង្គង់អធិស្ឋាន *(សូមឲ្យកុមារលុតជង្គង់ចុះ ហើយឱនក្បាល)* ។ បន្ទាប់មក ទ្រង់ប្រទានពរដល់កុមារម្នាក់ម្តងៗ ។ ព្រះយេស៊ូវ បានធ្វើដូច្នេះ ដោយសារតែទ្រង់ស្រឡាញ់កុមារតូចៗ *(សូមឲ្យកុមារតូចៗឱបខ្លួនគេ)* ។

ចម្រៀង សូមច្រៀង ឬ និយាយនូវពាក្យដូចខាងក្រោម « ខ្ញុំស្គាល់ក្តីស្នេហ៍ព្រះអង្គសង្គ្រោះ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 74–75) ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ។

ខ្ញុំស្គាល់ក្តីស្នេហ៍ព្រះសង្គ្រោះ *(សូមដាក់ដៃលើដើមទ្រូង*

គន្លឹះក្នុងការបង្រៀន

សេចក្តីណែនាំ ៖ ការសិក្សាបទគម្ពីរដែលបានរៀបរាប់នៅក្នុងវគ្គ « សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន » គឺជាការណ៍ល្អមួយ ដើម្បីអញ្ជើញព្រះវិញ្ញាណពេលរៀបចំមេរៀនរបស់អ្នក (សូមមើល *Teaching, No Greater Call* ទំព័រ (14)) ។

សកម្មភាព ៖ អ្នកអាចចង់ចំណាយពេលខ្លះ។ ដើម្បីនិយាយអំពីសកម្មភាពទាំងឡាយដែលត្រូវនឹងចម្រៀង ឬ វគ្គសកម្មភាព ។ ឧទាហរណ៍ អ្នកអាចពន្យល់ថា នៅពេលពួកគេដាក់ចុងម្រាមដៃទល់គ្នា (បន្ទាត់ទី 3 នៃវគ្គសកម្មភាពនេះ) ពួកគេធ្វើជារាងដែលមើលទៅដូចជាដំបូលផ្ទះ ហើយឆ្នើកនេះត្រូវនឹងពាក្យ « កន្លែងដែលខ្ញុំរស់នៅ » ។

ចម្រៀង ៖ មើចម្រៀងមួយបទ ឬ វគ្គសកម្មភាព វែងពេកសម្រាប់កុមារនៅក្នុងថ្នាក់ទារកដ្ឋានរបស់អ្នក សូមប្រើតែមួយឆ្នើកបានហើយ ។

ក្នុងពិភពលោកជុំវិញខ្ញុំ ។ *(សូមលាតសន្ធឹងដៃឲ្យធំ)* . . .
ខ្ញុំស្គាល់ក្តីស្នេហ៍ព្រះសង្គ្រោះ *(សូមដាក់ដៃលើដើមទ្រូង)*
ក្តីស្នេហ៍ទ្រង់ប្រទានដល់ខ្ញុំ ។ *(សូមចង្អុលមកខ្លួនឯង)*

សេចក្តីបញ្ចប់ សូមចែកចាយទីបន្ទាល់របស់អ្នកជាមួយកុមារថា ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវស្រឡាញ់ពួកគេម្នាក់ៗ ។ សូមឲ្យកុមារនិយាយឃ្លា « ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវ ស្រឡាញ់ខ្ញុំ » សារឡើងវិញនូវពាក្យពីរបីម៉ាត់ម្តង ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់សកម្មភាពកញ្ចក់ ៖* សូមយកកញ្ចក់តូចមួយ ដែលធំល្មមឲ្យកុមារមើលឃើញមុខរបស់ពួកគេ ។

សម្រាប់សកម្មភាពរូបភាព ៖ សូមយករូបភាពនៃវត្ថុចំនួនបួន ឬ ប្រាំ ដែលព្រះវរបិតាសួគ៌បានប្រទានពរដល់យើងដូចជា គ្រួសារ គេហដ្ឋាន ដើមឈើ ព្រះគម្ពីរជាដើម ។ អ្នកអាចប្រើរូបភាពចេញមកពីទស្សនាវដ្តីសាសនាចក្រ រូបភាពចម្លងចេញពីសៀវភៅនេះ ឬរូបភាពសាមញ្ញៗ ដែលអ្នកបានគូរដោយខ្លួនឯង ។

សម្រាប់សកម្មភាពជាត់ពណ៌ ៖ សូមចតចម្លង និង កាត់រូបភាពនៅទំព័រ 23 ចេញមកសម្រាប់កុមារម្នាក់ៗជាត់ពណ៌ (រូបរង្វង់មួយ សម្រាប់កុមារម្នាក់ៗ) ។ សូមចោះរន្ធដាក់ខ្សែ ឬ ខ្សែអំបោះនៅផ្នែកខាងលើរង្វង់នីមួយៗ ដើម្បីធ្វើជាខ្សែក ។

សកម្មភាពជាកញ្ចក់ សូមឲ្យកុមារអង្គុយជារង្វង់ ។ សូមរំកិលកញ្ចក់នៅក្នុងរង្វង់ជុំវិញ ហើយឲ្យកុមារម្នាក់ៗមើលមុខរបស់គេ ។ នៅពេលកុមារម្នាក់ៗ មើលទៅក្នុងកញ្ចក់ សូមឲ្យកុមារនិយាយឈ្មោះរបស់គេ (បើកុមារអាចនិយាយបាន) ។ បន្ទាប់មក សូមនិយាយថា « ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវស្រឡាញ់ [ឈ្មោះរបស់កុមារ] » ។

រូបភាពនានា សូមដាក់រូបភាពទាំងឡាយដែលអ្នកបានយកមក នៅតាមកន្លែងផ្សេងៗពេញក្នុងបន្ទប់ ។ សូមប្រាប់កុមារថា ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ បានប្រទានពរជ័យជាច្រើនដល់យើង ដោយសារពួកទ្រង់ស្រឡាញ់យើង ។ សូមអញ្ជើញពួកគេឲ្យដើរជាមួយអ្នកទៅរករូបភាពមួយ ហើយជួយពួកគេប្រាប់ពីពរជ័យដែលរូបភាពនោះតំណាងឲ្យ ។ សូមអញ្ជើញពួកគេធ្វើសកម្មភាពមួយដែលទាក់ទងទៅនឹងពរជ័យនោះ (សូមធ្វើជាអានព្រះគម្ពីរ ធ្វើជាដើមឈើ ជាដើម) ។ សូមធ្វើដដែលៗជាមួយនឹងរូបភាពផ្សេងទៀត ។

វគ្គសកម្មភាព ចូររៀបរាប់វគ្គសកម្មភាពនៅ ទំព័រ 9 ។

ការជាត់ពណ៌ ចូរឲ្យកុមារជាត់ពណ៌រូបខ្សែក ដែលអ្នកបានរៀបចំសម្រាប់ពួកគេ ។ ចូរអានពាក្យនៅលើរូបភាពឲ្យពួកគេស្តាប់ ។

គន្លឹះក្នុងការបង្រៀន

ទីបន្ទាល់ ៖ ការផ្តែងទីបន្ទាល់នឹងអញ្ជើញព្រះវិញ្ញាណ ។ សូមផ្តែងទីបន្ទាល់របស់អ្នកតាមរបៀបដ៏សាមញ្ញ និង សង្ខេបមួយ ឧទាហរណ៍ ៖ « ខ្ញុំដឹងថាព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវស្រឡាញ់យើងទាំងអស់គ្នា » ។

កុមារតូចៗ ៖ ដើម្បីជួយកុមារតូចៗឲ្យមន្តចាប់អារម្មណ៍ និងចូលរួមនៅក្នុងសកម្មភាពនានានោះអ្នកដឹកនាំថ្នាក់ទារកដ្ឋានម្នាក់ អាចផ្តល់ជំនួយបន្ថែមដល់ពួកគេ ហើយផ្តល់ការយកចិត្តទុកដាក់បន្ថែម ខណៈពេលដែលអ្នកដឹកនាំថ្នាក់ទារកដ្ឋានម្នាក់ទៀត កំពុងបង្រៀន ។

មេរៀនមុនៗ ៖ បើសិនជាអ្នកត្រូវការសកម្មភាពច្រើនទៀត សម្រាប់កុមារឲ្យធ្វើ សូមជ្រើសរើសសកម្មភាពចេញមកពីមេរៀនមុនៗ ។ មេរៀនទាំងអស់ឬ ផ្នែកខ្លះនៃមេរៀន អាចត្រូវបានបង្រៀនច្រើនជាងមួយដង ។ កុមារតូចៗ ចូលចិត្តការធ្វើដដែលៗ ហើយវាជាការរំឭកឡើងវិញដ៏ល្អមួយ ។

ព្រះវរបិតាសួគ៌ទិដ្ឋ ព្រះរាជ្ជវ៉ាត្ថ ឯកឋ ឯ្ឋ

ព្រះវរបិតាសួគ៌ទិដ្ឋ ព្រះរាជ្ជវ៉ាត្ថ ឯកឋ ឯ្ឋ

5 ព្រះយេស៊ូវគ្រីស្ទ បានបង្ហាញយើងអំពីរបៀបដើម្បីស្រឡាញ់អ្នកដទៃ

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

ព្រះយេស៊ូវគ្រីស្ទ បានធ្វើជាគំរូដ៏ឥតខ្ចោះមួយនៃការមានសន្តានចិត្តល្អ និង ក្តីស្រឡាញ់ ។ នៅពេញការបម្រើលើផែនដីរបស់ទ្រង់ ព្រះយេស៊ូវ បានបង្ហាញក្តីស្រឡាញ់របស់ទ្រង់ចំពោះអ្នកដទៃ តាមរយៈការប្រទានពរ និង ការបម្រើដល់ជនក្រីក្រ អ្នកឈឺ និង អ្នកមានទុក្ខ ។ ទ្រង់បានមានបន្ទូលប្រាប់ដល់សិស្សទាំងឡាយរបស់ទ្រង់ថា « នេះជាសេចក្តីបញ្ញត្តិរបស់ខ្ញុំ គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ » (យ៉ូហាន 15:12 ; សូមមើលផងដែរ យ៉ូហាន 13:34–35 ; ម៉ារ៉ូណៃ 7:46–48) ។

ការរៀបចំខ្លួន

- សូមគូសចំណាំទំព័រ 22 នៅក្នុងសៀវភៅសិក្សានេះ ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។
- សូមយកព្រះគម្ពីរមកជាមួយ ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

ចម្រៀង សូមប្រាប់ដល់កុមារថា នៅពេលព្រះយេស៊ូវគ្រីស្ទ រស់នៅលើផែនដី ទ្រង់បានបង្រៀនយើងឲ្យស្រឡាញ់អ្នកដទៃ ទ្រង់បង្ហាញដល់យើងតាមរយៈអ្វីដែលទ្រង់បានធ្វើ ។ សូមច្រៀង ឬ និយាយនៅកន្លែងបន្ទរនៃបទ « ខ្ញុំព្យាយាមក្លាយដូចព្រះយេស៊ូវ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 78–79) ហើយធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ។

« ចូរស្រឡាញ់គ្នាដូចព្រះទ្រង់ស្រឡាញ់អ្នក ។ *(សូមឱបខ្លួនអ្នក ហើយរេខ្លួនចុះឡើង)*
ចូរបង្ហាញមេត្តាក្នុងកិច្ចការដែលអ្នកធ្វើ ។ *(សូមងក់ក្បាលចុះឡើង)*
ដោយស្លូតបូត និង ក្តីស្រឡាញ់ ទាំងចិត្តគំនិត *(សូមឱបខ្លួនអ្នក ហើយរេខ្លួនចុះឡើង)*
នេះជាអ្វីដែលទ្រង់បានបង្រៀន ។ *(សូមងក់ក្បាល)*

រឿងបទគម្ពីរទាំងឡាយ សូមបង្ហាញព្រះគម្ពីរមួយក្បាលដល់កុមារ ។ សូមប្រាប់ពួកគេថា នៅក្នុងព្រះគម្ពីរ យើងរៀនអំពីរបៀបដែលព្រះយេស៊ូវ បានបង្ហាញសេចក្តីស្រឡាញ់ ។ សូមប្រាប់រឿងដូចខាងក្រោមដោយសង្ខេប ៖

រឿងទី 1 (សូមបង្ហាញរូបភាពនៅទំព័រ 27) ៖ មនុស្សជាច្រើន បានមកស្តាប់ព្រះយេស៊ូវបង្រៀន ។ ពួកគេនៅទីនោះយ៉ាងយូរ ហើយពួកគេស្រេកឃ្លានយ៉ាងខ្លាំង *(សូមឲ្យកុមារធ្វើជាស្រេកឃ្លាន)* ។ នៅទីនោះ មានតែនំប៉័ង និង ត្រីបន្តិចបន្តួចប៉ុណ្ណោះដើម្បីផ្តល់ទៅឲ្យប្រជាជនបរិភោគ ។ ព្រះយេស៊ូវ បានប្រទានពរដល់ម្ហូបអាហារ រួចហើយបានប្រាប់ដល់សិស្សរបស់ទ្រង់ឲ្យផ្តល់អាហារនោះទៅដល់ប្រជាជន ។ មនុស្សគ្រប់គ្នាមានល្មមគ្រប់គ្រាន់ដើម្បីបរិភោគ ហើយមានម្ហូបអាហារនៅសល់ជាច្រើនទៀត *(សូមឲ្យកុមារធ្វើជាបរិភោគអាហារ)* ។ (សូមមើល ម៉ាថាយ 14:13–21) ។

សូមឲ្យកុមារនិយាយជាមួយអ្នកថា « ព្រះយេស៊ូវ បានបង្ហាញយើងអំពីរបៀបដើម្បីស្រឡាញ់អ្នកដទៃ » ពីរបីពាក្យម្តង ។

រឿងទី 2 (សូមបង្ហាញរូបភាពនៅទំព័រ 26) ៖ ថ្ងៃមួយ ព្រះយេស៊ូវ បានឃើញបុរសម្នាក់ដែលខ្វាក់ភ្នែក— គាត់ពុំអាចមើលឃើញទេ *(សូមឲ្យកុមារបិទភ្នែករបស់ពួកគេ)* ។ ព្រះយេស៊ូវ បានប្រសិទ្ធពរដល់បុរសម្នាក់នោះ ដើម្បីគាត់អាចមើលឃើញ *(សូមឲ្យកុមារបើកភ្នែករបស់ពួកគេ)* ។(សូមមើល យ៉ូហាន 9:1–12) ។

សូមឲ្យកុមារនិយាយជាមួយអ្នកថា « ព្រះយេស៊ូវ បានបង្ហាញយើងពីរបៀបដើម្បីស្រឡាញ់អ្នកដទៃ » ។

គន្លឹះក្នុងការបង្រៀន

ចម្រៀង ៖ កុមារចូលចិត្តអ្វីៗដែលពួកគេបានមើលឃើញ និង ស្តាប់ឮកាលពីមុនៗមក ។ សូមច្រៀងចម្រៀង ឬ ធ្វើវគ្គសកម្មភាពចេញពីមេរៀននេះ ឬមេរៀនមុនៗ នៅពេលណាក៏បាន អំឡុងថ្នាក់ទារកដ្ឋាន ។ ការរំឭកនេះ នឹងជួយពួកគេឲ្យរៀនចម្រៀង ហើយចងចាំគោលការណ៍ដ៏ល្អទាំងឡាយ ដែលអ្នកបានបង្រៀន ។

រឿងទាំងឡាយ ៖ មុនពេលប្រាប់រឿងមួយ សូមអានវាឲ្យបានច្រើនដង ដើម្បីឲ្យស្គាល់រឿងនោះ ។ នៅពេលអ្នកប្រាប់រឿង សូមមើលទៅកុមារឲ្យចំភ្នែក ដើម្បីជួយពួកគេមន្តយកចិត្តទុកដាក់ ។ (សូមមើល *Teaching, No Greater Call* ទំព័រ 181–82) ។

កុមារតូច ។ ប្រហែលជាពុំអាចនិយាយឃ្លានេះឡើងវិញបានឡើយ ។ សូមជួយពួកគេនិយាយពាក្យគន្លឹះ ដូចជា « ព្រះយេស៊ូវ » និង « ស្រឡាញ់ » ។

រឿងទី 3 (សូមបង្ហាញរូបភាពនៅទំព័រ 22) ៖ បន្ទាប់ពីព្រះយេស៊ូវ បានរស់ឡើងវិញ ទ្រង់បានយាងមកជួបនឹងពួកសាសន៍នីហ្វៃ ។ ដោយសារតែទ្រង់ស្រឡាញ់កុមារតូចៗ នោះទ្រង់បានប្រទានពរដល់ពួកគេម្នាក់ម្តងៗ *(សូមឲ្យកុមារឱបខ្លួនឯង)* ។ (សូមមើល នីហ្វៃទី 3 17:21–24) ។

សូមឲ្យកុមារនិយាយជាមួយអ្នកថា « ព្រះយេស៊ូវ បានបង្ហាញយើងពីរបៀបដើម្បីស្រឡាញ់អ្នកដទៃ » ។

ចម្រៀង សូមច្រៀង ឬ និយាយនៅកន្លែងបន្ទរនៃបទ « ខ្ញុំព្យាយាមក្លាយដូចជាព្រះយេស៊ូវ » ។ សូមអញ្ជើញកុមារឲ្យច្រៀង និង ធ្វើកាយវិការជាមួយអ្នក ។

សេចក្តីបញ្ចប់ សូមចែកចាយទីបន្ទាល់របស់អ្នកថា យើងអាចស្រឡាញ់អ្នកដទៃ ដូចជាព្រះយេស៊ូវបានធ្វើដែរ ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់រូបផ្គុំ ៖* សូមយករូបភាពមួយអំពីព្រះយេស៊ូវ (អ្នកអាចប្រើរូបភាពនៅ ទំព័រ 106 បើអ្នកចង់ប្រើ) ។ សូមរកក្រដាសមួយសន្លឹកដែលមានទំហំស្មើគ្នានឹងរូបភាព (ឬ កាត់ក្រដាសឲ្យមានទំហំដូចគ្នា) ហើយសូមកាត់ក្រដាសជាបី ឬ ជាបួនចំណែក ដើម្បីធ្វើជារូបផ្គុំ ។ សូមសរសេរថា « ខ្ញុំនឹងស្រឡាញ់អ្នកដទៃ » នៅខាងក្រោយក្រដាសនីមួយៗ ។



សម្រាប់សកម្មភាពក្នុងព្រះគម្ពីរ ៖ សូមយកព្រះគម្ពីរបរិសុទ្ធមកជាមួយ ។ សូមគូសចំណាំយ៉ូហាន 15:12 ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។

សម្រាប់សកម្មភាពជារូបភាព ៖ សូមថតចម្លងរូបភាពនៅទំព័រ 27 សម្រាប់កុមារម្នាក់ៗ ។

រូបផ្គុំ សូមបាំងរូបភាពព្រះយេស៊ូវដោយចំណែករូបផ្គុំ ។ សូមឲ្យកុមារម្នាក់ជ្រើសរើសក្រដាសមួយផ្ទាំង ។ សូមអានឃ្លានៅលើផ្ទាំងក្រដាសនោះ ហើយឲ្យកុមារទាំងអស់ថាតាម ។ សូមពិភាក្សាអំពីរបៀបមួយ ដែលយើងអាចស្រឡាញ់អ្នកដទៃ (សូមនិយាយពាក្យអរគុណ ចែកចាយ ធ្វើអ្វីដែលម៉ាក់ ឬ ប៉ាសុំឲ្យធ្វើ រៀបចំសម្ភារលេងដាក់តាមកន្លែងដើមវិញ ។ល។) ។ សូមចាពាក្យលើផ្ទាំងក្រដាសនីមួយៗឡើងវិញ រហូតដល់រូបភាពទាំងអស់ត្រូវបានបើក ។ សូមជួយពង្រឹងបន្ថែមលើគំនិតដែលថា ព្រះយេស៊ូវ បានបង្ហាញយើងអំពីរបៀបដើម្បីស្រឡាញ់អ្នកដទៃ ។

បទគម្ពីរ សូមប្រាប់កុមារថា នៅក្នុងបទគម្ពីរ ព្រះយេស៊ូវ បានបង្រៀនយើងឲ្យស្រឡាញ់គ្នាទៅវិញទៅមក ។ សូមបើកព្រះគម្ពីរបរិសុទ្ធទៅ យ៉ូហាន 15:12 ហើយអាន « ស្រឡាញ់ដល់គ្នាទៅវិញទៅមក » ។ សូមអញ្ជើញកុមារឲ្យចាឃ្លានេះ ជាមួយអ្នកសារឡើងវិញ ។

ចម្រៀង សូមច្រៀង ឬ និយាយពាក្យនៅក្នុងបទ « ព្រះយេស៊ូវ មានបន្ទូលស្រឡាញ់មនុស្សគ្រប់រូប » (*សៀវភៅចម្រៀងកុមារ* ទំព័រ 61) ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ។

ព្រះយេស៊ូវ ប្រាប់ឲ្យស្រឡាញ់ *(សូមលាតសន្ធឹងដៃឲ្យធំ)*
ធ្វើល្អគ្រប់មនុស្ស ។ *(សូមងក់ក្បាលចុះឡើង)*
ពេលចិត្តអ្នកមានក្តីស្រឡាញ់ *(សូមដាក់ដៃលើដើមទ្រូង)*
គេស្រឡាញ់អ្នកវិញ ។ *(សូមឱបខ្លួន)*

រូបភាព សូមផ្តល់ឲ្យកុមារម្នាក់ៗនូវច្បាប់ចម្លងនៃរូបភាពនៅទំព័រ 27 ។ សូមសួរសំណួរដល់កុមារអំពីរូបភាព ដើម្បីរំឭកពួកគេអំពីរឿង ដែលអ្នកបានប្រាប់ដល់ពួកគេពីមុន ។ ឧទាហរណ៍ ៖
តើប្អូនអាចមើលឃើញព្រះយេស៊ូវនៅក្នុងរូបភាពនេះដែរឬទេ ? *(សូមឲ្យកុមារចង្អុលទៅរូបព្រះយេស៊ូវនៅលើផ្ទាំងរូបភាពរបស់ពួកគេ)*
តើមានអ្វីនៅក្នុងកន្ត្រកទាំងអស់ ? *(សូមឲ្យកុមារធ្វើដូចជាបរិភោគអាហារ)*

គន្លឹះក្នុងការបង្រៀន

សកម្មភាពជម្រើស ៖ ដើម្បីរក្សាឲ្យមានការចូលរួម និងការរៀនសូត្រយ៉ាងសកម្ម សូមផ្លាស់ប្តូរការស្តាប់ជាមួយនឹងសកម្មភាព ដែលទាក់ទងនឹងការធ្វើចលនា ។ សូមរក្សារយៈពេលនៃសកម្មភាពនីមួយៗឲ្យនៅប្រហែលជា៥ ឬ ប៊ីនាទី ។

ពាក្យផ្តួន ៖ កុមារដែលមានវ័យស្ថិតក្នុង-ថ្នាក់ទារកដ្ឋាន ចូលចិត្តការធ្វើអ្វីផ្តួន។ ហើយវាជួយដល់ពួកគេឲ្យរៀន ។ បើកុមារនៅតែមានចំណាប់អារម្មណ៍ ហើយយកចិត្តទុកដាក់ សូមធ្វើសកម្មភាពនោះឡើងវិញ ដើម្បីឲ្យកុមារម្នាក់ៗមានឱកាសចូលរួម ។



ព្រះយេស៊ូវគ្រីស្ទ បានបង្ហាញយើងអំពីរបៀបដើម្បីស្រឡាញ់អ្នកដទៃ

6 ព្រះវិញ្ញាណបរិសុទ្ធជួយខ្ញុំ

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

ព្រះវិញ្ញាណបរិសុទ្ធ គឺជាសមាជិកមួយអង្គនៃក្រុមព្រះ ដែលមានព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។ តួអង្គរបស់ទ្រង់គឺជាវិញ្ញាណ (សូមមើល គ. និង ស. 130:22) ។ បេសកកម្មរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺដើម្បីថ្លែងទីបន្ទាល់អំពីព្រះវរបិតា និង ព្រះរាជបុត្រា និង អំពីសេចក្តីពិតនៃរឿងគ្រប់យ៉ាង (សូមមើល នីហ្វៃទី 3 11:36 ; មរ៉ូណៃ 10:5) ។ ទ្រង់ក៏អាចដឹកនាំយើងឲ្យធ្វើការសម្រេចចិត្តត្រឹមត្រូវ ហើយលួងលោមចិត្តរបស់យើងផងដែរ (សូមមើល គ. និង ស. 31:11) ។ របៀបដែលព្រះវិញ្ញាណបរិសុទ្ធមានព្រះបន្ទូលមកកាន់យើង គឺត្រូវបានពិពណ៌នាក្នុងព្រះគម្ពីរថាជា « សម្លេងតូចរហៀង » (សូមមើល ពង្សាវតារក្យត្រ 19:11–12) ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន អញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

ចម្រៀង សូមប្រាប់កុមារថា អ្នកនឹងច្រៀងចម្រៀងមួយអំពីព្រះវរបិតាសួគ៌ ។ សូមច្រៀង ឬ និយាយពាក្យនៅវគ្គទីមួយនៃបទ « ខ្ញុំដឹងព្រះបិតារស់ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 59) ហើយធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ។

ខ្ញុំដឹងព្រះវរបិតារស់ ហើយស្រឡាញ់ខ្ញុំ ។ *(សូមយកដៃទៅប៉ះដើមទ្រូង)*

ព្រះវិញ្ញាណទ្រង់ខ្សឹបប្រាប់ឲ្យខ្ញុំដឹងថា រឿងនេះពិតមែន *(សូមយកដៃដាក់ផ្នត់ត្រចៀក)*

ប្រាប់ថារឿងនេះពិតមែន ។

សកម្មភាពផ្នែកៗ សូមអញ្ជើញកុមារឲ្យនិយាយថា « ព្រះវិញ្ញាណ » ។ សូមប្រាប់ពួកគេថា ព្រះនាមមួយទៀតសម្រាប់ព្រះវិញ្ញាណនៃព្រះ គឺព្រះវិញ្ញាណបរិសុទ្ធ ។ សូមអញ្ជើញកុមារឲ្យនិយាយថា « ព្រះវិញ្ញាណបរិសុទ្ធ » ។ សូមពន្យល់ថា ព្រះវិញ្ញាណបរិសុទ្ធ ជួយយើងឲ្យដឹងថា ព្រះវរបិតាសួគ៌ស្រឡាញ់យើង ។

ការសម្តែង សូមប្រាប់កុមារថា នៅពេលយើងធ្វើអ្វីដែលត្រូវ ព្រះវិញ្ញាណបរិសុទ្ធ ជួយយើងដឹងថា យើងបានធ្វើការជ្រើសរើសដ៏ល្អមួយ ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក នៅពេលអ្នកសម្តែង ដោយធ្វើនូវអ្វីដែលត្រឹមត្រូវ ។ ឧទាហរណ៍ ៖

វាគឺជារឿងត្រឹមត្រូវដើម្បីទៅព្រះវិហារ ។ សូមធ្វើដូចជាដើរទៅព្រះវិហារ *(សូមធ្វើដៃបង់ចោយ នៅពេលអ្នកដើរជារង្វង់)* ។

សូមធ្វើសារឡើងវិញជាមួយនឹងឧទាហរណ៍ផ្សេងទៀត ដូចជា ការចែកចាយសម្ភារលេង ការជួយម៉ាក់ចោសផ្ទះ ជាដើម ។

រឿង សូមពន្យល់ថា ព្រះវិញ្ញាណបរិសុទ្ធ ក៏អាចជួយយើង នៅពេលយើងភ័យខ្លាចផងដែរ ។ សូមប្រាប់រឿងដូចខាងក្រោម ៖

មានថ្ងៃមួយ មានព្យុះយ៉ាងខ្លាំងនៅខាងក្រៅផ្ទះរបស់ ដេវីឌ ។ មានសម្លេងផ្គរលាន់យ៉ាងខ្លាំង *(សូមឲ្យកុមារបិទត្រចៀករបស់ពួកគេ)* ហើយមានខ្យល់យ៉ាងខ្លាំង *(សូមឲ្យកុមារផ្លុំ ត្រាប់ធ្វើជាខ្យល់)* និង មានភ្លៀង *(សូមឲ្យកុមារផ្លុំ ត្រាប់ធ្វើជាភ្លៀង ដោយប្រើម្រាមដៃរបស់ពួកគេ)* ។ ដេវីឌ ភ័យខ្លាច ។ ម្តាយរបស់គាត់ បានប្រាប់គាត់ថា នៅពេលម៉ាក់ខ្លាច ម៉ាក់អធិស្ឋានដល់ព្រះវរបិតាសួគ៌ *(សូមបង្ហាញរូបភាពនៅទំព័រ 30)* ។ ដាវីឌ និង ម៉ាក់របស់គាត់ បានអធិស្ឋាន សុំឲ្យព្រះវរបិតាសួគ៌ ជួយថែរក្សាពួកគេឲ្យមានសុវត្ថិភាព ។ បន្ទាប់មក ដេវីឌ មានអារម្មណ៍សុវត្ថិភាព និងសប្បាយចិត្ត ។ ម្តាយរបស់គាត់ បានប្រាប់ថា ព្រះវរបិតាសួគ៌ បានបញ្ជូនព្រះវិញ្ញាណបរិសុទ្ធដល់គាត់ឲ្យមានអារម្មណ៍ទាំងនោះ ដើម្បីកុំឲ្យគាត់ភ័យខ្លាច ។

សូមអញ្ជើញកុមារឲ្យនិយាយថា « ព្រះវិញ្ញាណបរិសុទ្ធ » ។

គន្លឹះក្នុងការបង្រៀន

ព្រះវិញ្ញាណបរិសុទ្ធ ៖ ទោះជានៅវ័យក្មេងក៏ដោយ កុមារក៏អាចរៀនស្គាល់ពីតន្ទិពលនៃព្រះវិញ្ញាណបរិសុទ្ធបានដែរ ។ អំឡុងពេលមេរៀនណាក៏ដោយ សូមជួយដល់ពួកគេឲ្យស្គាល់អារម្មណ៍នៃក្តីស្រឡាញ់ និង ភាពកក់ក្តៅដែលមកពីព្រះវិញ្ញាណបរិសុទ្ធ —ជាពិសេស នៅពេលកំពុងរៀនអំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។

កុមារតូច ៖ សូមចងចាំថា កុមារភាគច្រើនមានការពិបាកក្នុងការផ្តោតការយកចិត្តទុកដាក់ក្នុងរយៈពេលមួយយូរ ។ សូមរកមើលសញ្ញាដែលពួកគេត្រូវការនូវការផ្លាស់ប្តូរមួយ ។ បើពួកគេបានអង្គុយយូរពេកហើយ សូមធ្វើសកម្មភាពមួយ ដែលអាចឲ្យពួកគេធ្វើចលនាវាងកាយរបស់ពួកគេ ។

សេចក្តីបញ្ចប់ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីព្រះវិញ្ញាណបរិសុទ្ធ ។ ទីបន្ទាល់នេះ អាចរួមបញ្ចូលនូវបទពិសោធន៍សាមញ្ញ និងសង្ខេបមួយ ដែលចេញមកពីជីវិតផ្ទាល់ខ្លួនរបស់អ្នក នៅពេលអ្នកត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់សកម្មភាពបទគម្ពីរ ៖* សូមយកព្រះគម្ពីរបរិសុទ្ធមកជាមួយ ។ សូមគូសចំណាំយ៉ូហាន 14:26ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។
សម្រាប់សកម្មភាពជារូបភាព ៖ សូមថតចម្លងរូបភាពនៅទំព័រ 31 សម្រាប់កុមារម្នាក់ៗ ។
សម្រាប់វល្លិងកំសាន្តរាងជាគូប ៖ សូមថតចម្លងរូបភាពនៅទំព័រ 31 ហើយជាត់ពណ៌វាតាមចំណូលចិត្ត ។ សូមកាត់តាមបន្ទាត់ ហើយសូមបត់វាតាមចំនុចចុចៗ ។ សូមបិទការផ្ទាំងតូចៗដើម្បីធ្វើជាជុំការ៉ែបួនជ្រុង ។

វគ្គសកម្មភាព សូមឲ្យកុមាររអង្គុយជារង្វង់ ហើយរៀបរាប់វគ្គសកម្មភាពដូចខាងក្រោម ៖
ព្រះវិញ្ញាណបរិសុទ្ធ មានបន្ទូលយ៉ាងទន់ភ្លន់ ។ *(សូមដាក់ម្រាមដៃលើបបូរមាត់)*
ពិតណាស់ ទ្រង់ពុំដែលស្រែកទេ ។ *(សូមយកដៃផ្ទប់មាត់ ធ្វើដូចជាស្រែក)*
ទ្រង់នឹងប្រទានពរ ហើយជួយដឹកនាំអ្នក *(សូមកាន់ដៃគ្នា ហើយដើរនៅក្នុងរង្វង់)*
នៅគ្រប់អ្វីដែលអ្នកធ្វើ ។ *(សូមអង្គុយចុះ)*

បទគម្ពីរ សូមប្រាប់កុមារថា ព្រះយេស៊ូវ បានបង្រៀននៅក្នុងបទគម្ពីរថា ព្រះវិញ្ញាណបរិសុទ្ធ នឹងបង្រៀនយើង ។ សូមបើកព្រះគម្ពីរបរិសុទ្ធទៅ យ៉ូហាន 14:26 ហើយអានថា « ព្រះវិញ្ញាណបរិសុទ្ធ . . . នឹងបង្រៀនអ្នករាល់គ្នាពីគ្រប់សេចក្តីទាំងអស់ » ។ សូមអញ្ជើញកុមារឲ្យនិយាយឃ្លានេះជាមួយអ្នក ដោយនិយាយពីរបីពាក្យម្តង ។

រូបភាព សូមបង្ហាញរូបភាពនៅទំព័រ 31 ហើយសូមឲ្យរូបភាពដល់កុមារម្នាក់ៗ ។ សូមចង្អុលទៅរូបភាព អគារសាសនាចក្រ ហើយសូមពន្យល់ថា ព្រះវិញ្ញាណបរិសុទ្ធ នឹងជួយយើងឲ្យដឹងថា ការទៅព្រះវិហារ គឺជារឿងដ៏ត្រឹមត្រូវដើម្បីធ្វើ ។ សូមអញ្ជើញកុមារឲ្យចង្អុលទៅអគារសាសនាចក្រនៅលើរូបភាពរបស់ពួកគេ ។ សូមធ្វើសារឡើងវិញចំពោះរូបភាពដទៃទៀត ។

វល្លិងរាងជាគូប សូមរមៀលគូបដែលអ្នកបានធ្វើ ។ សូមអានចំណងជើងនៅលើជ្រុងគូបនោះ ហើយឲ្យកុមារថាតាមអ្នក ។ បន្ទាប់មក សូមឲ្យកុមារធ្វើសកម្មភាពងាយៗមួយចំនួន ដែលត្រូវនឹងរូបភាព ។ នៅពេលរមៀលត្រូវជ្រុងដែលមានពាក្យថា « ព្រះវិញ្ញាណបរិសុទ្ធជួយខ្ញុំ » ផ្ទាររឡើង សូមប្រាប់កុមារថា ព្រះវិញ្ញាណបរិសុទ្ធ ជួយយើងឲ្យដឹងនៅពេលណាយើងបានធ្វើអ្វីមួយល្អ ។ សូមធ្វើឡើងវិញ ដោយឲ្យកុមារម្នាក់ៗបានរមៀលគូបគ្រប់គ្នា ។



គន្លឹះក្នុងការបង្រៀន

បទពិសោធន៍ផ្ទាល់ខ្លួន ៖ ការរៀបរាប់បទពិសោធន៍ផ្ទាល់ខ្លួន អាចជួយដល់អ្នកទាំងឡាយដែលអ្នកបង្រៀន ឲ្យឃើញពីរបៀបដែលឥទ្ធិពលនៃដំណឹងល្អមាននៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង (សូមមើល *Teaching, No Greater Call* ទំព័រ 45, 180) ។ សម្រាប់ក្រុមកុមារវ័យនេះ បទពិសោធន៍ដែលអ្នកចែកចាយ ចាំបាច់ត្រូវតែសាមញ្ញបំផុត ហើយខ្លី —ពុំច្រើនជាងមួយប្រយោគ ឬ ពីរប្រយោគឡើយ ។

ព្រះគម្ពីរ ៖ « នៅពេលអ្នកបង្រៀនកុមារ អ្នកគួរតែប្រើព្រះគម្ពីរជាញឹកញាប់ ហើយស្វែងរកវិធីដើម្បីឲ្យកុមារមានភាពងាយស្រួលក្នុងការប្រើព្រះគម្ពីរ » (*Teaching, No Greater Call* ទំព័រ 59) ។ អ្នកអាចជួយពួកគេឲ្យអភិវឌ្ឍសេចក្តីស្រឡាញ់ចំពោះព្រះគម្ពីរ ទោះបីជាពួកគេពុំទាន់ចេះអានក្តី ។ ទោះបីជាអ្នកគ្រាន់តែអានឆ្នៃកខ្ពីមួយក្នុងខគម្ពីរទៅដល់កុមារក្តី សូមអ្នកអានខគម្ពីរទាំងមូលអំឡុងពេលអ្នកបៀបចំមេរៀននោះ ។

ការដាក់វេនគ្នា គឺជាការពិបាកសម្រាប់កុមារតូច។ ។ បើអ្នកមានកុមារច្រើននៅក្នុងថ្នាក់ទារកដ្ឋានរបស់អ្នក អ្នកអាចចង់រមៀលគូបដោយខ្លួនអ្នកគ្រប់ពេល ជាជាងឲ្យកុមារដាក់វេនគ្នារមៀលគូប ។

ព្រះវិញ្ញាណបរិសុទ្ធ
ជួយខ្ញុំ



ទៅព្រះវិហារ

អធិស្ឋាន



មានចិត្តល្អ

គោរពឪពុកម្តាយ



អានព្រះគម្ពីរ

7 ព្រះយេស៊ូវគ្រីស្ទ បានបង្កើតពិភពលោកសម្រាប់ខ្ញុំ



សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

ដោយធ្វើការនៅក្រោមការដឹកនាំនៃព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ បានបង្កើតពិភពលោកមួយដ៏ស្រស់ស្អាតឲ្យយើងរស់នៅ (សូមមើល ម៉ូសេ 2:1) ។ គោលបំណងនៃការបង្កបង្កើតផែនដីនេះ គឺដើម្បីផ្តល់កន្លែងមួយ ដែលយើងអាចទទួលបាននូវការសាកល្បង ហើយទទួលបទពិសោធន៍ ដើម្បីប្រែក្លាយឲ្យកាន់តែដូចជាព្រះវរបិតាសួគ៌របស់យើង (សូមមើល អ័ប្រាហាំ 3:24–25) ។ សម្រស់ដ៏ស្រស់ស្អាតនៃផែនដីនេះ បានធ្វើជាសាក្សីអំពីព្រះចេស្តា និង ក្តីស្រឡាញ់ដ៏មហិមារបស់ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ (សូមមើល ម៉ូសេ 6:63) ។

ការរៀបចំខ្លួន

សូមយកព្រះគម្ពីរបរិសុទ្ធមកជាមួយ ។ សូមគូសចំណាំ លោកុប្បត្តិ 1:1 ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។

សកម្មភាពក្នុងការបង្រៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

ចម្រៀង សូមច្រៀង ឬ និយាយពាក្យនៅក្នុងបទ « ព្រះវរបិតាស្រឡាញ់ខ្ញុំ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 228–29) ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ។

គ្រប់ពេលដែលខ្ញុំឮបក្សាបក្សីយំ *(សូមយកដៃខ្ទប់ត្រចៀក)*
ឬ សម្លឹងមើលទៅផ្ទៃមេឃ *(សូមមើលទៅលើ ដោយការយកដៃបាំងភ្នែក)*
រាល់ពេលដែលមានភ្លៀងធ្លាក់ស្រក់លើមុខខ្ញុំ *(សូមយកម្រាមដៃប៉ះមុខ)*
ឬ មានខ្យល់បក់ផាត់មកប៉ះកាយ *(សូមរាដៃចុះឡើង)*
នៅគ្រប់ពេលខ្ញុំពាល់ស្រទាប់កុលាប *(សូមក្បាច់ដៃទាំងពីររួមគ្នា)*
ឬ ដើរកាត់តាមដើមលីឡាក់ *(សូមប្រើម្រាមដៃពីរ « ដើរ » លើដៃម្ខាងទៀត)*
ខ្ញុំមានអំណរដែលខ្ញុំបានរស់នៅលើផែនដីដ៏ស្អាតនេះ *(សូមលើកដៃឡើងធ្វើជារង្វង់ពីលើក្បាល)*
ព្រះវរបិតា បានបង្កើតឲ្យខ្ញុំ ។ *(សូមចង្អុលខ្លួនឯង)*

បទគម្ពីរ សូមបើកព្រះគម្ពីរបរិសុទ្ធទៅ លោកុប្បត្តិ 1:1 ហើយអានថា « កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃ និង ផែនដី » ។ សូមអញ្ជើញឲ្យកុមារនិយាយបទគម្ពីរសារឡើងវិញជាមួយនឹងអ្នក ដោយនិយាយពីរបីពាក្យម្តង ។ សូមពន្យល់ថា ព្រះវរបិតាសួគ៌ បានឲ្យព្រះយេស៊ូវគ្រីស្ទ បង្កើតពិភពលោក និង អ្វីៗគ្រប់យ៉ាង ហើយព្រះយេស៊ូវក៏បានបង្កើតព្រះអាទិត្យដើម្បីផ្តល់ជាពន្លឺដល់យើងផងដែរ ។ សូមអញ្ជើញកុមារឲ្យលើកដៃដាក់លើក្បាលរបស់ពួកគេ ធ្វើជារង្វង់ ហើយនិយាយថា « ព្រះអាទិត្យ » ។

សូមប្រាប់កុមារថា ព្រះយេស៊ូវ បានបង្កើតផ្កាយ ដែលយើងមើលឃើញនៅពេលយប់ ។ សូមអញ្ជើញកុមារឲ្យក្តាប់ដៃ ហើយលាដៃរបស់គេ ធ្វើដូចជាផ្កាយដែលកំពុងតែបញ្ចេញពន្លឺព្រាកៗ ហើយនិយាយថា « ផ្កាយ » ។

រូបភាព សូមបង្ហាញរូបភាពនៅទំព័រ 34 ។ សូមចង្អុលទៅដើមឈើ ហើយសូមប្រាប់កុមារថា ព្រះយេស៊ូវបានបង្កើតរុក្ខជាតិទាំងឡាយ ។ សូមអញ្ជើញកុមារឲ្យឈរ ហើយលើកដៃឲ្យខ្ពស់ ធ្វើដូចជាដើមឈើកំពុងយោលយោគតាមវាយោ ។ សូមអញ្ជើញពួកគេឲ្យនិយាយថា « ដើមឈើ » ។

គន្លឹះក្នុងការបង្រៀន

ចម្រៀង ៖ « កុមារភាគច្រើនចូលចិត្តចូលរួមនៅក្នុងសកម្មភាពតន្ត្រី ។ សូមបង្ហាញអំពីពាក្យចុងជួននៅក្នុងតន្ត្រី ដើម្បីជួយឲ្យកុមារចងចាំ . . . សារលិខិតនៃទំនុកបទ ។ តន្ត្រីអាចបង្កើនការយល់ដឹងរបស់កុមារអំពីគោលការណ៍ទាំងឡាយនៃដំណឹងល្អ ហើយជួយពង្រឹងដល់ទីបន្ទាល់របស់ពួកគេ » (*Teaching, No Greater Call* ទំព័រ (174)) ។

កុមារតូច ។ ៖ បើកុមារបង្ហាញនូវអារម្មណ៍រសាប់រសល់ មុនពេលអ្នកបញ្ចប់សកម្មភាពរៀនសូត្រទាំងអស់ ភាមិនជាអ្វីឡើយក្នុងការបញ្ឈប់មេរៀន ហើយធ្វើសកម្មភាពមួយដែលអាចឲ្យកុមារអាចធ្វើចលនា ដូចជាដើរយោលខ្លួន ឬ លើកដៃលើកជើង ។ នៅពេលកុមារធំឡើង ពួកគេនឹងអាចផ្តោតការយកចិត្តទុកដាក់បានរយៈពេលយូរជាងនេះ ។

សូមចង្អុលទៅសត្វទាំងឡាយនៅក្នុងរូបភាព ហើយសូមពន្យល់ថា ព្រះយេស៊ូវបានបង្កើតសត្វទាំងឡាយ ។ សូមអញ្ជើញកុមារឲ្យប្រាប់ឈ្មោះសត្វមួយចំនួន ហើយធ្វើសំឡេងសត្វនោះ ។

សេចក្តីបញ្ចប់ សូមពន្យល់ថា ព្រះយេស៊ូវបានបង្កើតវត្ថុទាំងអស់នេះ ដោយសារតែទ្រង់ស្រឡាញ់យើង ។ សូមសម្តែងនូងការដឹងគុណរបស់អ្នកចំពោះពិភពលោកដ៏ស្រស់ស្អាតយើង ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់សកម្មភាពអំពីគ្រាប់ពូជ ៖* សូមយកកែវទឹកជ័រមួយឲ្យកុមារម្នាក់ៗ ។ សូមយកដីដើម្បីដាក់នៅក្នុងកែវ ហើយយកគ្រាប់ពូជខ្លះៗផងដែរ (ដូចជា គ្រាប់សណ្តែក គ្រាប់ពោត ឬ គ្រាប់ស្រូវ) ដើម្បីឲ្យកុមារម្នាក់ៗដាក់ដាំ ។ នៅលើកែវនីមួយៗមានសរសេរថា « ព្រះយេស៊ូវគ្រីស្ទ បានបង្កើតគ្រាប់ពូជសម្រាប់ខ្ញុំ » ។ សូមរៀបចំសៀវភៅកត់ចំណាំមួយ ដើម្បីយកទៅផ្ទះជាមួយកុមារ ដែលពន្យល់ពីរបៀបមើលថែគ្រាប់ពូជ ។
សម្រាប់សកម្មភាពធ្វើសៀវភៅ ៖ សូមចតចម្លងទំព័រ 35 សម្រាប់កុមារម្នាក់ៗជាត់ពណ៌ ។ សូមយកស្កុត ឬ កាវខ្លះមក ។

ចម្រៀង សូមច្រៀង ឬ និយាយពាក្យក្នុងបទ « លោកិយគួរឲ្យស្រឡាញ់ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 233) ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ។

លោកិយគួរឲ្យស្រឡាញ់ ! ខ្ញុំរីករាយខ្លាំងណាស់ *(សូមទាញមាត់ធ្វើជាញញឹម)*
អរគុណអ្វីគ្រប់យ៉ាងដែលព្រះបង្កើតឲ្យខ្ញុំ— *(សូមចង្អុលមកខ្លួនឯង)*
ព្រះអាទិត្យរះ *(សូមលើកដៃធ្វើជារង្វង់ពីលើក្បាល)* បុប្ផា *(សូមធ្វើជាហិតក្លិនផ្កា)*
តារាលើមេឃ *(សូមក្តាប់ដៃ ហើយលាដៃ ដូចជាផ្កាយកំពុងតែបញ្ចាំងពន្លឺព្រាកៗ)*
ផ្ទះដែលខ្ញុំរស់នៅ និង គ្រួសារគួរឲ្យស្រឡាញ់ ។ *(សូមឱបខ្លួនឯង)*

សកម្មភាពអំពីគ្រាប់ពូជ សូមដាក់ដីខ្លះនៅក្នុងកែវនីមួយៗ ដែលអ្នកបានយកមក ហើយឲ្យទៅកុមារម្នាក់ៗ ដាំគ្រាប់ពូជមួយ ។ ខណៈពេលដែលពួកគេកំពុងតែធ្វើដូចនេះ សូមប្រាប់ពួកគេថា បើពួកគេស្រោចទឹកលើគ្រាប់ពូជរបស់ពួកគេ ហើយដាក់វានៅកន្លែងដែលមានពន្លឺព្រះអាទិត្យគ្រប់គ្រាន់ នោះគ្រាប់ពូជនឹងរីកលូតលាស់ទៅជារុក្ខជាតិ ។ សូមរំឭកប្រាប់ពួកគេថា ព្រះយេស៊ូវគ្រីស្ទ បានបង្កើតគ្រាប់ពូជ ដី ស្លៀង និង ពន្លឺព្រះអាទិត្យ ។ សូមឲ្យឪពុកម្តាយយកកែវគ្រាប់ពូជរបស់កូនពួកគាត់ទៅផ្ទះ ដូច្នេះកូនគាត់អាចមើលថែគ្រាប់ពូជរបស់ពួកគេឲ្យដុះលូតលាស់បាន ។ សកម្មភាពនេះ គឺសមរម្យបំផុតសម្រាប់កុមារធំៗ ។

សៀវភៅ សូមឲ្យកុមារជាត់ពណ៌លើរូបភាពនៅទំព័រ 35 ។ ខណៈពេលដែលពួកគេកំពុងតែជាត់ពណ៌ សូមរំឭករឿងទាំងឡាយ ដែលអ្នកបានបង្រៀននៅក្នុងមេរៀននេះ ។ ពេលពួកគេជាត់ពណ៌ចប់ សូមបត់រូបភាព ហើយសូមបិទស្កុត ឬ កាវ ស្របទៅតាមការណែនាំនៅលើរូបភាពនោះ ។ បន្ទាប់មក សូមអានសៀវភៅជាមួយនឹងកុមារ ។

គន្លឹះក្នុងការបង្រៀន

សកម្មភាពអំពីគ្រាប់ពូជ ៖ បើអ្នកជ្រើសរើសដើម្បីធ្វើសកម្មភាពនេះ សូមរក្សាកែវដ៏នោះនៅកន្លែងមានសុវត្ថិភាព រហូតដល់ពេលឲ្យកុមារយកវាទៅផ្ទះ ។ បើថ្នាក់ទារកដ្ឋានរបស់អ្នកជួបគ្នាមុនពេលការប្រជុំសាក្រាម៉ង់ សូមកុំឲ្យកុមារយកកែវដីចូលទៅក្នុងសាលាជំនុំឡើយ ។ ផ្ទុយទៅវិញ សូមឲ្យកែវនោះទៅឪពុកម្តាយ បន្ទាប់ពីម៉ោងសាក្រាម៉ង់ ។

សៀវភៅ ៖ សូមពិចារណាអំពីការធ្វើប្រអប់សកម្មភាពមួយ ដើម្បីរក្សាទុកក្នុងថ្នាក់ទារកដ្ឋាន ។ វាអាចមានសៀវភៅដែលអ្នកបានធ្វើសម្រាប់មេរៀននេះ និង អ្វីផ្សេងៗទៀតដែលអ្នកបានធ្វើ ឬ ប្រើប្រាស់សម្រាប់សកម្មភាពដទៃទៀត ។ បន្ទាប់មក អ្នកអាចធ្វើសកម្មភាពទាំងឡាយសារឡើងវិញ អំឡុងពេលថ្នាក់ទារកដ្ឋាននាពេលអនាគត ដើម្បីរំឭកមេរៀនមុន។ ។ ការរំឭកនេះ អាចកើតមាននៅគ្រប់ពេល អំឡុងថ្នាក់ទារកដ្ឋាន ។

ព្រះយេស៊ូវ បានបង្កើត
ព្រះអាទិត្យ ។

ខ្ញុំចង់ធ្វើល្អ
ដូចអ្វីដែលព្រះយេស៊ូវ
បានបង្គាប់ខ្ញុំ។

ព្រះអាទិត្យ ធ្វើការនៅពេលថ្ងៃ
ព្រះច័ន្ទ និងផ្កាយ ធ្វើការនៅពេលយប់ ។

ព្រះអាទិត្យ ព្រះច័ន្ទ និង
ផ្កាយទាំងឡាយ ។

ព្រះបានបង្កើតផ្កាជាច្រើន ។

ព្រះបានបង្កើតសត្វទាំងអស់ ។

ព្រះបានបង្កើតសត្វស្លាប ។

1. ស្មៅ ផ្កាយ ព្រះច័ន្ទ ព្រះអាទិត្យ

2. ស្មៅ បក្សី ផ្កាយ ព្រះច័ន្ទ ព្រះអាទិត្យ

3. ស្មៅ បក្សី ផ្កាយ ព្រះច័ន្ទ ព្រះអាទិត្យ

4. ផ្កា ត្រី ទន្សាយ

5. ស្មៅ បក្សី ផ្កាយ ព្រះច័ន្ទ ព្រះអាទិត្យ

8

ថ្ងៃអាទិត្យ គឺជាថ្ងៃមួយដើម្បីរំឭកចាំអំពី ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ



គន្លឹះក្នុងការបង្រៀន

ចម្រៀង ៖ នៅពេលអ្នកបៀបចំដើម្បីបង្រៀន សូមព្យាយាមទន្ទេញពាក្យក្នុងចម្រៀង និង វគ្គសកម្មភាព ។ ការធ្វើបែបនេះនឹងអនុញ្ញាតឲ្យអ្នកអាចផ្តោតទៅលើកុមារ និង ការបង្រៀនសូត្ររបស់ពួកគេ ។ (សូមមើល *Teaching, No Greater Call* ទំព័រ 159) ។

ចម្រៀង ៖ សូមពិចារណាអំពីការធ្វើបញ្ជីចម្រៀងមួយ ដែលកុមារកំពុងរៀន ជាពិសេសចម្រៀងដែលពួកគេចូលចិត្តច្រៀង ។ សូមច្រៀងវានៅក្នុងថ្នាក់ទាក់ទងជារៀងរាល់សប្តាហ៍ ខណៈពេលដែលកុមារកំពុងលេងសម្ភារលេង មុនពេល ឬ បន្ទាប់ពីម៉ោងបរិភោគអាហារសម្រន់ ឬ ខណៈពេលដែលកុមារកំពុងរង់ចាំឪពុកម្តាយ ។ នេះគឺជាវិធីដ៏ល្អមួយ ដើម្បីរំឭកមេរៀនមុន។ ។ ទោះបីជាកុមារពុំច្រៀងជាមួយនឹងអ្នកនៅគ្រាដំបូងក្តី ក៏ពួកគេស្តាប់ និង រៀនដែរ ។

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

ចាប់តាំងពីជំនាន់ព្រះគម្ពីរសញ្ញាចាស់មក រាស្ត្ររបស់ព្រះបានញែកមួយថ្ងៃក្នុងចំណោមថ្ងៃទាំងប្រាំពីរ ជាថ្ងៃឈប់សម្រាក—ជាថ្ងៃមួយដែលសម្រាកពីកិច្ចការទាំងអស់របស់យើង ហើយមកថ្វាយបង្គំព្រះ (សូមមើល លោកុប្បត្តិ 2:2–3 ; និក្ខមនំ 20:8–11) ។ ព្រះអម្ចាស់បានមានព្រះបន្ទូលសារឡើងវិញអំពីបទបញ្ញត្តិនេះ នៅក្នុងជំនាន់របស់យើង ហើយទ្រង់បានសន្យាថា ការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ នឹងជួយយើង « កុំឲ្យប្រឡាក់ពីលោកិយ » (សូមមើល គ. និង ស. 59:9–10) ។

សកម្មភាពក្នុងការបង្រៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

រូបភាព សូមបង្ហាញរូបភាពគ្រួសារកំពុងដើរទៅព្រះវិហារនៅទំព័រ 38 ហើយសូមប្រាប់ដល់កុមារថា គ្រួសារនេះ កំពុងទៅព្រះវិហារនៅថ្ងៃអាទិត្យ ។ សូមពន្យល់ថា ថ្ងៃអាទិត្យ គឺជាថ្ងៃដ៏ពិសេសមួយ ហើយថាយើងទៅព្រះវិហារនៅថ្ងៃអាទិត្យ ដើម្បីថ្វាយបង្គំព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ហើយរៀនអំពីទ្រង់ទាំងពីរព្រះអង្គ ។

ចម្រៀង សូមប្រាប់កុមារថា « ចូរយើងធ្វើជាកំពុងតែដើរទៅព្រះវិហារ » ។ សូមឲ្យពួកគេដើរជារង្វង់ ហើយច្រៀង ឬ និយាយពាក្យនៅក្នុងបទ « សប្បាយធ្វើការ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 253) ៖

ការទៅព្រះវិហារ គឺសប្បាយណាស់
សប្បាយណាស់ សប្បាយ សប្បាយ !
ការទៅព្រះវិហារ គឺសប្បាយណាស់
សប្បាយ សប្បាយ សប្បាយ !

សូមឲ្យកុមារអង្គុយចុះ ហើយសូមប្រាប់ពួកគេថា នៅពេលយើងមកព្រះវិហារ យើងរំឭកចាំ (*សូមចង្អុលទៅក្បាលរបស់អ្នក*) ហើយគិតអំពី (*សូមចង្អុលទៅក្បាលរបស់អ្នកម្តងទៀត*) ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវ ។ សូមច្រៀង ឬ អានបន្ទាត់ទីមួយនៅក្នុងបទ « ដោយគោរព ដោយស្ងៀមស្ងាត់ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 26) ៖

ដោយគោរព ដោយស្ងៀមស្ងាត់ យើងគិតដល់ទ្រង់ដោយក្តីស្នេហ៍ ។

សូមបង្ហាញរូបភាពនៃគ្រួសារនៅផ្ទះ នៅក្នុងទំព័រ 38 ។ សូមចង្អុលបង្ហាញទៅសមាជិកគ្រួសារផ្សេងៗគ្នា ហើយសូមពន្យល់ថា បន្ទាប់ពីទៅព្រះវិហារ នៅក្នុងគេហដ្ឋានរបស់យើង យើងក៏អាចរំឭកចាំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវ ជាមួយនឹងគ្រួសាររបស់យើងដែរ ។ យើងអាចអានបទគម្ពីរជាមួយនឹងគ្នា (*សូមឲ្យកុមារធ្វើដូចជាអានព្រះគម្ពីរ*) ហើយអធិស្ឋានជាមួយគ្នា (*សូមឲ្យកុមារធ្វើដូចជាឱបដៃរបស់ពួកគេ*) ហើយបង្ហាញសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក (*សូមឲ្យកុមារធ្វើជាដាក់ដៃរបស់ពួកគេនៅលើខ្លួនគេ*) ។ សូមច្រៀង ឬ អានពាក្យនៅក្នុងបទ « ក្រុមគ្រួសារដ៏រីករាយមួយ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 198) ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ។

ខ្ញុំស្រឡាញ់ម៉ាក់ ម៉ាក់ស្រឡាញ់ខ្ញុំ ។
យើងស្រឡាញ់ប៉ា ប៉ាស្រឡាញ់យើង
គាត់ស្រឡាញ់យើង ហើយអ្នកអាចឃើញ
យើងជាគ្រួសារដ៏រីករាយមួយ ។

សេចក្តីបញ្ចប់ សូមរំឭកកុមារថា ថ្ងៃអាទិត្យ គឺជាថ្ងៃមួយដើម្បីរំឭកចាំអំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវ នៅព្រះវិហារ និង នៅផ្ទះជាមួយនឹងគ្រួសាររបស់យើង ។ សូមអញ្ជើញកុមារឲ្យនិយាយថា « ថ្ងៃអាទិត្យ » ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់វល្លេងថង់ ៖* សូមថតចម្លងមួយច្បាប់ពីទំព័រ 39 ។ សូមកាត់រូបភាព ឬ ជាត់ពណ៌វាតាមចំណូចិត្ត ។ សូមដាក់រូបភាពនៅក្នុងថង់មួយ ឬ ក្នុងប្រអប់មួយទៀត ។

សម្រាប់សកម្មភាពបទគម្ពីរ ៖ សូមយកព្រះគម្ពីរបរិសុទ្ធមកជាមួយ ។ សូមគូសចំណាំលោកុប្បត្តិ 2:2 ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។ សូមគូសចំណាំទំព័រ 34 នៅក្នុងសៀវភៅសិក្សានេះផងដែរ ។

សម្រាប់សកម្មភាពធ្វើសៀវភៅ ៖ សូមថតចម្លងរូបភាពនៅទំព័រ 39 សម្រាប់កុមារម្នាក់ៗ ជាត់ពណ៌ ។

វល្លេងថង់ សូមអញ្ជើញកុមរម្នាក់ ឲ្យជ្រើសរើសរូបភាពមួយចេញពីក្នុងថង់ ។ សូមអានចំណងជើងហើយសូមអញ្ជើញកុមារឲ្យធ្វើសកម្មភាពមួយ ដែលបានផ្តល់យោបល់តាមរូបភាព (ដូចជាការដើរនៅនឹងកន្លែងសម្រាប់ « នៅថ្ងៃអាទិត្យ ខ្ញុំអាចទៅព្រះវិហារ » ឬ ចង្អុលទៅក្បាលរបស់ពួកគេសម្រាប់ « ថ្ងៃអាទិត្យ គឺជាថ្ងៃមួយដើម្បីរំឭកចាំអំពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ») ។ សូមអញ្ជើញកុមារឲ្យនិយាយពាក្យគន្លឹះចេញមកពីចំណងជើងនីមួយៗ ដូចជា « ព្រះយេស៊ូវ » « ព្រះគម្ពីរ » « គ្រួសារ » និង « ព្រះវិហារ » ។ សូមធ្វើសារឡើងវិញជាមួយនឹងរូបភាពនីមួយៗ ឬ ទាល់តែកុមារម្នាក់ៗ ដែលចង់ធ្វើបានធ្វើម្តង ។

បទគម្ពីរ សូមបង្ហាញរូបភាពនៅលើទំព័រ 34 ហើយសូមរំឭករឿងអំពីការបង្កបង្កើតជាមួយកុមារ (សូមមើល លោកុប្បត្តិ 1 និង មេរៀនទី 7 នៅក្នុងសៀវភៅសិក្សានេះ) ។ សូមពន្យល់ថាព្រះយេស៊ូវបានធ្វើការយៈពេលប្រាំមួយថ្ងៃ ដើម្បីបង្កើតពិភពលោក ។

សូមប្រាប់កុមារថា អ្នកនឹងអានបទគម្ពីរមួយ ដែលប្រាប់យើងអំពីអ្វីដែលព្រះយេស៊ូវបានធ្វើនៅថ្ងៃទីប្រាំពីរ ។ សូមបើកគម្ពីរបរិសុទ្ធទៅ លោកុប្បត្តិ 2:2 ហើយអាន « ទ្រង់ក៏ឈប់ផ្អាកសម្រាកនៅថ្ងៃទី 7 នោះ ពីគ្រប់ទាំងការដែលទ្រង់ធ្វើ » ។ សូមគូសបញ្ជាក់ពាក្យ *ឈប់ ផ្អាក សម្រាក* នៅពេលអ្នកអាន ។

សូមសួរថា ៖ « តើព្រះយេស៊ូវបានធ្វើអ្វីខ្លះ នៅថ្ងៃទីប្រាំពីរ ? »

ចម្លើយ ៖ « ទ្រង់ក៏ឈប់ ផ្អាក សម្រាក » ។

សូមប្រាប់កុមារថា នៅថ្ងៃទាំងប្រាំមួយក្នុងសប្តាហ៍ យើងធ្វើការ ។ សូមអញ្ជើញកុមារឲ្យសម្តែងធ្វើជាធ្វើការងារផ្សេងៗគ្នា ដូចជា ការបោសជូតឥដ្ឋ ការជីកដាំដុះក្នុងសួនជាដើម ។ សូមពន្យល់ថា នៅថ្ងៃអាទិត្យ យើងឈប់សម្រាក ។ សូមអញ្ជើញកុមារឲ្យអង្គុយចុះ ហើយសូមប្រាប់ពួកគេថា អ្នកមានអំណរគុណខ្លាំងយ៉ាងណា ដែលព្រះវរបិតាសួគ៌បានប្រទានដល់យើងនូវថ្ងៃមួយ ដើម្បីឈប់សម្រាកពីការងាររបស់យើង ។

សៀវភៅ សូមឲ្យកុមារជាត់ពណ៌លើរូបភាពដែលចម្លងពីទំព័រ 39ៗ ខណៈពេលដែលពួកគេកំពុងជាត់ពណ៌ សូមនិយាយទៅពួកគេអំពីរូបភាព ហើយសូមរំឭកពួកគេថា ទាំងនេះគឺជារឿងទាំងឡាយដែលយើងធ្វើ ដើម្បីរំឭកចាំ និង ថ្វាយបង្គំដល់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ នៅថ្ងៃអាទិត្យ ។ នៅពេលពួកគេបានជាត់ពណ៌ចប់ហើយ សូមបត់តាមចំណុចចុចៗ ដើម្បីធ្វើជាសៀវភៅមួយ ។ បន្ទាប់មក សូមអានពីសៀវភៅដល់កុមារស្តាប់ ។

គន្លឹះក្នុងការបង្រៀន

វល្លេងថង់ ៖ បើអ្នកពុំមានថង់មួយ ឬ ប្រអប់មួយទៀតទេ អ្នកអាចដាក់រូបភាពផ្តាច់ចុះ ហើយសូមឲ្យកុមារម្នាក់បីសរូបភាពមួយ ហើយមើកវាឡើង ។

ការជាក់ស្តែងគ្នា អាចជាការពិបាកសម្រាប់កុមារតូច។ ។ សូមឲ្យពួកគេអង្គុយនៅលើកៅអីមួយ ឬ នៅលើតដ្ឋ ខណៈពេលដែលពួកគេកំពុងរង់ចាំដល់វេនពួកគេ នោះវាអាចជួយសម្រួលបាន ។ អ្នកក៏អាចឲ្យអ្នកដឹកនាំថ្នាក់ទារកដ្ឋានម្នាក់ ផ្តោតទៅលើការជួយពួកគេឲ្យរង់ចាំ ខណៈពេលដែលអ្នកដឹកនាំថ្នាក់ទារកដ្ឋានដទៃទៀត កំពុងបង្រៀន ។

សៀវភៅ ៖ សូមលើកទឹកចិត្តដល់កុមារឲ្យបង្ហាញសៀវភៅរបស់ពួកគេទៅដល់ក្រុមគ្រួសាររបស់ពួកគេ ។ វានឹងផ្តល់ឱកាសមួយដល់ឪពុកម្តាយរបស់ពួកគេឲ្យរំឭកមើលជាមួយនឹងកុមារអំពីអ្វី ដែលពួកគេបានរៀន ។ (សូមមើល *Teaching, No Greater Call* ទំព័រ 167) ។



ខ្ញុំរៀនឆ្លឹះយកចុលលរបូជា
ឃ្លាបាទលាឡ្លីឧលរយិជ្ជីរាធអខ្ញុំ ឡែនឱអឲ្ញុំរុនរ



ខ្ញុំរៀនឱរាឡ្ធាធអខ្ញុំ ឡែនឱអឲ្ញុំរុនរ



នៅថ្ងៃអាទិត្យ ខ្ញុំអាចរៀនព្រះគម្ពីរ ។

ថ្ងៃអាទិត្យ គឺជាថ្ងៃមួយដើម្បីរំព្ធកចាំអំពី
ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។

9 ខ្ញុំមានរូបកាយដូចជារូបអង្គរបស់ព្រះវរបិតាសួគ៌

គន្លឹះក្នុងការបង្រៀន

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

យើងម្នាក់ៗ គឺជាបុត្ររបស់ព្រះ ។ បទគម្ពីរបង្រៀនថា « ព្រះក៏បង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ » (លោកុប្បត្តិ 1:27 ; សូមមើលផងដែរ ម៉ូសេ 2:26–27 ; អ័ប្រាហាំ 4:26–27) ។ នេះមានន័យថា រូបកាយរបស់យើង គឺស្រដៀងគ្នានឹងរូបអង្គទ្រង់ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានឃើញព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ហើយលោកបានបង្រៀនថា « ព្រះវរបិតា ទ្រង់មានព្រះកាយជាសាច់ និង ឆ្អឹង ដែលជាក់ស្តែងដូចជារូបកាយមនុស្ស ហើយព្រះរាជបុត្រាក៏ដូច្នោះដែរ » (គ. និង ស. 130:22) ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

ចម្រៀង សូមច្រៀងវគ្គទីមួយនៅក្នុងបទ « ខ្ញុំជាកូនរបស់ព្រះ » (*សៀវភៅចម្រៀងកុមារ ទំព័រ* 58) ៖

ខ្ញុំជាកូនរបស់ព្រះ
ហើយទ្រង់បានចាត់ខ្ញុំមក
បានឲ្យផ្ទះខ្ញុំនៅលើផែនដី
ជាមួយឪពុកម្តាយល្អ

សូមច្រៀងសារឡើងវិញ ហើយសូមអញ្ជើញកុមារឲ្យស្តាប់ ឬ ច្រៀងជាមួយអ្នក ។ ប្រាប់ពួកគេថា នៅពេលយើងនិយាយថា « ព្រះ » យើងមានន័យថា ព្រះវរបិតាសួគ៌ ។

រឿងបទគម្ពីរ សូមបង្ហាញរូបភាពនៅលើទំព័រ 42 ។ សូមប្រាប់រឿងអំពីការនិមិត្តដំបូងរបស់ យ៉ូសែប ស្ម៊ីធ ដោយសង្ខេប ដើម្បីបង្រៀនកុមារថា ព្រះវរបិតាសួគ៌មានរូបកាយដូចជាយើង (សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:17) ។ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយ ៖

កាលពីយ៉ូសែប ស្ម៊ីធ នៅក្មេង *(សូមចង្អុលទៅយ៉ូសែបនៅក្នុងរូបភាព)* លោកបានអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ ។ អ្វីមួយដែលអស្ចារ្យបានកើតឡើង ។ យ៉ូសែបបានឃើញព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ *(សូមចង្អុលទៅព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវ នៅក្នុងរូបភាព)* ។ ទ្រង់ទាំងពីរព្រះអង្គ បានយាងមក ហើយមានព្រះបន្ទូលទៅកាន់យ៉ូសែប ។ យ៉ូសែប បានឃើញថា ព្រះវរបិតាសួគ៌មានរូបកាយដូចជាយើងមានផងដែរ ។ ព្រះវរបិតាសួគ៌ មានព្រះហស្ត ។ តើប្អូនមានដៃឬទេ ? សូមបង្ហាញដៃរបស់ប្អូន ។ ព្រះវរបិតាសួគ៌ មានប្រអប់ព្រះហស្ត ។ តើប្អូនមានប្រអប់ដៃឬទេ ? សូមបង្ហាញប្រអប់ដៃរបស់ប្អូន ។ ព្រះវរបិតាសួគ៌ មានព្រះភក្ត្រ ។ តើប្អូនមានមុខឬទេ ? សូមប៉ះមុខរបស់ប្អូន ។ ប្អូនគឺជាមនុស្សពិតម្នាក់ ។ ព្រះវរបិតាសួគ៌ គឺជាតួអង្គពិត ។ ទ្រង់បានបង្កើតរូបកាយរបស់ប្អូន ។ ប្អូនមានរូបកាយដូចជារូបកាយរបស់ព្រះវរបិតាសួគ៌ ។

វគ្គសកម្មភាព សូមអញ្ជើញកុមារឲ្យឈរ ហើយធ្វើតាមវគ្គសកម្មភាពដូចខាងក្រោមជាមួយអ្នក ៖

ខ្ញុំមានរូបកាយពិសេសមួយ
ព្រះវរបិតាសួគ៌ បានប្រទានដល់ខ្ញុំ ។ *(សូមយកដៃប៉ះដើមទ្រូង)*
ទ្រង់បានប្រទានត្រចៀកដល់ខ្ញុំ ដើម្បីខ្ញុំអាចស្តាប់ឮ *(សូមយកដៃដាក់ផ្នប់ត្រចៀក)*
និងភ្នែក ដែលខ្ញុំអាចមើលឃើញ ។ *(សូមចង្អុលទៅភ្នែក)*
ទ្រង់បានប្រទានដៃដល់ខ្ញុំ ដើម្បីខ្ញុំអាចទះដៃ *(សូមទះដៃ)*
ជើងពីរដើម្បីរត់លេង ។ *(សូមបង្វិលខ្លួនជុំវិញ)*
ហើយនៅពេលខ្ញុំចង់ ខ្ញុំប៉ះម្រាមជើងខ្ញុំ *(សូមឱនចុះ ហើយប៉ះម្រាមជើង)*
បន្ទាបចុះដល់ដី ។
នៅពេលខ្ញុំគិតអំពីរូបកាយរបស់ខ្ញុំ *(សូមដាក់ម្រាមដៃប៉ះក្បាល)*
ផ្នែកសំខាន់បំផុតនៃរូបកាយគឺ
ថាព្រះវរបិតាសួគ៌ បានរៀបផែនការ
ដើម្បីឲ្យមើលទៅដូចជាទ្រង់ ។ *(សូមអង្គុយចុះដោយស្ងៀមស្ងាត់)*

សកម្មភាពក្នុងការរៀនសូត្រ ៖ សូមពិនិត្យមើលនូវការចូលរួមរបស់កុមារអំឡុងពេលសកម្មភាពទាំងឡាយ ។ អ្នកស្គាល់សមត្ថភាព និង តម្រូវការរបស់កុមារនៅក្នុងថ្នាក់ទារកដ្ឋានរបស់អ្នក ។ សូមសម្របសកម្មភាពទៅតាមតម្រូវការ ។ (សូមមើល *Teaching, No Greater Call* ទំព័រ 33–34) ។

វគ្គសកម្មភាពនានា ៖ អ្នកអាចប្រើវគ្គសកម្មភាពនៅគ្រប់ពេលក្នុងថ្នាក់ទារកដ្ឋាន នៅពេលណាកុមារត្រូវការធ្វើចលនា ឬ នៅពេលអ្នកចង់ឲ្យពួកគេយកចិត្តទុកដាក់ ។ វាក៏ជាវិធីមួយល្អ ដើម្បីឮកគោលការណ៍ទាំងឡាយ ដែលអ្នកបានបង្រៀនពីមុនផងដែរ ។

សេចក្តីបញ្ចប់ សូមអញ្ជើញកុមារឲ្យថាតាមអ្នកនូវពាក្យពីរបីម៉ាត់ម្តង « ខ្ញុំមានរូបកាយដូចជារូបអង្គរបស់ព្រះវរបិតាសួគ៌ » ។ សូមបង្ហាញការដឹងគុណរបស់អ្នកចំពោះរូបកាយរបស់អ្នក ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់រឿងតុក្កតាអាយ៉ងដែលប្រើម្រាមដៃ ៖* សូមថតចម្លង ជាត់ពណ៌ ហើយកាត់រូបតុក្កតាអាយ៉ងដែលប្រើម្រាមដៃ នៅទំព័រ 91 ។

សម្រាប់សកម្មភាពដានរូប ៖ សូមយកក្រដាសលាតមួយមកឲ្យកុមារម្នាក់ៗ និង អ្វីមួយសម្រាប់សរសេរ ។

សម្រាប់សកម្មភាពរូបភាព ៖ សូមថតចម្លងរូបភាពនៅទំព័រ 43 សម្រាប់កុមារម្នាក់ៗ ។

ចម្រៀង សូមច្រៀង ឬ និយាយពាក្យក្នុងបទ « ក្បាល ស្មា ជង្គង់ និង ជើង » (*សៀវភៅចម្រៀងកុមារ* ទំព័រ 275) ហើយសូមចង្អុលទៅផ្នែកនីមួយនៃរូបកាយ នៅពេលអ្នកនិយាយ ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ។

ក្បាល ស្មា ជង្គង់ និង ជើង, ជង្គង់ និង ជើង, ជង្គង់ និង ជើង
ក្បាល ស្មា ជង្គង់ និង ជើង, ភ្នែក ត្រចៀក មាត់ និង ច្រមុះ ។

សូមធ្វើសារឡើងវិញឲ្យបានញឹកញាប់តាមដែលកុមារចូលចិត្ត ។ សូមរំឭកពួកគេថា ព្រះវរបិតាសួគ៌បានប្រទានដល់យើងនូវរូបកាយ ដែលមើលទៅដូចជារូបអង្គទ្រង់ ដូច្នោះដែរ។

រឿងតុក្កតាអាយ៉ងដែលប្រើម្រាមដៃ សូមប្រាប់រឿងនៃការនិមិត្តដំបូងសារជាថ្មី ដោយប្រើតុក្កតាអាយ៉ងដែលប្រើដៃ ដែលអ្នកបានធ្វើ (សូមមើល យ៉ូសែប ស៊្មីធ—ប្រវត្តិ 1:11–17 ; សូមមើលឧទាហរណ៍ នៅទំព័រ 88 ផងដែរ) ។ សូមគូសបញ្ជាក់ពីការពិតដែលយ៉ូសែប ស៊្មីធ បានឃើញថា ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ មានរូបកាយដូចជារូបកាយយើងដែរ ។



ការដានរូប សូមដានរូបដៃរបស់កុមារម្នាក់ៗនៅលើក្រដាសមួយសន្លឹក ។ សូមឲ្យពួកគេជាត់ពណ៌រូបដាននោះ ។ សូមសរសេរនៅលើក្រដាសនូវឈ្មោះ អាយុរបស់កុមារ និងកាលបរិច្ឆេទ ។

រូបភាព សូមដាក់បង្ហាញរូបភាពនៅទំព័រ 43 ហើយផ្តល់រូបភាពដល់កុមារម្នាក់ៗមួយសន្លឹក ។ សូមចង្អុលទៅមុខរបស់ក្មេងប្រុស ហើយសូមរំឭកកុមារថា យើងមានមុខ ហើយព្រះវរបិតាសួគ៌ក៏មានដែរ ។ សូមអញ្ជើញកុមារឲ្យចង្អុលទៅមុខនៅលើរូបភាពរបស់ពួកគេ ។ សូមធ្វើសារឡើងវិញនូវផ្នែកផ្សេងៗទៀតនៃរាងកាយ ។ សូមឲ្យកុមារជាត់ពណ៌រូបភាពរបស់ពួកគេតាមចំណូលចិត្ត ។

គន្លឹះក្នុងការបង្រៀន

តុក្កតាអាយ៉ងដែលប្រើម្រាមដៃ ៖ នៅពេលអ្នកធ្វើតុក្កតាអាយ៉ងដែលប្រើម្រាមដៃ ឬ ជំនួយក្នុងការបង្រៀនផ្សេងទៀតសម្រាប់មេរៀនក្នុងថ្នាក់ទារកដ្ឋាន សូមរក្សាវាទុក ។ អ្នកអាចប្រើវានៅមេរៀនក្រោយ។ទៀត ។

ការរំឭក ៖ សូមធ្វើសកម្មភាពសារឡើងវិញចេញពីមេរៀនមុន។ ឲ្យបានញឹកញាប់តាមដែលអ្នកចង់ធ្វើ ។ ការធ្វើសារឡើងវិញ គឺសម្បាយសម្រាប់កុមារ ហើយវាជួយពួកគេឲ្យរៀន ។

ខ្ញុំមានរូបកាយដូចជារូប
អង្គរបស់ព្រះវរបិតាសួគ៌

ខ្ញុំមានមុខដូចជា
ព្រះវរបិតាសួគ៌ ។



ខ្ញុំមានដៃពីរដូចជា
ព្រះវរបិតាសួគ៌ ។

ខ្ញុំមានជើងពីរដូចជា
ព្រះវរបិតាសួគ៌ ។

10 ខ្ញុំនឹងមើលថែរូបកាយរបស់ខ្ញុំ

គន្លឹះក្នុងការបង្រៀន

កំណត់ចំណាំ ៖ អំឡុងពេលមេរៀននេះ សូមយល់ពីអារម្មណ៍របស់កុមារទាំងអស់នៅក្នុងថ្នាក់ទារកដ្ឋានរបស់អ្នក ដែលមានរាងកាយពិការ ។ អ្នកអាចនឹងចាំបាច់ត្រូវផ្ទាស់ប្តូរសំណួរ ដែលអ្នកសួរ អំឡុងពេលសកម្មភាពរូបភាពនានា ។ សូមផ្តោតទៅលើអ្វីដែលកុមារ *អាច* ធ្វើបាន ពុំមែនផ្តោតទៅលើអ្វីដែលពួកគេពុំអាចធ្វើនោះទេ ។ សម្រាប់ព័ត៌មានបន្ថែម អំពីការបង្រៀនដល់កុមារទាំងឡាយដែលពិការ សូមមើល *Teaching, No Greater Call* ទំព័រ 38–39 ។

ការសម្តែង ៖ កុមារតូច។ អាចនឹងពុំដឹងពីរបៀបដើម្បីធ្វើតាមសកម្មភាពមួយចំនួន ដែលបានផ្តល់យោបល់ឲ្យធ្វើនៅក្នុងសកម្មភាពសម្តែងនោះទេ ។ ដើម្បីជាការផ្ទាស់ប្តូរ អ្នកអាចអញ្ជើញពួកគេឲ្យចង្អុលផ្នែកផ្សេង។នៃរូបកាយរបស់ពួកគេ ។ ឧទាហរណ៍ សូមចង្អុលទៅមាត់របស់អ្នក ហើយនិយាយថា « នេះជាមាត់របស់ខ្ញុំ ។ តើប្អូនអាចបង្ហាញមាត់របស់ប្អូនបានទេ ? » សូមទះដៃរបស់អ្នក ហើយសូមសរសើរដល់កុមារ ។ សូមធ្វើដដែល។ចំពោះផ្នែកផ្សេងទៀតនៃរាងកាយ ។

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

ពរជ័យដ៏មហិមាបំផុតមួយនៃផែនការនៃសេចក្តីសង្រ្គោះ គឺជាឱកាសមួយដើម្បីទទួលរូបកាយសាច់ឈាម ។ ព្រះអម្ចាស់ ចង់ឲ្យយើងគោរពដល់រូបកាយរបស់យើង ហើយមើលថែរូបកាយយើងឲ្យបានល្អ ។ ទ្រង់ប្រទានពរដល់យើង នៅពេលយើងធ្វើដូច្នោះ (សូមមើល កូរិនថូសទី 1 3:16 ; គ. និង ស. 89:18–21) ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

រូបភាព សូមប្រាប់កុមារថា ព្រះវរបិតាសួគ៌ប្រទានរូបកាយដល់យើង ហើយរូបកាយរបស់យើងអាចធ្វើនូវរឿងដ៏អស្ចារ្យជាច្រើន ។ សូមបង្ហាញរូបភាពនៅទំព័រ 46 ។ សូមចង្អុលបង្ហាញសមាជិកគ្រួសារម្នាក់ៗនៅក្នុងរូបភាព នៅពេលអ្នកចង្អុលទៅរូបទារក សូមសួរសំណួរស្រដៀងគ្នាទៅនឹងសំណួរដែលសរសេរនៅខាងក្រោម ។ បន្ទាប់ពីសួរសំណួរនីមួយៗរួចហើយ សូមអញ្ជើញកុមារឲ្យឆ្លើយតបនឹងអ្នក ដោយនិយាយថា « ទេ » នៅពេលអ្នកងាកក្បាលចេញ តាមរបៀបបំផ្លើស ។

- តើទារកអាចដើរបានទេ ?
- តើទារកអាចនិយាយបានឬទេ ?
- តើទារកអាចបោះបាល់បានឬទេ ?

សូមប្រាប់កុមារថា កាលពីមុន ពួកគេគឺជាទារកតូចប៉ុណ្ណោះ ប៉ុន្តែឥឡូវពួកគេធំឡើងហើយ ។

ចម្រៀង សូមឲ្យកុមារក្រោកឈរ ។ សូមច្រៀង ឬ អានពាក្យដូចខាងក្រោមតាមបទ « គ្រាមួយមានមនុស្សព្រិល » (*សៀវភៅចម្រៀងកុមារ* ទំព័រ 249) ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ។

គ្រាមួយខ្ញុំជាទារក ទារក ទារក ។ *(សូមធ្វើជាបីទារកក្នុងដៃ)*
គ្រាមួយខ្ញុំជាទារក តូច តូច តូច ។ *(សូមបន្ទន់ខ្លួនចុះទាបបន្តិចម្តងៗ)*
ឥឡូវខ្ញុំធំឡើងហើយ ធំឡើង ធំឡើង ។ *(សូមក្រោកឈរឡើងយឺតៗ)*
ឥឡូវខ្ញុំធំឡើងហើយ ខ្ពស់ ខ្ពស់ ខ្ពស់ ។ *(សូមលាតសន្ធឹងដៃឡើងផុតក្បាល)*

រូបភាព សូមបង្ហាញរូបភាពម្តងទៀត ហើយសូមចង្អុលទៅកុមារតូចដែលកំពុងលេងជាមួយនឹងឱពុកនាង ។ សូមប្រាប់កុមារថា កុមារនេះ មានទំហំប្រហែលនឹងពួកគេ ។ សូមសួរកុមារនូវសំណួរស្រដៀងគ្នាទៅនឹងសំណួរទាំងឡាយដែលសរសេរនៅខាងក្រោម ។ បន្ទាប់ពីសួរសំណួរនីមួយៗរួច សូមអញ្ជើញកុមារឲ្យឆ្លើយតបជាមួយនឹងអ្នក ដោយឆ្លើយថា « បាទ » នៅពេលអ្នកងក់ក្បាលតាមរបៀបបំផ្លើស ។

- តើអ្នកអាចដើរបានឬទេ ? *(សូមឲ្យកុមារដើរនៅនឹងកន្លែង)*
- តើអ្នកអាចនិយាយបានឬទេ ? *(សូមរាប់ដល់ប្រាំជាមួយកុមារ)*
- តើអ្នកអាចបោះបាល់បានឬទេ ? *(សូមឲ្យកុមារធ្វើជាបោះបាល់ ហើយចាប់វា)*

សូមប្រាប់កុមារថា ពួកគេកំពុងធំឡើងហើយ ដោយសារតែពួកគេបរិភោគអាហារល្អៗ ចូលគេង ហើយលាងសម្អាតខ្លួនប្រាណរបស់ពួកគេបានស្អាត ។

ការសម្តែង សូមបង្ហាញរូបភាពនៅទំព័រ 47 ។ សូមចង្អុលរូបភាពក្មេងស្រីកំពុងគេង ហើយពន្យល់ថា ការគេងគឺជារបៀបមួយដើម្បីមើលថែរូបកាយរបស់យើង ។ សូមអញ្ជើញកុមារឲ្យធ្វើដូចជាគេង ។ សូមធ្វើសារឡើងវិញសម្រាប់រូបភាពផ្សេងទៀតនៅក្នុងរូបភាពនេះ ។

សេចក្តីបញ្ចប់ សូមសម្តែងនូវការដឹងគុណរបស់អ្នកចំពោះរូបកាយ ដែលព្រះវរបិតាសួគ៌បានប្រទានឲ្យយើង ។ សូមអញ្ជើញកុមារឲ្យនិយាយថា « ខ្ញុំនឹងមើលថែរូបកាយរបស់ខ្ញុំ » ជាពាក្យពីរបីម៉ាត់ម្តង ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់ល្បែងទាយ ៖* សូមនាំយកអាហារដែលមានជីវជាតិបី ឬ បួនមុខដូចជា ផ្លែឈើ និង បន្លែ ដាក់នៅលើចានមួយ ។ សូមយកក្រណាត់ធំមួយផ្ទាំងមកគ្របពីលើចានអាហារនោះ ។

សម្រាប់សកម្មភាពជាត់ពណ៌ ៖ សូមថតចម្លងរូបភាពនៅទំព័រ 47 សម្រាប់កុមារម្នាក់ៗ ជាត់ពណ៌ ។

ល្បែងទាយ សូមបង្ហាញចានអាហារដល់កុមារ ។ សូមចង្អុលទៅចំណីមួយមុខៗ ហើយសូមឲ្យកុមារប្រាប់ឈ្មោះចំណីនោះ ។ សូមគ្របអាហារដោយក្រណាត់នោះ បន្ទាប់មកសូមដកយកចំណីមួយមុខចេញ ហើយដកក្រណាត់ចេញផងដែរ ។ សូមអញ្ជើញឲ្យកុមារទាយថា តើបាត់ចំណីអាហារមួយណា ។ សកម្មភាពនេះ មានប្រសិទ្ធភាពបំផុតសម្រាប់កុមារធំៗ ។

វគ្គសកម្មភាព សូមរៀបរាប់វគ្គសកម្មភាពដូចខាងក្រោម ហើយសូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ៖

ប្អូនតូចម្នាក់នេះ នឹងចូលគេង ។ *(សូមលើកម្រាមដៃមួយឡើង)*
គាត់ដាក់ក្បាលគេងលើខ្នើយ ។ *(សូមដាក់ម្រាមដៃនៅលើបាតដៃមួយទៀត)*
សូមរុំខ្លួនគាត់នឹងភួយយ៉ាងណែន *(សូមបិទដៃផ្គប់ពីលើម្រាមដៃ)*
ហើយនេះ គឺជារបៀបមួយដែលគាត់គេងរាល់យប់ ។
ព្រឹកឡើង គាត់បើកភ្នែកឡើង ។
រលាស់ភួយចេញ ។ *(សូមបើកដៃដើម្បីបង្ហាញម្រាមដៃ)*
មិនយូរប៉ុន្មាន គាត់ក៏បានក្រោកឡើង ហើយស្លៀកពាក់ ហើយចេញដំណើរទៅ *(សូមលើកម្រាមដៃឡើង)*
ត្រៀមខ្លួនដើម្បីញញឹម ធ្វើការ និង លេងកំសាន្ត ។

ការជាត់ពណ៌ សូមឲ្យកុមារតូចៗ ជាត់ពណ៌លើរូបភាពដែលថតចម្លងមកពីទំព័រ 47 ។ ខណៈពេលដែលពួកគេកំពុងជាត់ពណ៌ សូមចង្អុលទៅរូបភាព ដែលបង្ហាញពីរបៀបដែលយើងអាចមើលថែដល់រូបកាយរបស់យើង ។



គន្លឹះក្នុងការបង្រៀន

សកម្មភាពជម្រើស អនុញ្ញាតឲ្យអ្នកបំពេញតម្រូវការរបស់កុមារនៅក្នុងថ្នាក់ទារកដ្ឋានរបស់អ្នក ។ អ្នកអាចជ្រើសរើសធ្វើសកម្មភាពណាមួយ ឬ ធ្វើទាំងអស់ ហើយអ្នកអាចធ្វើវាសារឡើងវិញឲ្យបានញឹកញាប់តាមតែអ្នកចង់ធ្វើ ។ សូមជ្រើសរើសសកម្មភាពដែលកុមារនឹងរីករាយធ្វើ ហើយដែលនឹងជួយពួកគេរៀន ។ អ្នកអាចសម្របសកម្មភាពទៅតាមស្ថានភាព និង តាមតម្រូវការរបស់អ្នកដោយសេរី ។

ការជាត់ពណ៌ ៖ កុមារទាំងអស់ពុំមែនសុទ្ធតែរីករាយនឹងការជាត់ពណ៌នោះទេ ។ កុមារមួយចំនួនអាចគួរតែមួយ ឬ ពីរគំនូសនៅលើទំព័រគំនូរតែប៉ុណ្ណោះ ។ ពួកគេនៅតែអាចរៀនមកពីគំនូរទោះបីជាពួកគេពុំចំណាយពេលច្រើនជាត់ពណ៌លើវាក្តី ។

ខ្ញុំនឹងមើលថែរូបកាយរបស់ខ្ញុំ



11 ខ្ញុំស្រឡាញ់គ្រួសារខ្ញុំ

គន្លឹះក្នុងការបង្រៀន

រូបភាព ៖ បើអ្នកពុំមានម៉ាស៊ីនចតចម្លង សូមដាក់ក្រដាស ស ពីលើរូបភាព ហើយដានរូបវាន៏ងខ្មៅដៃ ឬ ប៊ិច ។ សូមកុំព្រួយបារម្ភអំពីការដានរូបភាពឲ្យបានលម្អិតឡើយ គ្រាន់តែដានគ្រោង។ គ្រប់គ្រាន់ដើម្បីឲ្យស្គាល់រូបភាពបានហើយ ។

សូមរក្សារូបភាពទាំងនេះដើម្បីប្រើក្នុងមេរៀនក្រោយ។ ទៀត (ដូចជាមេរៀនទី 13) ។ អ្នកក៏អាចប្រើរូបនេះ ដើម្បីរំឭកមេរៀននេះ នៅពេលណាក៏បានអំឡុងពេលច្នាក់ទារកដ្ឋាន ។

កំណត់ចំណាំ ៖ អំឡុងពេលមេរៀននេះ ចូរយល់អំពីស្ថានភាពក្នុងគេហដ្ឋាន និង ស្ថានភាពគ្រួសាររបស់កុមារទាំងឡាយ ។

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

គ្រួសារ គឺជាផ្នែកដ៏សំខាន់នៅក្នុងផែនការនៃសេចក្តីសង្គ្រោះ ។ ព្រះវរបិតាសួគ៌ បានស្ថាបនាក្រុមគ្រួសារឡើង ដើម្បីនាំសុភមង្គលដល់យើង ហើយរៀបចំយើងសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ។ នៅក្នុងគ្រួសារមួយ យើងអាចរៀនពីគោលការណ៍ត្រឹមត្រូវទាំងឡាយនៅក្នុងបរិយាកាសជាទីស្រឡាញ់ ។ វាសំខាន់ដែលសមាជិកគ្រួសារត្រូវស្រឡាញ់គ្នា ហើយមើលថែគ្នាទៅវិញទៅមក ។ យើងបង្ហាញសេចក្តីស្រឡាញ់របស់យើង តាមរយៈការធ្វើជាមនុស្សដែលមានប្រយោជន៍ និង ចេះគោរពកោតខ្លាច (សូមមើល អេភេសូរ 6:1–3) ។ បទគម្ពីរបង្រៀនយើងឲ្យ « មានចិត្តសប្បុរសនឹងគ្នាទៅវិញទៅមក [និង] មានចិត្តទន់សណ្តោស » (អេភេសូរ 4:32 ; ក៏សូមមើលផងដែរ « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1995 ទំព័រ 102) ។

ការរៀបចំខ្លួន

សូមដានរូប ឬ ចតចម្លងរូបភាពគ្រួសារនៅទំព័រ 51 ។ សូមជាត់ពណ៌លើរូបភាព តាមចំណូចិត្ត ។ សូមកាត់វាចេញ ហើយសូមដាក់បិទនៅលើប្រអប់មួយ ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

រូបភាព សូមបង្ហាញរូបភាពអំពីគ្រួសារដ៏រីករាយមួយនៅទំព័រ 50 ។ សូមប្រាប់កុមារថា ព្រះវរបិតាសួគ៌បានប្រទានក្រុមគ្រួសារដល់យើងម្នាក់ៗ ។ សូមពន្យល់ថា ក្រុមគ្រួសាររបស់យើង ស្រឡាញ់យើង ហើយយើងអាចបង្ហាញសេចក្តីស្រឡាញ់ចំពោះគ្រួសាររបស់យើង តាមរយៈការមានចិត្តល្អ និង ការចេះជួយគ្នា ។

ការសម្តែង សូមកាន់ប្រអប់ ហើយសុំឲ្យកុមារម្នាក់ជ្រើសរើសរូបភាពគ្រួសារមួយ ។ សូមប្រាប់កុមារថា នរណាខ្លះជាសមាជិកគ្រួសារ (ម្តាយ ឪពុក បងប្អូនប្រុស បងប្អូនស្រី ឬ ទារក) ហើយសូមឲ្យកុមារថាតាមអ្នក ។ សូមផ្តល់វិធីមួយ ដែលពួកគេអាចបង្ហាញក្តីស្រឡាញ់ចំពោះសមាជិកគ្រួសារ (តាមរយៈការទុកដាក់សម្ភារលេង ការចេះចែកចាយ ការញញឹម ជាដើម) ។ សូមអញ្ជើញកុមារឲ្យសម្តែងដូចជាធ្វើកាយវិការ ។ សូមធ្វើសកម្មភាពនេះឡើងវិញចំពោះរូបភាពគ្រួសារនីមួយៗ ។

ចម្រៀង សូមច្រៀង ឬ អានពាក្យក្នុងបទ « ក្រុមគ្រួសារីករាយ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 198) ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ។

ខ្ញុំស្រឡាញ់ម៉ាក់ ម៉ាក់ស្រឡាញ់ខ្ញុំ ។ *(សូមដាក់ដៃលើដើមទ្រូង)*
យើងស្រឡាញ់ប៉ា ប៉ាស្រឡាញ់យើង *(សូមងក់ក្បាលចុះឡើង)*
គាត់ស្រឡាញ់យើង អ្នកអាចឃើញ *(សូមត្រដាងដៃ)*
យើងគឺជាគ្រួសារដ៏រីករាយ ។ *(សូមឱបខ្លួនឯង)*

ខ្ញុំស្រឡាញ់បងស្រី គាត់ស្រឡាញ់ខ្ញុំ ។ *(សូមដាក់ដៃលើដើមទ្រូង)*
យើងស្រឡាញ់បងប្រុស គាត់ស្រឡាញ់យើង *(សូមងក់ក្បាលចុះឡើង)*
គាត់ស្រឡាញ់យើង អ្នកអាចឃើញ *(សូមត្រដាងដៃ)*
យើងគឺជាគ្រួសារដ៏រីករាយ ។ *(សូមឱបខ្លួនឯង)*

សេចក្តីបញ្ចប់ សូមលើកទឹកចិត្តកុមារឲ្យចេះស្រឡាញ់ និង មានសណ្តានចិត្តល្អចំពោះសមាជិកគ្រួសាររបស់ពួកគេ ។ សូមអញ្ជើញពួកគេឲ្យនិយាយថា « ខ្ញុំស្រឡាញ់គ្រួសារខ្ញុំ » ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់រឿង* ៖ សូមគូសចំណាំទំព័រ 18 នៅក្នុងសៀវភៅសិក្សានេះ ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។

សម្រាប់ប័ណ្ណប្រកាស ៖ សូមសួរឪពុកម្តាយរបស់កុមារថ្នាក់ទារកដ្ឋានម្នាក់ៗ សុំរូបថតតូចមួយ ដែលបង្ហាញពីកុមារ និង គ្រួសាររបស់គេ (ពួកគេអាចផ្តល់រូបថតនេះឲ្យហើយនៅពេលកុមារមកចូលរួមក្នុងថ្នាក់ទារកដ្ឋានជាលើកដំបូងនោះ សូមមើល ទំព័រ 7) ។ សូមភ្ជាប់រូបថតទៅនឹងផ្ទាំងប័ណ្ណប្រកាស ។ នៅពីខាងលើ សូមសរសេរថា « ខ្ញុំស្រឡាញ់គ្រួសារខ្ញុំ » ។

រឿង សូមបង្ហាញកុមារអំពីរូបភាពរបស់ព្រះយេស៊ូវ និង មាតារបស់ទ្រង់ (ទំព័រ 18) ។ សូមចង្អុលទៅរូបព្រះយេស៊ូវ ហើយសូមប្រាប់កុមារថា នេះគឺជារូបភាពមួយរបស់ព្រះយេស៊ូវពេលទ្រង់នៅតូច ។ សូមចង្អុលទៅ ម៉ារា ហើយនិយាយថា នេះគឺជារូបមាតារបស់ព្រះយេស៊ូវ ។ សូមពន្យល់ថា ព្រះយេស៊ូវ មានគ្រួសារមួយជាទីស្រឡាញ់ ដែលមើលថែទ្រង់យ៉ាងល្អ ពេលទ្រង់នៅតូច ហើយទ្រង់ស្រឡាញ់គ្រួសាររបស់ទ្រង់យ៉ាងខ្លាំង ។ សូមផ្តល់យោបល់អំពីរបៀបដែលកុមារ អាចបង្ហាញសេចក្តីស្រឡាញ់ចំពោះម្តាយរបស់ពួកគេ (ដោយការញញឹម ការជួយសម្អាត ការឱប ជាដើម) ។ សូមអញ្ជើញពួកគេឲ្យសម្តែងដូចជាធ្វើការណ៍ទាំងនោះ ។

ចម្រៀង សូមបន្ថែមពាក្យថ្មីទៅក្នុងចម្រៀង « សប្បាយធ្វើការ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 253) ដើម្បីបង្រៀនកុមារអំពីរបៀបខ្លះ ដែលពួកគេអាចបង្ហាញសេចក្តីស្រឡាញ់ចំពោះក្រុមគ្រួសារពួកគេ ។ ឧទាហរណ៍ សូមនិយាយទៅកាន់កុមារថា « ចូរបង្ហាញរបៀបដែលយើងអាចស្រឡាញ់បងស្រី » ។ សូមច្រៀងបទ « ចែកសម្ភារលេង គឺសប្បាយណាស់ » ហើយធ្វើសកម្មភាពសាមញ្ញៗ ។ ពាក្យផ្សេងទៀត ដែលអ្នកអាចប្រើគឺ « រៀបសម្ភារទុក គឺសប្បាយណាស់ » « សម្អាតបន្ទប់គេងគឺសប្បាយណាស់ » « មានស្នាមញញឹម គឺសប្បាយណាស់ » « ការជួយលោកប៉ា គឺសប្បាយណាស់ » ជាដើម ។

ប័ណ្ណប្រកាស សូមដាក់បង្ហាញប័ណ្ណដែលអ្នកបានរៀបចំ ។ សូមចង្អុលទៅរូបភាពមួយ ហើយនិយាយថា « នេះគឺជាគ្រួសាររបស់ [ឈ្មោះរបស់កុមារ] ។ នេះគឺជា [ឈ្មោះរបស់កុមារ] » ។ សូមធ្វើដដែលៗសម្រាប់កុមារម្នាក់ៗ ។ សូមគូសបញ្ជាក់ថា យើងទាំងអស់គ្នាមានក្រុមគ្រួសារដែលស្រឡាញ់យើង ហើយយើងស្រឡាញ់ពួកគាត់ ។ សូមដាក់បង្ហាញប័ណ្ណប្រកាសរាល់សប្តាហ៍ ហើយសូមអនុញ្ញាតឲ្យកុមារឆ្លើយសំណួរអំពីគ្រួសាររបស់ពួកគាត់ (« តើគ្រួសាររបស់ [ឈ្មោះរបស់កុមារ] នៅកន្លែងណា ? » « តើ [ឈ្មោះរបស់កុមារ] នៅកន្លែងណា ? » « តើប៉ានៅកន្លែងណា ? » ជាដើម) ។ សូមបន្ថែមរូបភាពទៅលើប័ណ្ណប្រកាស នៅពេលកុមារដទៃទៀតចូលរួមក្នុងថ្នាក់ទារកដ្ឋាន ។

គន្លឹះក្នុងការបង្រៀន

ការរៀបចំ ៖ ការរៀបចំដែលអ្នកធ្វើមុនពេលថ្នាក់ទារកដ្ឋានចាប់ផ្តើម នឹងអនុញ្ញាតឲ្យអ្នកផ្តោតការយកចិត្តទុកដាក់របស់អ្នកទៅលើកុមារ នៅពេលពួកគេមកដល់ថ្នាក់ ។ សូមស្វាគមន៍ពួកគេដោយស្នាមញញឹម ។ (សូមមើល *Teaching, No Greater Call* ទំព័រ 79) ។

ពាក្យផ្តួន ៖ វិធីសាស្ត្រក្នុងការបង្រៀនដ៏សំខាន់បំផុតមួយចំពោះកុមារដែលមានវ័យស្ថិតក្នុងថ្នាក់ទារកដ្ឋាន គឺពាក្យផ្តួន ។ កុមារចូលចិត្តស្តាប់ចម្រៀង និងរឿងដដែលៗម្តងហើយម្តងទៀត ។ សូមប្រើពាក្យដូចគ្នាគ្រប់ពេល ។

ខ្ញុំស្រឡាញ់គ្រួសារខ្ញុំ



12 ខ្ញុំអាចអធិស្ឋានជាមួយគ្រួសាររបស់ខ្ញុំ

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

ព្រះអង្គសង្គ្រោះមានព្រះបន្ទូលថា « ចូរអធិស្ឋាននៅក្នុងក្រុមគ្រួសាររួកដល់ព្រះវរបិតា ដោយនូវនាមយើងជានិច្ច ដើម្បីឲ្យ [គ្រួសារ] របស់អ្នកអាចបានពរ » (នីហ្វៃទី 3 18:21) ។ តាមរយៈការអធិស្ឋានជាមួយគ្នា នោះក្រុមគ្រួសារអាចខិតទៅកាន់តែជិតនឹងព្រះវរបិតាសួគ៌ និង ជិតស្និតជាមួយគ្នាទៅវិញទៅមក ហើយវានឹងអញ្ជើញព្រះវិញ្ញាណបរិសុទ្ធមកគង់ក្នុងគេហដ្ឋាន (សូមមើល គ. និង ស. 19:38) ។

ការរៀបចំខ្លួន

- សូមគូសចំណាំទំព័រ 106 នៅក្នុងសៀវភៅសិក្សានេះ ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។
- សូមយកព្រះគម្ពីរមរមនមកជាមួយ ។ សូមគូសចំណាំនីហ្វៃទី3 18:21ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។

សកម្មភាពក្នុងការបង្រៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

ចម្រៀង សូមអញ្ជើញកុមារឲ្យនិយាយពាក្យ « ការអធិស្ឋានជាគ្រួសារ » ពីរបីដង ។ សូមប្រាប់ពួកគេថា អ្នកនឹងរៀនច្រៀងបទអំពីការអធិស្ឋានជាគ្រួសារ ។ សូមឲ្យកុមារអង្គុយជារង្វង់ ហើយឲ្យគ្រប់គ្នាកាន់ដៃគ្នា ។ សូមច្រៀង ឬ អានពាក្យក្នុងបទ « ចូរអធិស្ឋានជាគ្រួសារ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 189) ហើយសូមជួយកុមារឲ្យធ្វើសកម្មភាពជាមួយអ្នក ៖

ចូរយើងប្រជុំគ្នាជារង្វង់ *(សូមដើរជុំវិញរង្វង់)*
ហើយលុតជង្គង់អធិស្ឋាន *(សូមឈប់ដើរ ហើយលុតជង្គង់ចុះ សូមឲ្យកុមារនិយាយពាក្យ « ចូរអធិស្ឋានជាគ្រួសារ » តាមអ្នក)*
អរព្រះគុណដល់ព្រះបិតា *(សូមឱបដៃ)*
សម្រាប់ព្រះពរទ្រង់ប្រទាន ។

រូបភាព សូមបង្ហាញរូបភាពការអធិស្ឋានជាគ្រួសារ (ទំព័រ 54) ។ សូមជួយកុមារឲ្យស្គាល់សមាជិកផ្សេងៗនៅក្នុងគ្រួសារ ហើយសូមចង្អុលបង្ហាញថា ពួកគេកំពុងតែលុតជង្គង់ចុះ ហើយឱបដៃរបស់ពួកគេ ឱនក្បាលរបស់ពួកគេចុះ ហើយបិទភ្នែករបស់ពួកគេ ។ សូមប្រាប់ពួកគេថា គ្រួសារនេះកំពុងតែអធិស្ឋានជាគ្រួសារ ។ សូមអញ្ជើញកុមារឲ្យនិយាយពាក្យ « ការអធិស្ឋានជាគ្រួសារ » ។ សូមអញ្ជើញកុមារឲ្យលុតជង្គង់ចុះ ឱបដៃ ហើយឱនក្បាលចុះ ។ សូមពន្យល់ថា នៅពេលយើងមានការអធិស្ឋានជាគ្រួសារ នោះយើងកំពុងនិយាយទៅកាន់ព្រះវរបិតាសួគ៌ ។ យើងថ្លែងអំណរគុណទ្រង់ចំពោះពរជ័យទាំងឡាយរបស់យើង ហើយយើងសុំទ្រង់ឲ្យជួយ និង ប្រទានពរដល់គ្រួសាររបស់យើង ។

វគ្គសកម្មភាព សូមរៀបរាប់វគ្គសកម្មភាពដូចខាងក្រោម ហើយសូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ៖

នេះគឺជាម៉ាក់របស់ខ្ញុំ ដែលជួយខ្ញុំពេលលេង ។ *(សូមលើកមេដៃឡើង)*
នេះគឺជាប៉ារបស់ខ្ញុំ ដែលធ្វើការពេញមួយថ្ងៃ ។ *(សូមលើកម្រាមដៃទីពីរឡើង)*
នេះគឺជាបងប្រុសដ៏ខ្លាំង ហើយខ្ពស់របស់ខ្ញុំ ។ *(សូមលើកម្រាមដៃទីបីឡើង)*
នេះគឺជាបងស្រីរបស់ខ្ញុំ ដែលចូលចិត្តលេងបាល់ ។*(សូមលើកម្រាមដៃទីបួនឡើង)*
ហើយនេះ គឺជារូបខ្ញុំ ខ្ញុំចូលចិត្តនិយាយ *(សូមលើកម្រាមដៃទីប្រាំឡើង)*
គ្រួសាររបស់យើងលុតជង្គង់ចុះជាមួយគ្នាអធិស្ឋាន ។ *(សូមភ្ជាប់ដៃ)*

បទគម្ពីរ សូមបង្ហាញរូបភាពព្រះយេស៊ូវគ្រីស្ទនៅទំព័រ 106 ។ សូមបើកព្រះគម្ពីរមរមនទៅ នីហ្វៃទី 3 18:21 ហើយសូមនិយាយថា « ព្រះយេស៊ូវ មានព្រះបន្ទូលថា ‹ អធិស្ឋាននៅក្នុងក្រុមគ្រួសារ

គន្លឹះក្នុងការបង្រៀន

ចម្រៀង ៖ ដើម្បីបង្រៀនចម្រៀងមួយបទ ឬ វគ្គសកម្មភាពមួយ សូមទន្ទេញពាក្យ និង សកម្មភាពទាំងនោះឲ្យចាំជាមុនសិន ។ នៅពេលអ្នកប្រើ ឬរៀបរាប់ពាក្យ សូមសង្កត់ធ្ងន់លើពាក្យ និងសកម្មភាពនីមួយ។ ។ អ្នកអាចបន្ថែមសកម្មភាពសាមញ្ញដ៏សមរម្យនានាទៅក្នុងចម្រៀងណាមួយ ឬវគ្គណាមួយ ដើម្បីជួយរក្សាឲ្យកុមារផ្តោតការយកចិត្តទុកដាក់ និង ពង្រីកបន្ថែមនូវការបៀនសូត្រ ។ (សូមមើល *Teaching, No Greater Call* ទំព័រ 159) ។

កុមារតូច។ មានពេលយកចិត្តទុកដាក់ខ្លីណាស់ ។ ប៉ើកុមារមានភាពរសាប់រសល់ មុនពេលអ្នកបញ្ចប់គ្រប់សកម្មភាពនានា អ្នកអាចបញ្ចប់មេរៀន ដើម្បីឲ្យកុមារអាចក្រោកឈរ ហើយធ្វើចលនា រួចត្រឡប់មករៀនមេរៀននៅពេលក្រោយបាន ។

បទគម្ពីរ ៖ សូមប្រើបទគម្ពីរនៅពេលអ្នកបង្រៀនកុមារ និងនៅពេលអ្នករៀបចំមេរៀន ។ ការធ្វើដូច្នេះ វានឹងអញ្ជើញព្រះវិញ្ញាណ ហើយជួយកុមារឲ្យអភិវឌ្ឍសេចក្តីស្រឡាញ់ចំពោះព្រះបន្ទូលនៃព្រះ ។ សូមបង្ហាញពួកគេថា អ្វីដែលអ្នកកំពុងបង្រៀនពួកគេ គឺចេញមកពីព្រះគម្ពីរ ។

របស់អ្នក ។ » សូមអញ្ជើញកុមារឲ្យនិយាយប្រយោគនេះសារឡើងវិញជាមួយអ្នក ជាពាក្យពីរបីម៉ាត់ម្តង ។

សេចក្តីបញ្ចប់ សូមអញ្ជើញកុមារឲ្យនិយាយថា « ខ្ញុំអាចអធិស្ឋានជាមួយគ្រួសាររបស់ខ្ញុំ » ដោយនិយាយពីរបីម៉ាត់ម្តង ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់រឿងតុក្កតាអាយ៉ងដែលប្រើម្រាមដៃ ៖* សូមថតចម្លង ហើយកាត់តុក្កតាអាយ៉ងដែលប្រើម្រាមដៃចេញមកពីទំព័រ 59 ។ សូមជាត់ពណ៌តាមចំណូចិត្ត ។

សម្រាប់ល្បែងថង់ ៖ សូមបើកថង់តូចៗចំនួនបួន « យើងមានអំណរគុណចំពោះពរជ័យទាំងឡាយរបស់យើង » ។ នៅក្នុងថង់នីមួយៗ សូមដាក់រូបភាពមួយអំពីអ្វីដែលយើងមានអំណរគុណ (ដូចជា អាហារ សម្លៀកបំពាក់ គេហដ្ឋាន និង គ្រួសារ ជាដើម) ។ បើអ្នកចង់ អ្នកអាចប្រើរូបភាពដែលថតចម្លងចេញមកពីទំព័រ 55 ឬ កន្លែងផ្សេងទៀតនៅក្នុងសៀវភៅសិក្សានេះ ។

សម្រាប់សកម្មភាពជាត់ពណ៌ ៖ សូមថតចម្លងរូបភាពនៅទំព័រ 55 សម្រាប់កុមារម្នាក់ៗជាត់ពណ៌ ។ សូមយកកន្ត្រៃ និង បង់ស្អិតមកជាមួយ ។

រឿងតុក្កតាអាយ៉ងដែលប្រើម្រាមដៃ សូមប្រើតុក្កតាអាយ៉ងដែលប្រើម្រាមដៃ ដើម្បីប្រាប់រឿងដូចខាងក្រោមអំពីការអធិស្ឋានជាគ្រួសារ ៖



នេះគឺជាគ្រួសារមួយ ។ នេះគឺជាឪពុក ហើយនេះគឺជាម្តាយ ។ នេះគឺជាបងស្រី ហើយនេះគឺជាបងប្រុស ។ នេះគឺជាពេត្រុស ជាប្អូនប្រុសតូច *(សូមចង្អុលទៅតុក្កតាអាយ៉ងដែលជាទារកតូច)* មានថ្ងៃមួយ ពេត្រុសបានលេង ហើយប៉ះត្រូវភ្នែករបស់គាត់ឈឺ *(សូមអញ្ជើញកុមារឲ្យយកដៃរបស់ពួកគេបិទភ្នែក)* ។ ឪពុក និង ម្តាយនាំគាត់ទៅជួបវេជ្ជបណ្ឌិត *(សូមដកតុក្កតាអាយ៉ងចេញពីម្រាមដៃ ហើយដាក់ផ្តេកទៅលើឥដ្ឋ)* ។ គ្រួសាររបស់ពេត្រុសបានលុតជង្គង់ចុះអធិស្ឋានជាគ្រួសារ *(សូមអញ្ជើញកុមារឲ្យលុតជង្គង់)* ។ ពួកគេបានសុំដល់ព្រះវរបិតាសួគ៌ឲ្យប្រទានពរដល់ពេត្រុស ។ ព្រះវរបិតាសួគ៌ បានស្តាប់ឮការអធិស្ឋានរបស់ពួកគេ ។ ទ្រង់បានជួយពេត្រុសឲ្យជាសះស្បើយ *(សូមពាក់តុក្កតាអាយ៉ងទៅលើម្រាមដៃវិញ)* ។ បន្ទាប់មក ពេត្រុស និង គ្រួសាររបស់គាត់ ធ្វើការអធិស្ឋានជាគ្រួសារម្តងទៀត ដើម្បីអរព្រះគុណដល់ព្រះវរបិតាសួគ៌ ចំពោះការប្រទានពរដល់ពេត្រុស ។

ល្បែងថង់ សូមដាក់ថង់នៅលើឥដ្ឋ ។ សូមឲ្យកុមារគ្រប់គ្នាកាន់ដៃគ្នា ធ្វើជារង្វង់នៅជុំវិញថង់ ហើយដើរជារង្វង់ នៅពេលអ្នកច្រៀងបទ « ការអធិស្ឋានជាគ្រួសារ » ។ បន្ទាប់មក សូមឈប់ដើរ ហើយសូមឲ្យកុមារជ្រើសរើសថង់មួយ រួចបង្ហាញរូបភាពនៅខាងក្នុង ។ សូមនិយាយថា « យើងអរគុណចំពោះ [ឈ្មោះវត្ថុក្នុងរូបភាព] » ។ សូមសរសើរកុមារចំពោះការចូលរួមរបស់ពួកគេ ។ សូមធ្វើសារឡើងវិញរហូតដល់កុមារម្នាក់ៗ ដៃលចាំដល់វេនរបស់ខ្លួនបានធ្វើម្តង ។

ការជាត់ពណ៌ សូមឲ្យកុមារជាត់ពណ៌លើរូបភាពដែលថតចម្លងមកពីទំព័រ 55 ។ នៅពេលពួកគេបញ្ចប់ សូមកាត់វាជាបន្ទះ ហើយភ្ជាប់វាជាមួយគ្នាដោយបិទបង់ស្អិត ដើម្បីធ្វើជាទ្រវ៉ាក់សម្រាប់កុមារម្នាក់ៗយកទៅផ្ទះ ។



គន្លឹះក្នុងការបង្រៀន

តុក្កតាអាយ៉ង ៖ « តុក្កតាអាយ៉ងអាចប្រើដើម្បីសម្តែងជាល្ខោនក្នុងថ្នែកខ្លះនៃមេរៀន ឬ រឿងមួយ ដើម្បីស្វាគមន៍ដល់កុមារក្នុងថ្នាក់ ដើម្បីផ្តល់ជាការណែនាំដើម្បីច្រៀងចម្រៀង ជួយក្នុងការសម្តែង សួរសំណួរ ឬ ជួយកុមារឲ្យបន្តយកចិត្តទុកដាក់ » (*Teaching, No Greater Call* ទំព័រ 176–77) ។

ល្បែងថង់ ៖ បើអ្នកពុំមានថង់ ឬ ស្បោងទេ អ្នកអាចដាក់រូបភាពផ្កាប់ចុះក្រោម ហើយឲ្យកុមារម្នាក់ជ្រើសរើសយកមួយ ហើយមើកវាឡើង ។

កំណត់ចំណាំ ៖ សូមដាក់កន្ត្រៃ និង វត្ថុដែលអាចមានគ្រោះថ្នាក់ខ្លាំងដទៃទៀត ឲ្យផុតពីភ្នែកកុមារ ហើយសូមកុំឲ្យពួកគេយកបាន ។

之典
李福子
聚蘇之本

ខ្ញុំអាចអធិស្ឋានជាមួយគ្រួសាររបស់ខ្ញុំ



យើងមានអំណរគុណចំពោះក្រុមគ្រួសារយើង ។



យើងមានអំណរគុណចំពោះគេហដ្ឋានរបស់យើង ។



យើងមានអំណរគុណចំពោះអាហារសម្រាប់បរិភោគ ។

យើងមានអំណរគុណចំពោះសម្លៀកបំពាក់របស់យើង ។

13 គ្រួសារខ្ញុំ អាចរស់នៅជាមួយគ្នាជានិរន្តរ៍

គន្លឹះក្នុងការបង្រៀន

កំណត់ចំណាំ ៖ សូមយល់អំពីស្ថានភាពគ្រួសារ និង ស្ថានភាពផ្ទះរបស់កុមារ អំឡុងពេលបង្រៀនមេរៀននេះ ។

ចម្រៀង ៖ សូមពិចារណាអំពីការធ្វើបញ្ជីចម្រៀង ដែលកុមារចូលចិត្តច្រៀង ហើយច្រៀងវាជារៀងរាល់សប្តាហ៍ នៅពេលផ្សេងៗគ្នា អំឡុងពេលថ្នាក់ទាក់ដ្ឋាននេះ ។ ឧទាហរណ៍ អ្នកអាចច្រៀងខណៈពេលដែលកុមារកំពុងលេង មុនពេល ឬ បន្ទាប់ពីបរិភោគអាហារសម្រន់ ឬ ខណៈពេលដែលកុមារកំពុងរង់ចាំឪពុកម្តាយរបស់ពួកគេ ។ នេះគឺជាវិធីដ៏ល្អមួយ ដើម្បីរំឭកមេរៀនមុនៗ ។

សេចក្តីបញ្ចប់ ៖ សេចក្តីបញ្ចប់នេះ អាចនឹងខ្លីបំផុត ឧទាហរណ៍ ៖ « ខ្ញុំស្រឡាញ់ព្រះវិហារបរិសុទ្ធ ! » ។ ខ្ញុំដឹងថា ក្រុមគ្រួសារអាចរស់នៅជាមួយគ្នាជានិរន្តរ៍ » ។

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

ព្រះវរបិតាសួគ៌ បានធ្វើឲ្យទំនាក់ទំនងគ្រួសារបន្តមានក្រោយពីជីវិតនេះទៀត ។ បើសមាជិកគ្រួសារ ត្រូវបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ហើយរក្សាបទបញ្ញត្តិទាំងឡាយយ៉ាងស្មោះត្រង់ នោះពួកគេនឹងរួបរួមគ្នាជាគ្រួសារដ៏នៅអស់កល្បជានិច្ចមួយ ហើយរស់នៅក្នុងវត្តមានរបស់ព្រះវរបិតាសួគ៌ ។ (សូមមើល ម៉ាថាយ 16:19 ; គ. និង ស. 138:47–48) ។

ការរៀបចំខ្លួន

បើអាចធ្វើទៅបាន សូមយក រូបភាពនៃព្រះវិហារបរិសុទ្ធ ដែលនៅក្នុងតំបន់របស់អ្នកមក ។

សកម្មភាពក្នុងការបង្រៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

រូបភាព សូមបង្ហាញរូបភាពនៃព្រះវិហារបរិសុទ្ធនៅក្នុងតំបន់របស់អ្នក (ឬ បង្ហាញរូបភាពនៅទំព័រ 58) ។ សូមប្រាប់កុមារថា នេះគឺជារូបភាពមួយនៃព្រះវិហារបរិសុទ្ធ ។ សូមពិពណ៌នាអំពីរូបភាពដល់ពួកគេ ដោយចង្អុលទៅកំពូល បង្អួច និង ទ្វារ ជាដើម ។ ចូរសុំពួកគេឲ្យនិយាយពាក្យ « ព្រះវិហារបរិសុទ្ធ » ពីរបីដង ។ សូមឲ្យពួកគេសម្តែងធ្វើជាព្រះវិហារបរិសុទ្ធដ៏ស្រស់ស្អាតមួយ ដោយការដាក់ដៃរបស់ពួកគេផ្គុំគ្នាពីលើក្បាលដើម្បីធ្វើជាកំពូលព្រះវិហារបរិសុទ្ធ ។

ចម្រៀង សូមអញ្ជើញកុមារឲ្យក្រោកឈរ ។ សូមច្រៀង ឬ អានពាក្យក្នុងបទ « ខ្ញុំចូលចិត្តមើលព្រះវិហារបរិសុទ្ធ » *សៀវភៅចម្រៀងកុមារ* ទំព័រ 95) ហើយសូមធ្វើកាយវិការដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ។

ខ្ញុំចូលចិត្តវិហារបរិសុទ្ធ ។ *(សូមដាក់ម្រាមដៃផ្គុំគ្នាធ្វើជាកំពូលស្រួច)*
ខ្ញុំទៅនឹងទីនោះថ្ងៃមួយ *(សូមដើរនៅមួយកន្លែង)*
ដើម្បីទទួលព្រះវិញ្ញាណ *(សូមដាក់ដៃលើដើមទ្រូង)*
ទៅស្តាប់ និង អធិស្ឋាន ។ *(សូមឱបដៃ)*

សូមប្រាប់កុមារថា ព្រះវិហារបរិសុទ្ធ គឺជាដំណាក់របស់ព្រះអម្ចាស់ ។ សូមអញ្ជើញឲ្យពួកគេនិយាយថា « ដំណាក់របស់ព្រះអម្ចាស់ » ។ សូមគូសបញ្ជាក់ថា ព្រះវិហារបរិសុទ្ធ គឺជាកន្លែងដ៏ពិសេសមួយ ដោយសារព្រះវិហារបរិសុទ្ធ នោះក្រុមគ្រួសាររបស់យើងអាចរស់នៅជាមួយគ្នាជានិរន្តរ៍ ។

វគ្គសកម្មភាព សូមរៀបរាប់វគ្គសកម្មភាពដូចខាងក្រោម ហើយសូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ៖

នេះគឺជាម្តាយ ។ *(សូមលើកដៃឡើង ហើយចង្អុលទៅមេដៃ)*
នេះគឺជាឪពុក ។ *(សូមចង្អុលទៅម្រាមដៃចង្អុល)*
នេះគឺជាបងប្រុសខ្ពស់ ។ *(សូមចង្អុលទៅម្រាមដៃកណ្តាល)*
នេះគឺជាបងស្រី ។ *(សូមចង្អុលទៅម្រាមដៃនាង)*
នេះគឺជាទារកតូច ។ *(សូមចង្អុលទៅម្រាមកូនដៃ)*
ឱ ! យើងស្រឡាញ់ពួកគាត់ទាំងអស់គ្នា ។ *(សូមដាក់ដៃទាំងពីរលើដើមទ្រូង)*

ចម្រៀង សូមច្រៀង ឬ អានបន្ទាត់ទីពីរនៃវគ្គបន្តក្នុងបទ « ក្រុមគ្រួសារអាចនៅជាមួយគ្នាជានិរន្តរ៍ » *សៀវភៅចម្រៀងកុមារ* ទំព័រ 188) ៖

ក្រុមគ្រួសារអាចនៅជាមួយគ្នាជានិរន្តរ៍
តាមផែនការព្រះបិតា ។

សូមអញ្ជើញកុមារឲ្យថាតាមពាក្យទាំងនេះជាមួយអ្នកឲ្យបានច្រើនដង ដោយយឺតៗ ។

សេចក្តីបញ្ចប់ សូមចែកចាយអារម្មណ៍របស់អ្នកដោយសង្ខេបអំពីព្រះវិហារបរិសុទ្ធ ។ សូមចែកចាយទីបន្ទាល់របស់អ្នកថា ក្រុមគ្រួសារអាចនៅជាមួយគ្នាជានិរន្តរ៍ ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់វគ្គសកម្មភាព ៖* សូមថតចម្លង ហើយកាត់តុក្កតាអាយ៉ងដែលប្រើម្រាមដៃចេញមកពីទំព័រ 59 ឬ ប្រើតុក្កតាអាយ៉ងដែលប្រើម្រាមដៃ ដែលអ្នកធ្វើសម្រាប់សកម្មភាពជម្រើសនៅក្នុងមេរៀនទី 12 ។ សូមជាត់ពណ៌តុក្កតាអាយ៉ងដែលប្រើម្រាមដៃ តាមចំណូចិត្ត ។

សម្រាប់ល្បែងទាយ ៖ សូមថតចម្លង ហើយសូមកាត់រូបក្រុមគ្រួសារនៅទំព័រ 51 ឬ ប្រើរូបភាព ដែលអ្នកបានរៀបចំសម្រាប់មេរៀនទី 11 ។ សូមយកភួយ ឬ ក្រណាត់មកបាំងរូបភាព ។ បើអាចធ្វើទៅបាន សូមយករូបភាពព្រះវិហារបរិសុទ្ធនៅក្នុងតំបន់អ្នកមកជាមួយ ។

សម្រាប់សកម្មភាពជាត់ពណ៌ ៖ សូមថតចម្លង ហើយកាត់រង្វង់នៅទំព័រ 59 សម្រាប់កុមារម្នាក់ៗ ។ សូមដោតខ្សែ ឬ អំបោះតាមប្រឡោះរង្វង់ទាំងពីរ ដើម្បីធ្វើជាខ្សែក ។

សកម្មភាពដែលប្រើម្រាមដៃ សូមប្រាប់កុមារថា យើងត្រូវតែរៀបចំខ្លួនដើម្បីទៅព្រះវិហារបរិសុទ្ធ ។ សូមឲ្យពួកគេលើកម្រាមដៃប្រាំឡើង ហើយសូមជួយពួកគេរៀបរាប់នៅលើម្រាមដៃរបស់ពួកគេនូវរឿងប្រាំយ៉ាង ដែលពួកគេអាចធ្វើដើម្បីរៀបចំខ្លួនទៅព្រះវិហារបរិសុទ្ធ នៅពេលពួកគេធំឡើង (អធិស្ឋាន, គោរពឪពុកម្តាយ, ស្រឡាញ់អ្នកដទៃ, ទៅព្រះវិហារ និង ធ្វើតាមព្យាការី ជាដើម) ។ ជាពិសេស សកម្មភាពនេះសមរម្យសម្រាប់កុមារធំៗ ។

វគ្គសកម្មភាព សូមធ្វើវគ្គសកម្មភាពនៅទំព័រ 56 សារឡើងវិញ ដោយម្តងនេះ សូមប្រើតុក្កតាអាយ៉ងដែលប្រើម្រាមដៃ ។

ល្បែងទាយ សូមដាក់រូបភាពគ្រួសារនៅលើតុដ្ឋ បន្ទាប់ពីរូបភាពព្រះវិហារបរិសុទ្ធ (រូបភាពមួយដែលអ្នកបានយកមក ឬ រូបភាពមួយនៅទំព័រ 58) ។ សូមបាំងរូបភាពដោយភួយ ឬ ដោយក្រណាត់ ។ សូមដករូបភាពតុក្កតាអាយ៉ងដែលប្រើម្រាមដៃមួយចេញ ។ សូមបើកក្រណាត់នោះចេញ ហើយសូមឲ្យកុមារទាយពីអ្វីដែលបានបាត់ ។ បន្ទាប់មក សូមដាក់រូបភាពដែលបាត់ត្រឡប់មកកន្លែងដើមវិញ ហើយប្រាប់កុមារថា ព្រះវរបិតាសូគ៌ចង់ឲ្យក្រុមគ្រួសារទាំងអស់នៅជាមួយគ្នាជានិរន្តរ៍ ដោយគ្មានបាត់នរណាម្នាក់ឡើយ ។ សកម្មភាពនេះសមរម្យសម្រាប់កុមារធំៗជាពិសេស។

ការជាត់ពណ៌ សូមអញ្ជើញកុមារឲ្យជាត់ពណ៌ខ្សែក ដែលអ្នកបានរៀបចំ ។ ខណៈពេលដែលពួកគេកំពុងជាត់ពណ៌ សូមគូសបញ្ជាក់បន្ថែមអំពីគោលការណ៍ទាំងឡាយថា ដោយសារមានព្រះវិហារបរិសុទ្ធ នោះក្រុមគ្រួសារអាចនៅជាមួយគ្នាជានិរន្តរ៍ ។



គន្លឹះក្នុងការបង្រៀន

តុក្កតាអាយ៉ងដែលប្រើម្រាមដៃ ៖ វាជាគំនិតល្អមួយ ដើម្បីរក្សាទុករូបភាពទាំងឡាយ តុក្កតាអាយ៉ងដែលប្រើម្រាមដៃ ល្បែងកំសាន្ត និង វត្ថុផ្សេងៗទៀត ដែលអ្នកបានរៀបចំសម្រាប់មេរៀនទាំងនេះ ។ អ្នកអាចប្រើវានៅក្នុងមេរៀនក្រោយ។ ឬ នៅពេលណាក៏បាន អំឡុងថ្នាក់ទារកដ្ឋានដើម្បីរំឭកអំពីគោលការណ៍ទាំងឡាយដែលអ្នកបានបង្រៀនកាលពីមុន ។

ការជាត់ពណ៌ ៖ សូមលើកទឹកចិត្តដល់កុមារឲ្យបង្ហាញខ្សែករបស់ពួកគេទៅដល់ក្រុមគ្រួសាររបស់ពួកគេ ។ ការធ្វើដូច្នេះ អាចជួយពួកគេឲ្យចងចាំអំពីអ្វីដែលពួកគេបានរៀន ហើយភាជ្ជល់ឱកាសមួយដល់ឪពុកម្តាយរបស់ពួកគេឲ្យពិភាក្សាអំពីគោលការណ៍ទាំងឡាយនៃមេរៀនជាមួយពួកគេ ។ (សូមមើល *Teaching, No Greater Call* ទំព័រ 167) ។

សូមថតចម្លងទំព័រនេះ ហើយសូមកាត់តុក្កតាអាយ៉ងដែលប្រើម្រាមដៃតាមបន្ទាត់ត្រង់នេះ ។ សូមបត់តាមចំណុចចុចៗ ។ បន្ទាប់មក សូមបិទគែមៗ ដោយទុកគែមខាងក្រោមចំហរ ដើម្បីឲ្យកុមារអាចដាក់ម្រាមដៃចូលទៅក្នុងតុក្កតាអាយ៉ងនោះ ។



14 ខ្ញុំនឹងគោរពតាម

គន្លឹះក្នុងការបង្រៀន

សេចក្តីស្រឡាញ់ ៖ ចូរព្យាយាមស្រឡាញ់កុមារនៅក្នុងថ្នាក់ទារកដ្ឋានទាំងអស់ ។ « នៅពេលយើងស្រឡាញ់អ្នកទាំងឡាយដែលយើងបង្រៀន នោះយើងអធិស្ឋានសម្រាប់ពួកគេម្នាក់។ ។ . . . យើងមត់បែនការបង្រៀនរបស់យើងដើម្បីបំពេញតម្រូវការរបស់ពួកគេ ទោះជាការធ្វើដូច្នេះចំណាយពេលច្រើន និង ទាមទារការខិតខំខ្លាំងក៏ដោយ ។ យើងត្រូវកត់សម្គាល់នៅពេលពួកគេអវត្តមាន ហើយត្រូវដឹងនៅពេលពួកគេមានវត្តមាន ។ យើងផ្តល់ជំនួយនៅពេលត្រូវការ » (*Teaching, No Greater Call* ទំព័រ 32) ។

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

ព្រះវរបិតាសួគ៌ បានផ្តល់ការទទួលខុសត្រូវជាចម្បងដល់ឪពុកម្តាយ ដើម្បីបង្រៀនកូនៗរបស់ពួកគេអំពី បទបញ្ញត្តិទាំងឡាយ ផ្តល់តម្រូវការខាងសាច់ឈាម និង ខាងវិញ្ញាណដល់ពួកគេ ហើយនឹងការពារពួកគេពីភាពអន្តរាយ ។ ទ្រង់លើកទឹកចិត្តយើងឲ្យគោរព និង ប្រតិបត្តិចំពោះឪពុកម្តាយរបស់យើង នោះទ្រង់នឹងប្រទានពរដល់យើងឲ្យមានសុវត្ថិភាព និង សុភមង្គលនៅពេលយើងធ្វើដូច្នោះ ។ (សូមមើល និក្ខមនំ 20:12 ; អេភេសូរ 6:1–3 ; កូល៉ុស 3:20 ; « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *Ensign* ខែវិច្ឆិកា ឆ្នាំ 1995 ទំព័រ 102) ។

ការរៀបចំខ្លួន

- សូមយកព្រះគម្ពីរបរិសុទ្ធមកជាមួយ ។ សូមគូសចំណាំអេភេសូរ 6:1 ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។
- សូមគូសចំណាំទំព័រ 106 នៅក្នុងសៀវភៅសិក្សានេះ ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

សកម្មភាពទាំងឡាយ សូមឲ្យកុមារធ្វើនូវសកម្មភាពចំនួនប្រាំ ឬ ប្រាំមួយដូចជា ក្រោកឈរ លើកដៃ បង្វិលខ្លួន ទះដៃ និង អង្គុយចុះ ។ សូមសរសើរដល់ពួកគេចំពោះការធ្វើតាមអ្នក ។

រូបភាព សូមឲ្យកុមារម្នាក់កាន់រូបភាពនៅទំព័រ 62 ។ សូមចង្អុលទៅឪពុក និង ម្តាយនៅក្នុងរូបភាពនេះ ។ សូមពន្យល់ថា ឪពុក និង ម្តាយ បានសុំឲ្យកូនៗជួយកិច្ចការក្នុងសួនច្បារ ហើយកូនៗបាននិយាយថា « ខ្ញុំនឹងធ្វើតាម » ។ សូមចង្អុលទៅកុមារនៅក្នុងរូបភាព ហើយសូមគូសបញ្ជាក់ថា ពួកគេកំពុងជួយដល់ឪពុកម្តាយរបស់ពួកគេ ។

បទគម្ពីរ សូមប្រាប់កុមារថា នៅក្នុងបទគម្ពីរ យើងរៀនថា ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ចង់ឲ្យយើងគោរពឪពុកម្តាយរបស់យើង ។ សូមបើកព្រះគម្ពីរបរិសុទ្ធទៅ អេភេសូរ 6:1 ហើយអានថា « ក្មេងរាល់គ្នាអើយ ចូរស្តាប់បង្គាប់មាតាបិតាខ្លួនក្នុងព្រះអម្ចាស់ ត្បិតធ្វើដូច្នោះទើបបានត្រូវ » ។ សូមអញ្ជើញកុមារឲ្យនិយាយថា « ខ្ញុំនឹងគោរពតាម » ។ (*កំណត់ចំណាំ ៖* វាអាចនឹងមានកុមារមួយចំនួន ដែលត្រូវបានចិញ្ចឹមដោយជីដូនជីតា ឬ សាច់ញាតិដទៃទៀត ។ សូមយល់អំពីស្ថានភាពនេះ អំឡុងពេលបង្រៀនមេរៀន) ។

ចម្រៀង សូមអញ្ជើញកុមារឲ្យក្រោកឈរ ។ សូមច្រៀង ឬ អានពាក្យក្នុងបទ « ខ្ញុំនឹងឆាប់ធ្វើតាម » (*សៀវភៅចម្រៀងកុមារ* ទំព័រ 197) ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ។

ពេលខ្ញុំឮម៉ាក់ហៅខ្ញុំ (*សូមយកដៃផ្អប់មាត់*)
ខ្ញុំនឹងឆាប់ធ្វើតាម ។ (*សូមរត់ដោយស្ងាត់ស្ងៀមនៅមួយកន្លែង*)
ខ្ញុំចង់ធ្វើអ្វីឲ្យល្អបំផុត (*សូមងក់ក្បាលចុះឡើង*)
គ្រប់ពេលរៀងរាល់ថ្ងៃ ។

ពេលខ្ញុំឮប៉ាហៅខ្ញុំ (*សូមយកដៃផ្អប់មាត់*)
ខ្ញុំនឹងឆាប់ធ្វើតាម ។ (*សូមរត់ដោយស្ងាត់ស្ងៀមនៅមួយកន្លែង*)
ខ្ញុំចង់ធ្វើអ្វីឲ្យល្អបំផុត (*សូមងក់ក្បាលចុះឡើង*)
គ្រប់ពេលរៀងរាល់ថ្ងៃ ។

ព្រះវរបិតាសួគ៌ស្រឡាញ់ខ្ញុំ (*សូមឱបខ្លួនឯង*)
ប្រទានពររាល់ថ្ងៃ ។ (*សូមបន្តឱបខ្លួនឯង នៅពេលអ្នករវេទៅឆ្វេង ទៅស្តាំ*)

ខ្ញុំចង់ធ្វើអ្វីឲ្យល្អបំផុត *(សូមងក់ក្បាលចុះឡើង)*
គ្រប់ពេលរៀងរាល់ថ្ងៃ ។

រូបភាព សូមបង្ហាញរូបភាពព្រះយេស៊ូវ នៅទំព័រ 106 ។ សូមប្រាប់កុមារថា ព្រះយេស៊ូវបានគោរពព្រះវរបិតាសួគ៌ ហើយទ្រង់ចង់ឲ្យយើងគោរពផងដែរ ។

សេចក្តីបញ្ចប់ សូមចែកចាយទីបន្ទាល់របស់អ្នកថា យើងនឹងបានសប្បាយរីករាយ បើយើងគោរពតាម ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់សកម្មភាពវត្ថុ ៖* សូមយកប្រអប់មួយ កន្ត្រក ឬ ប្រអប់ផ្សេងទៀត ដែលមានវត្ថុមួយចំនួននៅខាងក្នុង ដែលផ្តល់ជាការការពារ ដូចជា ឆ័ត្រ ស្បែកជើង មួក អាវរងា ឬ ស្រោមដៃ ។ សូមព្យាយាមឲ្យកុមារម្នាក់ៗកាន់វត្ថុយ៉ាងតិចណាស់មួយម្នាក់ ។



សម្រាប់សកម្មភាពតុក្កតាអាយ៉ងដែលប្រើម្រាមដៃ ៖ សូមថតចម្លង ហើយសូមកាត់រូបភាពនៅទំព័រ 63 សម្រាប់កុមារម្នាក់ៗជាត់ពណ៌ ។ សូមបិទការ៉ូ ឬ បិទស្កុតរូបភាពជាប់នឹងឈើ ឬ ចង់ក្រដាសដើម្បីធ្វើជាតុក្កតាអាយ៉ង ។

ការសម្តែង សូមនិយាយ និង ធ្វើតាមដូចខាងក្រោមជាមួយនឹងកុមារ ៖
ម៉ាក់ និយាយថា « សូមទៅស្លៀកពាក់ខោអាវ » ។ ចូរស្លៀកពាក់ខោអាវ *(សូមធ្វើដូចជាស្លៀកពាក់ខោអាវ)* ។
ប៉ា និយាយថា « សូមកូនលុបមុខចេញ » ។ ចូរលុបមុខយើងចេញ *(សូមធ្វើដូចជាលុបមុខ)* ។
សូមធ្វើដដែលៗជាមួយនឹងសកម្មភាពដទៃទៀតដូចជា « បរិភោគអាហារពេលព្រឹក » និង « ចូលគេង » ជាដើម ។ សូមសរសើរកុមារចំពោះការគោរពតាម ។

សកម្មភាពវត្ថុ ចូរសុំឲ្យកុមារម្នាក់ជ្រើសរើសវត្ថុមួយចេញមកពីប្រអប់ ហើយប្រើវា ។ សូមនិយាយជាមួយកុមារអំពីប្រភេទនៃការការពារ ដែលវត្ថុនោះផ្តល់ឲ្យ (ឧទាហរណ៍ ស្បែកជើង ជួយធ្វើឲ្យជើងរបស់យើងកុំឲ្យប្រឡាក់ដី ឬ ឈឺ ហើយ ឆ័ត្រការពារយើងកុំឲ្យទទឹកទឹកភ្លៀង ឬ ការពារពីកំដៅព្រះអាទិត្យ ជាដើម) ។ សូមពន្យល់ថា វត្ថុទាំងនេះ ធ្វើឲ្យយើងឲ្យមានសុវត្ថិភាព យើងក៏អាចមានសុវត្ថិភាព ហើយរីករាយ នៅពេលយើងគោរពតាមឪពុកម្តាយរបស់យើងផងដែរ ។

សកម្មភាពតុក្កតាអាយ៉ង សូមឲ្យកុមារជាត់ពណ៌តុក្កតាអាយ៉ងដែលអ្នកបានរៀបចំ ។ សូមធ្វើតាមស្ថានភាពដូចខាងក្រោម (ឬ បង្កើតស្ថានភាពខ្លះៗដោយខ្លួនអ្នក) ។ បន្ទាប់ពីស្ថានភាពនីមួយៗចប់ ចូរឲ្យកុមារប្រើតុក្កតាអាយ៉ងរបស់ពួកគេឆ្លើយថា « ខ្ញុំនឹងគោរពតាម » ។
ម៉ាក់ និយាយថា « សូមមានចិត្តល្អចំពោះប្អូនស្រីរបស់អ្នក » ។ តើអ្នកនឹងនិយាយអ្វី ?
ប៉ា និយាយថា « ដល់ពេលចូលគេងហើយ » ។ តើអ្នកនឹងនិយាយអ្វី ?
លោកយាយ និយាយថា « មកបរិភោគអាហារពេលល្ងាច » ។ តើអ្នកនឹងនិយាយអ្វី ?
គ្រូបង្រៀន និយាយថា « សូមត្រៀមខ្លួនដើម្បីអធិស្ឋាន » ។ តើអ្នកនឹងនិយាយអ្វី ?
ព្រះយេស៊ូវ មានព្រះបន្ទូលថា « ចូរស្រឡាញ់គ្នាទៅវិញទៅមក » ។ តើអ្នកនឹងនិយាយអ្វី ?
សកម្មភាពនេះ សមរម្យសម្រាប់កុមារធំៗជាពិសេស។

គន្លឹះក្នុងការបង្រៀន

ការអធិស្ឋាន ៖ បើកុមារត្រូវការជំនួយក្នុងការអធិស្ឋាន សូមរំឭកគេឲ្យអធិស្ឋានខ្លី ដោយប្រាប់ឃ្លាសាមញ្ញៗដើម្បីឲ្យគេចាតាម ។ កុមារធំៗ អាចអធិស្ឋានដោយប្រើពាក្យរបស់គេផ្ទាល់ ។

ការសរសើរ គឺសារៈសំខាន់ចំពោះកុមារ ។ ពួកគេមានក្តីស្រឡាញ់ ហើយចង់បានក្តីស្រឡាញ់ និងចង់ឲ្យគេទទួលយក ។ សូមធ្វើឲ្យពួកគេមានទំនុកចិត្ត ហើយសូមបង្ហាញក្តីស្រឡាញ់របស់អ្នកដល់ពួកគេ ដោយសរសើរចំពោះការខិតខំរបស់ពួកគេដោយស្មោះស ត្រប់ពេលដែលអ្នកអាចធ្វើទៅបាន ។

ការរំឭក ៖ នៅពេលកុមារចេញពីថ្នាក់ទារកដ្ឋាន សូមជួយពួកគេឲ្យប្រាប់ដល់ឪពុកម្តាយរបស់ពួកគេអំពីអ្វីដែលពួកគេបានរៀន ។





15 ខ្ញុំនឹងមានអំណរគុណ

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

ព្រះអម្ចាស់បានបញ្ជាថា « អ្នកត្រូវថ្វាយអំណរគុណដល់ព្រះអម្ចាស់ជាព្រះនៃអ្នកនៅគ្រប់ការណ៍ទាំងអស់ » (គ. និង ស. 59:7) ។ យើងគួរតែថ្លែងអំណរគុណចំពោះព្រះសម្រាប់ពរជ័យជាច្រើន ដែលទ្រង់ប្រទានដល់យើង ។ យើងក៏គួរតែមានអំណរគុណចំពោះឪពុកម្តាយ គ្រូបង្រៀន មិត្តភក្តិ និង អ្នកដទៃទៀត ដែលជួយយើងតាមរបៀបផ្សេងៗជាច្រើនដែរ ។ (សូមមើលផងដែរ ទំនុកតម្កើង 100:3–4) ។

ការរៀបចំខ្លួន

- សូមអាន លូកា 17:11–19 ហើយសូមរៀបចំខ្លួនដើម្បីសង្ខេបរឿងឲ្យខ្លីអំពីមនុស្សឃ្លង់ទាំងដប់នាក់ ។
- សូមយកព្រះគម្ពីរបរិសុទ្ធមកជាមួយ ។ សូមគូសចំណាំ លូកា 17:11–19 ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

សេចក្តីណែនាំអំពីគោលលទ្ធិ សូមប្រាប់កុមារថា ព្រះវរបិតាសួគ៌បានប្រទានពរជ័យជាច្រើនដល់យើង ដូចជារូបកាយរបស់យើង វុត្ថជាតិ និង សត្វទាំងឡាយ ក្រុមគ្រួសាររបស់យើង និង សាសនាចក្រ ។ សូមពន្យល់ថា យើងអាចបង្ហាញក្តីស្រឡាញ់របស់យើងចំពោះទ្រង់ ដោយនិយាយថា « អរព្រះគុណ » ហើយយើងក៏អាចនិយាយថា « អរគុណ » ដល់គ្រួសារ និង មិត្តភក្តិ និង មនុស្សណាម្នាក់ ដែលបានធ្វើអ្វីមួយល្អចំពោះយើងផងដែរ ។

រឿងបទគម្ពីរ សូមដាក់តាំងរូបភាពនៅទំព័រ 66 ។ សូមចង្អុលទៅរូបព្រះយេស៊ូវ និង មនុស្សដែលឈឺធ្ងន់ ។ សូមបើកព្រះគម្ពីរបរិសុទ្ធទៅលូកា 17:11–19 ហើយសូមប្រាប់រឿងអំពីមនុស្សឃ្លង់ទាំង 10 នាក់ ។ នៅខាងក្រោមនេះ គឺជាឧទាហរណ៍មួយ ៖

មានមនុស្ស 10 នាក់ ដែលឈឺធ្ងន់ ។ ព្រះយេស៊ូវ បានព្យាបាលពួកគេ ហើយធ្វើឲ្យពួកគេជាសះស្បើយ *(សូមចង្អុលទៅរូបព្រះយេស៊ូវនៅក្នុងរូបភាព)* ។ ពួកគេទាំងអស់គ្នាសប្បាយចិត្តណាស់ *(សូមចង្អុលទៅមនុស្សឃ្លង់ទាំងអស់នៅក្នុងរូបភាព)* ។ ប៉ុន្តែមានតែបុរសម្នាក់ប៉ុណ្ណោះដែលបាននិយាយថា « អរព្រះគុណ » ដល់ព្រះយេស៊ូវ *(សូមចង្អុលទៅមនុស្សឃ្លង់ដែលមានអំណរគុណនៅក្នុងរូបភាព)* ។ យើងអាចនិយាយថា « អរគុណ » *(សូមអញ្ជើញកុមារឲ្យនិយាយថា « អរគុណ »)* ។

រូបភាព សូមបង្ហាញរូបភាពនៅទំព័រ 67 ។ សូមប្រាប់កុមារថា យើងបង្ហាញសេចក្តីស្រឡាញ់របស់យើងចំពោះព្រះវរបិតាសួគ៌ តាមរយៈការថ្លែងអំណរគុណទ្រង់ចំពោះអ្វីៗគ្រប់យ៉ាងដែលទ្រង់ប្រទានដល់យើង ។ សូមចង្អុលទៅរូបភាពមួយ ហើយសូមអញ្ជើញកុមារឲ្យធ្វើសកម្មភាពមួយ ដែលទាក់ទងទៅនឹងរូបភាពនោះ (ដូចជាការលើកដៃដាក់លើក្បាលធ្វើជាដំបូលផ្ទះ ធ្វើជាបេះផ្លែឈើ ហើយបរិភោគ និង ធ្វើជាពាក់ស្បែកជើង ជាដើម) ។ សូមធ្វើសារឡើងវិញចំពោះរូបភាពនីមួយៗ ។

ចម្រៀង សូមច្រៀង ឬ អានពាក្យនៅឃ្លាទី 1 និង ទី 2 ក្នុងបទ « អរគុណព្រះបិតា » *(សៀវភៅចម្រៀងរបស់កុមារទំព័រ 20)* ហើយសូមធ្វើកាយវិការដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ។

យើងសូមអរគុណដល់ព្រះបិតា *(សូមឱបដៃ)*
ទ្រង់ប្រទានឲ្យយើងគ្រប់យ៉ាង ។ *(សូមលាតត្រដាងដៃ)*
មានភ្នែក ត្រចៀក ដៃ និង ជើង *(សូមចង្អុលទៅ ភ្នែក ត្រចៀក ដៃ និង ជើង)*

គន្លឹះក្នុងការបង្រៀន

សកម្មភាពប្រមូលផ្តុំ ៖ កុមារនឹងមានអារម្មណ៍ថា មានសុវត្ថិភាពនៅពេលមានទម្លាប់ជាទៀងទាត់ និង ការផ្លាស់ប្តូរស្រដៀងគ្នាពីសកម្មភាពមួយទៅសកម្មភាពមួយទៀត ។ ការធ្វើដូច្នេះ នឹងជួយពួកគេឲ្យយកចិត្តទុកដាក់ និង ចូលរួមក្នុងសកម្មភាពនានា ។

រឿងទាំងឡាយ ៖ សូមយោគយល់អំពីលទ្ធភាពក្នុងការយល់ដឹងរបស់កុមារ ។ សូមចៀសវាងប្រើភាសាដែលទាកនិយាយ ឬ ប្រើពាក្យដែលពិបាកខ្ជាក់ពេក ។ ឧទាហរណ៍ សូមប្រើ « មនុស្សដែលឈឺធ្ងន់ » ជំនួសឲ្យ « មនុស្សឃ្លង់ » ។

សម្លៀកបំពាក់ (សូមចង្អុលទៅសម្លៀកបំពាក់) និង *ម្ហូបអាហារ* ។ *(សូមធ្វើដូចជាបរិភោគ)*

សេចក្តីបញ្ចប់ សុំឲ្យកុមារនិយាយថា « អរគុណ » ។ សូមចែកចាយអារម្មណ៍របស់អ្នកអំពីការដឹងគុណដល់ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទដោយសង្ខេប។ ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់សកម្មភាពជារូបភាព ៖* សូមយករូបភាពអំពីអ្វី ដែលអ្នកមានអំណរគុណដល់នោះ អ្នកអាចប្រើរូបភាពនៅក្នុងសៀវភៅសិក្សានេះ ឬ នៅក្នុងទស្សនាវដ្តីសាសនាចក្រ ឬ អ្នកអាចគូសដោយខ្លួនអ្នកផ្ទាល់ ។

សម្រាប់សកម្មភាពជាត់ពណ៌ និង ល្បែងផ្លូវផ្គង ៖ សូមថតចម្លងរូបភាពនៅទំព័រ 67 សម្រាប់កុមារម្នាក់ៗជាត់ពណ៌ ។ សូមយកក្រដាសតូចៗ ឬ អ្វីមួយដែលកុមារស្គាល់ ដើម្បីប្រើជាវត្ថុគូសចំណាំសម្រាប់ល្បែងផ្លូវផ្គង ហើយសូមយកវាឲ្យគ្រប់គ្រាន់សម្រាប់កុមារម្នាក់ៗ យ៉ាងហោចណាស់ត្រូវមានវត្ថុគូសចំណាំចំនួនបួន ។

វគ្គសកម្មភាព សូមប្រាប់កុមារថា យើងមានអំណរគុណដល់ព្រះវរបិតាសួគ៌សម្រាប់រូបកាយរបស់យើង ។ សូមអញ្ជើញកុមារឲ្យក្រោកឈរ និង ធ្វើវគ្គសកម្មភាពដូចខាងក្រោមជាមួយអ្នក ។ សូមច្នៃប្រឌិតសកម្មភាពដែលបានណែនាំដោយពាក្យទាំងឡាយ ។

សូមប៉ះភ្នែក ប៉ះច្រមុះ
សូមប៉ះត្រចៀក ប៉ះជើង ។
សូមលើកដៃឲ្យខ្ពស់
ឲ្យកាន់តែខ្ពស់ទៅលើមេឃ ។
សូមដាក់ដៃនៅលើសក់ ។
សូមអង្គុយចុះដោយស្ងាត់ស្ងៀមនៅលើកៅអីរបស់ប្អូនៗ ។

សូមចង្អុលទៅមាត់ ហើយសូមនិយាយថា « ខ្ញុំមានអំណរគុណសម្រាប់មាត់ » ។ សូមឲ្យកុមារនិយាយឃ្លា និង ធ្វើកាយវិការសារឡើងវិញ ។ សូមនិយាយពាក្យ ភ្នែក ច្រមុះ ត្រចៀក ដៃ និង ជើង សារឡើងវិញ ។ សូមអញ្ជើញកុមារឲ្យផ្តល់យោបល់អំពីអ្វី ដែលពួកគេមានអំណរគុណ ហើយសូមនិយាយឃ្លាដែលពួកគេបានប្រាប់សម្រាប់អ្វីទាំងនោះសារឡើងវិញ ។

រូបភាព សូមបង្ហាញកុមារនូវរូបភាព ដែលអ្នកបានយកមក ហើយសូមពន្យល់ដោយខ្លីៗ អំពីមូលហេតុដែលអ្នកមានអំណរគុណចំពោះវត្ថុទាំងនេះ ។ សូមអញ្ជើញកុមារឲ្យរាប់ឈ្មោះរបស់មួយចំនួនដែលពួកគេមានអំណរគុណ ។

ការជាត់ពណ៌ សូមឲ្យកុមារជាត់ពណ៌លើរូបភាពថតចម្លងមកពីទំព័រ 67 ។ ខណៈពេលដែលពួកគេកំពុងជាត់ពណ៌ សូមចង្អុលបង្ហាញពីព័ត៌មានលម្អិតនៅក្នុងរូបភាព ហើយសូមពន្យល់ទៅដល់កុមារអំពីអ្វីដែលពួកគេកំពុងជាត់ពណ៌នោះ ។ សូមអានពាក្យនៅលើរូបភាពដល់ពួកគេ ។



ល្បែងផ្លូវផ្គង សូមឲ្យក្រដាសតូចៗចំនួនបួនដល់កុមារម្នាក់ៗ ។ សូមដាក់តាំងរូបភាពនៅទំព័រ 67 សូមចង្អុលទៅរូបភាពគ្រួសារ ហើយអានចំណងជើងឲ្យកុមារស្តាប់ ។ សូមអញ្ជើញកុមារឲ្យដាក់ក្រដាសតូចមួយត្រង់កន្លែងគ្រួសារ នៅលើក្រដាសរូបភាពរបស់ពួកគេ ។ សូមអញ្ជើញពួកគេឲ្យនិយាយឃ្លានៅលើរូបភាពជាមួយអ្នកសារឡើងវិញ ។ សូមធ្វើសកម្មភាពនេះសារឡើងវិញ សម្រាប់រូបភាពផ្សេងៗទៀត ។

គន្លឹះក្នុងការបង្រៀន

កុមារតូចៗ ពុំអាចរួមចំណែកពេញមួយមេរៀនបានទេ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកអាចបង្រៀនពួកគេឲ្យធ្វើតាមអ្វីដែលអ្នកធ្វើ ដោយក្តីស្រឡាញ់ និង ការលើកទឹកចិត្ត ។ សូមជួយពួកគេនិយាយថា « អរគុណ » នៅពេលសមរម្យ ។ គំរូរបស់អ្នកអាចជាឧបករណ៍បង្រៀនដ៏មានអំណាចបំផុតរបស់អ្នក ។ កុមារនឹងរៀនពីអាកប្បកិរិយា ទង្វើ និង ភាសាដោយការសង្កេតមើលអ្នក ។ (សូមមើល *Teaching, No Greater Call* ទំព័រ 109) ។

ពាក្យផ្តួន ជួយកុមារៀន ហើយវាជារឿងសប្បាយសម្រាប់ពួកគេ ។ ពួកគេចូលចិត្តស្តាប់រឿងដដែល។ ។ ពួកគេអាចរៀនឃ្លាខ្លី។ ដែលផ្តួន និង ដែលអាចទាយបាន ។



ខ្ញុំមានអំណរគុណចំពោះគ្រួសារខ្ញុំ ។



ខ្ញុំមានអំណរគុណចំពោះ
សម្លៀកបំពាក់ខ្ញុំ ។



ខ្ញុំមានអំណរគុណចំពោះគេហដ្ឋានខ្ញុំ ។



ខ្ញុំមានអំណរគុណចំពោះអាហារ
បរិភោគ ។

16 ខ្ញុំនឹងនិយាយថា « ខ្ញុំសុំទោស »

គន្លឹះក្នុងការបង្រៀន

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

នៅពេលណាដែលយើងធ្វើអ្វីមួយខុស ឬ មានកំហុសមួយ យើងគួរតែសារភាពកំហុសរបស់យើង ហើយព្យាយាមកែវា (សូមមើល យ៉ាកុប 5:16) ។ ឆន្ទៈរបស់យើងដើម្បីបន្ទាបខ្លួន ហើយសុំការអភ័យទោស អាចបន្ធន់ចិត្ត និង រៀបចំយើងដើម្បីចូលមករកព្រះគ្រីស្ទ (សូមមើល នីហ្វៃទី3 12:23–24) ។

ការរៀបចំខ្លួន

- សូមគូសចំណាំទំព័រ 106 នៅក្នុងសៀវភៅសិក្សានេះ ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។
- សូមអាន នីហ្វៃទី 1 17:7–8, 17–19, 49–55 ; 18:1 ។ សូមរៀបចំសង្ខេបដោយខ្លី អំពីរឿងរបស់នីហ្វៃ និង បងប្រុសរបស់គាត់ សាងសង់សំពៅ ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

រូបភាព សូមបង្ហាញរូបភាពព្រះយេស៊ូវគ្រីស្ទនៅទំព័រ 106 ។ សូមប្រាប់កុមារថា ព្រះយេស៊ូវបានបង្រៀនយើងអំពីរបៀបដើម្បីសប្បាយចិត្ត ។ សូមពន្យល់ថា ការនិយាយពាក្យសម្តីល្អ អាចធ្វើឲ្យយើងសប្បាយចិត្ត ហើយវាអាចធ្វើឲ្យអ្នកដទៃសប្បាយចិត្ត នៅពេលយើងធ្វើកំហុសមួយ ឬ ធ្វើអ្វីមួយដែលពុំល្អ យើងចាំបាច់ត្រូវប្រើពាក្យល្អទាំងនេះថា ៖ « ខ្ញុំសុំទោស » ។ សូមអញ្ជើញកុមារឲ្យនិយាយថា « ខ្ញុំសុំទោស » ។

ចម្រៀង សូមច្រៀង ឬ អានពាក្យនៅក្នុងវគ្គបន្ទរនៃបទ « ខ្ញុំព្យាយាមក្លាយដូចជាព្រះយេស៊ូវ » (*សៀវភៅចម្រៀងរបស់កុមារ* ទំព័រ 78–79) ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ។

ចូរស្រឡាញ់គ្នាដូចព្រះ ទ្រង់ស្រឡាញ់អ្នក ។ *(សូមឱបខ្លួនអ្នក ហើយងាករវែខ្លួនទៅឆ្វេង ទៅស្តាំ)*

ចូរបង្ហាញមេត្តាក្នុងកិច្ចការ អ្នកធ្វើ ។ *(សូមងក់ក្បាល)*

ដោយស្លូតបូត និង ក្តីស្រឡាញ់ ទាំងសកម្មភាព និង ចិត្តគំនិត *(សូមឱបខ្លួនអ្នក ហើយងាករវែខ្លួនទៅឆ្វេង ងាកទៅស្តាំ)*

នេះជាអ្វីដែលទ្រង់បានបង្រៀន ។ *(សូមងក់ក្បាល)*

ចម្រៀង ៖ ដើម្បីជួយកុមារៀនចម្រៀង ចូរច្រៀងឃ្លាខ្លី។ ហើយសុំឲ្យកុមារថាតាមអ្នក ។ បន្ទាប់មក សូមឲ្យពួកគេនិយាយឡើងវិញនូវឃ្លាទាំងមូល រួចហើយចម្រៀងទាំងមូល ។

រឿងបទគម្ពីរ សូមបង្ហាញរូបភាពរបស់នីហ្វៃកំពុងសង់សំពៅ (ទំព័រ 70) ហើយសូមប្រាប់រឿងរបស់នីហ្វៃ និង បងប្រុសរបស់គាត់សាងសង់សំពៅ ។ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយ ៖

នេះគឺជានីហ្វៃ *(សូមចង្អុលទៅនីហ្វៃដែលនៅកណ្តាលរូបភាព)* ។ ព្រះអម្ចាស់ បានប្រាប់នីហ្វៃឲ្យសង់សំពៅមួយ ។ សំពៅគឺជាកប៉ាល់ដ៏ធំមួយ *(សូមចង្អុលទៅសំពៅនៅក្នុងរូបភាព)* ។ នេះគឺជាបងប្រុសរបស់នីហ្វៃ *(សូមចង្អុលទៅពួកគេនៅក្នុងរូបភាព)* ។ ពួកគេមួយចំនួននិយាយអ្វីមិនល្អដល់នីហ្វៃ ហើយពុំបានជួយគាត់សង់សំពៅឡើយ ។ នីហ្វៃមានអារម្មណ៍ក្រៀមក្រំ *(សូមឲ្យកុមារធ្វើជាមានអារម្មណ៍ក្រៀមក្រំ)* ។ ក្រោយមក បងប្រុសរបស់នីហ្វៃ បានសុំទោស ហើយបានជួយគាត់សង់សំពៅ ។ បន្ទាប់មក មនុស្សគ្រប់គ្នាសប្បាយចិត្តឡើងវិញ *(សូមឲ្យកុមារធ្វើជាសប្បាយចិត្ត)* ។

សូមរំឭកកុមារថា នៅពេលយើងនិយាយ « ខ្ញុំសុំទោស » នោះយើងអាចបានសប្បាយចិត្ត ហើយជួយឲ្យអ្នកដទៃសប្បាយចិត្តដែរ ។ សូមអញ្ជើញកុមារឲ្យនិយាយថា « ខ្ញុំសុំទោស » ។

រឿងទាំងឡាយ ៖ កុមារៀនចេះមកពីការនិយាយដដែល។ ឆ្លងគ្នា ។ សូមប្រាប់រឿងដែលកុមារពេញចិត្តឡើងវិញ នៅពេលណាក៏បានអំឡុងពេលថ្នាក់ទារកដ្ឋាន ។ នេះគឺជារបៀបដ៏សប្បាយរីករាយមួយ ដើម្បីរំឭកជាមួយនឹងកុមារអំពីអ្វី ដែលពួកគេបានរៀន ។

ការសម្តែងល្ខោន សូមឲ្យកុមារធ្វើជាជួយនីហ្វៃសង់សំពៅ —អារឈើ, លើឈើទៅមាត់សមុទ្រ, ដំដែកគោលលើឈើ ហើយលើកក្តោងឡើង ។ សូមធ្វើចលនា ធ្វើសំឡេង ហើយការផ្លាស់ប្តូរនានាដើម្បីជួយឲ្យកុមារចូលរួម ។

សេចក្តីបញ្ចប់ សូមចែកចាយទីបន្ទាល់របស់អ្នកថា យើងអាចបានសប្បាយចិត្ត នៅពេលយើងនិយាយថា « ខ្ញុំសុំទោស » ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់ល្បែងទាយ ៖* សូមថតចម្លងរូបភាពចេញពីទំព័រ 71 ហើយសូមកាត់រូបភាពមួយចេញពីរង្វង់ ។ សូមជាត់ពណ៌តាមចំណូលចិត្ត ។ សូមយកកន្សែងដៃចំនួនបី ឬ ផ្ទាំងក្រណាត់តូចៗមក ។

សម្រាប់សកម្មភាពខ្សែដៃ ៖ សូមថតចម្លង ហើយកាត់រង្វង់នៅទំព័រ 71 ដើម្បីចែកឲ្យកុមារម្នាក់មួយៗ ។ សូមដាក់ខ្សែ ឬ ខ្សែអំបោះចងតាមកំពូលលើដើម្បីធ្វើជាខ្សែដៃ ឬ ខ្សែកសម្រាប់កុមារម្នាក់ៗ ។

ល្បែងទាយ សូមដាក់កន្សែងដៃចំនួនបីនៅលើឥដ្ឋ ។ សូមឲ្យកុមារបិទភ្នែកពួកគេ ខណៈពេលដែលអ្នកលាក់រូបមុខ ដែលអ្នកបានកាត់ទុកនោះ នៅក្រោមកន្សែងដៃមួយ ។ សូមឲ្យកុមារផ្លាស់វេនគ្នាបើកកន្សែងដៃរហូតដល់ពួកគេរកឃើញរូបមុខនោះ ។ បន្ទាប់មក សូមអានចំណងជើងឲ្យកុមារស្តាប់ ហើយសូមអញ្ជើញពួកគេឲ្យធ្វើសារឡើងវិញជាមួយអ្នក ។ សូមលេងល្បែងឡើងវិញ ទាល់តែដល់វេនកុមារគ្រប់គ្នា ។

រឿងទាំងឡាយ សូមប្រាប់រឿងសាមញ្ញមួយចំនួន ដើម្បីជួយកុមារនិយាយថា « ខ្ញុំសុំទោស » ដូចជា ៖

- មានក្មេងស្រីម្នាក់បានដណ្តើមយកសម្ភារលេងរបស់ប្អូនប្រុសនាង ។ ប្អូនប្រុសពុំសប្បាយចិត្តទេ *(សូមឲ្យកុមារធ្វើមុខក្រញ៉ូវ)* ។ បន្ទាប់មក នាងបាននិយាយថា « ខ្ញុំសុំទោស » ហើយបានឲ្យសម្ភារលេងនោះទៅវិញ *(សូមឲ្យកុមារនិយាយថា « ខ្ញុំសុំទោស »)* ។ ប្អូនប្រុសនាងសប្បាយចិត្ត ! *(សូមឲ្យកុមារញញឹម)* ។
- មានក្មេងប្រុសម្នាក់កំពុងរត់ ហើយបានទៅបុកនឹងប្អូនស្រីរបស់គាត់ ។ ប្អូនស្រីគាត់ ពុំសប្បាយចិត្តទេ *(សូមឲ្យកុមារធ្វើមុខក្រញ៉ូវ)* ។ បន្ទាប់មក កុមារនោះនិយាយថា « ខ្ញុំសុំទោស » *(សូមឲ្យកុមារនិយាយថា « ខ្ញុំសុំទោស »)* ។ ប្អូនស្រីរបស់គាត់ សប្បាយចិត្ត ! *(សូមឲ្យកុមារញញឹម)* ។

សូមធ្វើសារឡើងវិញជាមួយនឹងឧទាហរណ៍ដទៃទៀត ។

ខ្សែដៃ សូមឲ្យខ្សែដៃ ឬ ខ្សែកមួយទៅកុមារម្នាក់ៗពាក់ ។ សូមអានពាក្យនៅលើរូបភាពដល់ពួកគេ ។

គន្លឹះក្នុងការបង្រៀន

ការសម្តែងល្ខោន ៖ ការសម្តែងរឿងចេញមកពីបទគម្ពីរ នឹងជួយកុមារឲ្យយល់ និង ចងចាំអំពីអ្វីដែលអ្នកកំពុងព្យាយាមបង្រៀន ។ (សូមមើល *Teaching, No Greater Call* ទំព័រ 165–66) ។

ធនធានទាំងឡាយ ៖ សូមប្រើតែធនធានដែលបានបោះពុម្ពដោយសាសនាចក្រនៅក្នុងថ្នាក់ទារកដ្ឋានប៉ុណ្ណោះ ។ បើអ្នកត្រូវការអ្វីច្រើនទៀតសម្រាប់ឲ្យកុមារធ្វើ សូមជ្រើសរើសរឿងដទៃទៀត, ល្បែងកំសាន្ត, រូបតុក្កតាអាយ៉ង ឬ សកម្មភាពជាតិពណ៌នានា ចេញពីសៀវភៅនេះ ឬ ចេញមកពីទស្សនាវដ្តីសាសនាចក្រ ។ អ្នកអាចប្រើសកម្មភាពទាំងនេះ ញឹកញាប់តាមតែអ្នកចង់ប្រើ ហើយអ្នកអាចបង្រៀនមេរៀនមួយក្នុងរយៈពេលមួយ ឬ ពីរសប្តាហ៍ជាប់គ្នា ។

ពាក្យដដែល ៖ បើកុមារស្តាប់ឃ្លាមួយសារឡើងវិញច្រើនដង នោះវាអាចក្លាយទៅជាចំណែកនៃពាក្យដែលពួកគេស្តាប់ឮ ។ បើពួកគេនិយាយឃ្លានោះជាច្រើនដង វាអាចក្លាយទៅជាចំណែកនៃពាក្យនិយាយរបស់ពួកគេ ។

ខ្ញុំអាចស្ងៀមស្ងាត់ នៅពេលខ្ញុំនិយាយថា « ខ្ញុំស៊ុតទាស់ » ។

ខ្ញុំអាចស្ងៀមស្ងាត់ នៅពេលខ្ញុំនិយាយថា « ខ្ញុំស៊ុតទាស់ » ។

ខ្ញុំអាចស្ងៀមស្ងាត់ នៅពេលខ្ញុំនិយាយថា « ខ្ញុំស៊ុតទាស់ » ។

ខ្ញុំអាចស្ងៀមស្ងាត់ នៅពេលខ្ញុំនិយាយថា « ខ្ញុំស៊ុតទាស់ » ។

17 ខ្ញុំនឹងចែករំលែក

គន្លឹះក្នុងការបង្រៀន

ការចែកចាយ ជាញឹកញាប់មានការពិបាកសម្រាប់កុមារតូច។ធ្វើ ។ ពួកគេនឹងរៀនតាមគំរូរបស់អ្នក ។ អំឡុងមេរៀន និង នៅក្នុងម៉ោងថ្នាក់ទារកដ្ឋាន ទាំងមូល សូមបង្ហាញដល់ពួកគេអំពីរបៀបដែលអ្នកចែកចាយ បន្ទាប់មកសូមឲ្យពួកគេហាត់ធ្វើវា ។ (សូមមើល *Teaching, No Greater Call* ទំព័រ 168) ។ បើពួកគេមានការស្ទាក់ស្ទើរ សូមបង្ហាញដល់ពួកគេម្តងទៀតយ៉ាងសាមញ្ញ ដោយពុំបង្ខំដល់ពួកគេឲ្យចែកចាយ ។

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

អ្នកដើរតាមដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទ ត្រូវបានគេស្គាល់ថា តែងតែចង់ចែកចាយអ្វីដែលពួកគេមានជាមួយនឹងអ្នកដទៃ ដោយស្ម័គ្រចិត្ត (ឧទាហរណ៍ សូមមើល កិច្ចការ 2:44–45 ; ម៉ូសាយ 18:28 ; នីហ្វៃ 4 1:3) ។ តាមរយៈការចែកចាយពរជ័យរបស់យើងជាមួយនឹងអ្នកទាំងឡាយដែលត្រូវការ នោះយើងទទួលស្គាល់ថា ពរជ័យទាំងនេះបានមកពីព្រះ ហើយយើងបង្ហាញសេចក្តីស្រឡាញ់របស់យើងចំពោះកូនចៅរបស់ទ្រង់ទាំងអស់ ។

ការរៀបចំខ្លួន

សូមយកវត្ថុសាមញ្ញមួយមក ដែលអ្នកអាចប្រើដើម្បីបង្ហាញពីការចែកចាយ (អ្នកក៏អាចប្រើវត្ថុមួយនៅក្នុងថ្នាក់ទារកដ្ឋាន ដូចជាសម្ភារលេង ឬ សៀវភៅដែរ) ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

ចម្រៀង ច្រៀង ឬ អានពាក្យនៅក្នុងវគ្គបទន្លនៃបទ « ខ្ញុំព្យាយាមគ្លាយដូចព្រះយេស៊ូវ » *សៀវភៅចម្រៀងរបស់កុមារ* ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ។

ចូរស្រឡាញ់គ្នាដូចព្រះ ទ្រង់ស្រឡាញ់អ្នក ។ *(សូមឱបខ្លួនអ្នក ហើយងាកវិលខ្លួន)*
ចូរបង្ហាញមេត្តាក្នុងកិច្ចការអ្នកធ្វើ ។ *(សូមងក់ក្បាល)*
ដោយស្លូតបូត និង ក្តីស្រឡាញ់ ទាំងសកម្មភាព និង ចិត្តគំនិត *(សូមឱបខ្លួនអ្នក ហើយងាកវិលខ្លួន)*
នេះជាអ្វីដែលទ្រង់បានបង្រៀន ។ *(សូមងក់ក្បាល)*

សូមប្រាប់កុមារថា ព្រះវរបិតាសួគ៌ ចង់ឲ្យយើងមានចិត្តល្អចំពោះគ្នាទៅវិញទៅមក ។ សូមពន្យល់ថា នៅពេលយើងចេះចែកចាយ នោះយើងមានចិត្តល្អ ។

ការសម្តែងល្ខោន សូមប្រាប់កុមារថា អ្នកនឹងហាត់រៀនអំពីការចែករំលែក ។ សូមបង្ហាញពួកគេអំពីរបៀបដើម្បីចេះ ចែកចាយ ដោយនិយាយថា « ខ្ញុំនឹងចែកចាយ » នៅពេលអ្នកផ្តល់វត្ថុដែលអ្នកបានយកមក ឲ្យទៅអ្នកដឹកនាំថ្នាក់ទារកដ្ឋានម្នាក់ទៀត ។ សូម គូសបញ្ជាក់ពីសុភមង្គលដែលកើតមកពីការចេះចែកចាយ ។ សូមអញ្ជើញកុមារឲ្យនិយាយថា « ខ្ញុំនឹងចែកចាយ » ។

រូបភាព សូមបង្ហាញរូបភាពដំបូងគេនៅទំព័រ 74 ។ សូមចង្អុលទៅកុមារីនៅខាងឆ្វេងដៃ ហើយសូមប្រាប់កុមារថា កុមារីនេះ មានតុក្កាមួយ ដែលនាងចូលចិត្តលេង ។ នៅពេលមិត្តរបស់នាងមកលេង កុមារីនិយាយថា « ខ្ញុំនឹងចែកតុក្ការបស់ខ្ញុំឲ្យអ្នកលេង » ។ សូមបង្ហាញថា ពួកគេទាំងពីរនាក់សប្បាយចិត្ត ។ សូមអញ្ជើញកុមារឲ្យនិយាយថា « ខ្ញុំនឹងចែកចាយ » ។

សូមបង្ហាញរូបភាពទីពីរនៅទំព័រ 74 ។ សូមចង្អុលទៅកុមារានៅខាងស្តាំដៃ ហើយសូមប្រាប់កុមារថា កុមារានេះចូលចិត្តលេង ។ នៅពេលមិត្តភក្តិរបស់គាត់មកលេងជាមួយ នោះកុមារានិយាយថា « ខ្ញុំនឹងចែកចាយតុក្តារបស់ខ្ញុំជាមួយឯង » ។ សូមពន្យល់ថា ឥឡូវពួកគេទាំងពីរនាក់សប្បាយចិត្ត ។ សូមអញ្ជើញកុមារឲ្យនិយាយថា « ខ្ញុំនឹងចែកចាយ » ។

ចម្រៀង សូមច្រៀង ឬ អានពាក្យដូចខាងក្រោម ក្នុងបទ « សប្បាយធ្វើការ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 253) ខណៈពេលដែលអ្នកធ្វើជាចែកចាយជាមួយនឹងកុមារ ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ។

ចែកចាយដល់អ្នក គឺសប្បាយណាស់
សប្បាយណាស់ សប្បាយ សប្បាយ !
ចែកចាយដល់អ្នក គឺសប្បាយណាស់
សប្បាយ សប្បាយ សប្បាយ !

សេចក្តីបញ្ចប់ សូមប្រាប់កុមារអំពីសុភមង្គល ដែលអ្នកមាននៅពេលអ្នកចែកចាយ ។ សូមពន្យល់ថា ព្រះវរបិតាសួគ៌ក៏មានការសប្បាយព្រះទ័យផងដែរ នៅពេលយើងចែកចាយ ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់សកម្មភាពរូបភាព ៖* សូមថតចម្លងរូបភាពនៅទំព័រ 75 ឲ្យកុមារម្នាក់មួយៗ ។ *សម្រាប់ល្បែងកំសាន្តគូប (រាងដុំបួនជ្រុង)* សូមថតចម្លង ហើយកាត់រូបភាពនៅទំព័រ 75 ។ ជាត់ពណ៌តាមចំណូលចិត្ត ។ សូមបត់តាមចំណុចចុចៗ ហើយសូមបិទស្អិត ឬ បិទការ៉ាដើម្បីធ្វើឲ្យចេញជាដុំរាងបួនជ្រុង ។

រូបភាព សូមបង្ហាញរូបភាពនៅទំព័រ 75 រួចហើយសូមឲ្យកុមារម្នាក់ៗថតចម្លងរូបភាពនោះ ។ សូមចង្អុលទៅរូបភាពកុមារាញញឹម ហើយសូមពន្យល់ថា យើងអាចចែកចាយស្នាមញញឹមរបស់យើង ។ សូមអញ្ជើញកុមារឲ្យចង្អុលទៅកុមារាញញឹម នៅក្នុងក្រដាសរូបភាពរបស់ពួកគេ ។ សូមធ្វើដូចគ្នាចំពោះរូបភាពដទៃទៀត ។

ល្បែងកំសាន្តគូប(ដុំរាងបួនជ្រុង) សូមរៀលដុំរាងបួនជ្រុងដែលអ្នកបានធ្វើ ។ សូមឲ្យកុមារធ្វើសកម្មភាពសាមញ្ញមួយចំនួន តាមរូបភាពនៅលើជ្រុងនៃដុំរាងបួនជ្រុង ។ បន្ទាប់មកសូមអញ្ជើញកុមារឲ្យនិយាយជាមួយអ្នកថា « ខ្ញុំនឹងចែករំលែក [ស្នាមញញឹម សម្ភារលេង អាហារជាដើម] » ។ នៅពេលមានជ្រុងដែលមានតែពាក្យថា « ខ្ញុំនឹងចែកចាយ » ជ្លាវឡើង នោះសូមឲ្យកុមារទះដៃ ហើយនិយាយថា « ខ្ញុំនឹងចែកចាយ » ។ សូមធ្វើដូចគ្នាទាល់តែកុមារម្នាក់ៗ ដល់វេនដើម្បីរមៀលដុំរាងបួនជ្រុងនោះ ។

វគ្គសកម្មភាព សូមរៀបរាប់វគ្គសកម្មភាពដូចខាងក្រោម ហើយសូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ៖

ខ្ញុំចង់ធ្វើតាមព្រះយេស៊ូវ
សូមមានចិត្តល្អ និង ក្តីស្រឡាញ់ *(សូមឱបខ្លួនឯង)*
ខ្ញុំនឹងចែកចាយស្នាមញញឹម *(សូមចង្អុលទៅមាត់ និង ស្នាមញញឹម)*
ខ្ញុំនឹងចែកចាយសម្ភារលេងរបស់ខ្ញុំ ។ *(សូមធ្វើដូចជាឲ្យសម្ភារលេង)*
នោះជាអ្វីដែលទ្រង់ចង់ឲ្យខ្ញុំធ្វើ ។

គន្លឹះក្នុងការបង្រៀន

ការថតចម្លង ៖ បើអ្នកពុំមានម៉ាស៊ីនថតចម្លងទេ អ្នកអាចដាក់ក្រដាសពីលើរូបភាព ហើយគូសដានវាដោយខ្ចិច ឬ ខ្មៅដៃបាន ។ ចូរកុំបារម្ភអំពីការគូសដានយករូបភាពទាំងស្រុងឡើយ គ្រាន់តែគូសដានជាគ្រោង ហើយអាចមើលរូបភាពយល់ទៅ បានហើយ ។

ល្បែងគូប (ដុំរាងបួនជ្រុង) ៖ បើអ្នកមានកុមារច្រើននៅក្នុងថ្នាក់ទារកដ្ឋានរបស់អ្នក អ្នកអាចនឹងចង់រមៀលដុំរាងបួនជ្រុងដោយខ្លួនអ្នករាល់ពេល ដោយភាល្ងជាជាងឲ្យកុមារដាក់វេនគ្នា ។

វគ្គសកម្មភាព ៖ កុមារចូលចិត្តកំណាព្យ និង ចម្រៀងដែលមានសកម្មភាពសាមញ្ញ។ ។ អ្នកអាចប្រើវគ្គសកម្មភាពដែលបានអនុម័តដោយសាសនាចក្រ ដើម្បីជួយកុមារឲ្យមានអារម្មណ៍នៃការស្វាគមន៍ ត្រៀមខ្លួនដើម្បីអធិស្ឋាន រៀនពីគោលការណ៍ដំណឹងល្អនានា ឬ ចូលរួមនៅក្នុងមេរៀនមួយ ។

ខ្ញុំនឹង
ចែករំលែក

ខ្ញុំនឹងចែករំលែកអាហារ ។

ខ្ញុំនឹងចែករំលែកស្នាមញញឹម ។

ខ្ញុំនឹងចែកចាយសម្ភារលេង ។

ខ្ញុំនឹងចែកចាយគ្រឿងសិល្បៈ ។

ខ្ញុំនឹងចែករំលែកសៀវភៅ ។

18 ខ្ញុំនឹងស្រឡាញ់អ្នកដទៃ

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

សូមស្រឡាញ់អ្នកដទៃ ទោះជាពួកគេខុសពីយើងក្តី វាគឺជារបៀបមួយដ៏សំខាន់បំផុត ដែលយើងអាចធ្វើតាមព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ (សូមមើល យ៉ូហាន 13:34–35) ។ យើងបង្ហាញក្តីស្រឡាញ់របស់យើងចំពោះអ្នកដទៃ តាមរយៈការមានចិត្តល្អចំពោះពួកគេ, ការស្តាប់ពួកគេ, ការលួងលោមចិត្តពួកគេ និង ការបម្រើដល់ពួកគេ ។ (សូមមើល ម៉ាថាយ 25:34–40 ; ម៉ូសាយ 18:8–9) ។

ការរៀបចំខ្លួន

- សូមអាន លូកា 10:25–37 ហើយសូមត្រៀមខ្លួនដើម្បីប្រាប់រឿងអំពីសាសន៍សាម៉ារីដ៏ល្អម្នាក់ ដោយសាមញ្ញបំផុត ។
- សូមយកព្រះគម្ពីរបរិសុទ្ធមកជាមួយ ។
- សូមគូសចំណាំទំព័រ 74 នៅក្នុងសៀវភៅសិក្សានេះ ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។

សកម្មភាពក្នុងការបង្រៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

រូបភាព សូមបង្ហាញរូបភាពនៅទំព័រ 74 ។ សូមពន្យល់ថា កុមារនៅក្នុងរូបភាពទាំងនេះ កំពុងលេងជាមួយគ្នាដោយមានសន្តានចិត្តល្អ ។ នៅពេលយើងមានចិត្តល្អចំពោះអ្នកដទៃ យើងកំពុងបង្ហាញក្តីស្រឡាញ់ដល់ពួកគេ ។

ចម្រៀង សូមច្រៀង ឬ អានពាក្យនៅក្នុងបទ « ព្រះយេស៊ូវមានបន្ទូលស្រឡាញ់មនុស្សគ្រប់គ្នា » (*សៀវភៅចម្រៀងកុមារ* ទំព័រ 61) ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ។

ព្រះយេស៊ូវ ប្រាប់ឲ្យស្រឡាញ់ *(សូមលាតត្រដាងដៃ)*
ធ្វើល្អគ្រប់មនុស្ស ។
ពេលចិត្តអ្នកមានក្តីស្រឡាញ់ *(សូមដាក់ដៃលើដើមទ្រូង)*
គេស្រឡាញ់អ្នកវិញ ។ *(សូមឱបខ្លួនឯង)*

រឿងបទគម្ពីរ សូមបង្ហាញរូបភាពរបស់សាសន៍សាម៉ារីដ៏ល្អម្នាក់ នៅទំព័រ 78 ។ សូមបើកព្រះគម្ពីរបរិសុទ្ធ ហើយសូមប្រាប់កុមារថា អ្នកនឹងចែកចាយរឿងមួយ ដែលព្រះយេស៊ូវប្រាប់អំពីការស្រឡាញ់ដល់អ្នកដទៃ ។ សូមប្រើភាសាសាមញ្ញ។ ពេលប្រាប់រឿងអំពីសាសន៍សាម៉ារីដ៏ល្អនោះ ។ ខាងក្រោមនេះគឺជាឧទាហរណ៍ ៖

ថ្ងៃមួយ មានបុរសម្នាក់ដេកនៅលើដី *(សូមចង្អុលទៅលើបុរសដែលមានរបួសក្នុងរូបភាព)* ។ គាត់មានរបួស ។ បុរសពីរនាក់បានដើរទៅជិត ។ ពួកគេឃើញគាត់ ប៉ុន្តែពួកគេពុំជួយគាត់ទេ ។ បុរសទីបី បានមកដល់ *(សូមចង្អុលទៅសាសន៍សាម៉ារីដ៏ល្អនៅក្នុងរូបភាព)* ។ គាត់បានឃើញបុរសនោះដេកលើដី ហើយគាត់បានជួយ ។ គាត់បានបង្ហាញក្តីស្រឡាញ់ ។

ការសម្តែង សូមប្រាប់កុមារថា ព្រះយេស៊ូវមានបន្ទូលថា យើងគួរតែបង្ហាញក្តីស្រឡាញ់ផងដែរ ។ សូមអញ្ជើញពួកគេឲ្យធ្វើដូចជាដើរលេង ហើយសូមផ្តល់ឱកាសដល់ពួកគេឲ្យធ្វើដូចជាបង្ហាញក្តីស្រឡាញ់ដល់អ្នកដទៃ ។ ឧទាហរណ៍ ៖

តោះទៅដើរលេង *(សូមដើរនៅមួយកន្លែង)* ។ មើលន៎! មានមិត្តម្នាក់បានដួល ។ សូមជួយមិត្តរបស់យើងឲ្យឈរឡើង *(សូមធ្វើដូចជាជួយមិត្តឲ្យឈរឡើង)* ។ ចូរបន្តដើរទៀត ។ យើងមើលឃើញមិត្តម្នាក់ស្រេកទឹក ។ សូមឲ្យទឹកដល់មិត្តរបស់យើងផឹក *(សូមធ្វើដូចជាឲ្យទឹក)* ។ ចូរបន្តដើរទៀត ។ យើងមើលឃើញម៉ាក់ និង ប៉ារបស់

គន្លឹះក្នុងការបង្រៀន

ការរៀបចំ ៖ « នៅពេលយើងបង្រៀនដំណឹងល្អ យើងគួរតែទទួលស្គាល់ដោយភាពសាមញ្ញថា ព្រះវិញ្ញាណបរិសុទ្ធ គឺជាគ្រូបង្រៀនដ៏ពិត ។ ឯកសិទ្ធិរបស់យើង គឺដើម្បីបម្រើជាឧបករណ៍មួយដែលព្រះវិញ្ញាណអាចបង្រៀន ផ្លែងទីបន្ទាល់ លួងលោមចិត្ត និង បំផុសគំនិត ។ ហេតុដូច្នោះហើយ យើងគួរតែមានភាពសក្តិសមដើម្បីទទួលព្រះវិញ្ញាណ ។ . . . នៅពេលអ្នកត្រៀមខ្លួនខាងវិញ្ញាណ ហើយទទួលស្គាល់ព្រះអម្ចាស់នៅក្នុងការបង្រៀនរបស់អ្នក នោះអ្នកនឹងក្លាយទៅជាឧបករណ៍មួយនៅក្នុងព្រះហស្តរបស់ទ្រង់ ។ ព្រះវិញ្ញាណបរិសុទ្ធនឹងលើកតម្កើងពាក្យទាំងឡាយរបស់អ្នកដោយព្រះចេស្តា » (*Teaching, No Greater Call* ទំព័រ 41) ។

ព្រះគម្ពីរ ៖ សូមប្រើព្រះគម្ពីរនៅពេលអ្នកបង្រៀនកុមារ ។ នៅពេលអ្នកច្រាប់រឿងមួយចេញមកពីព្រះគម្ពីរ សូមច្រាប់កន្លែងដែលរឿងនោះមានក្នុងព្រះគម្ពីរ ។ សូមបង្រៀនកុមារឲ្យមានអំណរគុណ និង មានការគោរពចំពោះព្រះគម្ពីរ ។

យើង ។ តោះយើងទៅឱបពួកគាត់ ហើយនិយាយថា « កូនស្រឡាញ់ម៉ាក់ ឬ ប៉ា »
(សូមឱបខ្លួនឯង ហើយសូមនិយាយថា « កូនស្រឡាញ់ម៉ាក់ ឬ ប៉ា ») ។

សេចក្តីបញ្ចប់ សូមប្រាប់កុមារដោយស្មោះថា អ្នកស្រឡាញ់ពួកគេ ។ សូមប្រាប់ពួកគេអំពីអារម្មណ៍របស់អ្នក នៅពេលអ្នកបង្ហាញក្តីស្រឡាញ់ចំពោះអ្នកដទៃ ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់សកម្មភាពបទគម្ពីរ ៖* សូមយកព្រះគម្ពីរបរិសុទ្ធមកជាមួយ ។ សូមគូសចំណាំយ៉ូហាន 15:12ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។
សម្រាប់សកម្មភាពជាត់ពណ៌ និង សកម្មភាពរូបបេះដូង ៖ សូមថតចម្លងរូបភាពនៅទំព័រ 79 សម្រាប់កុមារម្នាក់ៗជាត់ពណ៌ ។

បទគម្ពីរ សូមប្រាប់កុមារថា យើងរៀននៅក្នុងគម្ពីរថា ព្រះយេស៊ូវបានបង្រៀនយើងឲ្យស្រឡាញ់គ្នាទៅវិញទៅមក ។ សូមអានយ៉ូហាន 15:12 ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ។

នេះជាសេចក្តីបញ្ញត្តិរបស់យើង
គឺឲ្យអ្នករាល់គ្នាស្រឡាញ់ដល់គ្នាទៅវិញទៅមក *(សូមដាក់ដៃទាំងពីរលើដើមទ្រូង)*
ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ ។ *(សូមលាតត្រដាងដៃ)*

ការជាត់ពណ៌ សូមឲ្យកុមារជាត់ពណ៌រូបភាពនៅលើទំព័រ 79 ។ ខណៈពេលដែលពួកគេកំពុងជាត់ពណ៌ សូមជួយពួកគេឲ្យយល់ថា យើងទាំងអស់គ្នាគឺជាកូនរបស់ព្រះ ហើយយើងម្នាក់ៗគឺជាមនុស្សពិសេស ។ សូមរំឭកពួកគេថា ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវសព្វព្រះទ័យឲ្យយើងស្រឡាញ់មនុស្សគ្រប់គ្នា ។

សកម្មភាពរូបបេះដូង សូមអានឧទាហរណ៍ដូចខាងក្រោម (ឬ បង្កើតឧទាហរណ៍មួយចំនួនដោយខ្លួនអ្នកផ្ទាល់) ហើយសូមសួរថា « តើការធ្វើដូច្នេះបង្ហាញក្តីស្រឡាញ់ដែរឬទេ ? »
បន្ទាប់ពីឧទាហរណ៍នីមួយៗ ចូរឲ្យកុមារលើកក្រដាសរូបបេះដូងរបស់ពួកគេឡើង ហើយសូមនិយាយថា « សេចក្តីស្រឡាញ់ » ។
នៅពេលអ្នកជួយសម្អាត ។
នៅពេលអ្នកនិយាយថា « សូម » និង « អរគុណ » ។
នៅពេលអ្នកចែកចាយសម្ភារលេងរបស់អ្នក ។
នៅពេលអ្នកជួយនរណាម្នាក់ដែលឈឺ ។
សូមសរសើរដល់កុមារចំពោះការចូលរួម ។ សកម្មភាពនេះ សមរម្យសម្រាប់កុមារធំៗជាពិសេស ។

គន្លឹះក្នុងការបង្រៀន

សេចក្តីបញ្ចប់ ៖ សូមញញឹមនៅពេលអ្នកប្រាប់កុមារថា អ្នកស្រឡាញ់ពួកគេ ។ សូមមើលចំកែវភ្នែករបស់ពួកគេ ។ ការបង្ហាញនៅលើទឹកមុខរបស់អ្នក និង សកម្មភាពទាំងឡាយរបស់អ្នក នឹងប្រាប់កុមារច្រើនជាងពាក្យសម្តីរបស់អ្នក ។

ការជាត់ពណ៌ ៖ កុមារតូច។ អាចនឹងពុំចេះជាត់រូបនៅក្នុងរង្វង់នោះទេ ។ ពួកគេអាចនឹងចាប់អារម្មណ៍នឹងការគូសតែមួយ ឬ ពីរបន្ទាត់នៅលើទំព័រតំនូរនោះតែប៉ុណ្ណោះ ។ សូមសរសើរចំពោះការខិតខំរបស់ពួកគេដោយចិត្តត្រេកអរ ដោយពុំបាច់សុំឲ្យពួកគេជាត់តាមរបៀបណាមួយជាក់លាក់នោះទេ ។ គោលបំណងនៃរូបភាពនៅក្នុងសៀវភៅសិក្សានេះ គឺដើម្បីផ្តល់ឲ្យកុមារអំពីនិមិត្តរូបមួយដែលអាចមើលឃើញនឹងភ្នែកអំពីគោលការណ៍ទាំងឡាយក្នុងមេរៀន ។

ខ្ញុំនឹងស្រឡាញ់អ្នកជានិច្ច



19 ខ្ញុំអាចសប្បាយចិត្ត

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

ព្រះវរបិតាសួគ៌របស់យើង ចង់ឲ្យយើងរីករាយ ។ ផែនការដែលទ្រង់បានបង្កើតសម្រាប់យើង ជាញឹកញាប់ ត្រូវបានហៅថា ជា « ផែនការនៃសុភមង្គលដ៏មហិមា » (អាលម៉ា 42:8) ។ ទោះជាភាពមិនអនុគ្រោះ គឺជាផ្នែកមួយដ៏សំខាន់នៃជីវិតក្តី ក៏យើងអាចជ្រើសរើសដើម្បីមានឥរិយាបទវិជ្ជមាន និង អាកប្បកិរិយារីករាយរបស់យើង ដែលអាចជួយអ្នកដទៃឲ្យកាន់តែមានគំនិតសុទិដ្ឋិនិយមផងដែរ ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

រឿង សូមឲ្យកុមារម្នាក់កាន់រូបភាពនៅទំព័រ 82 ។ សូមប្រាប់រឿងដូចខាងក្រោម ៖

ម៉ារី និង ម៉ាក់របស់នាង បានទៅដើរលេង *(សូមចង្អុលទៅរូបម៉ារី និង ម៉ាក់នៅក្នុងរូបភាព)* ។ ពួកគេបានដើរកាត់មនុស្សដែលមានមុខក្រញ៉ូវមួយចំនួន *(សូមឲ្យកុមារធ្វើមុខក្រញ៉ូវ)* ។ ម៉ារី បានសួរម៉ាក់ « ហេតុអ្វីបានជាមនុស្សកើតទុក្ខខ្លាំងម្ល៉ះ ? » ម៉ាក់បាននិយាយថា « ម៉ាក់មិនដឹងទេ ប៉ុន្តែយើងអាចញញឹមដាក់ពួកគេ ហើយជួយធ្វើឲ្យពួកគេរីករាយ » ។

នៅពេលពួកគេដើរ ម៉ារីបានឃើញស្ត្រីម្នាក់ដើរតម្រង់ឆ្ពោះមករកពួកគេ ។ ម៉ារី បានបង្ហាញស្នាមញញឹមយ៉ាងធំរបស់នាង *(សូមអញ្ជើញកុមារបង្ហាញស្នាមញញឹមយ៉ាងធំបំផុតរបស់ពួកគេ)* ។ នៅពេលស្ត្រីនោះបានឃើញទឹកមុខរីករាយរបស់ម៉ារី គាត់បានញញឹមតបវិញ ។ ម៉ារីបាននិយាយថា « វាមានប្រសិទ្ធភាពមែន ! » ម៉ាក់បាននិយាយថា « នៅពេលយើងជ្រើសរើសមានចិត្តរីករាយ វាជួយអ្នកដទៃឲ្យរីករាយផងដែរ » ។

ចូរសុំកុមារឲ្យញញឹមមកអ្នក ។ សូមប្រាប់ពួកគេថា ស្នាមញញឹមរបស់ពួកគេ អាចជួយមនុស្សគ្រប់គ្នាឲ្យមានអារម្មណ៍រីករាយ ។ សូមអញ្ជើញកុមារឲ្យនិយាយថា « រីករាយ » ។

ចម្រៀង សូមច្រៀង ឬ អានពាក្យនៅក្នុងបទ « ញញឹម » *(សៀវភៅចម្រៀងកុមារ ទំព័រ 267)* ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមនឹងអ្នក ។

បើមុខអ្នកប្រែជាក្រញ៉ូវ *(សូមទាញបបូរមាត់ចុះ ធ្វើជាមុខក្រញ៉ូវ)*
កុំទុកនៅឲ្យយូរ ។ *(សូមគ្រវីក្បាលចុះឡើង)*
ចូរផ្លាស់វាឲ្យបានរហ័ស
ប្រញាប់ញញឹមជួសវិញ ។ *(សូមទាញមាត់ធ្វើជាញញឹម)*
គេមិនចូលចិត្តមុខក្រញ៉ូវ ។ *(សូមទាញបបូរមាត់ចុះធ្វើមុខក្រញ៉ូវ)*
ផ្លាស់វាទៅញញឹម ។ *(សូមទាញមាត់ធ្វើជាញញឹម)*
ចូរធ្វើឲ្យលោកិយប្រសើរ ។
ដោយការញញឹមគ្រប់ពេល ។ *(សូមងក់ក្បាល)*

ល្បែងកំសាន្ត សូមឲ្យកុមារឈរជារង្វង់ ។ សូមប្រាប់ពួកគេថា អ្នកនឹងហាត់រៀនពីការចែកចាយស្នាមញញឹម ។ សូមឈរនៅខាងមុខកុមារម្នាក់ ហើយសូមញញឹមដាក់គាត់ ឬ នាង ។ សូមអញ្ជើញកុមារឲ្យញញឹម ។ បន្ទាប់មក សូមនិយាយថា « ចូរចែកចាយស្នាមញញឹមរបស់យើង » ។ សូមដឹកដៃកុមារទៅរកកុមារម្នាក់ទៀត ហើយញញឹម ។ សូមអញ្ជើញកុមារថ្មីឲ្យកាន់ដៃរបស់កុមារទីមួយ ហើយសូមចែកចាយស្នាមញញឹមជាមួយនឹងកុមារផ្សេងទៀត ។ សូមបន្តធ្វើរហូតដល់កុមារទាំងអស់បានកាន់ដៃគ្នា ។

គន្លឹះក្នុងការបង្រៀន

ចម្រៀង ៖ កុមារចូលចិត្តអ្វីដែលពួកគេបានឃើញ និង បានស្តាប់ឮពីមុន ។ សូមច្រៀងចម្រៀងមកពីមេរៀននេះ ឬ មេរៀនពីមុន។ នៅពេលណាក៏បាន អំឡុងពេលថ្នាក់ទារកដ្ឋាន ។ ការធ្វើបែបនេះ នឹងជួយពួកគេរៀនអំពីចម្រៀង ហើយសូមចងចាំអំពីគោលការណ៍ដំណឹងល្អនានាដែលអ្នកបានបង្រៀន ។

ល្បែងកំសាន្ត ៖ ដូចជានៅក្នុងសកម្មភាពផ្សេង។ សូមសម្របសម្រួលល្បែងកំសាន្តនេះទៅតាមទំហំថ្នាក់ទារកដ្ឋានរបស់អ្នក ។ បើអ្នកមានកុមារច្រើន អ្នកអាចនឹងចង់ចែកចាយស្នាមញញឹមជាមួយនឹងកុមារពីរ ឬ បីនាក់ម្តង ។

សេចក្តីបញ្ចប់ សូមប្រាប់កុមារថា នៅពេលយើងជ្រើសរើសដើម្បីមានការរីករាយ នោះយើងអាចជួយអ្នកដទៃឲ្យមានអារម្មណ៍រីករាយផងដែរ ។ សូមអញ្ជើញកុមារឲ្យនិយាយថា « ខ្ញុំអាចសប្បាយចិត្ត ! »

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់សកម្មភាពរំឭក ៖* សូមគូសចំណាំទំព័រ 67 នៅក្នុងសៀវភៅសិក្សានេះ ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។ សូមនាំយករូបភាពនៃវត្ថុទាំងឡាយ ដែលអ្នកមានអំណរគុណមកជាមួយ ។ អ្នកក៏អាចប្រើរូបភាពនានានៅក្នុងសៀវភៅសិក្សានេះ ឬ នៅក្នុងទស្សនាវដ្តីសាសនាចក្រ ឬ អ្នកអាចគូសរូបដោយខ្លួនឯង ។
សម្រាប់សកម្មភាពរូបភាព ៖ សូមថតចម្លងរូបភាពនៅទំព័រ 83 សម្រាប់កុមារម្នាក់ៗ ។

ចម្រៀង សូមច្រៀង ឬ អានពាក្យនៅក្នុងបទ « បើអ្នកសប្បាយ » (*សៀវភៅចម្រៀងកុមារ* 266) ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ។

បើអ្នកដឹងថា អ្នកសប្បាយចិត្ត សូមទះដៃ ។ (*សូមទះដៃ ទះដៃ*)
បើអ្នកដឹងថា អ្នកសប្បាយចិត្ត សូមទះដៃ ។ (*សូមទះដៃ ទះដៃ*)
បើអ្នកដឹងថា អ្នកសប្បាយចិត្ត
ហើយបង្ហាញនៅលើផ្ទៃមុខអ្នក (*សូមញញឹម ; សូមចង្អុលទៅមុខ*)
បើអ្នកដឹងថា អ្នកសប្បាយចិត្ត សូមទះដៃ ។ (*សូមទះដៃ ទះដៃ*)

សូមធ្វើសារឡើងវិញ ដោយជំនួស « ការទះដៃ » ជាមួយនឹងសកម្មភាពដទៃទៀតដូចជា « បង្វិលខ្លួន » « ទះជង្គង់ » ជាដើម ។

វគ្គសកម្មភាព សូមរៀបរាប់វគ្គសកម្មភាពដូចខាងក្រោម ហើយសូមអញ្ជើញកុមារឲ្យចូលរួមជាមួយនឹងអ្នក ៖

ស្នាមញញឹមមួយ គឺងាយស្រួលខ្លាំងណាស់ ។ (*សូមទាញមាត់ ធ្វើជាញញឹម*)
ដូច្នេះនៅពេលខ្ញុំមានអារម្មណ៍សោកសៅ (*សូមទាញបបូរមាត់ ធ្វើជាមុខក្រញ៉ូវ*)
ខ្ញុំព្យាយាមញញឹមឡើងវិញ (*សូមទាញមាត់ ធ្វើជាញញឹម*)
មិនយូរប៉ុន្មាន ខ្ញុំមានអារម្មណ៍រីករាយ ! (*សូមដាក់ដៃទាំងពីរនៅលើដើមទ្រូង*)

ការពិនិត្យឡើងវិញ សូមធ្វើសកម្មភាពក្នុងរូបភាពពីរដែលយកចេញមកពីមេរៀនទី 15 សារឡើងវិញ (ទំព័រ 64 និង 65) ។ សូមពន្យល់ថា ការចងចាំនូវអ្វីល្អៗទាំងអស់ ដែលព្រះវរបិតាសួគ៌បានប្រទានដល់យើង អាចជួយយើងមានអារម្មណ៍រីករាយ ។

រូបភាព សូមផ្តល់រូបភាពមុខញញឹម-មុខក្រញ៉ូវមួយច្បាប់ន ទំព័រ 83 ដល់កុមារម្នាក់ៗ ។ សូមអញ្ជើញកុមារឲ្យមើលទៅរូបភាពរបស់ពួកគេ នៅពេលពួកគេច្រៀងបទ « ញញឹម » ម្តងទៀត ។ សូមជួយពួកគេផ្លាស់ទីកមុខរបស់ពួកគេពីមុខក្រញ៉ូវទៅជាមុខញញឹម នៅពេលសមរម្យក្នុងបទចម្រៀងនោះ ។

គន្លឹះក្នុងការបង្រៀន

សកម្មភាពជម្រើស ៖ ដើម្បីក្សាចំណាប់អារម្មណ៍ និង ការចូលរួមយ៉ាងសកម្មភាពរបស់កុមារ សូមប្រើវិធីសាស្ត្របង្រៀនផ្សេងៗ ។ ការផ្លាស់ប្តូរឿងទៅជាចម្រៀង, វគ្គសកម្មភាព, ល្បែងកំសាន្ត និង ការធ្វើចលនា ។ សូមរៀបចំកុំឲ្យច្រើនជាងពីរ ឬ បីនាទីសម្រាប់សកម្មភាពនីមួយៗ ។ (សូមមើល *Teaching, No Greater Call* ទំព័រ 72, 89–90) ។

ការរំឭក ៖ សូមធ្វើសកម្មភាពចេញមកពីមេរៀនមុន។សារឡើងវិញឲ្យបានញឹកញាប់ តាមចំណូលចិត្តអ្នក ។ ការធ្វើសារឡើងវិញ គឺសម្បាយសម្រាប់កុមារ ហើយវាជួយពួកគេរៀន ។

ខ្ញុំអាចសប្បាយចិត្ត



20 ខ្ញុំនឹងមានគារវភាព

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

គារវភាព គឺជាអាកប្បកិរិយាមួយដែលមានការគោរព និង ការស្រឡាញ់យ៉ាងជ្រាលជ្រៅចំពោះព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។ គារវភាព គឺមានអត្ថន័យច្រើនជាងការនៅស្ងៀមស្ងាត់ និង ការអង្គុយនៅស្ងៀមអំឡុងពេលមេរៀន ខណៈដែលគារវភាពរបស់យើង ជាញឹកញាប់ វាស្តែងចេញតាមរបៀបដែលយើងធ្វើសកម្មភាពនៅព្រះវិហារ និង នៅកន្លែងពិសិដ្ឋដទៃទៀត ។ នៅពេលយើងព្យាយាមដើម្បីកាន់តែមានគារវភាព នោះយើងនឹងទទួលអារម្មណ៍ពីព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធកាន់តែខ្លាំងនៅក្នុងជីវិតរស់នៅរបស់យើង ។ (សូមមើល គ. និង ស. 63:64 ; 84:54 ; 109:21) ។

សកម្មភាពក្នុងការបង្រៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

រូបភាព សូមបង្ហាញរូបភាពនៅទំព័រ 86 ។ សូមប្រាប់កុមារថា គ្រួសារនេះ គឺនៅក្នុងព្រះវិហារ ហើយពួកគេមានគារវភាព ។ សូមអញ្ជើញកុមារឲ្យនិយាយថា « គារវភាព » ។ សូមពន្យល់ថា ការមានគារវភាព គឺមានន័យថាជាការគិតដោយស្ងៀមស្ងាត់អំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។ សូមពន្យល់រឿងដែលគ្រួសារនៅក្នុងរូបភាពកំពុងធ្វើដើម្បីបង្ហាញថាពួកគេមានគារវភាព ។ សូមយកចិត្តទុកដាក់ជាពិសេសចំពោះកុមារនៅក្នុងរូបភាព ។

ការហាត់រៀន សូមជួយកុមារឲ្យយល់ថា នៅពេលយើងមកព្រះវិហារ យើងអាចបង្ហាញក្តីស្រឡាញ់របស់យើងចំពោះព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវតាមរយៈការមានគារវភាព ។ សូមពិពណ៌នាអំពីរបៀបមួយចំនួន ដែលយើងអាចបង្ហាញគារវភាពនៅព្រះវិហារ ហើយសូមហាត់ធ្វើជាមួយនឹងកុមារ ។ ឧទាហរណ៍ ៖

- យើងនិយាយដោយសំឡេងតិចៗ ។ *(សូមហាត់និយាយតិចៗ)*
- យើងដើរថ្នមជើង ។ *(សូមហាត់ដើរដោយស្ងៀមស្ងាត់)*
- យើងអង្គុយដោយស្ងៀមស្ងាត់ ។ *(សូមហាត់អង្គុយដោយស្ងៀមស្ងាត់)*
- យើងស្តាប់គ្រូបង្រៀនរបស់យើង ។ *(សូមយកដៃដាក់ក្បាច់ត្រចៀក)*
- យើងគិតអំពីព្រះយេស៊ូវ ។ *(សូមចង្អុលទៅក្បាល)*

ចម្រៀង សូមពន្យល់ថា របៀបផ្សេងទៀតដែលយើងបង្ហាញគារវភាព គឺតាមរយៈការច្រៀងចម្រៀងដែលប្រកបដោយគារវភាព ។ សូមច្រៀង ឬ អានពាក្យនៅក្នុងបទ « ខ្ញុំព្យាយាមមានគារវភាព » *(សៀវភៅចម្រៀងកុមារទំព័រ 28)* ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ។

ខ្ញុំស្រឡាញ់ព្រះបិតាខ្ញុំ *(សូមដាក់ដៃលើដើមទ្រូង)*
ខ្ញុំនឹងមានគារវភាព *(សូមចង្អុលទៅខ្លួនឯង)*
ពេលខ្ញុំនៅក្នុងដំណាក់ទ្រង់ ។ *(សូមដាក់ចុងចង្អុលម្រាមដៃទល់គ្នា ធ្វើជាដំបូលផ្ទះ)*
នោះទ្រង់នឹងគង់ជិតខ្ញុំ ។ *(សូមឱបខ្លួនឯង)*

សេចក្តីបញ្ចប់ សូមសរសើរកុមារដែលមានគារវភាព ។ សូមពន្យល់ថា រឿងទាំងនេះ នឹងជួយយើង និងអ្នកទាំងឡាយដែលនៅជុំវិញយើងឲ្យគិតអំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវ ។ សូមឲ្យកុមារនិយាយថា « ខ្ញុំនឹងមានគារវភាព » ។ សូមអញ្ជើញពួកគេឲ្យមានគារវភាពនៅថ្ងៃនេះ ។

ការអធិស្ឋាន សូមប្រាប់កុមារថា វាដល់ពេលអធិស្ឋានបិទហើយ ។ សូមសួរថា « តើអ្នកអាចមានគារវភាពអំឡុងពេលអធិស្ឋានដោយរបៀបណា ? » សូមជួយពួកគេហាត់រៀនឱបដៃ ឱនក្បាល ហើយបិទភ្នែកនៅពេលអ្នកអធិស្ឋាន ។ សូមរំឭកកុមារថា ការធ្វើដូច្នេះ នឹងជួយយើងបង្ហាញដល់ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវថា យើងស្រឡាញ់ពួកទ្រង់ ។ សូមសរសើរពួកគេចំពោះការបង្ហាញគារវភាព ។

គន្លឹះក្នុងការបង្រៀន

គារវភាព ៖ « សូមគិតនូវរឿងសាមញ្ញ។ ដែលអ្នកអាចធ្វើដើម្បីរំឭក [កុមារ] ឲ្យមានគារវភាព ។ អ្នកអាចស្តារមរិយាកាសឲ្យមានគារវភាពឡើងវិញ តាមរយៈការច្រៀងតិច ឬ ការត្រហឹមមុនចម្រៀងគារវភាព ការដាក់តាំងរូបភាព ឬ ការប្រើសញ្ញាដៃ ដែលកុមារទទួលស្គាល់ថាជាការរំឭកមួយឲ្យមានគារវភាព ។

« ចូរចងចាំថា វាពិបាកណាស់សម្រាប់កុមារដើម្បីអង្គុយនៅស្ងៀមមួយកន្លែងក្នុងរយៈពេលយូរនោះ ។ សូមជួយកុមារឲ្យស្តាប់ និង ចូលរួមដោយសកម្ម ។ សូមឲ្យពួកគេឈប់សម្រាកម្តងម្កាល » (*Teaching, No Greater Call* ទំព័រ 83) ។

ការនិយាយឃ្លាឡើងវិញ ៖ កុមារមួយចំនួនពុំអាចនិយាយឃ្លាឡើងវិញជាមួយអ្នកបានទេ ។ នោះវាមិនអីទេ ។ ពួកគេនឹងនៅតែរៀនតាមរយៈការមើលអ្នក និង ការស្តាប់អ្នក និង កុមារដទៃទៀត ។

សកម្មភាពផម្រើស

ការរៀបចំខ្លួន *សម្រាប់សកម្មភាពសៀវភៅបើកមើលរូប* ៖ សូមថតចម្លងរូបភាពនៅទំព័រ 87 សូមជាត់ពណ៍ តាមចំណូលចិត្ត ។ សូមកាត់តាមចំណុចបន្ទាត់ត្រង់ ហើយធ្វើជាសន្លឹកបើកពីរ ។ សូមបត់សន្លឹកសៀវភៅដើម្បីបាំងគំនូរ ។

សម្រាប់សកម្មភាពជាត់ពណ៍ ៖ សូមថតចម្លងរូបភាពនៅទំព័រ 87 សម្រាប់កុមារម្នាក់ៗជាត់ពណ៍ ។ សូមកាត់តាមបន្ទាត់ ដើម្បីធ្វើជាសៀវភៅបើកមើលសម្រាប់កុមារ ។

សៀវភៅបើកមើល សូមលើករូបភាពដែលអ្នកបានរៀបចំនោះឡើង ដោយមានសន្លឹកសៀវភៅគ្របពីលើគំនូរ ។ សូមប្រាប់កុមារថា អ្នកនឹងបង្ហាញពួកគេនូវរូបភាពមួយចំនួន ដែលបង្ហាញយើងអំពីរបៀបដើម្បីមានគារវភាពអំឡុងពេលអធិស្ឋាន ។ សូមបើកសន្លឹកសៀវភៅខាងលើគេ ហើយអានពាក្យនៅខាងក្នុង ។ សូមធ្វើដូចគ្នាជាមួយនឹងសន្លឹកសៀវភៅក្រោមៗទៀត ។ ចូរធ្វើសកម្មភាពសារឡើងវិញ ម្តងនេះសូមអញ្ជើញកុមារឲ្យហាត់ឱនក្បាល បិទភ្នែក ហើយឱបដៃរបស់ពួកគេ ។

វគ្គសកម្មភាព សូមរៀបរាប់នូវខគម្ពីរដូចខាងក្រោម ហើយសូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ៖

បើក បិទ *(សូមលាដៃ ហើយបិទដៃ)*
បើក បិទ *(សូមលាដៃ ហើយបិទដៃ)*
សូមទះដៃតិចៗ ។ *(សូមទះដៃ)*
បើក បិទ *(សូមលាដៃ ហើយបិទដៃ)*
បើក បិទ *(សូមលាដៃ ហើយបិទដៃ)*
សូមដាក់ដៃលើភ្លៅរបស់អ្នក ។ *(សូមក្តោបដៃទាំងពីរដាក់លើភ្លៅ)*

ការជាត់ពណ៍ សូមឲ្យកុមារជាត់ពណ៍រូបសៀវភៅបើកមើល ដែលអ្នកបានរៀបចំសម្រាប់ពួកគេ ។

គន្លឹះក្នុងការបង្រៀន

ការសរសើរ ៖ « ចូរកុំផ្តល់ឆាងូន់ ឬ អាហារ ចំពោះតរិយាបទ ដែលមានគារវភាពឡើយ ។ ចូរកុំមានការប្រឡងប្រណាំងដើម្បីមើលថា តើនរណាអាចមានគារវភាពជាងគេនោះឡើយ ។ ការធ្វើដូច្នេះ នឹងនាំឲ្យផ្តោតទៅលើប្រឹងខុសគ្គង ។ សូមបង្រៀនអំពីរង្វាន់ពិតនៃគារវភាព ដូចជាការយល់ដឹងកើនឡើង និង ការកើននៃតន្ទិពលពីព្រះវិញ្ញាណ » (*Teaching, No Greater Call* ទំព័រ 83) ។ សូមសរសើរដោយពាក្យសម្តីជាក់លាក់ដល់កុមារនៅពេលពួកគេបង្ហាញគារវភាព ឧទាហរណ៍ ៖ « ខ្ញុំចូលចិត្តរបៀបដែល ម៉ារី អង្គុយយ៉ាងមានគារវភាព ។ អរគុណ ម៉ារី » ។

ការជាត់ពណ៍ ៖ ខណៈពេលដែលកុមារកំពុងជាត់ពណ៍ សូមរំឲ្យកគោលការណ៍នានាដែលបានបង្រៀននៅក្នុងមេរៀន ។ សូមចង្អុលបង្ហាញពីតឹមានលម្អិតនៅក្នុងរូបភាព ហើយសូមពន្យល់ដល់ពួកគេអំពីអ្វីដែលពួកគេកំពុងជាត់ពណ៍ ។ សូមអានពាក្យនៅលើរូបភាពដល់ពួកគេ ។

ខ្ញុំបិទភ្នែក ហើយឱនក្បាល

ហើយឱបដៃពេល
ធ្វើការអធិស្ឋាន ។

21 យ៉ូសែប ស្ម៊ីធ បានឃើញព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

យ៉ូសែប ស្ម៊ីធ គឺជាព្យាការីទីមួយក្នុងជំនាន់របស់យើង ។ លោកបានឃើញ និង បាននិយាយជាមួយនឹងព្រះ ជាព្រះវរបិតា និង ព្រះយេស៊ូវគ្រីស្ទ ។ តាមរយៈព្យាការីយ៉ូសែប ព្រះអម្ចាស់បានស្តារសាសនាចក្រពិត និង ភាពពេញលេញនៃដំណឹងល្អឡើងវិញ ។ (សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:9–19) ។

ការរៀបចំខ្លួន

- សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:9–19 ហើយសូមរៀបចំប្រាប់រឿងអំពីការនិមិត្តដំបូងដោយសង្ខេប ។
- សូមនាំយកព្រះគម្ពីរបរិសុទ្ធមកជាមួយ ។
- សូមនាំយកគម្ពីរមុក្តាដ៏មានតម្លៃហិមាមកជាមួយ ។ សូមគូសចំណាំយ៉ូសែប —ស្ម៊ីធ ប្រវត្តិ 1:17ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។

សកម្មភាពក្នុងការបង្រៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

រឿងបទគម្ពីរ សូមបង្ហាញរូបភាពនៅទំព័រ 90 នៅពេលអ្នកប្រាប់រឿងអំពីការនិមិត្តដំបូងដោយសង្ខេប (សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:9–19) ។ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយ ៖

នេះគឺជារូបភាពរបស់យ៉ូសែប ស្ម៊ីធ *(សូមចង្អុលទៅរូប យ៉ូសែប ; សូមអញ្ជើញកុមារឲ្យនិយាយថា « យ៉ូសែប ស្ម៊ីធ »)* ។ លោកចង់ដឹងថា ព្រះវិហារមួយណាពិត ។ លោកបានអាននៅក្នុងគម្ពីរបរិសុទ្ធ *(សូមបើកគម្ពីរបរិសុទ្ធ)* ដែលយើងអាចអធិស្ឋានដើម្បីឲ្យដឹងពីសេចក្តីពិត *(សូមអញ្ជើញកុមារឲ្យធ្វើជាអាន)* ។ យ៉ូសែប បានទៅក្នុងព្រៃ *(សូមចង្អុលទៅដើមឈើ)* ដើម្បីសូមសួរដល់ព្រះវរបិតាសួគ៌ក្នុងការអធិស្ឋាន ។ ខណៈពេលដែលលោកកំពុងអធិស្ឋាន នោះលោកមើលឃើញព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។

សូមបើកគម្ពីរមុក្តាដ៏មានតម្លៃហិមា យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:17 ហើយសូមប្រាប់កុមារថា អ្នកនឹងអាននូវអ្វីដែលព្រះវរបិតាសួគ៌ បានមានបន្ទូលទៅកាន់យ៉ូសែប ស្ម៊ីធ ។ សូមពន្យល់ថា ទ្រង់បានចង្អុលទៅកាន់ព្រះយេស៊ូវគ្រីស្ទ ហើយបានមានបន្ទូល ៖ « នេះគឺជាបុត្រសំណព្វរបស់យើង ។ ចូរស្តាប់តាមទ្រង់ចុះ ! » សូមពន្យល់ថា ព្រះយេស៊ូវបានប្រាប់យ៉ូសែបថា លោកនឹងនាំសាសនាចក្រពិតនៃព្រះយេស៊ូវគ្រីស្ទឲ្យមានឡើងវិញ ។

ការហាត់រៀន សូមប្រាប់រឿងម្តងទៀត ។ ម្តងនេះ សូមឲ្យកុមារឈរលាតដៃចេញ ធ្វើដូចជាដើមឈើនៅក្នុងព្រៃ ។ សូមឲ្យកុមារយោលខ្លួន ដូចជាត្រូវខ្យល់បក់ ខណៈពេលដែលអ្នកនិយាយអំពីការអធិស្ឋានរបស់យ៉ូសែប ។ បន្ទាប់មក សូមឲ្យពួកគេឈរនៅនឹង ហើយស្ងៀមស្ងាត់នៅពេលអ្នកប្រាប់ពួកគេថា ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវបានយាងចេញមកជួបនឹងយ៉ូសែប ។

ចម្រៀង សូមច្រៀង ឬ អានពាក្យដូចខាងក្រោមក្នុងបទ « និទាឃរដូវមាស » *សៀវភៅចម្រៀងកុមារទំព័រ 88*) ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ។

និទាឃរដូវមាសនៅក្នុងព្រៃធំមួយ *(សូមលើកដៃឡើងដូចជាដើមឈើ)*
ព្រះបិតា និង បុត្រាបង្ហាញអង្គទ្រង់ កាលយ៉ូសែបបានលុតជង្គង់អធិស្ឋាន ។ *(សូមលុតជង្គង់ ហើយឱបដៃ)*

សេចក្តីបញ្ចប់ សូមចែកចាយទីបន្ទាល់របស់អ្នកដោយសង្ខេបអំពី យ៉ូសែប ស្ម៊ីធ បានឃើញព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។

គន្លឹះក្នុងការបង្រៀន

រឿងទាំងឡាយ ៖ កុមារតូចៗមានរយៈពេលយកចិត្តទុកដាក់ខ្លី ។ សូមរៀបចំរបៀបនានាដែលជួយឲ្យកុមារចូលរួមក្នុងសាច់រឿងនេះ ។ ជាឧទាហរណ៍ អ្នកអាចឲ្យពួកគេគាន់រូបភាព ឬ និយាយឃ្លាសារឡើងវិញ ។ សូមឈប់ឲ្យបានញឹកញាប់ ដើម្បីចង្អុលបង្ហាញព័ត៌មានលម្អិតនៅក្នុងរូបភាព ហើយសូមបង្ហាញរូបភាពឲ្យយូរល្មមសម្រាប់កុមារម្នាក់ៗ។ មើល មុនពេលអ្នកចាប់ផ្តើមនិយាយរឿងបន្ត ។ (សូមមើល *Teaching, No Greater Call* ទំព័រ 181) ។

ចម្រៀង ៖ « ពាក្យចុងជួននៅក្នុងតន្ត្រី ជួយកុមារឲ្យចាំនូវអ្វីដែលពួកគេច្រៀង និង សារលិខិតនៃទំនុកបទ » (*Teaching, No Greater Call* ទំព័រ 174) ។ តន្ត្រីក៏ជាវិធីមួយដ៏មានប្រសិទ្ធភាពដើម្បីអញ្ជើញព្រះវិញ្ញាណនៅក្នុងថ្នាក់ឆងដែរ ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់រឿងតុក្កតាអាយ៉ងដែលប្រើម្រាមដៃ ៖* សូមថតចម្លង ហើយសូមកាត់រូបតុក្កតាអាយ៉ងដែលប្រើម្រាមដៃចេញមកពីទំព័រ 91 ឬ ប្រើរូបតុក្កតាអាយ៉ងដែលអ្នកបានធ្វើសម្រាប់សកម្មភាពជម្រើស នៅក្នុងមេរៀនទី 9 ។ សូមជាត់ពណ៌រូបតុក្កតាអាយ៉ង តាមចំណូលចិត្ត ។

សម្រាប់សកម្មភាពជាត់ពណ៌ ៖ សូមថតចម្លងរូបភាពនៅទំព័រ 91 សម្រាប់កុមារម្នាក់ៗជាត់ពណ៌ ។

វគ្គសកម្មភាព សូមធ្វើវគ្គសកម្មភាពដូចខាងក្រោម ហើយសូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ៖

យ៉ូសែប បានលុតជង្គង់នៅក្នុងព្រៃ *(សូមលើកដៃឡើងដូចដើមឈើ)*

ហើយលោកបានអធិស្ឋានជាពិសេសមួយ ។ *(សូមឱបដៃ)*

លោកបានឃើញព្រះបិតា និង ព្រះបុត្រា *(សូមមើលទៅលើដោយយកដៃបាំងភ្នែក)*

ហើយបានស្តាប់ព្រះទ្រង់ទាំងពីរអង្គនៅទីនោះ ។ *(សូមយកដៃដាក់ក្បាលត្រចៀក)*

សកម្មភាពរូបតុក្កតាអាយ៉ងដែលប្រើម្រាមដៃ សូមប្រាប់រឿងអំពីការនិមិត្តដំបូងឡើងវិញដោយសង្ខេប ម្តងនេះសូមប្រើរូបតុក្កតាអាយ៉ងដែលប្រើម្រាមដៃ ដែលអ្នកបានរៀបចំ ។ សូមឲ្យកុមារកាន់រូបតុក្កតាអាយ៉ង បើពួកគេចង់ ។

ការជាត់ពណ៌ សូមឲ្យកុមារម្នាក់ៗជាត់ពណ៌រូប ដែលបានថតចម្លងចេញពីទំព័រ 91 ។ ខណៈពេលដែលពួកគេកំពុងជាត់ពណ៌ សូមរំឭករឿងការនិមិត្តដំបូងឡើងវិញ ។ សូមចង្អុលបង្ហាញព័ត៌មានលម្អិតក្នុងរូបភាព ហើយសូមពន្យល់ដល់កុមារអំពីអ្វីដែលគេកំពុងជាត់ពណ៌ ។ សូមអានពាក្យនៅលើរូបភាពដល់ពួកគេ ។

គន្លឹះក្នុងការបង្រៀន

ទីបន្ទាល់ ៖ សូមឆ្លៀងនូវទីបន្ទាល់របស់អ្នកតាមរបៀបសាមញ្ញ និងសង្ខេប ឧទាហរណ៍ដូចជា ៖ « ខ្ញុំដឹងថា យ៉ូសែប ស្ម៊ីធ បានឃើញព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ » ។

រូបតុក្កតាអាយ៉ងដែលប្រើម្រាមដៃ ៖ បើអ្នកជ្រើសរើសធ្វើសកម្មភាពនេះ អ្នកអាចនឹងចង់ធ្វើរូបតុក្កតាអាយ៉ងដែលប្រើម្រាមដៃឲ្យបានច្រើនល្មម ដើម្បីឲ្យកុមារម្នាក់ៗអាចលេង ។

កុមារធំៗ ៖ ចូរពិចារណាអញ្ជើញកុមារធំៗ ឲ្យប្រាប់រឿងអំពីការនិមិត្តដំបូងសារជាថ្មី ដល់កុមារតូចៗ ។ សូមបង្ហាញពួកគេពីរបៀបប្រើរូបតុក្កតាអាយ៉ងដែលប្រើម្រាមដៃ ឬ រូបភាពនៅទំព័រ 42 ដើម្បីនិទានរឿង ។ ការជួយកុមារបង្រៀនគ្នាទៅវិញទៅមក គឺជាវិធីមួយដ៏ល្អ ដើម្បីជួយពង្រឹងបន្ថែមទៅលើអ្វីដែលអ្នកបានបង្រៀនដល់ពួកគេ ។



សូមថតចម្លងទំព័រនេះ ហើយសូម
កាត់រូបតុក្កតាអាយ៉ងដែលប្រើ
ម្រាមដៃតាមខ្សែបន្ទាត់ត្រង់ ។ សូម
បត់តាមបន្ទាត់ចុចៗ ។ បន្ទាប់មក
សូមបិទគែមៗ ដោយទុកគែមខាង
ក្រោមចំហរ ដើម្បីឲ្យកុមារអាច
ដាក់ម្រាមដៃរបស់ពួកគេក្នុងតុក្កតា
អាយ៉ងនោះបាន ។



22 ព្រះគម្ពីរមរមន បង្រៀនខ្ញុំអំពីព្រះយេស៊ូវគ្រីស្ទ

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

ព្រះគម្ពីរមរមន គឺជាសាក្សីដ៏មានព្រះចេស្តាមួយអំពីព្រះយេស៊ូវគ្រីស្ទ ។ វាមាននូវទីបន្ទាល់របស់ពួកព្យាការីពីបុរាណ ដែលបានទស្សន៍ទាយអំពីការយាងមករបស់ទ្រង់ ហើយដែលបានយល់អំពីបេសកកម្មរបស់ទ្រង់ ។ វាមាននូវកំណត់ត្រាមួយអំពីការយាងរបស់ទ្រង់ ទៅកាន់ទ្វីបអាមេរិក មិនយូរប៉ុន្មានបន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់ (សូមមើល នីហ្វៃទី 3 11–27) ។ គោលបំណងចម្បងនៃព្រះគម្ពីរមរមន គឺដើម្បីបញ្ចុះបញ្ចូលមនុស្សទាំងអស់ថា « ព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ ជាព្រះដ៏នៅអស់កល្បជានិច្ច ដែលបានសម្តែងរូបអង្គទ្រង់ដល់គ្រប់ទាំងសាសន៍ » (ទំព័រចំណងជើងនៃព្រះគម្ពីរមរមន ; សូមមើលផងដែរ នីហ្វៃទី1 13:40–41 ; នីហ្វៃទី2 25:26 ; 33:10–11) ។

ការរៀបចំខ្លួន

- សូមគូសចំណាំទំព័រ 22, 94 និង 126 នៅក្នុងសៀវភៅសិក្សានេះ ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។
- សូមនាំយកព្រះគម្ពីរមរមនមកជាមួយ ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

ចម្រៀង សូមច្រៀងចម្រៀងក្នុងវគ្គបន្ទរនៃបទ « ស្វែងរក, គិត, អធិស្ឋាន » (*សៀវភៅចម្រៀងកុមារ* ទំព័រ 109) ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ។

ការស្វែងរក *(សូមធ្វើដូចជាបើកសៀវភៅ)* គិត *(សូមចង្អុលទៅក្បាល)* និង អធិស្ឋាន *(សូមឱបដៃ)*
គឺជាអ្វីដែលខ្ញុំត្រូវធ្វើ ។ *(សូមចង្អុលខ្លួនឯង)*
ព្រះវិញ្ញាណនឹងដឹកនាំដក់ក្នុងចិត្ត *(សូមដាក់ដៃនៅលើដើមទ្រូង)*
ខ្ញុំដឹងថាព្រះគម្ពីរពិត ។ *(សូមចង្អុលទៅក្បាល)*

រូបភាព សូមលើកព្រះគម្ពីរមរមនឡើង ។ សូមប្រាប់កុមារថា « នេះគឺជាព្រះគម្ពីរមរមន ។ ព្រះគម្ពីរមរមន បង្រៀនយើងអំពីព្រះយេស៊ូវ » ។ សូមអញ្ជើញកុមារឲ្យនិយាយថា « ព្រះគម្ពីរមរមន » ។ សូមបើកព្រះគម្ពីរមរមន ហើយសូមដាក់វានៅខាងមុខអ្នក ។

សូមដាក់បង្ហាញរូបភាពនៃប្រសូត្រកម្ម (ទំព័រ 126 នៃសៀវភៅសិក្សានេះ) ។ សូមចង្អុលទៅព្រះគម្ពីរមរមន ហើយសូមប្រាប់កុមារថា ព្រះគម្ពីរមរមនបង្រៀនថា ព្រះយេស៊ូវគ្រីស្ទបានយាងមកផែនដី ។

សូមដាក់បង្ហាញរូបភាពព្រះយេស៊ូវ ព្យាបាលពួកសាសន៍នីហ្វៃ (ទំព័រ 94) ។ សូមចង្អុលទៅព្រះគម្ពីរមរមន ហើយសូមប្រាប់កុមារថា ព្រះគម្ពីរមរមនបង្រៀនថា ព្រះយេស៊ូវ បានព្យាបាលអ្នកឈឺ ។

សូមដាក់បង្ហាញរូបភាពព្រះយេស៊ូវ ប្រទានពរដល់កុមារតូចៗសាសន៍នីហ្វៃ (ទំព័រ 22) ។ សូមចង្អុលទៅព្រះគម្ពីរមរមន ហើយសូមប្រាប់កុមារថា ព្រះគម្ពីរមរមនបង្រៀនថា ព្រះយេស៊ូវ បានប្រទានពរដល់កុមារតូចៗ ។

សេចក្តីបញ្ចប់ សូមឲ្យកុមារនិយាយថា « ព្រះគម្ពីរមរមន បង្រៀនខ្ញុំអំពីព្រះយេស៊ូវគ្រីស្ទ » ពីរបីពាក្យម្តង ។ សូមប្រាប់ពួកគេថា អ្នកដឹងថា ព្រះគម្ពីរមរមនពិត ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

គន្លឹះក្នុងការបង្រៀន

ការរៀបចំ ៖ បើអ្នករៀបចំរឿងរូបភាព និង ល្បែងកំសាន្តនានាបានល្អ មុនពេលថ្នាក់ទាំងនេះចាប់ផ្តើម នោះអ្នកនឹងអាចផ្តោតការយកចិត្តទុកដាក់របស់អ្នកទៅលើកុមារបាន ។ សូមស្វែងរកការដឹកនាំពីព្រះវិញ្ញាណប្រកបដោយការអធិស្ឋាន នៅពេលអ្នករៀបចំមេរៀន ។

ចម្រៀង ៖ អ្នកអាចប្រើចម្រៀងកុមារស្នើតែគ្រប់មេរៀន ដើម្បីណែនាំ ឬ សង្ខេបគំនិតមួយ ។ ចម្រៀងកុមារ ជួយកុមារបានៀន និង ចងចាំអំពីគោលការណ៍នៃដំណឹងល្អទាំងឡាយ ។ វាក៏អនុញ្ញាតឲ្យកុមារថ្លែងទីបន្ទាល់របស់ពួកគេដោយសាមញ្ញ និង យ៉ាងល្អប្រពៃផងដែរ ។

ព្រះគម្ពីរ ៖ ការបើកព្រះគម្ពីរ ហើយនិងចង្អុលទៅបទគម្ពីរ ខណៈពេលដែលអ្នកកំពុងបង្រៀន ជួយកុមារឲ្យយល់ថារឿងរបស់ព្រះយេស៊ូវចេញមកពីព្រះគម្ពីរ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់ល្បែងជាថង់ ៖* សូមថតចម្លងរូបភាពនៅទំព័រ 95 ។ សូមកាត់តាមចំណុចចុចៗ ។ សូមដាក់រូបភាពនៅក្នុងថង់មួយ ឬ ប្រអប់ផ្សេងទៀត ។

សម្រាប់សៀវភៅ ៖ សូមថតចម្លងរូបភាពពីទំព័រ 95 សម្រាប់កុមារម្នាក់ៗជាត់ពណ៌ ។

វគ្គសកម្មភាព សូមសូត្រវគ្គសកម្មភាពដូចខាងក្រោម ហើយសូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ៖

ចូរអានព្រះគម្ពីរមរមន ។ *(សូមចាប់ផ្តើមដោយដាក់ដៃផ្គុំគ្នា បន្ទាប់មកសូមបើកដូចជាសៀវភៅ)*

សូមអានវាជារៀងរាល់ថ្ងៃ ។

មុនពេលអ្នកចាប់ផ្តើមសិក្សា *(សូមចង្អុលទៅក្បាល)*

ចូរកុំភ្លេចអធិស្ឋាន ។ *(សូមឱបដៃ)*

[Terri Clark « Read the Book of Mormon » *Friend* ខែមិនា ឆ្នាំ 2004 ទំព័រ 11]

ល្បែងថង់ សូមឲ្យកុមារជ្រើសរើសរូបភាពមួយចេញពីថង់ ឬ ប្រអប់ ។ សូមអានចំណងជើងនៅលើរូបភាពដល់កុមារ ។ សូមធ្វើសារឡើងវិញរហូតដល់កុមារម្នាក់ៗ ដល់វេនរបស់ខ្លួន ។

សៀវភៅ សូមឲ្យកុមារម្នាក់ៗ ជាត់ពណ៌រូបភាពដែលថតចម្លងមកពីទំព័រ 95 ។ ខណៈពេលដែលពួកគេកំពុងជាត់ពណ៌ សូមនិយាយជាមួយពួកគេអំពីរូបភាព ។ សូមចង្អុលទៅព្រះយេស៊ូវនៅក្នុងរូបភាពនីមួយៗ ។ នៅពេលពួកគេបញ្ចប់ការជាត់រូប សូមបត់តាមចំណុចចុចៗ ដើម្បីធ្វើជាសៀវភៅ ។ បន្ទាប់មក សូមអានសៀវភៅដល់កុមារ ។



គន្លឹះក្នុងការបង្រៀន

សកម្មភាព ៖ សូមជួយកុមារឲ្យចូលរួមជាមួយអ្នក ដោយប្រើសកម្មភាពផ្សេង។ ។ ការធ្វើដូច្នេះ ប្រហែលជាវិធីល្អបំផុតមួយដើម្បីការពារកុំឲ្យមានការរំខាន ។ (សូមមើល *Teaching, No Greater Call* ទំព័រ 72, 80) ។

កុមារតូច។ ងាយស្រួលនឹងត្រូវបានរំខាន ។ នៅពេលអ្នកដឹកនាំថ្នាក់ទារកដ្ឋានម្នាក់កំពុងបង្រៀន ឬ ដឹកនាំសកម្មភាព នោះអ្នកដឹកនាំថ្នាក់ទារកដ្ឋានម្នាក់ទៀត អាចជួយដឹកនាំឲ្យកុមារយកចិត្តទុកដាក់ក្នុងសកម្មភាព ។ ការឲ្យអ្វីមួយដល់កុមារកាន់ ក៏អាចជួយគាត់ ឬ នាង ចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពផងដែរ ។

ព្រះគម្ពីរមរមន បង្រៀនខ្ញុំអំពី ព្រះយេស៊ូវគ្រីស្ទ



ព្រះគម្ពីរមរមនបង្រៀនថា ព្រះយេស៊ូវ បានប្រទានពរដល់កុមារតូចៗ
(សូមមើលនីហ្វៃទី 3 17:21–24) ។



លម្ពីរមរមន (ឌ្នមធ្មៃតមធាចបាន វ៉ូស្ទ៉ាះហ៊ា ចាមង្រៀរបានមរមរម្ពីតះហ៊ា
ឆ្លាតម្ពីរ 7:10–12) ។



ញ្ញាតម្ពីរបាយាបាន វ៉ូស្ទ៉ាះហ៊ា ចាមង្រៀរបានមរមរម្ពីតះហ៊ា
(ឆ្លាតម្ពីរ 3 17:7–10) ។

23 ខ្ញុំស្រឡាញ់ព្រះគម្ពីរ

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ទទួលយកគម្ពីរបរិសុទ្ធបរិសុទ្ធ, ព្រះគម្ពីរមរមន, ព្រះគម្ពីរគោលលទ្ធិ និង សេចក្តីសញ្ញា ព្រមទាំងព្រះគម្ពីរមុក្តាដ៏មានតម្លៃមហិមា ជាព្រះគម្ពីរ ។ គោលបំណងនៃព្រះគម្ពីរ គឺដើម្បីថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ដោយជួយយើងឲ្យមករកទ្រង់ ហើយទទួលបានជីវិតដ៏អស់កល្បជានិច្ច (សូមមើល នីហ្វៃទី2 25:26 ; ហេលេមិន 3:29–30) ។ ព្រះគម្ពីរក៏រួមមាននូវរឿងអំពីប្រជាជន ដែលត្រូវបានប្រទានពរ តាមរយៈការគោរពតាមព្រះវរបិតាសួគ៌ផងដែរ ។ នីហ្វៃ បានបង្ហាញសេចក្តីស្រឡាញ់របស់គាត់ចំពោះព្រះគម្ពីរតាមរបៀបនេះ ៖ « ត្បិតព្រលឹងខ្ញុំត្រេកអរចំពោះបទគម្ពីរទាំងឡាយ ឯចិត្តខ្ញុំរំពឹងគិតពីបទគម្ពីរទាំងនោះ » (នីហ្វៃទី 2 4:15) ។

ការរៀបចំខ្លួន

- សូមអាន ម៉ាកុស 10:13–16 និងនីហ្វៃទី1 17:7–10 ; 18:1–4 ។ សូមត្រៀមខ្លួនដើម្បីសង្ខេបរឿងទាំងនេះឲ្យខ្លីៗសម្រាប់កុមារ ។
- សូមនាំយកព្រះគម្ពីរមកជាមួយ ។
- សូមគូសចំណាំ ទំព័រ 70 នៅក្នុងសៀវភៅនេះ ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

សេចក្តីណែនាំខាងគោលលទ្ធិ សូមបង្ហាញព្រះគម្ពីររបស់អ្នកដល់កុមារ ហើយសូមប្រាប់ពួកគេថា អ្នកស្រឡាញ់ព្រះគម្ពីរខ្លាំងប៉ុណ្ណា ។ សូមអញ្ជើញកុមារឲ្យនិយាយថា « ព្រះគម្ពីរ » ។ សូមប្រាប់ពួកគេថា យើងរៀនអំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ចេញមកពីព្រះគម្ពីរ ។ យើងដឹងថា ពួកទ្រង់ស្រឡាញ់យើង ហើយទ្រង់ចង់ឲ្យយើងរីករាយ ។

រឿងបទគម្ពីរ សូមបង្ហាញរូបភាពនៅលើទំព័រ 98 ហើយសូមចង្អុលទៅរូបព្រះយេស៊ូវ ។ សូមពន្យល់ថា បទគម្ពីរបង្រៀនយើងអំពីព្រះយេស៊ូវ ។ សូមបើកព្រះគម្ពីរបរិសុទ្ធបរិសុទ្ធ ហើយសូមសង្ខេបរឿងអំពីព្រះយេស៊ូវដែលបានប្រទានពរដល់កុមារដោយខ្លីៗ (សូមមើល ម៉ាកុស 10:13–16) ។ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយ ៖

ព្រះយេស៊ូវ ស្រឡាញ់កុមារ ។ ថ្ងៃមួយ មានមនុស្សមួយចំនួនបាននាំកូនតូចៗរបស់ពួកគេមករកព្រះយេស៊ូវ *(សូមចង្អុលទៅកូនតូចៗនៅក្នុងរូបភាព)* ។ ទ្រង់នាំពួកគេមកក្នុងរង្វង់ព្រះហស្តទ្រង់ ហើយប្រទានពរដល់ពួកគេ ។

សូមដាក់បង្ហាញរូបភាពនៅទំព័រ 70 ។ សូមពន្យល់ថា បទគម្ពីរប្រាប់យើងអំពីប្រជាជនដែលត្រូវបានប្រទានពរ នៅពេលពួកគេបានគោរពតាមព្រះវរបិតាសួគ៌ ។ សូមបើកព្រះគម្ពីរមរមន ហើយសូមសង្ខេបរឿងដោយខ្លីអំពីការសាងសង់សំពៅរបស់នីហ្វៃ (សូមមើល នីហ្វៃទី1 17:7–10 ; 18:1–4) ។ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយ ៖

នេះគឺជានីហ្វៃ *(សូមចង្អុលទៅរូបនីហ្វៃក្នុងរូបភាព)* ។ ព្រះអម្ចាស់ បានមានព្រះបន្ទូលប្រាប់នីហ្វៃឲ្យសង់សំពៅ ។ នីហ្វៃ ពុំដែលសង់សំពៅពីមុនទេ ប៉ុន្តែគាត់បានគោរពតាម ។ ព្រះអម្ចាស់ បានបង្ហាញពីរបៀបសង់សំពៅដល់គាត់ ។ *(សូមឲ្យកុមារធ្វើជាសង់សំពៅមួយ)*

ចម្រៀង សូមច្រៀង ឬ អានវគ្គបន្ទរនៅក្នុងបទ « ស្វែងរក, គិត, អធិស្ឋាន » *សៀវភៅចម្រៀងកុមារ* ទំព័រ 109) ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ។

ការស្វែងរក *(សូមធ្វើជាបើកព្រះគម្ពីរ)* គិត អធិស្ឋាន *(សូមឱបដៃ)* គឺជាអ្វីដែលខ្ញុំត្រូវធ្វើ ។ *(សូមចង្អុលមកខ្លួនឯង)*

គន្លឹះក្នុងការបង្រៀន

ព្រះគម្ពីរ ៖ « នៅពេលអ្នកបង្រៀនកុមារ អ្នកគួរតែប្រើព្រះគម្ពីរឲ្យបានញឹកញាប់ ហើយសូមរកវិធីដើម្បីឲ្យកុមារច្នៃក្នុងការប្រើព្រះគម្ពីរ » (*Teaching, No Greater Call* ទំព័រ 59) ។ សូមជួយពួកគេឲ្យស្គាល់មនុស្ស និង រឿងទាំងឡាយនៅក្នុងព្រះគម្ពីរ ។ សូមជួយពួកគេមើលឃើញថា អ្វីដែលអ្នកបង្រៀនពួកគេ គឺចេញមកពីព្រះគម្ពីរ ។

ចម្រៀង ៖ នៅពេលច្រៀង ឬ សូត្រខគម្ពីរមួយទៅកុមារ សូមទន្ទេញឲ្យចាំពាក្យ និង សកម្មភាពទាំងឡាយ ។ ការធ្វើដូច្នោះ នឹងជួយអ្នកឲ្យបន្តផ្តោតមើលទៅកុមារ ហើយបង្ហាញពីចំណាប់អារម្មណ៍របស់អ្នកចំពោះសកម្មភាព ។

ព្រះវិញ្ញាណនឹងដឹកនាំដក់ក្នុងចិត្ត
ខ្ញុំដឹងថាព្រះគម្ពីរពិត ។ *(សូមធ្វើជាកាន់សៀវភៅដែលបើកមួយ)*

សេចក្តីបញ្ចប់ សូមឲ្យកុមារនិយាយឃ្លា « ខ្ញុំស្រឡាញ់ព្រះគម្ពីរ » សារឡើងវិញ ។ សូមចែកចាយក្តីស្រឡាញ់របស់អ្នកចំពោះព្រះគម្ពីរ និង ទីបន្ទាល់របស់អ្នកថា ព្រះគម្ពីរគឺពិត ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់សកម្មភាពរូបតុក្កតាអាយ៉ង ៖* សូមថតចម្លង ហើយសូមកាត់រូបភាព ដែលចម្លងនោះចេញពីទំព័រ 99) សម្រាប់កុមារម្នាក់ៗ ហើយសូមថតចម្លងបន្ថែមសម្រាប់ខ្លួនអ្នក ។ សូមបិទស្អិត ឬ បិទការលើឈើមួយនៅពីខាងក្រោយរូបភាពនីមួយៗ ដើម្បីធ្វើជាឈើរបស់រូបតុក្កតាអាយ៉ងនោះ ។

សកម្មភាពរូបតុក្កតាអាយ៉ង សូមឲ្យកុមារជាត់ពណ៌រូបភាពដែលអ្នកបានកាត់ ។ នៅពេលពួកគេបញ្ចប់ការជាត់រូប សូមលើករូបតុក្កតា អាយ៉ងរូប អ័ដាម និង អេវ៉ា របស់អ្នកឡើង ហើយសូមអញ្ជើញកុមារឲ្យលើករូបរបស់ពួកគេឡើងផងដែរ ។ សូមឲ្យពួកគេនិយាយថា « អ័ដាម និង អេវ៉ា » ។ សូមបើកគម្ពីរសញ្ញាចាស់ ហើយសូមប្រាប់កុមារថា បទគម្ពីរប្រាប់យើងថា អ័ដាម និង អេវ៉ា គឺជាមនុស្សដំបូងនៅលើផែនដី ; ពួកគេបានរស់នៅក្នុងសួនច្បារអេដែន ។ សូមឲ្យកុមារធ្វើជាឲ្យរូបតុក្កតាអាយ៉ងរបស់ពួកគេដើរនៅក្នុងសួនច្បារ ។

សូមលើករូបតុក្កតាអាយ៉ង រូបណូអេ របស់អ្នកឡើង ហើយសូមអញ្ជើញកុមារឲ្យលើករូបរបស់ពួកគេឡើងផងដែរ ។ សូមឲ្យពួកគេនិយាយថា « ណូអេ » ។ សូមប្រាប់ពួកគេថា បទគម្ពីរប្រាប់យើងថា ណូអេបានសង់សំពៅមួយ ហើយបានប្រមូលសត្វដាក់នៅលើសំពៅរបស់គាត់ ។ សូមឲ្យកុមារធ្វើជាសត្វពាហនៈ ។



សូមលើករូបតុក្កតាអាយ៉ង រូបម៉ូសេរបស់អ្នកឡើង ហើយសូមអញ្ជើញកុមារឲ្យលើករូបរបស់ពួកគេឡើងផងដែរ ។ សូមឲ្យពួកគេនិយាយថា « ម៉ូសេ » ។ សូមប្រាប់ពួកគេថា បទគម្ពីរប្រាប់យើងថា ព្រះអម្ចាស់បានប្រទានក្រឹត្យវិន័យដប់ប្រការដល់ម៉ូសេ ។ សូមអញ្ជើញកុមារឲ្យលើកម្រាមដៃ 10 ឡើង ខណៈពេលដែលអ្នករាប់ដល់10 ។

វគ្គសកម្មភាព សូមរៀបរាប់វគ្គសកម្មភាពដូចខាងក្រោម ហើយសូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ៖

បង្រៀនខ្ញុំពីព្រះគម្ពីរ *(សូមធ្វើដូចជាអានព្រះគម្ពីរ)*
ព្រះគម្ពីរប្រាប់ខ្ញុំពីសេចក្តីពិត ។ *(សូមចង្អុលខ្លួនឯង)*
បង្រៀនខ្ញុំពីរបៀបដែលព្យាការីគោរពតាម ។
បង្រៀនខ្ញុំពីព្រះគម្ពីរ *(សូមធ្វើដូចជាអានគម្ពីរ)*
ខ្ញុំត្រូវតែដឹងពីសេចក្តីពិត ។*(សូមចង្អុលខ្លួនឯង)*
បង្រៀនខ្ញុំ ដូច្នេះខ្ញុំនឹងស្គាល់ផ្លូវ ។

គន្លឹះក្នុងការបង្រៀន

ការជាត់ពណ៌ ៖ ខណៈពេលដែលកុមារកំពុងជាត់ពណ៌ សូមប្រាប់ពួកគេអំពីមនុស្សនៅក្នុងរូបភាព ។ សូមពន្យល់ថាព្រះគម្ពីរប្រាប់យើងនូវរឿងពិតទាំងឡាយអំពីប្រជាជនទាំងនេះ និង អ្នកដទៃទៀតជាច្រើន ដែលបានគោរពតាមព្រះវរបិតាសួគ៌ ។

បើអ្នកចង់បាន អ្នកអាចរង់ចាំដើម្បីប្រមូលរូបតុក្កតាអាយ៉ងដែលបិទលើឈើរបស់កុមារបន្ទាប់ពីពួកគេបានជាត់ពណ៌រូបភាពរួច ។ ឬ អ្នកអាចឲ្យកុមារយករូបភាពទៅផ្ទះ ឲ្យឪពុកម្តាយរបស់ពួកគេប្រមូល ។

វគ្គសកម្មភាព ៖ អ្នកអាចប្រើវគ្គសកម្មភាពនៅគ្រប់ពេល ក្នុងថ្នាក់ទារកដ្ឋាន នៅពេលណាដែលកុមារត្រូវការធ្វើចលនា ឬ នៅពេលដែលអ្នកត្រូវការឲ្យកុមារយកចិត្តទុកដាក់ ។ វាក៏ជាវិធីមួយល្អ ដើម្បីឭកគោលការណ៍ទាំងឡាយ ដែលអ្នកបានបង្រៀនពីមុនផងដែរ ។



អ័ដាម និង អេវ៉ា



ណូអេ

ម៉ូសេ

24 ខ្ញុំនឹងធ្វើតាមព្យាការី

គន្លឹះក្នុងការបង្រៀន

*សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន*មុនពេលការរៀបចំមេរៀន សូមចំណាយពេលមួយសន្ទុះដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណ ។ ឧទាហរណ៍ អ្នកអាចអានការណែនាំពេលចាប់ផ្តើមមេរៀន រួមមានទាំងបទគម្ពីរដែលបានសរសេរទុក ។ ការសិក្សាគោលលទ្ធិនៅក្នុងមេរៀន អាចជួយអ្នកឲ្យទទួលយកការបំផុសគំនិតពីព្រះវិញ្ញាណ នៅពេលអ្នករៀបចំមេរៀន និង នៅពេលអ្នកបង្រៀនមេរៀនដល់កុមារ ។ (សូមមើល *Teaching, No Greater Call* ទំព័រ 14) ។

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

ព្យាការី គឺជាបុរសម្នាក់ ដែលត្រូវបានហៅដោយព្រះ ដើម្បីនិយាយជំនួសទ្រង់ ។ ពួកព្យាការី ទទួលព្រះបន្ទូលរបស់ព្រះតាមរយៈវិវរណៈ ហើយបន្ទាប់មកត្រូវបានបញ្ជាឲ្យផ្សាយទៅកាន់ប្រជាជន (សូមមើល អេម៉ុស 3:7 ; នីហ្វៃទី1 22:2 ; គ. និង ស. 1:38 ; Bible Dictionary « Prophet » 754) ។ យើងមានពរ ដែលត្រូវបានដឹកនាំដោយព្យាការីដែលនៅរស់ ។ ក៏ដូចជាព្យាការីពីបុរាណដែរ ព្យាការីសម័យបច្ចុប្បន្ន ថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ហើយបង្រៀនដំណឹងល្អរបស់ទ្រង់ ។ ការបង្រៀនរបស់ពួកគាត់ គឺជាព្រះទ័យ និង ព្រះឆន្ទៈរបស់ព្រះអម្ចាស់ ។

ការរៀបចំខ្លួន

សូមនាំយក រូបភាពប្រធានសាសនាចក្របច្ចុប្បន្នមកជាមួយ បើសិនជាមាន ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

ល្បែងកំសាន្ត សូមអញ្ជើញកុមារឲ្យលេងល្បែង « ធ្វើតាមអ្នកដឹកនាំ » ជាមួយអ្នក ។ សូមជ្រើសរើសកុមារម្នាក់ឲ្យដើរ ទះដៃ ឬ ធ្វើសកម្មភាពផ្សេងៗទៀត ។ សូមប្រាប់កុមារដទៃទៀតឲ្យធ្វើតាមកុមារទីមួយ ដោយធ្វើតាមអ្វីដែលគេបានធ្វើ ។ សូមបន្តលេងរហូតដល់កុមារម្នាក់ៗ ដែលចង់ដល់វេនធ្វើជាអ្នកដឹកនាំបានធ្វើម្តង ។ សូមកុមារឲ្យធ្វើតាមអ្នកទៅតាមមេរៀន ហើយសូមឲ្យពួកគេអង្គុយចុះ ។

សេចក្តីណែនាំខាងគោលលទ្ធិ សូមប្រាប់កុមារថា យើងមានអ្នកដឹកនាំពិសេសម្នាក់ដើម្បីធ្វើតាម គឺជាព្យាការីរបស់យើង ។ សូមពន្យល់ថា ព្យាការីគឺជាបុរសម្នាក់ដែលនិយាយជាមួយនឹងព្រះ— ព្រះប្រាប់ព្យាការីនូវអ្វីដែលយើងគួរធ្វើ ។ សូមប្រាប់កុមារថា បើយើងធ្វើតាមព្យាការី នោះយើងនឹងរីករាយ ហើយព្រះវរបិតាសួគ៌ នឹងប្រទានពរដល់យើង ។ សូមពន្យល់ថា ការធ្វើតាមព្យាការី មានន័យថាធ្វើអ្វីៗដែលគាត់ប្រាប់ឲ្យយើងធ្វើ ។

រូបភាព សូមបង្ហាញរូបភាព យ៉ូសែប ស៊្មីធ (ទំព័រ 102) ។ សូមនិយាយថា « នេះគឺជាព្យាការី យ៉ូសែប ស៊្មីធ ។ ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវ បានមានបន្ទូលទៅកាន់យ៉ូសែប ស៊្មីធ » ។ សូមហុចរូបភាពទៅឲ្យកុមារម្នាក់កាន់ ។ សូមប្រាប់កុមារនូវរឿងមួយដែលព្យាការី យ៉ូសែប ស៊្មីធ បានបង្រៀនយើងឲ្យធ្វើដូចជា ការអានព្រះគម្ពីរ ។ សូមឲ្យកុមារធ្វើដូចជាអានព្រះគម្ពីរ ហើយសូមអញ្ជើញពួកគេឲ្យនិយាយថា « ធ្វើតាមព្យាការី » ។ សូមហុចរូបភាពទៅឲ្យកុមារម្នាក់ទៀត ហើយសូមធ្វើសកម្មភាពដដែល ដោយធ្វើនូវអ្វីមួយផ្សេងទៀត ដែលព្យាការីបានបង្រៀនដូចជា ការអធិស្ឋាន ការបរិភោគអាហារល្អៗ ជាដើម ។ សម្រាប់សកម្មភាពនីមួយៗ សូមឲ្យកុមារនិយាយថា « ធ្វើតាមព្យាការី » ។ សូមបន្តរហូតដល់កុមារគ្រប់រូបមានឱកាសកាន់រូបភាព ។

សូមបង្ហាញរូបថតរបស់ប្រធាននៃសាសនាចក្រសព្វថ្ងៃ បើមាន ។ សូមប្រាប់កុមារនូវឈ្មោះរបស់គាត់ និង អ្វីមួយចំនួនដែលគាត់បានបង្រៀនឲ្យយើងធ្វើ ។ សូមពន្យល់ថា នៅពេលយើងធ្វើតាមរឿងទាំងនេះ នោះយើងនឹងបានប្រទានពរ ។

ការសម្តែង សូមអញ្ជើញកុមារឲ្យសម្តែងធ្វើជាអ្វី ដែលយើងអាចធ្វើតាមព្យាការី ។

ចម្រៀង សូមអញ្ជើញកុមារឲ្យដើរជុំវិញបន្ទប់ជាមួយអ្នក នៅពេលអ្នកច្រៀង ឬ អានពាក្យនៅក្នុងវគ្គបន្ទរនៃបទ « ធ្វើតាមព្យាការី »(*សៀវភៅចម្រៀងកុមារ* ទំព័រ 111) ៖

ធ្វើតាមព្យាការី, ធ្វើតាមព្យាការី
ធ្វើតាមព្យាការី កុំដើរផ្លូវខុស ។
ធ្វើតាមព្យាការី, ធ្វើតាមព្យាការី
ធ្វើតាមព្យាការី គាត់ស្គាល់ផ្លូវត្រូវ ។

សូមអញ្ជើញកុមារឲ្យច្រៀងជាមួយអ្នក ។ សូមធ្វើសារឡើងវិញ ដោយអនុញ្ញាតឲ្យកុមារផ្លាស់វេនដឹកនាំការដើរ ។ សូមពន្យល់ថា ការវង្វេង គឺមានន័យថាជាការធ្វើអ្វីខុសឆ្គង ។

សេចក្តីបញ្ចប់ សូមប្រាប់កុមារថា អ្នកដឹងថា នៅពេលយើងធ្វើតាមព្យាការី នោះយើងនឹងត្រូវបានប្រទានពរ ។ សូមឲ្យកុមារនិយាយថា « ខ្ញុំនឹងធ្វើតាមព្យាការី » ពីរបីពាក្យម្តង ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់សកម្មភាពរូបភាព និង ល្បែងទាយ ៖* សូមថតចម្លង ហើយសូមកាត់រូបភាពនៅលើទំព័រ 103 ។ សូមផាត់ពណ៍តាមចំណូលចិត្ត ។ សូមបត់តាមចំណុចចុចៗ ដើម្បីធ្វើជារូបឈរ ។

សម្រាប់សកម្មភាពផាត់ពណ៍ ៖ សូមថតចម្លង ហើយសូមកាត់រូបភាពនៅទំព័រ 103 សម្រាប់កុមារម្នាក់ៗផាត់ពណ៍ ។

រូបភាព សូមប្រាប់កុមារថា អ្នកនឹងជួយពួកគេឲ្យរៀនអំពីព្យាការីមួយចំនួន ដែលបានរស់នៅជាយូរលង់មកហើយ ។ សូមដាក់រូបភាពឈរចំនួនបួន នៅលើតដ្ឋ ឬ នៅលើតុ ។ សូមឲ្យកុមារផ្លាស់វេនគ្នាជ្រើសរើសរូបភាពមួយ ។ សូមប្រាប់ឈ្មោះរបស់ព្យាការី ហើយអានចំណងជើងដល់កុមារ ។ សូមអញ្ជើញកុមារឲ្យនិយាយពាក្យគន្លឹះឡើងវិញក្នុងចំណងជើងដូចជា « អធិស្ឋាន » « បុណ្យជ្រមុជទឹក » « គោរព » និង « ព្រះគម្ពីរ » ។ សូមធ្វើសារឡើងវិញទាល់តែកុមារម្នាក់ៗ ដែលចង់ធ្វើ បានធ្វើម្តង ។

ល្បែងទាយ សូមឲ្យកុមារបិទភ្នែករបស់ពួកគេ ឬ បែរខ្នង នៅពេលអ្នកដាក់រូបភាពឈរនៅកន្លែងណាមួយក្នុងបន្ទប់ ។ សូមប្រាកដថា កុមារងាយស្រួលរកឃើញរូបភាពទាំងនោះ ។ សូមឲ្យកុមារដើររករូបភាពទាំងនោះ ។ នៅពេលពួកគេរកឃើញមួយ សូមឲ្យពួកគេយកវាមកដាក់នៅកន្លែងរៀនមេរៀនវិញ ។ សូមប្រាប់ឈ្មោះរបស់ព្យាការី ហើយអានចំណងជើងឲ្យកុមារស្តាប់ ។ សកម្មភាពនេះ សមរម្យសម្រាប់កុមារធំៗជាពិសេស ។

ការផាត់ពណ៍ សូមឲ្យកុមារផាត់ពណ៍រូបភាពថតចម្លងមកពីទំព័រ 103 ។ នៅពេលពួកគេផាត់ពណ៍រួច សូមបត់តាមចំណុចចុចៗ ដើម្បីធ្វើជារូបឈរ ដើម្បីឲ្យកុមារយកទៅផ្ទះ ។ បើអ្នកពុំមានពេលធ្វើរូបភាព អំឡុងពេលថ្នាក់ទារកដ្ឋានទេ ចូរសុំឲ្យឱពុកម្តាយរបស់កុមារធ្វើវានៅផ្ទះ ។

គន្លឹះក្នុងការបង្រៀន

សកម្មភាពជម្រើស ត្រូវបានផ្តល់ដល់អ្នកដើម្បីជាជំនួយបន្ថែមចំពោះមេរៀន តាមចំណូលចិត្ត ។ ប្រើពុំមានសម្ភារដែលត្រូវការទេ អ្នកអាចជំនួសរបស់ដែលស្រដៀងគ្នាបាន ។

រូបភាព ៖ កុមារអាចនឹងចូលចិត្តស្តាប់អំពីរឿងរបស់ព្យាការីទាំងនេះជងដែរ ។ សូមប្រើ ដានីយ៉ែល 6:4–23 (ដានីយ៉ែលនៅក្នុងរូងសត្វតោ) ម៉ាថាយ 3:13–16 (យ៉ូហានបាទីស្ម ជ្រមុជទឹកព្រះយេស៊ូវ) ហេលមិន 13:2–4; 16:1–3 (សាំយ៉ូអែលជាសាសន៍លេមិន) និង បុព្វកថានៃព្រះគម្ពីរមរមន (យ៉ូសែប ស្មីធ បកប្រែផ្នាំងចំណារមាស) ។ សូមចងចាំថាត្រូវឲ្យរឿងមានភាពសាមញ្ញបំផុត និង សង្ខេបឲ្យខ្លី ។

ល្បែងទាយ ៖ តាមធម្មតា កុមារតូច។ ចង់ដឹងចង់ឃើញ ហើយពុំចង់បិទភ្នែក ឬ ប្រែខ្នងរបស់ពួកគេឡើយ ។ ពួកគេនឹងនៅតែពេញចិត្តមើលអ្នកលាក់រូបភាពបន្ទាប់មករត់ទៅយកវា ពេលអ្នកប្រាប់ពួកគេឲ្យទៅ ។



៤ រួយហសយង្ឆិតេន្ធខ្ញុំ



៤ រួយហសយង្ឆិតេន្ធខ្ញុំ



៤ រួយហសយង្ឆិតេន្ធខ្ញុំ



៤ រួយហសយង្ឆិតេន្ធខ្ញុំ



ដានីយែ៉ល បានបង្រៀនយើងថា យើងគួរតែ
អធិស្ឋាន ។



យ៉ូហាន-បាទីស្ទ បានបង្រៀនយើងឲ្យទទួល
បុណ្យជ្រមុជទឹក ។



សាំយ៉ូអែល ជាសាសន៍លេមិន បានបង្រៀន
យើងឲ្យគោរពតាមព្រះវរបិតាសួគ៌ ។

យ៉ូសែប ស្មីធ បានបង្រៀនយើងឲ្យអាន
ព្រះគម្ពីរ ។

25 ខ្ញុំជារបស់ផងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

នៅពេលព្រះយេស៊ូវគ្រីស្ទគង់នៅលើផែនដី ទ្រង់បានស្ថាបនាសាសនាចក្ររបស់ទ្រង់ឡើង ។ បន្ទាប់ពីការឆ្កាងរបស់ព្រះគ្រីស្ទ និង ការស្លាប់របស់ពួកសាវក នោះសេចក្តីពិតនៃដំណឹងល្អ ត្រូវបានបាត់បង់ ហើយសាសនាចក្រពិត ត្រូវបានដកចេញពីផែនដី ។ តាមរយៈព្យាការីយ៉ូសែប ស៊្មីធ នោះភាពពេញលេញនៃដំណឹងល្អ ត្រូវបានស្តារឡើងវិញ ហើយសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ចាប់មាននៅលើផែនដីនេះម្តងទៀត ។ (សូមមើល គ. និង ស. 1:15–30 ; យ៉ូសែប ស៊្មីធ—ប្រវត្តិ 1:68–72) ។

ការរៀបចំខ្លួន

- សូមនាំយកព្រះគម្ពីរមួយច្បាប់មកជាមួយ ។ សូមគូសចំណាំគ. និង ស 115:4ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។
- សូមយករូបភាពប្រធានសាសនាចក្របច្ចុប្បន្នមកជាមួយ បើមាន ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

រូបភាព សូមដាក់បង្ហាញរូបភាពនៅទំព័រ 106 ។ សូមប្រាប់កុមារថា នេះគឺជារូបភាពមួយរបស់ព្រះយេស៊ូវគ្រីស្ទ ហើយយើងជារបស់ផងសាសនាចក្រទ្រង់ ។ សូមចង្អុលទៅរូបភាព ហើយសូមសួរថា « តើនេះជានរណា ? »

ចម្លើយ ៖ « ព្រះយេស៊ូវគ្រីស្ទ » ។

បទគម្ពីរ សូមប្រាប់កុមារថា ព្រះយេស៊ូវ បានប្រាប់ឈ្មោះសាសនាចក្រដល់យើងនៅក្នុងបទគម្ពីរ ។ សូមបើកព្រះគម្ពីរ ហើយអាន គ. និង ស. 115:4 ៖ « ត្បិតសាសនាចក្ររបស់យើង នឹងត្រូវបានហៅថាដូច្នោះ ហើយនៅគ្រាចុងក្រោយបង្អស់ គឺជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ » ។ សូមអញ្ជើញកុមារឲ្យនិយាយឈ្មោះសាសនាចក្រជាមួយអ្នកសារឡើងវិញ ដោយនិយាយពីរបីពាក្យម្តង ។

សូមលើកព្រះគម្ពីររបស់អ្នកឡើង ។ សូមប្រាប់កុមារថា ព្រះយេស៊ូវ ប្រាប់យើងអំពីអ្វីដែលទ្រង់ចង់ឲ្យយើងដឹងនៅក្នុងបទគម្ពីរ ហើយថានៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ យើងមានព្រះគម្ពីរ ។ សូមឲ្យកុមារលាតដៃរបស់ពួកគេធ្វើដូចជាកំពុងអានព្រះគម្ពីរ ។ សូមអញ្ជើញពួកគេឲ្យនិយាយថា « សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ » ។

សូមពន្យល់ថា ព្រះយេស៊ូវ មានព្រះបន្ទូលទៅកាន់ពួកព្យាការីរបស់ទ្រង់ ហើយថានៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ យើងមានពួកព្យាការី ។ សូមអញ្ជើញកុមារឲ្យនិយាយថា « សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ » ។ សូមបង្ហាញរូបភាពមួយរបស់ព្យាការីបច្ចុប្បន្ននៃសាសនាចក្រ ។ សូមពន្យល់ថា គាត់គឺជាព្យាការីនាសព្វថ្ងៃរបស់យើង ។ សូមអញ្ជើញកុមារឲ្យនិយាយឈ្មោះរបស់គាត់ជាមួយអ្នក ។

ចម្រៀង សូមអញ្ជើញកុមារឲ្យដើរជាមួយអ្នកនៅជុំវិញបន្ទប់ ខណៈពេលដែលអ្នកច្រៀង ឬ អានពាក្យដូចខាងក្រោមនៃបទ « សាសនាចក្រព្រះយេស៊ូវគ្រីស្ទ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 77) ៖

ខ្ញុំនៅសាសនាចក្រព្រះយេស៊ូវគ្រីស្ទពួកបរិសុទ្ធថ្ងៃចុងក្រោយ ។
ខ្ញុំស្គាល់ខ្លួនឯង ។
ខ្ញុំដឹងផែនការ ។
ដើរតាមទ្រង់ដោយជំនឿ ។

គន្លឹះក្នុងការបង្រៀន

រូបភាព ៖ ដើម្បីបង្រៀនកុមារជាមួយនឹងរូបភាព ដំបូងឡើយត្រូវប្រាប់កុមារថាមានអ្វី ឬ នរណានៅក្នុងរូបភាពនោះជាមុនសិន ។ សូមបង្ហាញព័ត៌មានលម្អិតនៅក្នុងរូបភាព ដើម្បីធ្វើឲ្យកុមារចាប់អារម្មណ៍ ។ បន្ទាប់មក សូមអញ្ជើញពួកគេឲ្យនិយាយមួយ ឬ ពីរ ពាក្យឡើងវិញជាមួយអ្នក ។ នៅពេលកុមារស្តាប់ឮ និងនិយាយពាក្យទាំងនេះ ខណៈដែលកំពុងមើលទៅរូបភាព នោះពួកគេចាប់ផ្តើមរៀនពីពាក្យនៃដំណឹងល្អ ។

ការធ្វើចលនា ៖ កុមារដែលមានអាយុស្ថិតក្នុងថ្នាក់ទារកដ្ឋាន គឺសកម្មខ្លាំងណាស់ ។ សូមប្រើសកម្មភាពទាំងឡាយដែលរួមមាន ការទះដៃ ការដើរជាក្បួន និង ការដើរ ដើម្បីជួយកុមារឲ្យនៅមានចំណាប់អារម្មណ៍ ។

សេចក្តីបញ្ចប់ សូមចែកចាយទីបន្ទាល់របស់អ្នកដោយខ្លីថា យើងស្ថិតនៅក្នុងសាសនាចក្រពិតរបស់ព្រះយេស៊ូវគ្រីស្ទ ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់សកម្មភាពជាត់ពណ៌ និង ល្បែងផ្គូផ្គង ៖* សូមថតចម្លងរូបភាពនៅទំព័រ 107 សម្រាប់កុមារម្នាក់ៗជាត់ពណ៌ ។ សូមយកចម្រៀកក្រដាសតូចៗ ឬ អ្វីមួយដែលស្រដៀងគ្នានោះមក សម្រាប់ឲ្យកុមារប្រើធ្វើជាឧបករណ៍ដាក់ចំណាំ សម្រាប់លេងល្បែងផ្គូផ្គង សូមនាំយកមកឲ្យល្មមសម្រាប់កុមារម្នាក់ៗ មានឧបករណ៍ដាក់ចំណាំចំនួនបីម្នាក់ ។

ការជាត់ពណ៌ សូមឲ្យកុមារជាត់ពណ៌រូបភាពថតចម្លងមកពីទំព័រ 107 ។ ខណៈពេលដែលពួកគេកំពុងជាត់ពណ៌ សូមរំឭកពីគោលការណ៍ទាំងឡាយ ដែលបានបង្រៀននៅក្នុងមេរៀននេះ ។ សូមបង្ហាញពីព័ត៌មានលម្អិតនៅក្នុងរូបភាព ហើយសូមពន្យល់ដល់កុមារអំពីអ្វីដែលពួកគេកំពុងជាត់ពណ៌ ។ សូមអានពាក្យនៅលើរូបភាពដល់ពួកគេ ។



ល្បែងផ្គូផ្គង សូមឲ្យចម្រៀកក្រដាសបីតូចៗដល់កុមារម្នាក់ៗ ។ សូមបង្ហាញរូបភាពនៅទំព័រ 107 ។ សូមចង្អុលទៅរូបគំនូររបស់ព្រះយេស៊ូវ ហើយនិយាយថា « នេះគឺជារូបភាពមួយរបស់ព្រះយេស៊ូវគ្រីស្ទ ។ យើងជារបស់ផងនៃសាសនាចក្ររបស់ទ្រង់ » ។ សូមអញ្ជើញកុមារឲ្យដាក់ចម្រៀកក្រដាសមួយនៅលើរូបភាពព្រះយេស៊ូវលើច្បាប់ចម្លងរបស់ពួកគេ ។

បន្ទាប់មក សូមចង្អុលទៅរូបភាពរបស់ព្យាការី ហើយសូមអានចំណងជើងនោះ ។ សូមឲ្យកុមារនិយាយថា « ព្យាការី » ហើយដាក់ចម្រៀកក្រដាសតូចៗនៅលើគំនូររបស់ពួកគេ ។ សូមធ្វើដូចគ្នាចំពោះគំនូរព្រះគម្ពីរ ។ បន្ទាប់មក សូមឲ្យកុមារនិយាយជាមួយអ្នកថា « ខ្ញុំជារបស់ផងនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ » ជាពាក្យពីរបីម៉ាត់ម្តង ។

ការរំឭកឡើងវិញ សូមជ្រើសរើសសកម្មភាពមួយមកពី មេរៀនទី 23 ហើយមួយទៀតមកពី មេរៀនទី 24 ដើម្បីជួយកុមាររំឭកពីអ្វីដែលពួកគេបានរៀនពីបទគម្ពីរ និង ព្យាការីទាំងឡាយ ។ បន្ទាប់ពីការធ្វើសកម្មភាពទាំងនេះហើយ សូមរំឭកកុមារថា នៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ យើងមានព្រះគម្ពីរ និង ព្យាការី ។

គន្លឹះក្នុងការបង្រៀន

ការជាត់ពណ៌ ៖ ពុំមែនកុមារទាំងអស់ សុទ្ធតែចូលចិត្តជាត់ពណ៌រូបភាពនោះទេ ។ កុមារមួយចំនួនអាចនឹងគូសតែមួយ ឬ ពីរគំនូសនៅលើទំព័រគំនូរតែប៉ុណ្ណោះ ។ គោលបំណងនៃសកម្មភាពជាត់ពណ៌នៅក្នុងមេរៀនទាំងនេះ គឺដើម្បីឲ្យកុមារនូវការបង្ហាញរូបភាពនៃមេរៀនដែលពួកគេអាចកាន់ ហើយយកទៅផ្ទះបាន ។ វាពុំសំខាន់ថា ពួកគេត្រូវតែជាត់ពណ៌រូបភាពដោយប៉ិនប្រសប់នោះឡើយ ។

ការរំឭក ៖ កុមារបៀនមកពីការធ្វើសកម្មភាពជួន។គ្នា ។ សូមនិទានរឿង ឬ ធ្វើសកម្មភាពដទៃទៀតដែលពួកគេហាក់ដូចជាពេញចិត្តនោះសារឡើងវិញ ។ អ្នកអាចធ្វើដូច្នេះនៅគ្រប់ពេល អំឡុងថ្នាក់ទាមកដ្ឋាន ដូចជាអំឡុងពេលបរិភោគអាហារសម្រន់ ឬ ខណៈពេលដែលកុមារកំពុងរង់ចាំឪពុកម្តាយរបស់ពួកគេ ។



ខ្ញុំជារបស់ផងសាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ





សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ មាន ព្យាការី ។



សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ មាន ព្រះគម្ពីរ ។

26 ខ្ញុំនឹងទទួលបុណ្យជ្រមុជទឹក និង ទទួលពិធីបញ្ជាក់

គន្លឹះក្នុងការបង្រៀន

រូបភាព ៖ នៅពេលមានរូបភាពពីរនៅលើទំព័រតែមួយ អ្នកអាចជួយកុមារឲ្យផ្តោតទៅលើរូបភាពតែមួយសិន ដោយគ្របលើរូបភាពមួយទៀត ។

កុមារតូចៗ ៖ កុមារមួយចំនួន ជាពិសេសកុមារតូចៗ ពុំអាចយល់អំពីគំនិតទាំងអស់ដែលបានបង្រៀននៅក្នុងមេរៀនទាំងនេះឡើយ ។ ទោះជាយ៉ាងក៏ដោយ ពួកគេកំពុងរៀនអ្វីមួយជារៀងរាល់សប្តាហ៍ ហើយអ្នកកំពុងជួយដល់ពួកគេឲ្យមានអារម្មណ៍ពីព្រះវិញ្ញាណ ហើយបានស្គាល់ពាក្យ ឬ ឃ្លាដែលទាក់ទងនឹងដំណឹងល្អដែរ ។

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

ព្រះយេស៊ូវគ្រីស្ទ បានទទួលបុណ្យជ្រមុជទឹកដើម្បីបង្ហាញ « ដល់ព្រះវរបិតាថា ទ្រង់នឹងគោរពព្រះអង្គ ដោយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអង្គ » និងដើម្បីធ្វើជាគំរូសម្រាប់យើង (សូមមើល នីហ្វៃទី2 31:7, 9 ; សូមមើលផងដែរ ម៉ាថាយ 3:13–17) ។ នៅពេលយើងទទួលបុណ្យជ្រមុជទឹក យើងក៏បង្ហាញថា យើងមានឆន្ទៈធ្វើតាមព្រះអង្គសង្គ្រោះ ហើយគោរពតាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។ បន្ទាប់ពីព្រះយេស៊ូវទទួលបុណ្យជ្រមុជទឹក នោះ « ព្រះវិញ្ញាណបរិសុទ្ធក៏យាងចុះមកសណ្ឋិតលើទ្រង់ ក្នុងសណ្ឋានជាសត្វព្រាប » (នីហ្វៃទី2 31:8) ។ បន្ទាប់ពីយើងទទួលបុណ្យជ្រមុជទឹក យើងត្រូវបានផ្តល់ឲ្យនូវអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ តាមរយៈពិធីបរិសុទ្ធនៃពិធីបញ្ជាក់ ។ នេះមានន័យថា យើងអាចមានដៃគូនៃព្រះវិញ្ញាណបរិសុទ្ធជាប្រចាំ បើយើងកាន់តាមបទបញ្ញត្តិទាំងឡាយ ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

រូបភាព សូមបង្ហាញរូបភាពនៃព្រះយេស៊ូវគ្រីស្ទ ដែលកំពុងទទួលបុណ្យជ្រមុជទឹក (ទំព័រ 110) ។ សូមបង្ហាញព័ត៌មានលម្អិតនៅក្នុងរូបភាព (ព្រះយេស៊ូវ, ទឹក, យ៉ូហាន-បាទីស្ទ ជាដើម) ។ សូមពន្យល់ថា ព្រះយេស៊ូវទទួលបុណ្យជ្រមុជទឹក ដោយសារទ្រង់ស្រឡាញ់ព្រះវរបិតាសួគ៌ ហើយចង់គោរពតាមទ្រង់ ។ សូមអញ្ជើញកុមារឲ្យនិយាយតាមអ្នកថា « ព្រះយេស៊ូវ » និង « បុណ្យជ្រមុជទឹក » ។

កំណាព្យ សូមបង្ហាញនូវផ្នែកផ្សេងគ្នានៃរូបភាព ខណៈដែលអ្នករៀបរាប់ពាក្យក្នុងវគ្គទីមួយ នៃ« ពិធីបុណ្យជ្រមុជទឹក » (*សៀវភៅចម្រៀងកុមារ* ទំព័រ 100–101) ។ សូមអញ្ជើញកុមារឲ្យចង្អុលជាមួយអ្នក ។

ព្រះយេស៊ូវយាងមកឯយ៉ូហាន-បាទីស្ទ *(សូមចង្អុលទៅព្រះយេស៊ូវ បន្ទាប់មកទៅយ៉ូហាន)*
នៅក្នុងស្រុកយូដាជាយូរលង់ណាស់មកហើយ
ហើយទ្រង់បានទទួលបុណ្យជ្រមុជទឹកដោយការពន្លិចខ្លួន
នៅក្នុងទឹកទន្លេយ័រដាន់ ។ *(សូមចង្អុលទៅទឹក)*

អ្នកអាចពន្យល់ថា « ការពន្លិច » មានន័យថា ព្រះយេស៊ូវបានលិចទាំងស្រុងទៅក្រោមទឹក នៅពេលទ្រង់បានទទួលបុណ្យជ្រមុជទឹក ។

រូបភាព សូមបង្ហាញរូបភាពកុមារីម្នាក់ កំពុងទទួលបុណ្យជ្រមុជទឹក (ទំព័រ 110) ហើយសូមបង្ហាញពីភាពស្រដៀងគ្នា រវាងរូបភាពទាំងពីរនេះ ។ សូមប្រាប់កុមារថា ពួកគេអាចទទួលបុណ្យជ្រមុជទឹក ដូចជាព្រះយេស៊ូវដែរ នៅពេលពួកគេមានអាយុប្រាំបីឆ្នាំ ។ សូមលើកម្រាមដៃចំនួនប្រាំបីឡើង ដោយលើកដៃទាំងសង្ខាងនូវម្រាមបួន ហើយសូមរាប់វា ។ សូមធ្វើសារឡើងវិញ ហើយសូមអញ្ជើញកុមារឲ្យធ្វើវាជាមួយអ្នក ។ សូមគូសបញ្ជាក់ថា ការទទួលបុណ្យជ្រមុជទឹក គឺជាវិធីមួយ ដែលយើងអាចធ្វើតាមព្រះយេស៊ូវ ។ នៅពេលយើងទទួលបុណ្យជ្រមុជទឹក យើងបង្ហាញថា យើងស្រឡាញ់ព្រះវរបិតាសួគ៌ ហើយចង់គោរពតាមទ្រង់ ។

រូបភាព សូមបង្ហាញរូបភាពនៅទំព័រ 111 ។ សូមនិយាយជាមួយនឹងកុមារអំពីអ្វីដែលកំពុងកើតឡើងនៅក្នុងរូបភាព ។ សូមពន្យល់ថា បន្ទាប់ពីយើងទទួលបុណ្យជ្រមុជទឹកហើយ យើងទទួលពិធីបញ្ជាក់ ។ សូមអញ្ជើញកុមារឲ្យនិយាយថា « បានទទួលពិធីបញ្ជាក់ » ។ សូមប្រាប់ពួកគេថា នេះមានន័យថា បុរសដែលកាន់បព្វជិតភាព បានដាក់ដៃរបស់ពួកគាត់នៅលើក្បាលយើង ដើម្បីផ្តល់អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ។

សេចក្តីបញ្ចប់ សូមអញ្ជើញកុមារឲ្យនិយាយថា « ខ្ញុំនឹងទទួលបុណ្យជ្រមុជទឹក និង ទទួលពិធីបញ្ជាក់ » ដោយនិយាយពីរបីពាក្យម្តង ។ សូមប្រាប់កុមារដោយសង្ខេបអំពីអារម្មណ៍របស់អ្នកនៅពេលអ្នកទទួលបុណ្យជ្រមុជទឹក និង ទទួលពិធីបញ្ជាក់ ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់សកម្មភាពបទគម្ពីរ ៖* សូមនាំយកព្រះគម្ពីរមរមនមកជាមួយ ។ សូមគូសចំណាំនីហ្វៃទី3 12:1 ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។

សម្រាប់ល្បែងទាយ ៖ សូមថតចម្លងរូបភាពនៅទំព័រ 111 ហើយជាត់ពណ៌វាតាមចំណូលចិត្ត ។ សូមបត់ក្រដាសជាពីរ ដើម្បីបង្ហាញរូបភាពពិធីបុណ្យជ្រមុជទឹកនៅទំព័រម្ខាង ហើយរូបភាពពិធីបញ្ជាក់បង្ហាញនៅទំព័រម្ខាងទៀត ។

សម្រាប់សកម្មភាពជាត់ពណ៌ ៖ សូមថតចម្លងរូបភាពនៅទំព័រ 111 សម្រាប់ឲ្យកុមារម្នាក់ៗជាត់ពណ៌ ។

បទគម្ពីរ សូមប្រាប់កុមារថា ព្រះយេស៊ូវគ្រីស្ទប្រាប់យើងនៅក្នុងបទគម្ពីរថា ទ្រង់ចង់ឲ្យយើងទទួលបុណ្យជ្រមុជទឹក ។ សូមបើកព្រះគម្ពីរមរមនទៅ នីហ្វៃទី3 12:1 ហើយនិយាយថា « ព្រះយេស៊ូវ បានមានបន្ទូលថា ‹ ជឿដល់យើង ហើយទទួលបុណ្យជ្រមុជទឹក ។ › » សូមអញ្ជើញកុមារឲ្យនិយាយឃ្លានេះជាមួយអ្នកសារឡើងវិញ ដោយនិយាយពីរបីពាក្យម្តង ។ សូមរំឭកពួកគេថា ពួកគេអាចទទួលបុណ្យជ្រមុជទឹក នៅពេលពួកគេមានអាយុប្រាំបីឆ្នាំ ។

ល្បែងទាយ សូមបង្ហាញកុមារនូវរូបភាពពិធីបុណ្យជ្រមុជទឹករបស់អ្នក អានចំណងជើង ហើយអញ្ជើញកុមារនិយាយថា « បុណ្យជ្រមុជទឹក » ។ សូមបើកទៅទំព័រមួយទៀត ហើយសូមធ្វើដូចគ្នាចំពោះរូបភាពពិធីបញ្ជាក់ ។

សូមលាក់រូបភាពនៅខាងក្រោយខ្នងរបស់អ្នក ។ បន្ទាប់មក សូមបង្ហាញកុមារម្ខាងម្តង ហើយសូមសួរថា « តើកុមារានេះកំពុងទទួលបុណ្យជ្រមុជទឹក ឬ ទទួលពិធីបញ្ជាក់ ? » សូមអញ្ជើញកុមារឲ្យប្រាប់ចម្លើយដល់អ្នក ។ សូមលាក់រូបភាពនៅខាងក្រោយខ្នងរបស់អ្នកម្តងទៀត ហើយសូមធ្វើសកម្មភាពដូចគ្នា ដរាបណាកុមារនៅមានចំណាប់អារម្មណ៍ ។ សកម្មភាពនេះ សមរម្យសម្រាប់កុមារធំៗជាពិសេស ។

ការជាត់ពណ៌ សូមឲ្យកុមារជាត់ពណ៌រូបភាពនៅលើទំព័រ 111 ។ ខណៈពេលដែលពួកគេកំពុងជាត់ពណ៌ សូមរំឭកគោលការណ៍នានាដែលបានបង្រៀនក្នុងមេរៀននេះ ។ សូមបង្ហាញព័ត៌មានលម្អិតក្នុងរូបភាព អានចំណងជើងទាំងឡាយដល់កុមារ ហើយសូមពន្យល់ដល់ពួកគេអំពីអ្វីដែលពួកគេកំពុងតែជាត់ពណ៌ ។

គន្លឹះក្នុងការបង្រៀន

ការថតចម្លង ៖ បើអ្នកពុំមានម៉ាស៊ីនថតចម្លងទេ អ្នកអាចដាក់ក្រដាសពណ៌សពីលើរូបភាព ហើយគូសដានវាដោយប៊ិច ឬ ខ្មៅដៃ ។ សូមកុំបារម្ភអំពីការគូសដានយករូបភាពទាំងស្រុងឡើយ គ្រាន់តែគូសដានជាគ្រោង ហើយអាចមើលរូបភាពយល់ទៅ បានហើយ ។

ការជាត់ពណ៌ ៖ « សូមលើកទឹកចិត្ត [កុមារ] ឲ្យបង្ហាញរូបភាពរបស់ពួកគេ ដល់ក្រុមគ្រួសាររបស់ពួកគេ ។ ការធ្វើដូច្នេះ នឹងជួយពួកគេឲ្យចងចាំនូវអ្វីដែលពួកគេបានរៀន ។ វាក៏នឹងផ្តល់ឱកាសមួយដល់ឪពុកម្តាយផងដែរ ដើម្បីពិភាក្សាពីគោលការណ៍ទាំងឡាយនៃដំណឹងល្អជាមួយនឹងកូនៗរបស់ពួកគាត់ » (*Teaching, No Greater Call* ទំព័រ 167) ។



ខ្ញុំនឹងទទួលពិធីបញ្ជាក់

ខ្ញុំនឹងទទួលបុណ្យជ្រមុជទឹក

27 ពិធីសាក្រាម៉ង់ ជួយខ្ញុំគិតអំពីព្រះយេស៊ូវគ្រីស្ទ

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

នៅយប់មុនការសុគតរបស់ទ្រង់នៅលើឈើឆ្កាង ព្រះយេស៊ូវគ្រីស្ទ បានប្រទានសាក្រាម៉ង់ដល់ពួកសាវករបស់ទ្រង់ ហើយមានព្រះបន្ទូលថា « ចូរធ្វើបុណ្យនេះ ដើម្បីរំឭកពីខ្ញុំចុះ » (សូមមើល លូកា 22:19–20) ។ បន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់ ទ្រង់បានធ្វើដូចគ្នានៅក្នុងចំណោមសាសន៍នីហ្វៃ (សូមមើល នីហ្វៃទី3 18:1–11) ។ សព្វថ្ងៃនេះ យើងក៏ទទួលទានសាក្រាម៉ង់នៅក្នុងការចងចាំអំពីពលិកម្មរបស់ព្រះអង្គសង្គ្រោះសម្រាប់យើងផងដែរ ។ យើងធ្វើជាសាក្សីចំពោះព្រះថា យើងនឹងចងចាំព្រះយេស៊ូវគ្រីស្ទ ហើយរក្សាបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ជានិច្ច ។ (សូមមើល គ. និង ស. 20: 77, 79) ។

ការរៀបចំខ្លួន

- ដោយមានការអនុញ្ញាតមកពីប៊ីស្សព ឬ ប្រធានសាខា សូមយកថាសសាក្រាម៉ង់ទទេទៅកាន់ថ្នាក់ទារកដ្ឋាន ។
- សូមនាំយកព្រះគម្ពីរបរិសុទ្ធមកជាមួយ ។ សូមគូសចំណាំលូកា 22:19ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។ សូមគូសចំណាំទំព័រ 106 នៅក្នុងសៀវភៅសិក្សានេះផងដែរ ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

ចម្រៀង សូមបង្ហាញរូបភាពព្រះយេស៊ូវនៅទំព័រ 106 ខណៈពេលដែលអ្នកច្រៀងនៅបន្ទាត់ទីមួយក្នុងបទ « ដោយគោរព, ដោយស្ងៀមស្ងាត់ » *សៀវភៅចម្រៀងកុមារ* ទំព័រ 26) ៖

ដោយគោរព ដោយស្ងៀមស្ងាត់ យើងគិតដល់ទ្រង់ដោយក្តីស្នេហ៍ ។ *(សូមចង្អុលទៅរូបភាពព្រះយេស៊ូវ)*

សូមនិយាយឲ្យបានពីរបីដង ដើម្បីជួយកុមារឲ្យបង្កើតបរិយាកាសគារវភាពមួយ ។ សូមអញ្ជើញកុមារឲ្យច្រៀងជាមួយអ្នក ។

បទគម្ពីរ សូមប្រាប់កុមារថា ជារៀងរាល់ថ្ងៃអាទិត្យ យើងធ្វើអ្វីម៉្យាងដែលពិសេសដើម្បីចងចាំដល់ព្រះយេស៊ូវ—អំឡុងម៉ោងសាក្រាម៉ង់ យើងទទួលទានចំណិតនំប៉័ងតូចមួយ ហើយទទួលទានទឹកមួយកែវតូច ។ សូមប្រាប់កុមារថា នេះគឺត្រូវបានហៅថា ពិធីសាក្រាម៉ង់ ។ សូមអញ្ជើញកុមារឲ្យនិយាយថា « ពិធីសាក្រាម៉ង់ » ។ សូមប្រាប់កុមារថា យើងរៀននៅក្នុងព្រះគម្ពីរថា ព្រះយេស៊ូវ សព្វព្រះទ័យឲ្យយើងទទួលទានសាក្រាម៉ង់ដើម្បីចងចាំដល់ទ្រង់ ។ សូមបើកព្រះគម្ពីរបរិសុទ្ធទៅ លូកា 22:19 ហើយសូមនិយាយថា « ព្រះយេស៊ូវបានមានបន្ទូលថា ‹ ចូរធ្វើបុណ្យនេះ ដើម្បីរំឭកពីខ្ញុំចុះ › » ។

រូបភាព សូមបង្ហាញរូបភាពរបស់ឪពុកនៃចែកសាក្រាម៉ង់ (ទំព័រ 114) ។ សូមបង្ហាញព័ត៌មានលម្អិតក្នុងរូបភាព ដូចជាឪពុក និង មនុស្សដែលអង្គុយយ៉ាងស្ងាត់ស្ងៀម ។ សូមឲ្យកុមារកាន់ថាសសាក្រាម៉ង់ ដែលអ្នកយកមក ខណៈពេលដែលអ្នកពន្យល់ជាពាក្យសាមញ្ញអំពីអ្វីដែលកើតឡើង អំឡុងពេលបម្រើសាក្រាម៉ង់— យើងស្តាប់ដោយស្ងៀមស្ងាត់ ពេលពិធីសាក្រាម៉ង់ ត្រូវបានប្រសិទ្ធពរ នោះយើងយកនំប៉័ងមួយចំណិត យើងទទួលទានទឹក ហើយដាក់ពែងក្នុងថាសវិញ ហើយយើងគិតអំពីព្រះយេស៊ូវ ។

វគ្គសកម្មភាព សូមធ្វើវគ្គសកម្មភាពដូចខាងក្រោម ហើយសូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ៖

ខ្ញុំទទួលទាននំប៉័ងដោយស្ងៀមស្ងាត់ *(សូមធ្វើដូចជាទទួលទាននំប៉័ង)*
ហើយទទួលទានទឹកផងដែរ ។ *(សូមធ្វើដូចជាទទួលទានទឹក)*
ខ្ញុំឱបដៃរបស់ខ្ញុំ ហើយគិតអំពីព្រះយេស៊ូវ— *(សូមឱបដៃ)*
នោះជាអ្វីដែលខ្ញុំគួរធ្វើ ។ *(សូមងក់ក្បាល)*

[M. W. Verbica, « The Sacrament » *Friend,* ខែកុម្ភៈ ឆ្នាំ 1995 ទំព័រ 17]

គន្លឹះក្នុងការបង្រៀន

គារវភាព ៖ សូមនិយាយដោយសំឡេងតិច។ និង មានវិយាបទប្រកបដោយគារវភាព ដើម្បីជួយកុមារឲ្យយល់ថា សាក្រាម៉ង់ គឺជាពិធីដ៏ពិសិដ្ឋ ។

ការកាន់វត្ថុ ៖ កុមារតូច។ គិតយ៉ាងសាមញ្ញ និង តាមន័យត្រង់។ ពួកគេពុំយល់នូវគំនិតបង្កប់ពិបាក។នោះឡើយ ។ សូមផ្តល់ជាវត្ថុឲ្យពួកគេកាន់ដែលទាក់ទងនឹងមេរៀន ដើម្បីជួយពួកគេឲ្យរៀន ។ សូមប្រាកដថា ពួកគេកាន់ថាសសាក្រាម៉ង់ដោយមានគារវភាព និង គោរព ។ ពុំគួរមាននំប៉័ង ឬ ទឹកនៅក្នុងថាស សម្រាប់សកម្មភាពនេះឡើយ ។

សេចក្តីបញ្ចប់ សូមបង្ហាញរូបភាពព្រះយេស៊ូវនៅទំព័រ 106 ។ សូមសួរកុមារថា « តើយើងគួរតែគិតដល់អ្នកណា នៅពេលដែលយើងទទួលទានសាក្រាម៉ង់ ? » សូមអញ្ជើញកុមារឲ្យនិយាយថា « ព្រះយេស៊ូវ » ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់សកម្មភាពទាយ ៖* សូមរៀបចំឲ្យមានអ្នកកាន់បព្វជិតភាពអើរ៉ុនម្នាក់មកថ្នាក់ទារកដ្ឋាន ហើយនិយាយអំពីរបៀបដែលគាត់ជួយរៀបចំពិធីសាក្រាម៉ង់ ។
សម្រាប់ការសម្តែង និង ល្បែងកំសាន្ត ៖ សូមថតចម្លងប័ណ្ណនៅទំព័រ 115 ។ សូមជាត់ពណ៌ប័ណ្ណទាំងនោះ បើអ្នកចង់ ហើយសូមកាត់វាចេញមក ។
សម្រាប់សៀវភៅ ៖ សូមថតចម្លង ហើយកាត់ប័ណ្ណនៅទំព័រ 115 សម្រាប់កុមារម្នាក់ៗ ។ សូមយកអំបោះ ឬ ខ្សែមួយចំនួនមកជាមួយ ។

ភ្ញៀវ សូមណែនាំភ្ញៀវរបស់អ្នកដល់កុមារ ។ សូមពន្យល់ថា គាត់មានបព្វជិតភាព ។ សូមគាត់ឲ្យនិយាយដោយសង្ខេប អំពីរបៀបដែលគាត់រៀបចំ ប្រសិទ្ធពរ ឬ ចែកសាក្រាម៉ង់ ។ សូមអញ្ជើញគាត់ឲ្យចែកចាយអារម្មណ៍របស់គាត់អំពីសាក្រាម៉ង់ ។

ការសម្តែង សូមលើកប័ណ្ណដែលអ្នកបានរៀបចំឡើងម្តងមួយៗ ។ សូមអានចំណងជើង ហើយសូមឲ្យកុមារធ្វើដូចជាអ្វីដែលបានបង្ហាញនៅក្នុងរូប (សម្រាប់ប័ណ្ណបីដំបូងតែប៉ុណ្ណោះ) ។ ឧទាហរណ៍ សូមឲ្យពួកគេឱបដៃ ហើយខ្ទិនក្បាល និង ធ្វើជាយកនំបុ័ង និង ទឹក ។ សូមសរសើរពួកគេចំពោះការខិតខំរបស់ពួកគេគ្រប់ពេល ។ នៅពេលអ្នកលើករូបគំនូរព្រះយេស៊ូវឡើង សូមសួរកុមារថា « តើយើងគួរតែគិតដល់នរណា នៅពេលយើងទទួលទានសាក្រាម៉ង់ ? »

ល្បែងកំសាន្ត សូមដាក់ប័ណ្ណដែលអ្នកបានរៀបចំផ្កាប់ចុះក្រោមនៅលើឥដ្ឋ ឬ នៅលើតុ ។ សូមអញ្ជើញកុមារម្នាក់មកបើកប័ណ្ណនោះមួយ ។ សូមអានចំណងជើងនៅលើប័ណ្ណនោះ ។ សូមធ្វើសារឡើងវិញរហូតដល់កុមារម្នាក់ៗ ដែលចង់បើកបានធ្វើម្តង ។

សៀវភៅ សូមផ្តល់ប័ណ្ណដែលអ្នកបានរៀបចំចំនួនបួនដល់កុមារម្នាក់ៗ ។ សូមចោះរន្ធនៅកែងជ្រុងនៃប័ណ្ណនីមួយៗ ។ សូមដោតអំបោះ ឬ ខ្សែតាមរន្ធនោះ ហើយចងខ្សែដើម្បីធ្វើជាសៀវភៅតូចមួយ សម្រាប់កុមារម្នាក់ៗ ។ បន្ទាប់មក សូមអានតាមសៀវភៅនោះដល់កុមារ ។

គន្លឹះក្នុងការបង្រៀន

ការអធិស្ឋាន ៖ អ្នកអាចនឹងចង់ផ្តល់ការអធិស្ឋានមើក ឬ ការអធិស្ឋានមិនដោយខ្លួនអ្នកម្តងម្កាល ដើម្បីបង្ហាញដល់កុមារអំពីរបៀបអធិស្ឋាន ។ ពួកគេរៀនបានច្រើនតាមរយៈគំរូរបស់អ្នក ដូចគ្នានឹងតាមរយៈអ្វីដែលអ្នកនិយាយទៅកាន់ពួកគេ ។

ភាវភាព ៖ នៅពេលអ្នកសួរកុមារថា តើយើងគួរតែនឹកចាំដល់អ្នកណានៅពេលសាក្រាម៉ង់ កុមារខ្លះអាចនឹងស្រែកឆ្លើយ ។ បើពួកគេធ្វើដូច្នោះ ចូរបង្រៀនពួកគេដោយទន់ភ្លន់ ឲ្យចេះប្រើព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទដោយមានភាវភាព ។

សូមសម្របសម្រួលសកម្មភាព ដើម្បីបំពេញសេចក្តីត្រូវការ និង ធនធានរបស់អ្នក ។ ឧទាហរណ៍ បើអ្នកពុំមានអំបោះ ឬ ខ្សែដើម្បីប្រើសម្រាប់សកម្មភាពនេះទេ អ្នកអាចចងប័ណ្ណជាមួយគ្នាតាមរបៀបផ្សេងទៀត ។ ឬ អ្នកអាចឲ្យកុមារជាត់ពណ៌រូបភាព ដោយពុំចាំបាច់ធ្វើជាសៀវភៅឡើយ ។



ខ្ញុំអាចស្តាប់ ខណៈពេលដែលការអធិស្ឋាន
សាក្រាម៉ង់ ត្រូវបាននិយាយឡើង ។

ខ្ញុំអាចគិតអំពីព្រះយេស៊ូវ នៅពេល
ខ្ញុំទទួលទាននំប៉័ង ។



ខ្ញុំអាចគិតអំពីព្រះយេស៊ូវ នៅ
ពេលខ្ញុំទទួលទានទឹក ។

សាក្រាម៉ង់ ជួយខ្ញុំគិតអំពីព្រះយេស៊ូវ ។

28 ព្រះវរបិតាសួគ៌ ប្រទានពរខ្ញុំតាមរយៈបព្វជិតភាព

គន្លឹះក្នុងការបង្រៀន

សេចក្តីណែនាំខាងគោលលទ្ធិ ៖ គ្គនេះ មានបំណងចង់ជួយដល់កុមារឲ្យទទួលបាននូវការយល់ដឹងអំពីដំណឹងល្អជាមូលដ្ឋានចម្បង ។ ពួកគេមួយចំនួន អាចនឹងពុំយល់អ្វីៗដែលអ្នកនិយាយនោះទេ ប៉ុន្តែពួកគេនឹងស្គាល់ភាសានៃដំណឹងល្អ ហើយស្តាប់នាគ្រឹះមួយចំពោះរឿងទាំងឡាយ ដែលពួកគេរៀននៅពេលក្រោយក្នុងជីវិត ។

កុមារតូច ។ មានសមត្ថភាពខាងភាសាផ្សេងៗគ្នា (សូមមើល *Teaching, No Greater Call* ទំព័រ 110–11) ។ ដើម្បីជួយដល់កុមារតូច។ និយាយពាក្យចេញពីមេរៀនសារឡើងវិញ សូមនិយាយអ្វីមួយដោយទន់ភ្លន់ដូចជា « តើអ្នក។អាចនិយាយថា *បព្វជិតភាព បានឬទេ ?* និយាយថា *បព្វជិតភាព* ជាមួយខ្ញុំ » ហើយរង់ចាំការថាតាមនោះ ។ បើកុមារពុំថាតាមទេ សូមអញ្ជើញសារឡើងវិញដោយក្តីស្រឡាញ់ ប៉ុន្តែកុំដាក់សម្ពាធទៅលើគេឡើយ ។ កុមារអាចរៀនមេរៀនទោះជាគ្រាន់តែស្តាប់ក្តី ។

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

បព្វជិតភាព គឺជាព្រះចេស្តា និង ជាសិទ្ធិអំណាចរបស់ព្រះ ។ ព្រះប្រទានសិទ្ធិអំណាចនេះទៅដល់សមាជិកបុរសទាំងឡាយដែលមានភាពស័ក្តិសមក្នុងសាសនាចក្រ អាយុ 12 ឆ្នាំឡើងទៅ ដើម្បីពួកគាត់អាចធ្វើកិច្ចការក្នុងព្រះនាមរបស់ទ្រង់ ដើម្បីប្រទានពរដល់អ្នកដទៃ ។ ពិធីបរិសុទ្ធនានានៃដំណឹងល្អ ដូចជាពិធីបុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់, ពិធីសាក្រាម៉ង់ និង ពិធីផ្សេងៗទៀត គឺត្រូវបានធ្វើឡើងតាមរយៈសិទ្ធិអំណាចនៃបព្វជិតភាព (សូមមើល គ. និង ស. 13 ; 20:73–79 ; 84:19–22) ។ សមាជិកទាំងអស់ក្នុងសាសនាចក្រ ទទួលបានប្រយោជន៍មកពីបព្វជិតភាព ។

ការរៀបចំខ្លួន

សូមគូសចំណាំ ទំព័រ 26 និង ទំព័រ 114 ក្នុងសៀវភៅសិក្សានេះ ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

សេចក្តីណែនាំខាងគោលលទ្ធិ សូមប្រាប់កុមារថា បព្វជិតភាព គឺជាព្រះចេស្តារបស់ព្រះ ។ ព្រះប្រទានបព្វជិតភាពដល់កុមារធំៗ និង បុរសទាំងឡាយ ដើម្បីពួកគាត់អាចប្រទានពរដល់ក្រុមគ្រួសាររបស់គាត់ និងអ្នកដទៃទៀត ។ សូមឲ្យកុមារនិយាយថា « បព្វជិតភាព » ។ (*កំណត់ចំណាំ ៖* អំឡុងពេលនៃមេរៀននេះ សូមយល់អំពីអារម្មណ៍របស់កុមារក្នុងថ្នាក់ទារកដ្ឋាន ដែលពុំមានឪពុកនៅក្នុងផ្ទះ ឬ ដែលមានឪពុកពុំកាន់បព្វជិតភាព) ។

រូបភាព សូមបង្ហាញរូបភាពនៅទំព័រ 118 ហើយសូមអញ្ជើញកុមារឲ្យធ្វើដូចជាបីទារក ។ សូមពន្យល់ថា ទារកទាំងឡាយអាចត្រូវបានប្រសិទ្ធពរ និង ផ្តល់ឈ្មោះឲ្យដោយបុរសៗ ដែលមានបព្វជិតភាព ។ សូមអញ្ជើញកុមារឲ្យនិយាយថា « បព្វជិតភាព » ។

សូមបង្ហាញរូបភាពនៅទំព័រ 119 អំពីការប្រសិទ្ធពរដល់អ្នកឈឺ ។ សូមប្រាប់កុមារថា មនុស្សដែលមានបព្វជិតភាព អាចប្រសិទ្ធពរដល់អ្នកទាំងឡាយដែលឈឺ ដើម្បីឲ្យពួកគេអាចបានធូរស្បើយ ។ សូមបើកទៅរូបភាពនៅទំព័រ 26 ។ សូមចង្អុលទៅរូបព្រះយេស៊ូវ ហើយសូមពន្យល់ថា នៅក្នុងរូបភាពនេះ ព្រះយេស៊ូវកំពុងប្រសិទ្ធពរដល់មនុស្សខ្វាក់ម្នាក់ ។ សូមអញ្ជើញកុមារឲ្យនិយាយថា « បព្វជិតភាព » ។

សូមបង្ហាញរូបភាពនៅទំព័រ 114 ។ សូមរំឭកកុមារថា យើងទទួលទានសាក្រាម៉ង់ជារៀងរាល់ថ្ងៃអាទិត្យ ។ សូមពន្យល់ថា សាក្រាម៉ង់ ត្រូវបានរៀបចំ ប្រសិទ្ធពរ និង ចែកដោយអ្នកទាំងឡាយ ដែលមានបព្វជិតភាព ។ សូមអញ្ជើញកុមារឲ្យនិយាយថា « បព្វជិតភាព » ។

ចម្រៀង សូមអញ្ជើញកុមារឲ្យកាន់ដៃ ហើយដើរជារង្វង់ ពេលដែលអ្នកច្រៀង ឬ និយាយពាក្យដូចខាងក្រោមចេញមកពីបទ « យើងនិយាយដោយស្នេហ៍ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 190) ៖

ផ្ទះរបស់ខ្ញុំ ជាកន្លែងដែលទទួលពរជ័យពីអំណាចបព្វជិតភាព ។

សេចក្តីបញ្ចប់ សូមចែកចាយទីបន្ទាល់របស់អ្នកថា ព្រះវរបិតាសួគ៌ ប្រទានពរដល់យើងតាមរយៈបព្វជិតភាព ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់សកម្មភាពទាយ ៖* សូមរៀបចំឲ្យឪពុកម្ដាក់ដែលបានប្រសិទ្ធពរដល់ទារកតូចរបស់គាត់ក្នុងពេលថ្មីៗនេះ នាំទារកតូចរបស់គាត់មកថ្នាក់ទារកដ្ឋាន ហើយនិយាយអំពីបទពិសោធន៍របស់គាត់ ។

សម្រាប់សៀវភៅបើកមើល ៖ សូមថតចម្លងរូបភាពនៅទំព័រ 119) ។ សូមជាក់ពណ៌តាមចំណូលចិត្ត ។ សូមកាត់តាមបន្ទាត់ត្រង់ ហើយបត់តាមចំណុចចុចៗ ។

វគ្គសកម្មភាព សូមធ្វើវគ្គសកម្មភាពណាមួយដូចខាងក្រោម ឬ ធ្វើវគ្គសកម្មភាពនោះទាំងអស់ ហើយសូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ។ បន្ទាប់ពីវគ្គនីមួយៗ សូមរំឭកកុមារថា បព្វជិតភាពប្រទានពរដល់ជីវិតរស់នៅរបស់យើង ។

ការប្រសិទ្ធពរទារក (សូមបង្ហាញរូបភាពនៅទំព័រ 118) ៖

ឪពុកបីទារកតូច *(សូមធ្វើដូចជាបីទារកក្នុងដៃ)*
ដោយថ្នមៗ
ដើម្បីប្រសិទ្ធពរ និង ដាក់ឈ្មោះតាមរយៈអំណាចបព្វជិតភាព ។
គាត់ស្រឡាញ់ក្រុមគ្រួសាររបស់យើង ! *(សូមឱបខ្លួនឯង)*

ការប្រសិទ្ធពរអ្នកឈឺ (សូមចង្អុលទៅរូបភាពនៅទំព័រ 119) ៖

នៅពេលខ្ញុំឈឺ ខ្ញុំអាចទទួលការប្រសិទ្ធពរ *(សូមចង្អុលមកខ្លួនឯង)*
តាមរយៈបុរសដែលមានបព្វជិតភាពដ៏សុចរិត ។
ខ្ញុំមានអារម្មណ៍សុខសាន្ត ហើយខ្ញុំមានសេចក្ដីជំនឿ *(សូមដាក់ដៃលើដើមទ្រូង)*
ថាខ្ញុំនឹងបានជាសះស្បើយវិញ ។

សាក្រាម៉ង់ (សូមបង្ហាញរូបភាពនៅទំព័រ 114) ៖

ខ្ញុំទទួលទាននំប៉័ងដោយស្ងៀមស្ងាត់ *(សូមធ្វើដូចជាទទួលទាននំប៉័ង)*
ហើយទទួលទានទឹកផងដែរ ។ *(សូមធ្វើដូចជាទទួលទានទឹក)*
ខ្ញុំឱបដៃ ហើយគិតអំពីព្រះយេស៊ូវ— *(សូមឱបដៃ)*
នោះជាអ្វីដែលខ្ញុំគួរធ្វើ ។ *(សូមងក់ក្បាល)*

[M. W. Verbica, « The Sacrament » *Friend* ខែកុម្ភៈ ឆ្នាំ 1995 ទំព័រ 17]

ភ្ញៀវ សូមណែនាំភ្ញៀវរបស់អ្នកដល់កុមារ ។ សូមពន្យល់ពួកគេថា គាត់មានបព្វជិតភាព ហើយថាគាត់បានប្រើបព្វជិតភាព ដើម្បីប្រសិទ្ធពរដល់ទារកតូចរបស់គាត់ ។ សូមសួរឪពុកនោះនូវសំណួរដូចជា « តើលោកមានបព្វជិតភាពដែរឬទេ ? » « តើទារកតូចរបស់លោកមានឈ្មោះអ្វី ? » « តើលោកនិយាយអ្វីខ្លះ នៅពេលលោកប្រសិទ្ធពរដល់ទារកតូចរបស់លោក ? » « តើលោកនឹងប្រើបព្វជិតភាពដើម្បីប្រសិទ្ធពរទារកតូចរបស់លោកដោយរបៀបណា នៅពេលគាត់ [ឬ នាង] ធំឡើង ?

សៀវភៅបើកមើល សូមបង្ហាញកុមារអំពីសៀវភៅបើកមើល ដែលអ្នកបានរៀបចំ ។ សូមបើកគម្របទំព័រដំបូង អាន ចំណងជើង ហើយឲ្យកុមារនិយាយជាមួយអ្នក ។ សូមធ្វើដូចគ្នានេះសម្រាប់ការបើកទំព័រនីមួយៗ ។



គន្លឹះក្នុងការបង្រៀន

ការរំឭក ៖ កុមារចូលចិត្តរឿង, ចម្រៀង, រូបភាព និង សកម្មភាពទាំងឡាយ ដែលពួកគេមើល ឃើញ និង ស្ដាប់ឮរួចពីមុនហើយ ។ សូមច្រៀងចម្រៀង ឬ ធ្វើវគ្គសកម្មភាពនានាដែលចេញមកពីមេរៀននេះ ឬ មេរៀនមុន។ នៅពេលណាក៏បាន អំឡុងពេលថ្នាក់ទារកដ្ឋាន ។ ការរំឭកនេះ នឹងជួយពួកគេចងចាំគោលការណ៍ទាំងឡាយនៃដំណឹងល្អ ដែលអ្នកបានបង្រៀន ។



ការប្រសិទ្ធពរទារក

ការប្រសិទ្ធពរអ្នកឈឺ



ពិធីសាក្រាម៉ង់

ព្រះវរបិតាសួគ៌ ប្រទានពរខ្ញុំតាមរយៈបព្វជិតភាព

29 ព្រះយេស៊ូវគ្រីស្ទ បានរស់ឡើងវិញ (មុណ្យអ៊ីសស្ទើរ)

គន្លឹះក្នុងការបង្រៀន

ព្រះយេស៊ូវគ្រីស្ទ ៖ វប្បធម៌ជាច្រើន មានទំនៀមទម្លាប់មុណ្យអ៊ីសស្ទើរ ដែលសប្បាយរីករាយសម្រាប់កុមារ ប៉ុន្តែមានអត្ថន័យតិចតួចទាក់ទងនឹងការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមផ្តោតចំពោះមេរៀនមុណ្យអ៊ីស្ទើរ ទៅលើព្រះអង្គសង្គ្រោះ ហើយជួយកុមារឲ្យបង្កើនសេចក្តីស្រឡាញ់របស់ពួកគេចំពោះទ្រង់ ។ សូមបង្រៀនកុមារឲ្យរីករាយនឹងអំណោយទានដ៏អស្ចារ្យទាំងឡាយ ដែលទ្រង់បានប្រទានដល់យើង ដូចជា ការរស់ឡើងវិញ និង ការបង្រៀនរបស់ទ្រង់ ព្រមទាំងគំរូដ៏តត្តខ្ពោះរបស់ទ្រង់ ។

ចម្រៀង ៖ កុមារមួយចំនួនអាចនឹងមិនច្រៀងជាមួយអ្នកទេ ។ ទោះបីជាពួកគេធ្វើតែសកម្មភាព ឬ គ្រាន់តែមើល និង ស្តាប់អ្នកក្តី ក៏ពួកគេនៅតែអាចរីករាយនឹងចម្រៀង ព្រមទាំងរៀនពីចម្រៀងផងដែរ ។

ទីបន្ទាល់ ៖ សូមឆ្លើងទីបន្ទាល់របស់អ្នកតាមរបៀបសាមញ្ញមួយ និងសង្ខេប ឧទាហរណ៍ ៖ « ខ្ញុំដឹងថា ព្រះយេស៊ូវគ្រីស្ទ បានរស់ឡើងវិញ » ។

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

ដោយសារការធ្លាក់របស់អ័ដាម និង អេវ៉ា នោះមនុស្សគ្រប់គ្នានឹងទទួលបទពិសោធន៍សេចក្តីស្លាប់ខាងរូបកាយ ។ នៅពេលយើងស្លាប់ នោះវិញ្ញាណ និង រូបកាយរបស់យើង ត្រូវបានបែកចេញពីគ្នា ។ នៅពេលព្រះយេស៊ូវគ្រីស្ទ បានរស់ឡើងវិញ នោះរូបអង្គ និង វិញ្ញាណរបស់ទ្រង់ ត្រូវបានផ្គុំគ្នាវិញ ដែលពុំបែកគ្នាទៀតឡើយ ។ ដោយសារដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះមនុស្សគ្រប់គ្នានឹងត្រូវបានរស់ឡើងវិញ (សូមមើល កូរិនថូសទី1 15:22 ; អាលម៉ា 11:42–45) ។ ការយល់ដឹង និង ទីបន្ទាល់អំពីការរស់ឡើងវិញ ផ្តល់ក្តីអំណរ និង ក្តីសង្ឃឹមដល់យើង (សូមមើល អេសាយ 25:8 ; អាលម៉ា 22:14) ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

រឿង សូមបង្ហាញរូបភាពនៅទំព័រ 122 ។ សូមបង្ហាញព័ត៌មានលម្អិតនៅក្នុងរូបភាព នៅពេលអ្នកប្រាប់រឿងអំពីការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទដោយសាមញ្ញបំផុត (សូមមើល យ៉ូហាន 19:41–42 ; 20:1, 11–16) ។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយ ៖

នៅពេលព្រះយេស៊ូវសុគត មិត្តរបស់ទ្រង់សោកស្តាយយ៉ាងខ្លាំង *(សូមឲ្យកុមារធ្វើទឹកមុខសោកស្តាយ)* ។ ពួកគេបានដាក់ព្រះកាយរបស់ព្រះយេស៊ូវនៅក្នុងផ្នូរ ដែលដូចជារូងថ្មមួយ *(សូមចង្អុលទៅរូបផ្នូរនៅក្នុងរូបភាព)* ។ ថ្មធំមួយត្រូវបានប្រមៀលនៅខាងមុខច្រកទ្វារ *(សូមឲ្យកុមារធ្វើដូចជារុញថ្មធំផ្ទាល់មួយ)* ។ បន្ទាប់ពីរយៈពេលបីថ្ងៃ *(សូមឲ្យកុមារលើកម្រាមដៃខ្លួនចំនួនបីឡើង)* ទេវតាពីរអង្គបានរមៀលថ្មចេញ ។ ព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញ ! *(សូមចង្អុលទៅព្រះយេស៊ូវនៅក្នុងរូបភាព)* ។ ទ្រង់បានរស់ឡើងវិញ *(សូមជួយកុមារនិយាយថា « បានរស់ឡើងវិញ »)* ។ មិត្តរបស់ព្រះយេស៊ូវ សប្បាយចិត្តខ្លាំងណាស់ ! ទ្រង់មានព្រះជន្មរស់ ហើយនឹងមិនសុគតម្តងទៀតឡើយ !

ម៉ារា គឺជាមិត្តម្នាក់របស់ព្រះយេស៊ូវ *(សូមចង្អុលទៅនាងម៉ារានៅក្នុងរូបភាព)* ។ នាងមានអារម្មណ៍សោកស្តាយ ពេលទ្រង់បានសុគត ។ នពេលព្រះយេស៊ូវ បានរស់ឡើងវិញ នោះម៉ារា គឺជាមនុស្សដំបូងគេ ដែលបានឃើញទ្រង់ ។ នាងសប្បាយចិត្តខ្លាំងណាស់ ដោយសារព្រះយេស៊ូវ មានព្រះជន្មរស់ *(សូមឲ្យកុមារធ្វើទឹកមុខសប្បាយរីករាយ)* ។

សូមប្រាប់កុមារថា ដោយសារតែព្រះយេស៊ូវ នោះមនុស្សគ្រប់គ្នា នឹងត្រូវបានរស់ឡើងវិញ ហើយរស់នៅជារៀងរហូត ។ សូមឲ្យកុមារធ្វើទឹកមុខរីករាយម្តងទៀត ។

ចម្រៀង សូមច្រៀង ឬ អានវគ្គទីមួយក្នុងបទ « តើព្រះយេស៊ូវរស់ឡើងវិញឬ ? » *(សៀវភៅចម្រៀងកុមារ ទំព័រ 64)* ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ។

តើព្រះយេស៊ូវរស់ឡើងវិញឬ ?
មែន កាលដល់ថ្ងៃទីបី *(សូមលើកម្រាមដៃបីឡើង)*
ទ្រង់បានក្រោកឡើងចាកចេញពីផ្នូរ
ទ្រង់ហៅឈ្មោះម៉ារា ។ *(សូមឱបដៃ)*

សេចក្តីបញ្ចប់ សូមអញ្ជើញកុមារឲ្យនិយាយថា « ព្រះយេស៊ូវគ្រីស្ទ បានរស់ឡើងវិញ » ដោយនិយាយមួយពាក្យ ឬ ពីរពាក្យម្តង ។ សូមចែកចាយទីបន្ទាល់របស់អ្នកដោយខ្លីជាមួយនឹងកុមារថា ព្រះយេស៊ូវគ្រីស្ទ បានរស់ឡើងវិញ ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់រឿង ៖* សូមថតចម្លងរូបភាពនៅទំព័រ 123) ។ សូមជាត់ពណ៌រូបភាព ហើយបិទនៅលើក្រដាសរឹង បើចង់ធ្វើ ។ សូមកាត់រូបភាពនីមួយៗចេញ រួចហើយកាត់ទ្វារផ្នូរបើកចំហរ តាមចំណុចចុចៗ ។

សម្រាប់សកម្មភាពជាត់ពណ៌ ៖ សូមថតចម្លងទំព័រ 123 សម្រាប់កុមារម្នាក់ៗ ។ សូមកាត់រូបភាពនីមួយៗ ហើយសូមកាត់ទ្វារផ្នូរបើកចំហរ ។

ចម្រៀង សូមអញ្ជើញកុមារឲ្យឈរជារង្វង់ ហើយកាន់ដៃគ្នា ។ សូមច្រៀង ឬ អានពាក្យក្នុងបទ « ព្រះយេស៊ូវបានរស់ឡើងវិញ » *សៀវភៅចម្រៀងកុមារ* ទំព័រ 70) ហើយសូមធ្វើសកម្មភាពដូចខាងក្រោម ៖

ព្រះយេស៊ូវរស់វិញ *(សូមដើរជារង្វង់)*
ទ្រង់ជាមិត្តយើង ។
អំណរក្នុងចិត្ត *(សូមឈប់ ហើយដាក់ដៃលើដើមទ្រូង)*
ទ្រង់រស់ឡើងវិញ ។

សូមធ្វើសារឡើងវិញឲ្យបានញឹកញាប់ តាមដែលកុមារចូលចិត្ត ។

រឿង សូមប្រាប់រឿងអំពីការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទម្តងទៀត ដោយគ្រានេះសូមប្រើរូបភាពដែលអ្នកបានកាត់ចេញមក ។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយ ៖



(សូមចាប់ផ្តើមជាមួយនឹងរូបភាពព្រះយេស៊ូវ ឈរត្រង់ ហើយថ្មរមៀលចេញពីទ្វារផ្នូរដែលបើកចំហរ) ។ នៅពេលព្រះយេស៊ូវបានសុគត ព្រះកាយរបស់ទ្រង់ត្រូវបានគេដាក់ទៅក្នុងផ្នូរមួយ *(សូមដាក់រូបភាពព្រះយេស៊ូវនៅ [ខាងក្រោយ] ផ្នូរ)* ។ ថ្មមួយផ្ទាំងយ៉ាងធំ ត្រូវបានរមៀលចេញពីច្រកទ្វារ *(សូមរុញថ្មនៅខាងមុខចេញពីទ្វារផ្នូរ)* ។ នៅថ្ងៃទីបី មានទេវតាពីរអង្គយាងមក ហើយបានរុញថ្មចេញ *(សូមរុញថ្មចេញ)* ។ ព្រះយេស៊ូវបានរស់ឡើងវិញ *(សូមបញ្ឈររូបភាពព្រះយេស៊ូវឲ្យត្រង់ឡើង)* ។ ព្រះវិញ្ញាណរបស់ទ្រង់ និង ព្រះកាយទ្រង់បានរួមបញ្ចូលគ្នាជាថ្មីម្តងទៀត ! [សូមមើល ស៊ូស្សាន ផេសុន « Easter Story » *Friend* ខែ មេសា ឆ្នាំ 1995 ទំព័រ 32–33] ។

ការជាត់ពណ៌ សូមឲ្យរូបភាពដែលអ្នកបានកាត់ចេញដល់កុមារ ។ សូមបង្ហាញពួកគេអំពីរបៀបដែលពួកគេអាចប្រើរូបភាពទាំងឡាយ ដើម្បីរំឭកអំពីរឿងនៃការរស់ឡើងវិញរបស់ព្រះយេស៊ូវ ។ សកម្មភាពនេះ សមរម្យសម្រាប់កុមារធំៗជាពិសេស ។



គន្លឹះក្នុងការបង្រៀន

សកម្មភាពជម្រើស ត្រូវបានផ្តល់ដល់អ្នកដើម្បីបន្ថែមចូលទៅក្នុងមេរៀន តាមចំណូលចិត្ត ។ ប៉ើគ្មានសម្ភារដែលអ្នកត្រូវការនោះទេ អ្នកអាចជំនួសដោយអ្វីមួយដែលស្រដៀងគ្នាបាន ។

រឿង ៖ « កុមារតូច។ ចូលចិត្តស្តាប់រឿងដដែល។សារឡើងវិញ ។ ប៉ើអ្នកកំពុងនិយាយរឿងសារឡើងវិញ សូមចាប់ផ្តើមដោយសួរថា « តើអ្វីខ្លះបានកើតឡើងបន្ទាប់ពីនេះទៀត ? › » (*Teaching, No Greater Call* ទំព័រ 181–82) ។ សូមអញ្ជើញកុមារធំម្នាក់ឲ្យប្រើរូបភាពដែលបានកាត់ចេញមក ឬ រូបភាពនៅទំព័រ 122 ដើម្បីប្រាប់រឿងអំពីការរស់ឡើងវិញ ដល់កុមារតូច។ នៅក្នុងថ្នាក់ទារកដ្ឋាន ។ ស្នើផ្តល់ជំនួយ តាមត្រូវការ ។

ប្រអប់សកម្មភាព ៖ ចូរពិចារណាអំពីការធ្វើប្រអប់សកម្មភាពមួយ ដើម្បីរក្សានៅក្នុងថ្នាក់ទារកដ្ឋាន ។ វាអាចមានសកម្មភាពជាត់ពណ៌នេះ និង វត្ថុដទៃទៀត ដែលអ្នកធ្វើ ឬ ប្រើសម្រាប់សកម្មភាពទាំងឡាយ ។ បន្ទាប់មក អ្នកអាចធ្វើសកម្មភាពទាំងនោះសារឡើងវិញ អំឡុងពេលថ្នាក់ទារកដ្ឋាន នៅថ្ងៃខាងមុខ ដើម្បីរំឭកមេរៀនមុន។ ។ ការរំឭកនេះ អាចធ្វើឡើងនៅពេលណាក៏បាន អំឡុងពេលថ្នាក់ទារកដ្ឋាន ។

30 ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រារបស់ព្រះវរបិតាសួគ៌ (បុណ្យគ្រីស្ទម៉ាស)

សេចក្តីផ្តើមសម្រាប់គ្រូបង្រៀន

ដើម្បីរៀបចំខ្លួនអ្នកខាងវិញ្ញាណក្នុងការបង្រៀនមេរៀននេះ សូមអាន និង ពិចារណាដូចខាងក្រោម ៖

ព្រះយេស៊ូវ បានចាប់កំណើតជាមួយម្តាយខាងសាច់ឈាម ម៉ារា និង ព្រះបិតាអមតៈ ដែលជាព្រះវរបិតាសួគ៌ ។ ទ្រង់គឺពិតជាព្រះរាជបុត្រានៃព្រះ ។ ដោយសារតែក្តីស្រឡាញ់ដ៏មហិមារបស់ទ្រង់ចំពោះយើង នោះព្រះវរបិតាសួគ៌ បានបញ្ជូនព្រះយេស៊ូវគ្រីស្ទមកកាន់ផែនដី ដើម្បីធ្វើជាព្រះអង្គសង្គ្រោះ និង ជាគំរូរបស់យើង ។ « ត្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉ះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រា នោះមិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ » (យ៉ូហាន 3:16) ។

ការរៀបចំខ្លួន

សូមគូសចំណាំទំព័រ 106 នៅក្នុងសៀវភៅសិក្សានេះ ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។

សកម្មភាពក្នុងការរៀនសូត្រ

សូមចាប់ផ្តើមជាមួយនឹងសកម្មភាពប្រមូលផ្តុំ ។ សម្រាប់គំនិតនានា សូមមើល ទំព័រ 3 ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបើក ។

រូបភាព សូមបង្ហាញរូបភាពនៅទំព័រ 126 ។ សូមអញ្ជើញកុមារឲ្យរកមើលទារកតូចនៅក្នុងរូបភាព ។ សូមប្រាប់ពួកគេថា ព្រះនាមរបស់ទ្រង់គឺ ព្រះយេស៊ូវ ហើយសូមអញ្ជើញឲ្យពួកគេនិយាយថា « ព្រះយេស៊ូវ » ។ សូមឲ្យកុមារធ្វើដូចជាបីទារកយោលក្នុងដៃរបស់ពួកគេ ។

សូមចង្អុលទៅ ម៉ារា នៅក្នុងរូបភាព ហើយសូមប្រាប់កុមារថា « នេះគឺជាមាតារបស់ព្រះយេស៊ូវ ។ ឈ្មោះរបស់គាត់គឺ ម៉ារា » ។

សូមប្រាប់កុមារថា ព្រះយេស៊ូវ គឺជាព្រះរាជបុត្រានៃព្រះវរបិតាសួគ៌ ។ សូមអញ្ជើញកុមារឲ្យនិយាយថា « ព្រះយេស៊ូវ គឺជាព្រះរាជបុត្រារបស់ព្រះវរបិតាសួគ៌ » ដោយនិយាយពីរបីពាក្យម្តង ។ សូមប្រាប់ពួកគេថា ព្រះវរបិតាសួគ៌ បានបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ឲ្យមកកាន់ផែនដី ដោយសារទ្រង់ស្រឡាញ់យើង ។

ចម្រៀង សូមចង្អុលទៅរូបទារកតូចយេស៊ូវ នៅក្នុងរូបភាពម្តងទៀត ។ សូមប្រាប់កុមារថា អ្នកនឹងច្រៀងចម្រៀងមួយបទ ។ នៅពេលអ្នកចង្អុលទៅទារកតូចយេស៊ូវ សូមអញ្ជើញពួកគេឲ្យនិយាយថា « ទ្រង់បញ្ជូនបុត្រាទ្រង់មក » ។ សូមឲ្យពួកគេហាត់រៀនពីរបីដង បន្ទាប់មកច្រៀង ឬ អានពាក្យដូចខាងក្រោមក្នុងបទ « ទ្រង់បញ្ជូនបុត្រាទ្រង់មក » *(សៀវភៅចម្រៀងកុមារ* ទំព័រ 34–35) ៖

ព្រះវរបិតា អាចប្រាប់លោកិយពីក្តីស្នេហ៍របៀបណា ?
ទ្រង់បញ្ជូនបុត្រាទ្រង់ *(សូមចង្អុលទៅរូបភាពទារកតូចយេស៊ូវ)* ទារកមេត្រី និង បរិសុទ្ធ ។

សូមបង្ហាញរូបភាពព្រះយេស៊ូវគ្រីស្ទនៅទំព័រ 106 ។ សូមប្រាប់កុមារថា ទារកតូចយេស៊ូវបានធំឡើងក្លាយជាព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ ។ នៅពេលអ្នកចង្អុលទៅរូបភាពព្រះអង្គសង្គ្រោះ សូមអញ្ជើញកុមារឲ្យនិយាយថា « ទ្រង់បញ្ជូនបុត្រាទ្រង់មក » ។ សូមច្រៀង ឬ អាននូវពាក្យដូចខាងក្រោមក្នុងបទ « ទ្រង់បញ្ជូនបុត្រាទ្រង់មក » ៖

តើព្រះបិតាបង្ហាញផ្លូវដល់យើងឲ្យដើរក្នុងលោកិយដោយរបៀបណា ?
ទ្រង់បញ្ជូនបុត្រា *(សូមបង្ហាញរូបភាពព្រះអង្គសង្គ្រោះ)* ឲ្យយាងនឹងមនុស្ស ដើម្បីយើងស្គាល់ ។

គន្លឹះក្នុងការបង្រៀន

ព្រះយេស៊ូវគ្រីស្ទ ៖ « អ្វីគ្រប់យ៉ាងដែលយើងបង្រៀន គួរតែបង្ហាញសមាជិកគ្រួសារ និង សមាជិកក្នុងថ្នាក់អំពីព្រះយេស៊ូវគ្រីស្ទ ។ . . . ចូរចងចាំរឿងនេះ នៅពេលអ្នករៀបចំ និង បង្រៀនមេរៀនរបស់អ្នក » *(Teaching, No Greater Call* ទំព័រ 80) ។

កុមារតូច ។ ៖ ចូរកត់សម្គាល់ដែលអាចប្រាប់អ្នកថា កុមារកំពុងតែយកចិត្តទុកដាក់ឬយ៉ាងណា ។ ដើម្បីជួយពួកគេឲ្យយកចិត្តទុកដាក់ សូមសាកល្បងផ្លាស់ប្តូរសំឡេងនៃការបង្រៀនរបស់អ្នក ដោយនៅតែមានការឆ្លើតត្រង់សៀភ្នែកដដែល និង ផ្លាស់ប្តូរវិធីសាស្ត្របង្រៀនរបស់អ្នក ។ (សូមមើល *Teaching, No Greater Call* ទំព័រ 71–72) ។

សេចក្តីបញ្ចប់ សូមបង្ហាញការដឹងគុណរបស់អ្នកថា ព្រះវរបិតាសួគ៌ បានបញ្ជូនព្រះយេស៊ូវគ្រីស្ទមក ។ សូមចែកចាយទីបន្ទាល់របស់អ្នកថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រារបស់ព្រះវរបិតាសួគ៌ ។

ការអធិស្ឋាន សូមអញ្ជើញកុមារម្នាក់ឲ្យអធិស្ឋានបិទ ។

សកម្មភាពជម្រើស

ការរៀបចំខ្លួន *សម្រាប់រូបតុក្កតាអាយ៉ងបិទជាប់ឈើ ៖* សូមថតចម្លង និង កាត់រូបភាពពីទំព័រ 127 សម្រាប់កុមារម្នាក់ៗ ។ សូមបិទស្កុត ឬ បិទកាវលើឈើមួយនៅខាងខ្នងរូបភាពនីមួយៗ ដើម្បីធ្វើជារូបតុក្កតាអាយ៉ងបិទជាប់ឈើសម្រាប់កុមារ ។

សម្រាប់សកម្មភាពបទគម្ពីរ ៖ សូមនាំយកព្រះគម្ពីរមរមនមកជាមួយ ។ សូមគូសចំណាំនីហ្វៃទី 3 9:15ដើម្បីអ្នកអាចបើកទៅវាដោយងាយស្រួល ។

រូបតុក្កតាអាយ៉ងបិទជាប់ឈើ សូមផ្តល់រូបតុក្កតាអាយ៉ងបិទជាប់ឈើដែលអ្នកធ្វើដល់ពួកគេ ។ សូមប្រាប់រឿងអំពីកំណើតរបស់ព្រះយេស៊ូវគ្រីស្ទម្តងទៀតជាសម្តីផ្ទាល់របស់អ្នក (សូមមើល លូកា 2:4–16) ។ សូមអញ្ជើញកុមារឲ្យលើករូបតុក្កតាអាយ៉ងបិទជាប់ឈើរបស់ពួកគេឡើង តាមពេលវេលាត្រឹមត្រូវនៅក្នុងអំឡុងពេលអានដំណើររឿង ។ សកម្មភាពនេះ សមរម្យសម្រាប់កុមារធំៗជាពិសេស ។



ចម្រៀង សូមច្រៀង ឬ អានពាក្យដូចខាងក្រោមក្នុងបទ « ផ្ទុំនៅក្នុងស្នូកទីឆ្ងាយ » (*សៀវភៅចម្រៀងកុមារ* ទំព័រ 42–43) ហើយសូមរៀបចំធ្វើសកម្មភាព ដែលបានផ្តល់យោបល់តាមទំនុក ។ សូមអញ្ជើញកុមារឲ្យចូលរួមជាមួយអ្នក ។

ផ្ទុំនៅក្នុងស្នូកទីឆ្ងាយ ឥតមានគ្រែដេកឡើយ ។
ព្រះយេស៊ូវទារកតូចផ្ទុំនៅឥតមានខ្មៅយ ។
ផ្កាយនៅលើមេឃដ៏ខ្ពស់ចាំងចំទីទ្រង់ផ្ទុំ ។
ព្រះយេស៊ូវទារកតូច ទ្រង់ផ្ទុំស្រួលសម្រុំ ។

វគ្គសកម្មភាព ចូរធ្វើវគ្គសកម្មភាពដូចខាងក្រោម ហើយសូមអញ្ជើញកុមារឲ្យចូលរួមនឹងអ្នក ៖

ទារកតូចនៅក្នុងស្នូក *(សូមយោលដៃដូចជាបីទារក)*
ម្តាយជាទីស្រឡាញ់នៅជិត
ផ្កាយរះនៅលើមេឃ *(សូមចង្អុលទៅលើមេឃ)*
ព្រះរាជបុត្រានៃព្រះគង់ទីនេះ ! *(សូមឱបដៃ)*

បទគម្ពីរ សូមប្រាប់កុមារថា ព្រះយេស៊ូវ បានប្រាប់យើងនៅក្នុងព្រះគម្ពីរថា ទ្រង់គឺជាព្រះរាជបុត្រារបស់ព្រះ ដែលជាព្រះវរបិតាសួគ៌របស់យើង ។ សូមបើកព្រះគម្ពីរមរមនទៅ នីហ្វៃទី3 9:15 ហើយសូមអាន « មើលចុះ យើងគឺព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ » ។ សូមអញ្ជើញកុមារឲ្យនិយាយថា « ព្រះរាជបុត្រានៃព្រះ » ជាមួយនឹងអ្នក ។

គន្លឹះក្នុងការបង្រៀន

ឆន្ទានុរូប ៖ សូមប្រើតែឆន្ទានុរូបដែលបានបោះពុម្ពដោយសាសនាចក្រនៅក្នុងថ្នាក់ទារកដ្ឋានបានហើយ ។ បើអ្នកត្រូវការអ្វីច្រើនទៀតសម្រាប់កុមារធ្វើ សូមជ្រើសរើសរឿងដទៃទៀត ល្បែងកំសាន្ត រូបតុក្កតាអាយ៉ង ឬ សកម្មភាពជាក់ពណ៌នានាចេញពីសៀវភៅនេះ ដែលអ្នកបានឆ្លាប់ប្រើរាល់ពីមុនមក ។ អ្នកក៏អាចប្រើល្បែងកំសាន្ត និង រឿងផ្សេង។ចេញមកពីទស្សនាវដ្តីសាសនាចក្រផងដែរ ។

ពាក្យផ្តួន ៖ សូមបង្រៀនមេរៀនទាំងអស់ ឬ ផ្នែកខ្លះនៃមេរៀននេះឲ្យបានច្រើនដង អំឡុងរដូវបុណ្យគ្រីស្ទម៉ាស់ ។ កុមារចូលចិត្តស្តាប់រឿងបុណ្យគ្រីស្ទម៉ាស់ម្តងហើយម្តងទៀត ។



ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រានៃ
ព្រះវរបិតាសួគ៌

ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រានៃ
ព្រះវរបិតាសួគ៌

មេរៀនខ្លី។ ៖ ស្វាគមន៍ការមកកាន់ថ្នាក់ទារកដ្ឋាន

គន្លឹះក្នុងការបង្រៀន

កុមារអាចមកកាន់ថ្នាក់ទារកដ្ឋានជាលើកដំបូង ដោយចំណង់ ឬ ដោយមានការភ័យខ្លាច ។ តាមរយៈការបង្ហាញសេចក្តីស្រឡាញ់ និង ការអត់ធ្មត់ នោះអ្នកអាចធ្វើបានយ៉ាងច្រើន ដើម្បីឲ្យបទពិសោធន៍ដំបូងរបស់កុមារម្នាក់។ នៅក្នុងថ្នាក់ទារកដ្ឋានជាបទពិសោធន៍ដ៏រីករាយ ។ កុមារកាន់តែមានភាពកក់ក្តៅ នៅពេលពួកគេដឹងថា ពួកគេត្រូវរំពឹងទៅលើអ្វីនោះ ។ សូមព្យាយាមធ្វើតាមទម្លាប់ឲ្យខ្ជាប់ខ្ជួនក្នុងថ្នាក់ទារកដ្ឋាន ឲ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន ។ សូមផ្តល់ពេលដល់កុមារថ្មីដើម្បីស្គាល់អ្នក ស្គាល់កុមារដទៃទៀត និង ស្គាល់បរិយាកាសជុំវិញខ្លួនគេ ។

បើកុមារចង់ចាកចេញទៅនៅជាមួយឪពុកម្តាយរបស់គេ សូមឲ្យឪពុកម្តាយដឹងថា នោះមិនអីទេ ។ សូមអញ្ជើញឪពុកម្តាយឲ្យនិយាយរឿងវិជ្ជមានអំពីថ្នាក់ទារកដ្ឋាន អំឡុងពេលសប្តាហ៍ ។

សកម្មភាពក្នុងការរៀនសូត្រ

សូមស្វាគមន៍ ! នៅពេលកុមារមកថ្នាក់ទារកដ្ឋានជាលើកដំបូង ចូររើសពេលមួយ ដែលកុមារនៅជុំគ្នា (ដូចជា ពេលរៀនមេរៀន, ពេលទទួលអាហារសម្រន់ ឬ ម៉ោងតន្ត្រី) ហើយសូមប្រាប់ឈ្មោះរបស់កុមារថ្មីដល់កុមារទាំងឡាយ ។ សូមប្រាប់កុមារថ្មីថា អ្នករីករាយខ្លាំងណាស់ដែលគេមកកាន់ថ្នាក់ទារកដ្ឋាន ។

ចម្រៀង សូមប្រាប់កុមារថា អ្នកចង់ច្រៀងចម្រៀងពិសេសមួយ ។ សូមច្រៀង ឬ អានពាក្យក្នុងបទ « បទសួស្តី »(*សៀវភៅចម្រៀងកុមារ* ទំព័រ 260) ហើយសូមកុមារឲ្យនិយាយថា « សួស្តី » នៅពេលអ្នកចង្អុលទៅពួកគេអំឡុងពេលច្រៀង ។ អ្នកអាចនឹងចង់ហាត់រៀនធ្វើដូច្នេះពីរបីដង មុនពេលអ្នកច្រៀង ។

*សួស្តី ! (សូមចង្អុលទៅកុមារ ៖ « សួស្តី ! »)*សួស្តី ! *(សូមចង្អុលទៅកុមារ ៖ « សួស្តី ! »)*
យើងសូមស្វាគមន៍ប្អូនថ្ងៃនេះ ។ *(សូមចង្អុលទៅកុមារ ៖ « សួស្តី ! »)*
*សួស្តី ! (សូមចង្អុលទៅកុមារ ៖ « សួស្តី ! »)*សួស្តី ! *(សូមចង្អុលទៅកុមារ ៖ « សួស្តី ! »)*
យើងរីករាយដែលប្អូនមក
ចូលរួមថ្នាក់កុមារជាមួយយើង
ហើយក្លាយជាមិត្តដ៏ពិសេសរបស់យើង ។
*សួស្តី ! (សូមចង្អុលទៅកុមារ ៖ « សួស្តី ! »)*សួស្តី ! *(សូមចង្អុលទៅកុមារ ៖ « សួស្តី ! »)*
យើងសូមស្វាគមន៍ប្អូនថ្ងៃនេះ ។

សេចក្តីបញ្ចប់ សូមនិយាយទៅកុមារថ្មីថា « [ឈ្មោះរបស់កុមារ] យើងរីករាយខ្លាំងណាស់ ដែលប្អូនមកចូលរួមថ្នាក់ទារកដ្ឋានរបស់យើង ! »

មេរៀនខ្ចី។ ៖ រីករាយថ្ងៃបុណ្យកំណើត

សកម្មភាពក្នុងការរៀនសូត្រ

សកម្មភាព នៅថ្ងៃអាទិត្យ ជិតនឹងថ្ងៃខួបកំណើតរបស់កុមារ ខណៈពេលដែលកុមារមកជុំគ្នារៀនមេរៀន ទទួលទានអាហារសម្រន់ ឬ ម៉ោងតន្ត្រី សូមប្រាប់កុមារ « [ឈ្មោះកុមារ] » មានថ្ងៃខួបកំណើត [ឬនឹងមានថ្ងៃខួបកំណើតក្នុងពេលឆាប់ៗ] ! » សូមអញ្ជើញកុមារឲ្យនិយាយថា « រីករាយថ្ងៃបុណ្យកំណើត » ។

សូមប្រាប់កុមារថា កុមារនោះនឹងមានអាយុប៉ុន្មាន នៅថ្ងៃខួបកំណើតរបស់គេ ។ សូមអញ្ជើញពួកគេឲ្យរាប់ម្រាមដៃពួកគេដល់លេខនោះជាមួយអ្នក ។ សូមធ្វើសារឡើងវិញពីរបីដង ។

ចម្រៀង សូមច្រៀង ឬ អានពាក្យក្នុងបទ « រីករាយថ្ងៃបុណ្យកំណើត » (*សៀវភៅចម្រៀងកុមារ* ទំព័រ 284) ហើយសូមអញ្ជើញកុមារឲ្យចូលរួមនឹងអ្នក ៖

រីករាយថ្ងៃបុណ្យខួបកំណើត [ឈ្មោះកុមារ] សម្លាញ់
ថ្ងៃរីករាយមានដល់អ្នកពេញមួយឆ្នាំ ។
បើខ្ញុំអាចផ្តល់បំណងប្រាថ្នាមួយ
នោះគឺរីករាយថ្ងៃបុណ្យខួបកំណើតដល់អ្នកពីខ្ញុំ !

សូមអញ្ជើញកុមារឲ្យនិយាយថា « រីករាយថ្ងៃបុណ្យកំណើត » ហើយទះដៃ ។

គន្លឹះក្នុងការបង្រៀន

កុមារចូលចិត្តស្តាប់ឈ្មោះរបស់ពួកគេ ។ អំណោយដ៏មហិមាបំផុតដែលអ្នកអាចផ្តល់ដល់កុមារ គឺ សេចក្តីស្រឡាញ់ ការទទួលស្គាល់ និង ការឲ្យតម្លៃដល់ពួកគេ ។ ចូរកុំឲ្យអំណោយដទៃទៀតសម្រាប់ថ្ងៃបុណ្យខួបកំណើតដល់គេ នៅក្នុងថ្នាក់ទារកដ្ឋានឡើយ ។ សូមធ្វើពិធីឲ្យកុមារ ពុំមែនជាការផ្តល់អំណោយនោះទេ ។

វគ្គសកម្មភាព (បន្ទាត់ទីមួយ)
« ទារកតូចនៅក្នុងស្នូក » ទំព័រ 125
« ឱពុក ត្រកងបីទារកតូច » ទំព័រ 117
« ព្រះវរបិតាសួគ៌ ស្គាល់ខ្ញុំ » ទំព័រ 20
« ព្រះវិញ្ញាណបរិសុទ្ធ មានបន្ទូលទន់ភ្លន់ » ទំព័រ 29
« ខ្ញុំចាប់ផ្តើមដោយនិយាយថា ‹ ឱ ព្រះវរបិតាសួគ៌ជាទីស្រឡាញ់ › » ទំព័រ 16
« បើសិនអ្នកខ្ពស់ ខ្ពស់ជាខ្លាំង »ទំព័រ 9
« ខ្ញុំមានរូបកាយពិសេសមួយ »ទំព័រ 40
« ខ្ញុំចង់ធ្វើតាមព្រះយេស៊ូវ » ទំព័រ 73
« យ៉ូសែប លុតជង្គង់នៅក្នុងព្រៃ » ទំព័រ 89
« បើក បិទ » ទំព័រ 85
« ខ្ញុំទទួលទាននំប៉័ងដោយស្ងៀមស្ងាត់ » ទំព័រ 112 , 117
« ចូរអានព្រះគម្ពីរមរមន ! » ទំព័រ 93
« ញញឹម គឺងាយស្រួលខ្លាំងណាស់ » ទំព័រ 81
« បង្រៀនខ្ញុំពីព្រះគម្ពីរ » ទំព័រ 97
« នេះគឺជាម្តាយ »ទំព័រ 56
« នេះគឺជាម៉ាក់របស់ខ្ញុំ ដែលជួយខ្ញុំពេលលេង » ទំព័រ 52
« ប្អូនតូចម្នាក់នេះ នឹងទៅចូលដេក » ទំព័រ 45
« ប៉ះភ្នែក ប៉ះច្រមុះ » ទំព័រ 65
« នៅពេលខ្ញុំឈឺ ខ្ញុំអាចទទួលការប្រសិទ្ធពរ » ទំព័រ 117
ល្បែងចង់ ទំព័រ 13, 37, 53, 93
សៀវភៅ ទំព័រ 33, 35, 37, 39, 93, 95, 113, 115 (សូមមើលផងដែរ *សៀវភៅបើកមើល*)
ខ្សែដៃ ទំព័រ 69 , 71
ច្រវ៉ាក់ ទំព័រ 53 , 55
គូប (ដុំវាងបួនជ្រុង) ទំព័រ 29, 31, 73, 75
រូបភាព ទំព័រ 48 , 51, 101 , 103
សកម្មភាពប្រើម្រាមដៃ ទំព័រ 57
រូបតុក្កតាអាយ៉ងដែលប្រើម្រាមដៃ ទំព័រ 41, 53, 57, 59, 89, 91
សៀវភៅបើកមើល ទំព័រ 17, 19, 85, 87, 117, 119
ធ្វើតាមអ្នកដឹកនាំ ទំព័រ 100
ល្បែងទាយ ទំព័រ 45, 57, 59, 69, 71, 101, 103, 109, 111
ភ្ញៀវ ទំព័រ 113, 117
ល្បែងផ្គូផ្គង ទំព័រ 65, 67, 105, 107
កញ្ចក់ ទំព័រ 21
ចល័ត ទំព័រ 13, 15
ខ្សែក ទំព័រ 21, 23, 57, 59, 69, 71
ប័ណ្ណប្រកាស ទំព័រ 9, 49
រូបតុក្កតាអាយ៉ង ទំព័រ 61, 63, 97, 99, 125, 127 (សូមមើលផងដែរ *រូបតុក្កតាអាយ៉ងដែលប្រើម្រាមដៃ*)
រូបផ្គុំ ទំព័រ 25
ការសម្តែង ទំព័រ 28, 44, 48, 61, 76, 100, 113
បទគម្ពីរ ទំព័រ 25, 29, 37, 52, 77, 104, 109, 112, 125
គ្រាប់ពូជ ទំព័រ 33
ចម្រៀង
« ផ្ទំនៅក្នុងស្នូកទីឆ្ងាយ »ទំព័រ 125
« ពិធីបុណ្យជ្រមុជទឹក » ទំព័រ 108
« សាសនាចក្រព្រះយេស៊ូវគ្រីស្ទ » ទំព័រ 104
« តើព្រះយេស៊ូវរស់ឡើងវិញឬ ? » ទំព័រ 120
« ក្រុមគ្រួសារអាចនៅជាមួយគ្នាជានិរន្តរ៍ » ទំព័រ 56
« ការអធិស្ឋានជាគ្រួសារ » ទំព័រ 52
« ធ្វើតាមព្យាការី » ទំព័រ 101
« សប្បាយធ្វើការ » ទំព័រ 36, 49, 72–73
« ក្រុមគ្រួសារវីរកាយ » ទំព័រ 36, 48
« រីករាយថ្ងៃបុណ្យកំណើត » ទំព័រ 129
« ក្បាល, ស្មា, ជង្គង់, និង ជើង »ទំព័រ 41
« បទសូស្តី »ទំព័រ 128
« ទ្រង់បញ្ជូនបុត្រាទ្រង់មក » ទំព័រ 124
« ខ្ញុំជាកូនរបស់ព្រះ » ទំព័រ 8, 12–13, 40
« ខ្ញុំស្គាល់ក្តីស្នេហ៍ព្រះសង្គ្រោះ » ទំព័រ 20–21
« បើអ្នកសប្បាយ » ទំព័រ 81
« ខ្ញុំដឹងព្រះបិតារស់ » ទំព័រ 28
« ខ្ញុំព្យាយាមក្លាយដូចព្រះយេស៊ូវ » ទំព័រ 24, 68, 72
« ខ្ញុំចូលចិត្តមើលព្រះវិហារបរិសុទ្ធ » ទំព័រ 56
« ខ្ញុំព្យាយាមមានគារវភាព » ទំព័រ 84
« ព្រះយេស៊ូវបានរស់ឡើងវិញ » ទំព័រ 121
« ព្រះយេស៊ូវ មានបន្ទូលស្រឡាញ់មនុស្សគ្រប់រូប » ទំព័រ 25,76
« យើងនិយាយដោយស្នេហ៍ » ទំព័រ 116
« ព្រះវរបិតាស្រឡាញ់ខ្ញុំ » ទំព័រ 32
« និទាឃរដូវមាស » ទំព័រ 88
« គ្រាមួយមានមនុស្សព្រិល » ទំព័រ 44
« ខ្ញុំនឹងឆាប់ធ្វើតាម » ទំព័រ 60
« ដោយគោរព ដោយស្ងៀមស្ងាត់ » ទំព័រ 36, 112
« ស្វែងរក, គិត, អធិស្ឋាន » ទំព័រ 92, 96–97
« ញញឹម » ទំព័រ 80
« អរគុណព្រះបិតា » ទំព័រ 64–65
« លោកិយគួរឲ្យស្រឡាញ់ » ទំព័រ 33
រឿងទាំងឡាយ
កុមារា ត្រូវបានព្រះវិញ្ញាណបរិសុទ្ធលួងលោមចិត្ត ទំព័រ 28
កុមារនិយាយថា « ខ្ញុំសុំទោស » ទំព័រ 69
អេណុស អធិស្ឋាន ទំព័រ 17
ក្រុមគ្រួសារ អធិស្ឋានសម្រាប់កុមារដែលឈឺ ទំព័រ 53
កុមារីញញឹម ទំព័រ 80
សាសន៍សាម៉ារីចិត្តល្អ ទំព័រ 76
ព្រះយេស៊ូវ និង មាតារបស់ទ្រង់ ទំព័រ 49
ព្រះយេស៊ូវ ប្រសិទ្ធពរកុមារតូចៗ ទំព័រ 20, 24, 96
ព្រះយេស៊ូវ ផ្តល់អាហារដល់ប្រជាជន ទំព័រ 24
ព្រះយេស៊ូវ ព្យាបាលបុរសខ្វាក់ ទំព័រ 24
ព្រះយេស៊ូវ ព្យាបាលមនុស្សឃ្លង់ 10 នាក់ ទំព័រ 64
ព្រះយេស៊ូវ បានរស់ឡើងវិញ ទំព័រ 120, 121
ការនិមិត្តដំបូងរបស់យ៉ូសែប ស្ម៊ីធ ទំព័រ 40, 88
នីហៃ សង់សំពៅមួយ ទំព័រ 68, 96
ការគូសដាន ទំព័រ 41
វគ្គ (សូមមើល *វគ្គសកម្មភាព*)

លិខិក្រមរូបភាព

អ័ដាម និង អេវ៉ា ទំព័រ 99
សត្វពាហនៈ ទំព័រ 35
ការប្រសិទ្ធពរដល់ទារកតូច ទំព័រ 118, 119
ពិធីបុណ្យជ្រមុជទឹក ទំព័រ 110, 111
ការប្រសិទ្ធពរដល់អ្នកឈឺ ទំព័រ 119 (សូមមើលផងដែរ *ព្រះយេស៊ូវគ្រីស្ទ ៖ ការព្យាបាល*)
រូបកាយ ទំព័រ 43, 47
សៀវភៅ ទំព័រ 75
អគារសាសនាចក្រ ទំព័រ 31, 39
សម្លៀកបំពាក់ ទំព័រ 55, 67
ទៀនពណ៌ ទំព័រ 75
ការបង្កបង្កើត ទំព័រ 34, 35
ពិធីបញ្ជាក់ ទំព័រ 111
ដានីយ៉ែលនៅក្នុងរូងសត្វតោ ទំព័រ 103
ក្រុមគ្រួសារ ទំព័រ 14, 15, 18, 31, 38, 39, 46, 50, 51, 54, 55, 59, 62, 67
ការនិមិត្តដំបូង ទំព័រ 42, 90, 91
ម្ហូបអាហារ ទំព័រ 19, 47, 55, 67, 75
សាសន៍សាម៉ារីចិត្តល្អ ទំព័រ 78
គេហដ្ឋាន ទំព័រ 55, 67
ព្រះយេស៊ូវគ្រីស្ទ ទំព័រ 19, 39, 106, 107, 115 (សូមមើលផងដែរ *ការនិមិត្តដំបូង*)
  ជាកុមារតូច ទំព័រ 18
  ពិធីបុណ្យជ្រមុជទឹកនៃ ទំព័រ 110
  កំណើតនៃ ទំព័រ 95, 126, 127
  ការផ្តល់ចំណីអាហារដល់មនុស្សប្រាំពាន់នាក់ ទំព័រ 27
  ការព្យាបាល ទំព័រ 26, 66, 94, 95
  ការរស់ឡើងវិញនៃ ទំព័រ 122, 123
  ជាមួយកុមារ ទំព័រ 15, 22, 95, 98
យ៉ូហាន-បាទីស្ទ ទំព័រ 103, 110
យ៉ូសែប ស្ម៊ីធ ទំព័រ 102, 103, 107 (សូមមើលផងដែរ *ការនិមិត្តដំបូង*)
ម៉ូសេ ទំព័រ 99
នីហ្វៃ ទំព័រ 70
ណូអេ ទំព័រ 99
ការអធិស្ឋាន ទំព័រ 18, 30, 54, 87
ជីវិតមុនជីវិតលើផែនដី ទំព័រ 15
បព្វជិតភាព ទំព័រ 118, 119
គារវភាព ទំព័រ 86 (សូមមើលផងដែរ *ការអធិស្ឋាន*)
សាក្រាម៉ង់ ទំព័រ 114, 115, 119
សាំយូអែលជាសាសន៍លេមិនទំព័រ 103
បទគម្ពីរ ទំព័រ 31, 39, 95, 107
ការចែកចាយ ទំព័រ 74
ពួកអ្នកគង្វាល ទំព័រ 127
មុខញញឹម - មុខក្រញ៊ូវទំព័រ 83
ព្រះវិហារបរិសុទ្ធ ទំព័រ 58, 59
សម្ភារលេង ទំព័រ 74, 75

រូបភាពជំនួយចក្ខុដែលមានសិទ្ធិអ្នកនិពន្ធ

Intellectual Reserve, Inc. មានសិទ្ធិអ្នកនិពន្ធចំពោះរូបភាព, រូបចំតិ និង រូបភាពដទៃទៀត នៅក្នុងសៀវភៅសិក្សានេះ ដោយមានករណីលើកលែងដូចខាងក្រោម ៖

គម្របខាងមុខ និង ទំព័រ 22 ៖ *ព្រះគ្រីស្ទ និង កុមារក្នុងព្រះគម្ពីរមរមន* ដោយ ដេល ផាសុន ។ © 1995 Del Parson ។

ទំព័រ 5 ៖ រូបចំតិ © 2000 Steve Bunderson ។

ទំព័រ 8 ៖ រូបចំតិ © Rubberball Productions ។

ទំព័រ 18 ៖ *តាមព្រះទ័យព្រះ* ដោយ សីម៉ូន ឌូវី ។ © 2001 Simon Dewey ។ ហាមចំតិចម្លង ។

ទំព័រ 24 និង 98 ៖ *ម៉ោងរឿងនិទាននៅកាលីឡេ* ដោយ ដេល ផាសុន ។ © 1990 Del Parson ។

ទំព័រ 28 ៖ រូបចំតិ © 1998 Robert Casey ។

ទំព័រ 32 ៖ រូបចំតិ © Corbis Images ។

ទំព័រ 42 ៖ *ការនិមិត្តដំបូង* ដោយ ហ្គារី កេប ។ © 1998 Gary Kapp ។ ហាមចំតិចម្លង ។

ទំព័រ 48 ៖ រូបចំតិ © 2000 Steve Bunderson ។

ទំព័រ 54 ៖ រូបចំតិ © 2006 Hyun-Gyu Lee ។

ទំព័រ 56 ៖ រូបចំតិ © 2006 Frank Helmrich ។

ទំព័រ 66 ៖ *មនុស្សឃ្លង់ ដែលបាននិយាយ « អរគុណ »* ដោយយ៉ូហាន ស្ទីល ។ © ProvidenceCollection.com ។ រក្សាសិទ្ធគ្រប់យ៉ាង ។

ទំព័រ 88 ៖ *ការនិមិត្តដំបូងរបស់យ៉ូសែប ស្ម៊ីធ* ដោយ ប្រ្គេត ខេ អូលសិន ។ © 1988 Greg K. Olsen ។

ទំព័រ 90 ៖ *បំណងប្រាថ្នានៃដួងចិត្តខ្ញុំ* ដោយវ៉ាលធើរ រ៉ែន ។ © 2004 Walter Rane, courtesy of the Museum of Church History and Art ។

ទំព័រ 94 ៖ *ហើយទ្រង់បានព្យាបាលពួកគេម្នាក់ម្តងៗ* ដោយ ហ្គារី ខេប ។ © 1993 Gary Kapp ។

ទំព័រ 102 ៖ *បងប្រុស យ៉ូសែប* ដោយ ដេវីឌ លីនស្លី ។ © 1998 David Lindsley ។

ទំព័រ 106 ៖ ព័ត៌មានលម្អិតចេញមកពី *ព្រះគ្រីស្ទ និង អ្នកមានវ័យក្មេង* ដោយ ហែនរីច ហូហ្វមែន ។ Courtesy of C. Harrison Conroy Co., Inc ។

ទំព័រ 110 ៖ *យ៉ូហាន-បាទីស្ទ កំពុងជ្រមុជទឹកឲ្យព្រះយេស៊ូវ* ដោយ ប្រ្គេត ខេ. អូលសិន ។ © 1988 Greg K. Olsen ។

ទំព័រ 120 ៖ *ទ្រង់រស់ឡើងវិញ* ដោយ ដេល ផាសុន ។ © 1996 Del Parson ។

ទំព័រ 124 ៖ *ទារកមួយបានប្រសូត្រមកដល់យើងហើយ* ដោយ មីលមែន វែលឌីនហ្គើរ ។ © 2002 Lynne Millman Weidinger, courtesy of the Museum of Church History and Art ។

ទំព័រ 126 ៖ *ម៉ាថា និង ព្រះគ្រីស្ទជាទារក*ដោយ រ៉ូបើត ធី ប៉ារ៉ែត ។ © 1993 Robert T. Barrett. ហាមចំតិចម្លង ។

ទំព័រ 128 ៖ រូបចំតិ © 1999 ប្រាយអិន លីវរីងស្តុន ។

«ឯកូនចៅទាំងប៉ុន្មានរបស់អ្នក នឹងធ្វើជាសិស្សរបស់ព្រះអម្ចាស់ ហើយវារាល់គ្នានឹងមានសន្តិសុខជាបរិបូរណ៍ » (នីហ្វៃទី3 22:13) ។

« [ព្រះយេស៊ូវ] បានមានបន្ទូលទៅហ្វូងមនុស្សថា ៖ មើលន៎ ! កូនតូចៗរបស់អ្នករាល់គ្នា ។ ហើយនៅពេលពួកគេក្រឡេកមើលទៅ នោះពួកគេបានសម្លឹងមើលទៅលើផ្ទៃមេឃ ហើយឃើញផ្ទៃមេឃបើកចំហ ហើយពួកគេឃើញពួកទេវតាហោះចុះមកពីស្ថានសួគ៌ ហាក់បីដូចជានៅកណ្តាលភ្លើង ហើយពួកទេវតាក៏ចុះមកហែរហមជុំវិញពួកកូនក្មេងទាំងនោះ រីឯភ្លើងក៏ព័ទ្ធជុំវិញពួកវា ហើយពួកទេវតាបានធ្វើការងារបម្រើដល់ពួកកូនក្មេង » (នីហ្វៃទី 3 17:23–24) ។

« ច្បាស់ណាស់ថា យើងទាំងអស់គ្នា ដែលត្រូវបានទុកចិត្តឲ្យមើលថែកុមារដ៏មានតម្លៃ គឺត្រូវបានប្រគល់ឲ្យនូវកិច្ចការដ៏ពិសិដ្ឋ និងថ្លៃថ្នូរមួយ ព្រោះយើងគឺជាមនុស្សដែលព្រះត្រូវបានតែងតាំងឲ្យឱបក្រសោបដល់កុមារតូចៗនាសព្វថ្ងៃនេះ ដោយក្តីស្រឡាញ់ និងភ្លើងនៃសេចក្តីជំនឿ និងការយល់ដឹង អំពីអត្តសញ្ញាណថាពួកគេជានរណា » (អែលឌើរ អិម រ័សុល បាឡឺដ « Great Shall Be the Peace of Thy Children » Ensign ខែមេសា ឆ្នាំ 1994 ទំព័រ 60) ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

CAMBODIAN
4 02371 08258 4
37108 258